# ចរចា

## ឈានដល់កិច្ចព្រមព្រៀងអំពីទឹក



IUCN

# ចរចា

## ឈានដល់កិច្ចព្រមព្រៀងអំពីទឹក

កិច្ចផ្តួចផ្តើមស្តីពីទឹក និងធម្មជាតិ

ពិនិត្យ និងកែសម្រួលដោយ

*John Dore, Julia Robinson* និង *Mark Smith*

IUCN

ការកំណត់ស្ថានភាពភូមិសាស្ត្រនៅក្នុងសៀវភៅនេះ និងការបង្ហាញជូនខ្លឹមសារនៅទីនេះមិនមានន័យថាជាការសំដែងយោបល់ណាមួយរបស់អង្គការ IUCN ដែលទាក់ទងទៅនឹងទិដ្ឋភាពនានាចំពោះមុខច្បាប់ នៃប្រទេសដែនដី ឬ តំបន់ ឬនៃអាជ្ញាធរណាមួយ ឬដែលទាក់ទងនឹងការកំណត់ព្រំដែន ឬ ខណ្ឌសីមារបស់តំបន់ទាំងនេះឡើយ។

ទស្សនៈដែលសំដែងនៅក្នុងសៀវភៅនេះ មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់អង្គការ IUCNឡើយ។


| | |
|---|---|
| បោះពុម្ពផ្សាយដោយ ៖ | អង្គការ IUCN, Gland, Switzerland |
| ប្រែសម្រួលជាភាសាខ្មែរដោយ៖ | លោកម៉ម កុសល<br>អង្គការសហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ និងធនធានធម្មជាតិ(IUCN) សូមអះអាងមិនទទួលខុសត្រូវលើរាល់កំហុស ឬការរម្លងពាក្យដែលអាចកើតមានឡើងពីការបកប្រែនេះ ឬខ្លឹមសារដែលអាចប្រាសចាកពីលំនាំដើមនោះឡើយ។ ក្នុងករណីមិនសមស្រប សូមយោងទៅច្បាប់ដើម ។ |



| | |
|---|---|
| រក្សាសិទ្ធិ ៖ | ©2013 អង្គការសហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ និងធនធានធម្មជាតិ<br>ការផលិតឯកសារនេះឡើងវិញសម្រាប់ការអប់រំ ឬសម្រាប់គោលបំណងផ្សេងទៀតក្រៅពី ពាណិជ្ជកម្មអាចអនុញ្ញាតឱ្យធ្វើបានដោយពុំចាំបាច់សុំការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីម្ចាស់រក្សាសិទ្ធិឡើយ ក្នុងករណីបានផ្តល់សេចក្តីយោងពេញលេញ។ ការផលិតឯកសារនេះឡើងវិញសម្រាប់លក់ ឬគោលបំណងពាណិជ្ជកម្មត្រូវហាមឃាត់ប្រសិនបើគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីម្ចាស់រក្សាសិទ្ធិ។ |



| | |
|---|---|
| ការធ្វើសេចក្តីយោង ៖ | Dore, J., Robinson, J. and Smith, M. (Eds) (2013). Negotiate - Reaching agreements over water. Gland, Switzerland: IUCN. (Khmer translated version). |
| ISBN | ៩៧៨-២-៨៣១៧-១៩៥២-៣ |
| រចនាបថដោយ ៖ | Melanie Kandelaars |
| បោះពុម្ពដោយ ៖ | Sunway Publishing |
| ឯកសារនេះមាននៅ ៖ | អង្គការសហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ និងធនធានធម្មជាតិ (IUCN)<br>ការិយាល័យអង្គការ IUCN ប្រចាំកម្ពុជា<br>ផ្ទះលេខ ៦បេ ផ្លូវ៣៦៨ បឹងកេងកង៣ ចំការមន ភ្នំពេញ<br>ទូរសព្ទ័លេខ ៖ ០២៣ ២២២ ៣១១<br>ទូរសារលេខ ៖ ០២៣ ២២២ ៣១២<br>E-mail: info.cambodia@iucn.org<br>www.iucn.org/cambodia |

បញ្ជីឈ្មោះសៀវភៅដែលបោះពុម្ពផ្សាយដោយអង្គការ IUCN ក៏មានសម្រាប់ផ្សព្វផ្សាយផងដែរ។

# មាតិកា

**សារគន្លឹះ**......................................................................................................................៦
**អារម្ភកថា**.....................................................................................................................១៣
**អ្នកពិនិត្យកែសម្រួលនិងអ្នកនិពន្ធ**..........................................................................................១៤
**សេចក្តីថ្លែងអំណរគុណ**......................................................................................................១៥
**ជំពូក១.ហេតុអ្វីចរចា**?.........................................................................................................១៧
១.១ ការចរចាជាឧបករណ៍មួយសម្រាប់គ្រប់គ្រងទឹកដោយស្មើភាពប្រកបដោយប្រសិទ្ធភាពនិងមាននិរន្តរភាព.................................................................................................................១៧
១.២ Rs ( Rewards, Risks, Rights, Responsibility ) ទាំងបួន..........................................................២១
១.៣ ជំពូកនានានៅក្នុងសៀវភៅនេះ..........................................................................................២៦
**ជំពូក២.ការចូលរួមប្រកបដោយការស្ថាបនា**..................................................................................២៩
២.១ ការចូលរួមប្រកបដោយការស្ថាបនាសម្រាប់ការធ្វើសេចក្តីសម្រេចដ៏ស្មុគស្មាញ................២៩
២.២ ការចូលរួមជាសាធារណៈប្រកបដោយប្រសិទ្ធភាព...........................................................៣១
២.៣ អភិក្រមនៃការចរចា............................................................................................................៣៣
២.៤ ការបង្កើតឲ្យមានបែបផែននៃដំណើរការចរចា......................................................................៤៥
**ជំពូក៣. វេទិកាពហុអ្នកពាក់ព័ន្ធ** Multi-Stakeholder Platforms ( MSPs )..........................................៤៧
៣.១ វេទិកាពហុអ្នកពាក់ព័ន្ធៈ មូលដ្ឋានមួយសម្រាប់អភិបាលកិច្ចទឹកបានត្រឹមត្រូវជាងមុន.......៤៧
៣.២ បរិបទនៃវេទិកាពហុអ្នកពាក់ព័ន្ធដែលចង់បាន.................................................................៤៩
៣.៣ ធាតុផ្សំនានានៃដំណើរការល្អ............................................................................................៥៦
៣.៤ ខ្លឹមសារ MSP ដែលជាការចង់បាន.......................................................................................៥៨
៣.៥ សមិទ្ធផល និងឥទ្ធិពល.......................................................................................................៧២
**ជំពូក៤.ការបង្កើតឲ្យមានការឯកភាពមតិ**...........................................................................................៧៥
៤.១ ការកែលម្អលើទម្លាប់នៃការចរចា......................................................................................៧៥
៤.២ ហេតុអ្វីអភិក្រមធម្មតានៅក្នុងការចរចាអំពីទឹកច្រើនតែបរាជ័យ.........................................៧៥
៤.៣ អភិក្រមបង្កើតការឯកភាពមតិ...........................................................................................៨១
៤.៤ យោបល់ណែនាំដល់អ្នកចរចាកិច្ចព្រមព្រៀងអំពីទឹក.........................................................៩៨
**ជំពូក៥.កិច្ចព្រមព្រៀង**..........................................................................................................១០៣
៥.១ សមិទ្ធផលពីការចូលរួមប្រកបដោយការស្ថាបនា..............................................................១០៣
៥.២ ស្វែងយល់អំពីកិច្ចព្រមព្រៀងស្តីពីទឹក...............................................................................១០៤
៥.៣ ប្រភេទនៃកិច្ចព្រមព្រៀង ...................................................................................................១១១
៥.៤ ការបង្កើតកិច្ចព្រមព្រៀង.....................................................................................................១១៧
៥.៥ ធ្វើចំណាត់ការតាមការព្រមព្រៀង ការអនុវត្តន៍ និងឥទ្ធិពល.............................................១២៦
**ករណី និងប្រអប់**.............................................................................................................១៣២
**តារាង និងរូប**.................................................................................................................១៣៣
**ករណីនៅតាមខេបសាយ និងអ្នកនិពន្ធ**...............................................................................១៣៤

**សទ្ទានុក្រម**..........................................................................................................................១៣៧
**ម្ចាស់រូបថត**..........................................................................................................................១៤៩
**ឯកសារយោង**.......................................................................................................................១៥០

# សារគន្លឹះ

## ១.ហេតុអ្វីចរចា?

ការគ្រប់គ្រងទឹកដោយស្មើភាពប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាព ទាមទារឲ្យមានអភិក្រម នៃពហុអ្នកពាក់ព័ន្ធតាមរយៈការចរចា។

ភាពស្មុគស្មាញ និងភាពចម្រុះនៃចំណាប់អារម្មណ៍ទាក់ទងនឹងទឹក គឺជាការប្រឈមមួយខាងសង្គម និង នយោបាយដែលក្នុងនោះការគ្រប់គ្រងទឹកតាមបែប "បញ្ជា និងត្រួតពិនិត្យ" មិនផ្តល់ដំណោះស្រាយសម្រាប់ រយៈពេលវែងឡើយ។ កង្វះការព្រមព្រៀងរួមគ្នា ឬការទទួលស្គាល់ អំពីនិត្យានុកូលភាពនៃការសម្រេចនានាអំពី ទឹក អាចមានន័យថាអ្នកទាំងឡាយ សម្រេចមិនអនុវត្តតាម ហើយធនធានទឹកនឹងត្រូវធ្លាក់ក្នុងស្ថានភាព នៃការប្រើប្រាស់ច្រើនហួសកម្រិត កខ្វក់ និងមានឱនភាព។ ការឈានមកដល់ការសម្រេចដែលមាន លក្ខណៈស្មើភាព ប្រសិទ្ធភាព និងនិរន្តរភាព គឺជាអ្វីដែលអាចធ្វើទៅបាន។ អ្នកពាក់ព័ន្ធនានាដែលមាន ចំណាប់អារម្មណ៍ទាក់ទងនឹងទឹកត្រូវធ្វើការជាមួយគ្នា ដើម្បីស្វែងយល់អំពីការមិនចុះសម្រុងគ្នារបស់ពួកគេ និងស្វែងរកដំណោះស្រាយដែលអាចប្រើការបានដែលអ្នកពាក់ព័ន្ធគ្រប់គ្នាទទួលយក។

ដំណើរការចរចា និងជំនាញចាត់ចែងចរចា សម្របសម្រួល និងចូលរួមនៅក្នុងការចរចាពហុ អ្នកពាក់ព័ន្ធ មានសារៈសំខាន់ជាសារវន្តសម្រាប់កែលម្អការគ្រប់គ្រងទឹក។

អ្នកប្រើប្រាស់ទឹក អ្នកគ្រប់គ្រងទឹក និងអ្នកកសាងគោលនយោបាយដែលពាក់ព័ន្ធនៅក្នុងការសម្រេច នានា ត្រូវតែបង្កើត ឲ្យមានទម្លាប់ចរចាដែលមានប្រសិទ្ធភាព។ ការចរចាបានប្រសើរជាងមុនអាចជួយអ្នក ពាក់ព័ន្ធនានាក្នុងការឈានដល់ដំណោះស្រាយដែលអាចប្រើការបានដែរ បើពុំនោះទេ ពួកគេនឹងមិនអាច សម្រេចបានឡើយ។ ការព្យាយាមដែលបានអនុវត្ត ដើម្បីធ្វើឲ្យការចចារបានល្អប្រសើរឡើងមានច្រើន ណាស់។ កិច្ចព្រមព្រៀងវិភាជន៍ទឹក ផែនការគ្រប់គ្រងទីជម្រាល កំណែទម្រង់ច្បាប់ជាតិស្តីពីទឹក គោលនយោបាយរួមស្តីពីទឹក និងសន្ធិសញ្ញាស្តីពីទឹកឆ្លងដែន សុទ្ធតែពាក់ព័ន្ធជាមួយអន្តរពាក់ព័ន្ធខុសៗ គ្នាជាច្រើន និងអាចពង្រឹងជាបន្ថែមតាមរយៈការចរចាពេញលេញ និងបែបជជែកវែកញែក។

ការផ្តោតឲ្យបានច្បាស់លាស់លើ4Rs ពោលគឺភាគលាភ ហានិភ័យ សិទ្ធិ និងការទទួលខុសត្រូវ ផ្តល់នូវការគាំទ្រឲ្យមានការចរចាអំពីទឹកប្រកបដោយប្រសិទ្ធភាព។

4Rs ផ្តល់នូវក្របខ័ណ្ឌមួយសម្រាប់បង្កើតរចនាសម្ព័ន្ធ វិភាគ និងស្វែងយល់អំពី ចំណាប់អារម្មណ៍ របស់អ្នកពាក់ព័ន្ធខុសៗគ្នាដោយផ្អែកលើការកំណត់អំពីថាតើអ្នកណាស្វែងរកភាគលាភ ទាមទារសិទ្ធិ រ៉ាប់រងហានិភ័យ ឬរ៉ាប់រងការទទួលខុសត្រូវណាមួយ។ នៅក្នុងការចរចាការបន្តផ្តោតលើ4Rs អាចជួយ បង្កើតឱកាសដែលអ្នកចរចាត្រូវការជាចាំបាច់សម្រាប់កំណត់អត្តសញ្ញាណផ្នែកនានាដែលត្រូវតែដាក់បញ្ចូល គ្នាដើម្បីសម្របតាមចំណាប់អារម្មណ៍ខុសៗគ្នានៅក្នុងកិច្ចព្រមព្រៀង។

*អភិបាលកិច្ចទឹកអាចពង្រឹងបានតាមរយៈការចូលរួមប្រកបដោយការស្ថាបនា។*

អភិបាលកិច្ចទឹកគ្របដណ្តប់ "ប្រព័ន្ធនយោបាយ សង្គម សេដ្ឋកិច្ច និងរដ្ឋបាលខុសៗគ្នាជាច្រើន ដែលមានស្រាប់សម្រាប់បង្កើត និងគ្រប់គ្រងធនធានទឹក និងផ្តល់សេវាកម្មទឹកនៅលំដាប់ថ្នាក់ខុសៗគ្នា នៃសង្គម។" អភិបាលកិច្ចទឹក អាចជាដំណើរការប្រកបដោយការស្ថាបនា និងច្នៃប្រឌិតតាមរយៈការ ចូលរួមនៃក្រុមមនុស្សខុសៗគ្នានៅក្នុងការចរចា។ គោលដៅទូលាយនៃការចរចាអំពីទឹកគឺការបង្វែរវិវាទ

ខាងនយោបាយឲ្យទៅជាការចូលរួមប្រកបដោយការស្ថាបនា និងតាមធម្មតាឲ្យទៅជាកិច្ចព្រមព្រៀងមួយបែបស្ម័គ្រចិត្តប្រកបដោយយុត្តិធម៌ និងមាននិរន្តរភាពជាយូរអង្វែងដែលអាចអនុវត្តបានដោយប្រសិទ្ធភាព។

## ២. ការចូលរួមប្រកបដោយការស្ថាបនា

តាមរយៈការចូលរួមប្រកបដោយការស្ថាបនា អ្នកពាក់ព័ន្ធនានាមានសមត្ថភាពកាន់តែច្រើនឡើងក្នុងការផ្តល់ឥទ្ធិពល និងក្នុងការបង្កើតសេចក្តីសម្រេចនានា។
អ្នកពាក់ព័ន្ធនានាដែលជ្រើសយកការចូលរួមប្រកបដោយការស្ថាបនា ទទួលស្គាល់ថា ការធ្វើការជាមួយគ្នាដើម្បីស្វែងរកជម្រើសដែលអាចទទួលយកបានទាំងអស់គ្នាអាចជាជម្រើសដែលគួរចង់បានជាងគេ។ ការចូលរួមជាសាធារណៈនៅក្នុងការកសាងផែនការ និងការសម្រេចជួយលើកទឹកចិត្តដល់អ្នកពាក់ព័ន្ធនានាឲ្យចូលរួមកាន់តែច្រើនឡើង។ ទោះជាយ៉ាងណាក៏ដោយគ្រាន់តែ "ជូនដំណឹង" ឬ "ការពិគ្រោះយោបល់" ជាមួយសាធារណជនមិនគ្រប់គ្រាន់ទេ។ ក្នុងកាលៈទេសៈខ្លះ សាធារណជនអាចទទួលសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេច ប៉ុន្តែជាញឹកញាប់អ្នកពាក់ព័ន្ធនានាមានឥទ្ធិពល និងធ្វើឲ្យការសម្រេចនានាលេចជារូបរាងឡើងដោយបង្កើត និងជជែកវែកញែកអំពីជម្រើសនានា។

ការចរចាដើរតួសំខាន់ដែលពហុអ្នកពាក់ព័ន្ធអាចចូលរួមតាមបែបស្ថាបនា។ ដើម្បីផ្តល់នូវវិធីមួយដែលត្រឹមត្រូវតាមច្បាប់សម្រាប់ដោះស្រាយរួមជាមួយគ្នានូវភាពមិនចុះសម្រុងគ្នា ការចរចាដើម្បីឈានដល់ការសម្រេចលើបញ្ហាទឹកដែលលក្ខណៈស្មុគស្មាញត្រូវមានតម្លាភាព និងពេញលេញ។ ប្រសិនបើអាចបង្កើតឲ្យមានការចរចាបានតាមវិធីមួយតាមបែបជជែកវែកញែក និងការស្ថាបនាការចរចានោះអាចជួយលើកទឹកចិត្តឲ្យមានការយោគយល់ និងដោះស្រាយបញ្ហារួមគ្នា ការគោរពចំពោះចំណាប់អារម្មណ៍និងគុណតម្លៃរបស់គ្នាទៅវិញទៅមក ហើយលទ្ធភាពនៃការដាក់បញ្ចូលប្រការទាំងនេះក្នុងការចូលរួមប្រកបដោយការស្ថាបនា គឺជាគន្លឹះ។

ការតថ្លៃតឹងតែងនៅក្នុងការចរចាបែបប្រកួតប្រជែងនាំឲ្យបាត់បង់ឱកាសក្នុងការទទួលផលទាំងអស់គ្នា។ នៅក្នុងការចរចាបែបប្រកួតប្រជែង ជាញឹកញាប់ភាគីនានាបង្កើតឲ្យមាន "ជំហរ" ជាក់លាក់មួយតាំងពីពេលចាប់ផ្តើម ដែលបន្ទាប់មកត្រូវភាគីម្ខាងប្រឹងប្រែងដើម្បីពង្រឹង និងការពារខ្លួន និងចោទគ្នាទៅវិញទៅមក។ ជាមួយការផ្តោតលើការតថ្លៃតឹងតែងដោយផ្អែកលើជំហរដែលបានកំណត់ទុកជាមុន និងការបែងចែកផលប្រយោជន៍ដើម្បីបង្កើតផលចំណេញ ជាអតិបរមាឬកាត់បន្ថយការខាតបង់ការចរចាបែបប្រកួតប្រជែងទំនងជានាំមកនូវយ៉ាងច្រើនបំផុតត្រឹមការធ្វើសម្បទានឲ្យគ្នាទៅវិញទៅមកតែប៉ុណ្ណោះ។ នៅក្នុងករណីនេះកាលានុវត្តភាពដើម្បីបង្កើតដំណោះស្រាយថ្មីៗ ដែលផ្តល់ផលចំណេញទាំងអស់គ្នាងាយនឹងបាត់បង់ណាស់ ។

ការចរចាបែបសហប្រតិបត្តិការជួយពង្រឹងការចូលរួមប្រកបដោយការស្ថាបនា។ ជាជាងផ្តោតតែលើជំហរការចរចាបែបសហប្រតិបត្តិការផ្តោតលើ "ផលប្រយោជន៍" ។ ផលប្រយោជន៍ទាក់ទងជាមួយហេតុផលដែលនាំឲ្យមានការប្រកាន់យកជំហរ គុណតម្លៃ តម្រូវការជាចាំបាច់កង្វល់ ឬទំនាក់ទំនងបែបណាមួយ។ នៅក្នុងការចរចាបែបសហប្រតិបត្តិការភាគីនានាបង្កើតឲ្យមានការជឿទុកចិត្តគ្នា និងការយោគយល់គ្នាអំពីផលប្រយោជន៍នានា។ ពួកគេបង្កើតជម្រើសថ្មីៗសម្រាប់កិច្ចព្រមព្រៀងដោយពិនិត្យមើលផលប្រយោជន៍ដែលទាក់ទងគ្នាទៅវិញទៅមករបស់ភាគីនានា និងស្វែងយល់ពីរបៀបដែលពួកគេអាចស្វែង

រកផលចំណេញទាំងអស់គ្នាដើម្បីឈានដល់កិច្ចព្រមព្រៀងមួយដែលយកជាការបាន និងសមធម៌។

## ៣. វេទិកាពហុអ្នកពាក់ព័ន្ធ(MSPs)

វេទិកាពហុអ្នកពាក់ព័ន្ធ(MSPs) គឺជាអភិក្រមមួយសម្រាប់ការចូលរួមប្រកបដោយការស្តាបនា និងការរៀនសូត្រអំពីបញ្ហាស្មុគស្មាញនៃទឹក។ ជម្រើសអំពីទឹកច្រើនតែទាក់ទងនឹងភាពជាក់ស្តែង និងគុណតម្លៃដែលប្រកួតប្រជែងគ្នា។ នៅក្នុងMSP ការជជែកវែកញែកត្រូវបានពង្រឹងក្នុងចំណោមអ្នកពាក់ព័ន្ធខុសៗគ្នាច្រើនដើម្បីជួយពួកគេឲ្យធ្វើការវិភាគរួមគ្នាមុនការសម្រេចនានា។ ភាពខុសគ្នាត្រូវបានទទួលស្គាល់ ឬយ៉ាងហោចណាស់យល់កាន់តែប្រសើរ ទន្ទឹមនឹងស្វែងរកកិច្ចព្រមព្រៀងដែលស្មើភាព និងប្រសិទ្ធភាពអំពីបញ្ហាស្មុគស្មាញនានា។

ការបង្កើតMSP មួយទាមទារឲ្យមានបែបផែន និងដំណើរការល្អដែលនាំមុខដោយអ្នកកោះប្រជុំដែលអាចទុកចិត្តបាន និងមានសមត្ថភាព។ គោលបំណង និងវិសាលភាពនៃMSP មួយត្រូវតែច្បាស់លាស់ទន្ទឹមនឹងកម្រិត និងលំដាប់ថ្នាក់សមស្របសម្រាប់ការជជែកវែកញែក និងការវិភាគ (ដូចជាទីជម្រាលធៀបនឹងអាងទន្លេ ឬថ្នាក់ស្រុកធៀបនឹងថ្នាក់ជាតិ)។ គេគួរតែមានធនធានមនុស្ស ហិរញ្ញវត្ថុ និងព័ត៌មានគ្រប់គ្រាន់ ការគាំទ្រខាងនយោបាយនិងមានពេលវេលាគ្រប់គ្រាន់សម្រាប់ការជជែកវែកញែកដើម្បីអាចឲ្យបានពេញលេញ។ការទទួលស្គាល់ដោយចំហរអំពីនយោបាយ និងអំណាចគួរតែបានដាក់បញ្ចូលទៅក្នុងបែបផែននិងដំណើរការនៃMSPនោះ។

ភាពពេញលេញ ការផ្លាស់ប្តូរព័ត៌មាន និងការប្រាស្រ័យទាក់ទងជាមួយអ្នកចូលរួម និងសមាជិកនៅក្នុងមណ្ឌលរបស់ខ្លួនទាំងមូល។ ការជជែកវែកញែកគឺជាមូលដ្ឋានគ្រឹះមួយដែលមានគោលដៅបង្កើតឲ្យមានយោបល់សមហេតុផលប្រកបដោយការយល់ដឹងដែលក្នុងនោះអ្នកចូលរួមមានឆន្ទៈក្នុងការកែប្រែវត្ថុបំណងរបស់ពួកគេដោយផ្អែកលើការពិភាក្សា ព័ត៌មានថ្មីៗ និងការទាមទាររបស់អ្នកចូលរួមនៅក្នុងក្រុមជាមួយគ្នា។ MSPs គួរប្រើប្រាស់ និងចែករំលែកព័ត៌មានល្អៗបំផុតដែលមាន និងបង្កើតមូលដ្ឋានចំណេះដឹង។ ការសម្រួលបានល្អមានសារៈសំខាន់ជាសារវន្ត។

ដំណើរការដែលមានគុណភាពខ្ពស់ដែលសម្រួលឲ្យមានការជជែកវែកញែក គឺជាគន្លឹះដែលធ្វើឲ្យ MSPsមានភាពស្របច្បាប់។ MSP ត្រូវតែមានស្តង់ដារកម្រិតខ្ពស់នៃការជជែកវែកញែក ការសម្របសម្រួលជំហានជាក់លាក់សម្រាប់ចាត់ចែង MSP មួយត្រូវតែចងចាំអំពីគោលដៅចុងក្រោយនៃការបង្កើតអនុសាសន៍នានាសម្រាប់ចំណាត់ការទៅមុខ។ ដើម្បីឈានទៅមុខត្រូវបង្កើតក្រុមអ្នកតម្រង់ទិសមួយ និងពន្យល់ពីហេតុផលសម្រាប់បង្កើត MSP មួយនោះ ដើម្បីជួយបង្កើតការគាំទ្រដល់ដំណើរការនេះ។ អ្នកកោះប្រជុំត្រូវកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធនានាដោយធ្វើការវិភាគក្រុមអ្នកពាក់ព័ន្ធ និងនៅពេលពួកគេមកជួបជុំគ្នាហើយនោះអ្នកកោះប្រជុំ និងតំណាងក្រុមអ្នកពាក់ព័ន្ធដែលចូលរួមត្រូវឯកភាពលើបទបញ្ញាសម្រាប់ការចូលរួម និងតួនាទី និងការទទួលខុសត្រូវ។ ការវិភាគដោយប្រុងប្រយ័ត្នអំពីបញ្ហាដែលទំនាស់គ្នាគឺជាប្រការចាំបាច់ដើម្បីផ្តល់ជាគំនិត និងដែលមានប្រយោជន៍សម្រាប់អ្នកពាក់ព័ន្ធទាំងអស់។ ឧបករណ៍សម្រាប់ការពិចារណា ដូចជាការបង្កើតសេណារីយ៉ូអាចជួយអ្នកចូលរួមក្នុងការបង្កើតជម្រើសសម្រាប់អនុសាសន៍ដែលបានការដោយផ្អែកលើការរៀនសូត្រអំពីចំណាប់អារម្មណ៍ គុណតម្លៃ អាទិភាព ការសន្មត និងឧបសគ្គខុសៗគ្នា ពីគ្នាទៅវិញទៅមក។ MSPs អាចធ្វើការសម្រេច និងអនុវត្តតាមការ

សម្រេចនានាទៅបានឬមិនអាចអាស្រ័យលើវិសាលភាពនៃអាណត្តិរបស់ពួកគេ។

MSPsជួយធ្វើឲ្យមានការជជែកវែកញែកជាប្រចាំដែលជម្រុញឲ្យមានការពិនិត្យមើលកាន់តែម៉ត់ចត់នូវបញ្ហាស្មុគស្មាញនៃទឹកនៅក្នុងការចរចាប្រកបដោយការយល់ដឹងជាមុន។ MSPs អាចនាំទៅរកសមិទ្ធផលខុសៗគ្នាដែលជាបំណងប្រាថ្នា។ វាអាចពង្រីកការធ្វើជាតំណាង និងការចូលរួមនៃអ្នកពាក់ព័ន្ធនានានៅក្នុងអភិបាលកិច្ច។ វាលើកទឹកចិត្តឲ្យមានការសិក្សារៀនសូត្រ និងការយល់ដឹងកាន់តែច្រើនថែមទៀតអំពីការពឹងផ្អែកលើគ្នាទៅវិញទៅមកក្នុងចំណោមអ្នកពាក់ព័ន្ធនានា និងវិធីនានានៃការដោះស្រាយបញ្ហាទំនាស់។ តាមរយៈការផ្តល់លំនាំផ្លូវមួយសម្រាប់ការជជែកវែកញែក MSPs អាចនាំឲ្យមានការសម្រេចបានប្រសើរជាងមុន និងការព្រមព្រៀងអំពីទឹកដែលអាចអនុវត្តប្រកបដោយជោគជ័យច្រើនជាងមុន។

## ៤. បង្កើតឲ្យមានការឯកភាពមតិ

ការបង្កើតឲ្យមានការឯកភាពមតិមានគោលដៅបំពេញតាមចំណាប់អារម្មណ៍របស់ភាគីទាំងអស់នៅក្នុងតុចរចា។ នៅក្នុងការបង្កើតឲ្យមានការឯកភាពមតិភាគីនានា ឯកភាពក្នុងការស្វែងរកការព្រមព្រៀងគ្នាជាឯកច្ឆ័ន្ទ ប៉ុន្តែសម្រេចត្រឹមតាមរយៈមតិភាគច្រើន។ ក្រុមអ្នកដែលមានអំណាចនយោបាយខ្សោយជាងអាចបានទទួលការអះអាងថាចំណាប់អារម្មណ៍របស់ខ្លួននឹងត្រូវដោះស្រាយហើយពួកគេនឹងមិនស្ថិតក្រោមការបង្ខិតបង្ខំឲ្យទទួលយកអ្វីដែលពួកគេជំទាស់នោះឡើយ។ ភាគីអ្នកមានអំណាចនយោបាយខ្លាំងរក្សាសមតារបស់ពួកគេនូវសិទ្ធិវេតូក្នុងករណីដែលពួកគេបានខិតខំប្រឹងប្រែងបំពេញតាមចំណាប់អារម្មណ៍របស់ភាគីដទៃទៀតទាំងអស់នៅក្នុងតុចរចា។ អ្នកសម្របសម្រួលតម្រូវឲ្យភាគីទាំងអស់មានគណនេយ្យភាពចំពោះការប្តេជ្ញានៃការបង្កើតឲ្យមានការឯកភាពមតិរបស់ពួកគេទាំងអស់គ្នា។

ការចរចាបង្កើតឲ្យមានការឯកភាពមតិបង្កើតឲ្យមានគុណតម្លៃថ្មីៗសម្រាប់អ្នកពាក់ព័ន្ធនានាតាមរយៈផលចំណេញសម្រាប់ទាំងអស់គ្នា។ នៅក្នុងការចរចាអំពីទឹក វាជាកំហុសឆ្គងប្រសិនបើគេត្រូវពិចារណាអំពីបញ្ហាតែមួយនៅក្នុងពេលណាមួយដោយសារការដោះដូរក្នុងចំណោមបញ្ហានានា គឺជាគន្លឹះក្នុងការបង្កើតគុណតម្លៃ។ របៀបវារៈគួរតែធានាដល់អ្នកចូលរួមទាំងអស់ថាបញ្ហានានានឹងមិនសម្រេចឡើយរហូតដល់មានការស្វែងយល់អំពីកញ្ចប់បញ្ហាទាំងមូលជាមុនសិន។ បើពុំនោះទេអ្នក ចរចាអាចមិនមានលទ្ធភាពផ្សារភ្ជាប់បញ្ហានានាជាមួយគ្នា ដើម្បីបង្កើតគុណតម្លៃតាមរយៈផលចំណេញសម្រាប់ទាំងអស់គ្នាឡើយ។

ការបង្កើតឲ្យមានការឯកភាពមតិទាមទារឲ្យមានការប្តេជ្ញាប្រើប្រាស់វិទ្យាសាស្ត្រ និងចំណេះដឹងពីបទពិសោធន៍នានាយ៉ាងម៉ត់ចត់ក៏ដូចជាផ្តោតលើការព្រមព្រៀងខាងនយោបាយផងដែរ។ នៅក្នុងដំណើរការបង្កើតការឯកភាពមតិដែលរួមបញ្ចូលការស្វែងរកការពិតរួមគ្នា និងបង្កើតរបៀបវារៈមួយពីសំណាក់ក្រុមនេះទាំងមូល ចំណេះដឹងវិទ្យាសាស្ត្រ និងចំណេះដឹងពីបទពិសោធន៍នឹងផ្តល់ជាមូលដ្ឋានសម្រាប់ការចរចា។ ក្រុមមនុស្សភាគច្រើនដែលមានអំណាចមិនអាចដាក់បន្ទុកនៃវត្ថុបំណងរបស់ខ្លួនមកលើក្រុមមនុស្សភាគតិច និងមើលរម្លងនូវអ្វីដែលលើកស្នើជាភស្តុតាងខាងបច្ចេកទេស និងពីបទពិសោធន៍នៅក្នុងមូលដ្ឋាននោះឡើយ។

ការបង្កើតឲ្យមានការឯកភាពមតិត្រូវអនុវត្តទៅតាមដំណើរការដែលមាន៦ជំហាន ដែលរួមទាំង

ការកោះប្រជុំដើម្បីធ្វើការសម្រេច ការអនុវត្តន៍ និងការរៀនសូត្រ។

ការចរចាប្រកបដោយជោគជ័យអំពីទឹកពឹងផ្អែកលើការធ្វើឲ្យមានភាគីសមស្របនៅក្នុងតុចរចាក្នុងជំហានទី១ ពោលគឺការកោះប្រជុំ។ ជំហានទី២ គឺការបំភ្លឺអំពីការទទួលខុសត្រូវ។ នៅពេលដែលភាគីសមស្របមានវត្តមាននៅក្នុងតុចរចារួចហើយពួកគេពិនិត្យមើលតួនាទី និងការទទួលខុសត្រូវ ជ្រើសរើសអ្នកសម្របសម្រួលឬប្រធាន និងឯកភាពលើរបៀបវារៈ ផែនការការងារ ថវិកា បទបញ្ជាផ្ទៃក្នុង និងនីតិវិធីស្វែងរកការពិតរួមគ្នា។ ជំហានទី៣ គឺការជជែកវែកញែកដែលផ្អែកលើរបកគំហើញពីការស្វែងរកការពិតរួមគ្នា និងផ្តល់លទ្ធភាពដល់ការបង្កើតជម្រើសនានា និងកញ្ចប់នានាដែលឆ្លើយតបទៅនឹងកង្វល់របស់ភាគីទាំងអស់។ ជំហានទី៤ គឺការសម្រេចដែលក្នុងនោះភាគីនានាបង្កើតជាកិច្ចព្រមព្រៀង និងពិនិត្យមើលថាតើរដ្ឋធម្មនុញ្ញរបស់ខ្លួនមានភាពស្របគ្នាជាមួយអ្វីដែលបានលើកស្នើនោះដែរឬទេ។ ជំហានទី៥គឺការអនុវត្តដែលរួមទាំងការបង្កើតយុទ្ធសាស្រ្តតាមដាន និងកាលវិភាគសម្រាប់ធ្វើរបាយការណ៍ផងដែរ។ ជំហានទី៦គឺការរៀនសូត្រជារចនាសម្ព័ន្ធតាមរយៈការអនុវត្តលទ្ធផលពីការតាមដានលើការគ្រប់គ្រងតាមបែបបន្សាំ។

## ៥. កិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងមួយ គឺជាលទ្ធផលជាក់លាក់ផ្ទាល់នៃការចរចាដែលចែងអំពីការសម្រេចរួមគ្នា និង អំពីជំហាននានាសម្រាប់ការអនុវត្តកិច្ចព្រមព្រៀងនោះ។

មានកិច្ចព្រមព្រៀងជាច្រើនបែបអំពីទឹកៈគោលនយោបាយ ច្បាប់ ធម្មនុញ្ញ ក្រមអនុវត្ត កិច្ចសន្យា ឬកិច្ចព្រមព្រៀងដទៃទៀតសម្រាប់គ្រប់គ្រង និងវិភាជន៍ទឹក។ កិច្ចព្រមព្រៀងអាចជាការណែនាំ ឬកំណត់ជាច្បាប់ ឬបទបញ្ញាជាក់លាក់។ កិច្ចព្រមព្រៀងមានលក្ខណៈជាផ្លូវការ ឬមិនផ្លូវការ ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ឬស្ម័គ្រចិត្ត ផ្ទាល់មាត់ឬជាលាយលក្ខអក្សរ។ កិច្ចព្រមព្រៀងអាចត្រូវគេយកទៅអនុវត្តនៅកម្រិត និងលំដាប់ថ្នាក់ខុសៗគ្នាដែលរាប់ចាប់ពីថ្នាក់មូលដ្ឋានដល់អន្តរជាតិ ពីកម្រិតអណ្តូងដល់ទីជម្រាលតូចៗ និងដល់អាងទន្លេ និងរវាងសកម្មជនជាច្រើនខុសៗគ្នា។

កិច្ចព្រមព្រៀងនាំមកនូវភាពប្រាកដប្រជា និងតម្លាភាពជាងមុននូវការរំពឹងលើភាគលាភ ហានិភ័យ សិទ្ធិ និងការទទួលខុសត្រូវ។

គេត្រូវបង្កើតកិច្ចព្រមព្រៀងនានាឲ្យមានសង្គតិភាពជាមួយក្របខ័ណ្ឌច្បាប់ និងគោលនយោបាយដែលមានស្រាប់។ កិច្ចព្រមព្រៀងដែលល្អត្រូវចែងអំពីជំហានច្បាស់លាស់សម្រាប់ដោះស្រាយភាពមិនចុះសម្រុងគ្នាទៅអនាគត ការអនុវត្តមិនបានគ្រប់គ្រាន់ ឬការរំលោភលើកិច្ចព្រមព្រៀងនោះ។ កាលណាកិច្ចព្រមព្រៀងកាន់តែច្បាស់លាស់ មាត្រាក្នុងកិច្ចសន្យាទាំងនោះនឹងពុំសូវមានទំនាស់គ្នាឡើយ។ ទោះជាកិច្ចព្រមព្រៀងប្រភេទណាក៏ដោយ ក៏ទិដ្ឋភាពស្នូលនៃកិច្ចព្រមព្រៀងដែលល្អចែងកំណត់ និងអធិប្បាយអំពីៈវិសាលភាព យន្តការភិបាលកិច្ចដែលរួមទាំងតួនាទី និងការទទួលខុសត្រូវ ហិរញ្ញប្បទាន ការផ្តល់ទិន្នន័យសម្រាប់ការចែករំលែកទិន្នន័យ និងព័ត៌មាន ភាពចាំបាច់ឲ្យមានការគោរពតាមយន្តការសម្រាប់ពង្រឹងការអនុវត្តនិងការដោះស្រាយវិវាទ និងកាលបរិច្ឆេទចូលជាធរមាន រយៈពេល និងនីតិវិធីធ្វើវិសោធនកម្ម។ លទ្ធផលអំពីវិភាជន៍ ការប្រើប្រាស់និងការគ្រប់គ្រងទឹកដោយស្មើភាព និងមាននិរន្តរភាពជាងមុន នឹងអាចទទួលបានពីកិច្ចព្រមព្រៀងនានាតែក្នុងករណីដែលមានការអនុវត្តដោយប្រសិទ្ធភាពតែប៉ុណ្ណោះ។

ការរៀបចំកិច្ចព្រមព្រៀងមួយចាប់ផ្តើមពីការចាត់ចែងជាសេចក្តីព្រាងអត្ថបទ និងទាមទារឲ្យមានការផ្ទៀងផ្ទាត់ពីសំណាក់អ្នកពាក់ព័ន្ធ និងការអនុម័តគាំទ្រតាមរយៈការចុះហត្ថលេខា។ សម្រាប់កិច្ចព្រមព្រៀងនានាដែលសមត្ថកិច្ចស្ថិតនៅក្រៅតុចរចាជំហានមួយបន្ថែមទៀតអាចជាតម្រូវការចាំបាច់រួមមានការអនុម័តពីថ្នាក់ក្រសួង ឬការផ្តល់សច្ចាប័នពីសភា។ ការអនុវត្តជំហាននានាសម្រាប់កិច្ចព្រមព្រៀងជាផ្លូវការរួមមានការដាក់ឲ្យអនុវត្តនូវរចនាសម្ព័ន្ធចាត់ចែងសំខាន់ៗខាងស្ថាប័ន ការកសាងសមត្ថភាពចំណាត់ការដែលបានឯកភាពគ្នា និងធ្វើការពិនិត្យតាមដាន។ ចំពោះកិច្ចព្រមព្រៀងដែលមានគោលដៅផ្តល់ឥទ្ធិពលមកលើការសម្រេចនានា ដែលធ្វើឡើងដោយអ្នកដទៃគេចាំបាច់ត្រូវបង្កើតយុទ្ធសាស្ត្រសម្រាប់ធ្វើឲ្យមានឥទ្ធិពលផងដែរ។

ការបម្លែងកិច្ចព្រមព្រៀងមួយឲ្យទៅជាចំណាត់ការគឺជាទឹកចិត្តនៃការធ្វើឲ្យមានការផ្លាស់ប្តូរ និងទាមទារឲ្យមានការប្តេជ្ញាជាប់ជាបន្ត។

អ្នកពាក់ព័ន្ធនានាត្រូវបន្តធ្វើការជាមួយគ្នាដើម្បីឆ្លុះបញ្ចាំងអំពីលក្ខខណ្ឌស្មើភាព និងប្រសិទ្ធភាពនៃការអនុវត្តន៍ ដោះស្រាយភាពមិនចុះសម្រុងគ្នា និងពង្រឹងកិច្ចសហប្រតិបត្តិការ។ លទ្ធផលបន្ថែមប៉ុន្តែ

មិនសូវជាក់លាក់ដែលបានពីការចរចាមានសារៈសំខាន់ណាស់សម្រាប់ពង្រឹងអភិបាលកិច្ចទឹកនៅក្នុងរយៈពេលវែង។ ទំនាក់ទំនងល្អជាងមុន ការយល់ដឹងកាន់តែប្រសើរ និងដំណើរការល្អជាងមុនសម្រាប់ការដដែកវែកញែក និងការសម្រេចនានាកើតចេញពីការចូលរួមប្រកបដោយការស្ថាបនា និងការចរចាពហុអ្នកពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព។ ក្នុងករណីដែលពុំមានចេញជាកិច្ចព្រមព្រៀងជាផ្លូវការ សមិទ្ធផលដទៃទៀតអាចមានឥទ្ធិពលជាខ្លាំងផងដែរមកលើវិធីវិភាជន៍ និងគ្រប់គ្រងទឹក។

អភិបាលកិច្ចទឹកតាមរយៈពហុអ្នកពាក់ព័ន្ធគឺជាដំណើរការដ៏វែងឆ្ងាយមួយដែលគ្របដណ្តប់វដ្តនានានៃការចូលរួម និងការចរចា។

កិច្ចព្រមព្រៀងនីមួយៗដែលបានពីការចរចាមានសារៈសំខាន់ណាស់ប៉ុន្តែបញ្ហាថ្មីៗកើតឡើងជាបន្តបន្ទាប់ និងត្រូវតែលើកឡើង និងដោះស្រាយ។ ប្រការសំខាន់គឺត្រូវពឹងផ្អែកលើចលនការ និងទំនាក់ទំនងដែលបានបង្កើតឡើងនៅក្នុងអំឡុងពេលនៃការចូលរួមប្រកបដោយការស្ថាបនាដើម្បីមានឥទ្ធិពលវិជ្ជមានមកលើដំណើរការធ្វើសេចក្តីសម្រេច និងមកលើស្ថាប័ននានាសម្រាប់រយៈពេលយូរអង្វែង។

# អារម្ភកថា

នៅជុំវិញពិភពលោក មានមនុស្សជាច្រើនដែលពាក់ព័ន្ធនៅក្នុងការចរចាអំពីទឹក។ នេះជាសៀវភៅមួយសម្រាប់ប្រតិបត្តិការដែលមានការប្តេជ្ញាធ្វើការចរចាដែលនាំទៅរកកិច្ចព្រមព្រៀងស្មើភាពអំពីរបៀបដែលសង្គមមនុស្សនានាប្រើប្រាស់ទឹកប្រកបដោយឈ្លាសវៃ។ សៀវភៅនេះផ្តល់គំនិតឧបករណ៍ និងការប៉ងប្រាថ្នា។

សៀវភៅនេះ ទទួលស្គាល់ថា ការចរចាអំពីទឹកច្រើនតែមានលក្ខណៈស្មុគស្មាញទាំងខាងសង្គម សេដ្ឋកិច្ច និងបរិស្ថាន។ ជាញឹកញាប់បំផុតនៅអាស៊ីបូព៌ាពោលគឺផ្នែកនេះនៃពិភពលោកដែលខ្ញុំមានការយល់ដឹងច្រើនបំផុត ភាពស្មុគស្មាញនេះមិនបានទទួលការយកចិត្តទុកដាក់ ឬកាត់បន្ថយឲ្យមកនៅត្រឹមកម្រិតងាយនោះឡើយ។ ដើម្បីដោះស្រាយភាពស្មុគស្មាញនេះ អ្នកនិពន្ធស្នើឲ្យមានការពិនិត្យដោយផ្តោតលើភាគលាភនិងកាលានុវត្តភាព សិទ្ធិរបស់អ្នកដើរតួខុសៗគ្នា ហានិភ័យនៃចំណាត់ការ ឬអវត្តមានចំណាត់ការ និងការទទួលខុសត្រូវរបស់ភាគីដែលពាក់ព័ន្ធទាំងអស់។

ជាញឹកញាប់ការចរចាសង្កត់ធ្ងន់ហួសកម្រិតមកលើការតថ្លៃ និងភាពប្រកួតប្រជែងដែលមានបង្កប់នៅក្នុងការគិតគូរអំពីវត្តមានអ្នកឈ្នះ និងអ្នកចាញ់។ នៅក្នុងការទទួលយកភាពផ្ទុយគ្នានេះ សៀវភៅនេះបានសង្កត់ធ្ងន់លើការចូលរួមប្រកបដោយការស្ថាបនា និងកាលានុវត្តភាពប្រកបដោយការលើកទឹកចិត្តនៅក្នុងការចរចាដើម្បីធ្វើឲ្យមានការជជែកវែកញែក ការស្តាប់ពួទស្សនវិស័យខុសៗគ្នាយ៉ាងច្រើន និងការបង្កើតឲ្យមានការឯកភាពមតិ។ តាមរយៈស្ថាបនាកម្មឬការបង្កើតឲ្យមានប្រក្រតីភាពអភិក្រមនេះនាំទៅរកការចរចាដែលផ្អែកលើការយល់ដឹងជាមុនកាន់តែច្រើនឡើង និងការគោរពគ្នាទៅវិញទៅមក និងសង្ឃឹមផងដែរថានេះជាជម្រើសដែលមានភាពឈ្លាសវៃ និងស្មើភាពច្រើនជាងមុនផងដែរ។

**បណ្ឌិតសាស្ត្រាចារ្យ Surichai Wun'gaeo**
នាយកមជ្ឈមណ្ឌលដើម្បីការសិក្សាអំពីសន្តិភាព និងវិវាទ
សាកលវិទ្យាល័យជូឡាឡុងគន
ប្រទេសថៃ

# អ្នកពិនិត្យកែសម្រួល និងអ្នកនិពន្ធ

ពិនិត្យ និងកែសម្រួលដោយJohn Dore, Julia Robinson និងand Mark Smith

| | |
|---|---|
| ជំពូក១ | John Dore ( AusAID ), Dr Mark Smith ( IUCN ) |
| ជំពូក២ | Alikki Vernon ( សាកលវិទ្យាល័យឡាត្រូបេ អូស្ត្រាលី ), John Dore; Dipak Gyawali ( មូលនិធិអភិរក្សទឹកនៃប្រទេសនេប៉ាល់ ) |
| ជំពូក៣ | John Dore |
| ជំពូក៤ | សាស្ត្រាចារ្យ Lawrence Susskind (វិទ្យាស្ថានបច្ចេកវិទ្យាម៉ាសូឈូសេត ), Catherine Ashcraft (វិទ្យាស្ថានបច្ចេកវិទ្យាម៉ាសូឈូសេត ) |
| ជំពូក៥ | Julia Robinson ( យុទ្ធនាការពិភពលោកសម្រាប់សកម្មភាពអាកាសធាតុ ) ដោយមានវិភាគទានពីបណ្ឌិត Alejandro Iza ( ELC ) និង Olga Buendía ( អតីតធ្វើការនៅ ELC ) |

# សេចក្តីថ្លែងអំណរគុណ

សៀវភៅចរចា គឺជាផលិតផលមួយរបស់មនុស្សជាច្រើននៅលើពិភពលោក និងមានគោលដៅឆ្លុះបញ្ចាំងទស្សនៈ និងបទពិសោធន៍ខុសៗគ្នាលើពិភពលោក។ ឯកសារនេះរួមបញ្ចូលករណីសិក្សានានាមកពីអាហ្វ្រិក អាមេរិក អាស៊ីប៉ាស៊ីហ្វិក អូស្ត្រាលី និងអឺរ៉ុបនូវការចរចានានាអំពីទឹកនៅលំដាប់ថ្នាក់ និងកម្រិតខុសៗគ្នា។ ករណីសិក្សាដែលមានលក្ខណៈពិស្តារនិងច្រើនជាងនេះមានក្នុងវេបសាយស្តីពីទឹករបស់អង្គការ IUCN ( www.iucn.org/water )។

យើងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកទាំងអស់គ្នាដែលបានឆ្លើយតបនឹងសំណើសុំផ្តល់វិភាគទាន។ លោក Ger Bergkamp មានឥទ្ធិពលជាចំបងមកលើខ្លឹមសារនៃសៀវភៅនេះ។ អ្នកដទៃទៀតដែលយើងសូមថ្លែងអំណរគុណផងដែរគឺជាក្រុមអ្នកដែលធ្លាប់បាននិងដែលកំពុងធ្វើការនៅក្នុងកិច្ចផ្តួចផ្តើមស្តីពីទឹក និងធម្មជាតិ ( WANI ) ដែលមាន Alejandro Iza, Kelly West, Rocio Cordoba, Daniel Yawson, Kate Lazarus និង Qin Liyi។

Dipak Gyawali និង Louis Lebel បានផ្តល់វិភាគទានពិសេសដែលជម្រុញឲ្យអ្នកពិនិត្យកែសម្រួលធ្វើការបង្ហាញភស្តុតាងអំពីជម្រើសនានារបស់ពួកគេ។

Mary Jane Real, Tim Cullen, Danielle Hirsch, Louis Lebel, Richard Kyle Paisley, George Radosevich, Jeroen Warner និង Jim Woodhill សុទ្ធតែបានផ្តល់ការពិនិត្យលើជំពូកនានា និងគំនិតជាច្រើនដែលផ្តល់ជាគោលគំនិតសម្រាប់សៀវភៅនេះ។

សូមថ្លែងអំណរគុណជាពិសេសដល់ Megan Cartin និង MagaliRouaud ដែលបានជួយគាំទ្រ និងខិតខំពុះពារក្នុងការចងក្រងបញ្ចប់ និងរៀបចំបោះពុម្ពសៀវភៅនេះ។

យើងខ្ញុំសូមថ្លែងអំណរគុណ ចំពោះវិភាគទានហិរញ្ញវត្ថុសម្រាប់ការផលិតសៀវភៅនេះ ដែលបានមកពីរដ្ឋាភិបាលនៃប្រទេសហូឡង់តាមរយៈកិច្ចផ្តួចផ្តើមស្តីពីទឹក និងធម្មជាតិ។

សូមថ្លែងអំណរគុណផងដែរចំពោះ ឯកឧត្តម វ៉ាត់ បុត្តកុសល លោក ម៉េង មុនីរក្ស និងលោក យ៉ង ភិរម្យ ដែលបានជួយពិនិត្យមើល និងកែសម្រួលទាំងខ្លឹមសារបច្ចេកទេស និងអក្ខរាវិរុទ្ធ។

សូមថ្លែងអំណរគុណជាពិសេសចំពោះ លោក ស គឹមឡឹង លោក លូ វន្នី លោក ស៊ន ភក្តី កញ្ញា សយ ចិន្តា លោក ស៊ុំ ទូច និងលោក គង់ គីមស្រេង នៃអង្គការ IUCN ប្រចាំកម្ពុជា ដែលបានជួយពិនិត្យ និងកែសម្រួលបន្ថែមចុងក្រោយលើខ្លឹមសារ និងអក្ខរាវិរុទ្ធ ដើម្បីឲ្យសៀវភៅចរចាអំពីទឹកជាភាសាខ្មែរនេះត្រូវបានបោះពុម្ពផ្សាយដោយជោគជ័យ។



# ជំពូក ១

## ហេតុអ្វីចរចា?

### *១.១ ការចរចាដែលជាឧបករណ៍មួយសម្រាប់គ្រប់គ្រងទឹកដោយស្មើភាពប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាព*

តាំងពីសម័យបុរាណមក ការគ្រប់គ្រងទឹកបានក្លាយជាប្រភពមួយនៃការប្រឈមការបង្កើតថ្មី និងការជម្រុញទៅមុខសម្រាប់សង្គមមនុស្ស។ ប្រការនេះបានបង្ហាញភស្តុតាងតាមរយៈហេដ្ឋារចនាសម្ព័ន្ធទឹកប្រកបដោយរចនាបថ វិស្វកម្មដ៏ប្រណិតតាំងពីច្រើនសហស្សវត្សរ៍ និងសតវត្សរ៍មកហើយដែលនៅតែអាចមើលឃើញហើយជួនកាលនៅតែមានប្រើប្រាស់តាមទីកន្លែងនានាទូទាំងពិភពលោកនៅឡើយ។ ប្រការជាក់ស្តែងជាងនេះគឺថា ការគ្រប់គ្រងទឹកបានក្លាយជាបញ្ហាខាងផ្នែកវិស្វកម្មដែលទាមទារឲ្យមានដំណោះស្រាយបច្ចេកទេស។ ស្ថាប័ននានាដែលអាចត្រួតត្រាលើការវិនិយោគ ចំណេះដឹង និងការធ្វើសេចក្តីសម្រេចនានាដែលចាំបាច់ដើម្បីបង្កើនផលប្រយោជន៍ពីទឹកគឺជាស្ថាប័នដែលបាននិងកំពុងអនុវត្តកិច្ចការទាំងនេះបានដោយជោគជ័យ។ ទោះជាយ៉ាងណាក៏ដោយការអនុញ្ញាតឲ្យមានអភិក្រម "បច្ចេកាធិបតេយ្យ" បញ្ចេញឥទ្ធិពលលើសលុបនៅក្នុងការគ្រប់គ្រងទឹកបានបង្កឲ្យមានភាពទន់ខ្សោយមួយ។ វាជាការបិទបាំងភាពស្មុគស្មាញពិតប្រាកដដែលទាក់ទងនឹងទឹក។

មនុស្សគ្រប់រូបត្រូវការទឹកជារៀងរាល់ថ្ងៃ សម្រាប់ការប្រើប្រាស់ជាច្រើនអនេកដែលមានសារៈសំខាន់បំផុតសម្រាប់ការរស់រានមានជីវិត សុខភាព និងវិបុលភាព។ តម្រូវការរបស់មនុស្សមានឆ្លុះបញ្ចាំងតាមរយៈតម្រូវការចាំបាច់សម្រាប់ធម្មជាតិហើយគេត្រូវបំពេញតាមតម្រូវការទាំងនោះទៅតាមបរិបទនៃរបបជលសាស្រ្តក្នុងរដូវរាំងស្ងួត និងរដូវមានទឹកជំនន់ដែលក្នុងពេលនោះអាចមានទឹកតិចតួចពេក ឬផ្ទុយទៅវិញមានទឹកច្រើនពេក។ ចំណាប់អារម្មណ៍ និងទស្សនៈខុសៗគ្នាជាច្រើនអំពីថាតើ ប្រើប្រាស់ទឹកបែបណាឲ្យបានប្រសើរបំផុត និងសម្រាប់ផលប្រយោជន៍ណាខ្លះ។ ការចាត់ចែងភាពស្មុគស្មាញ និងភាពចម្រុះបែបនេះគឺជាការប្រឈមខាងសង្គម និងនយោបាយដែលក្នុងនោះការគ្រប់គ្រងទឹកតាមវិធានពីលើមកក្រោម "បញ្ជានិងត្រួតត្រា" មិនផ្តល់នូវដំណោះស្រាយសម្រាប់រយៈពេលយូរអង្វែងឡើយ។ ការគ្រប់គ្រងទឹកឲ្យមានប្រសិទ្ធភាពនិងប្រកបដោយនិរន្តរភាពទាមទារឲ្យមានអភិក្រមខុសគ្នាមួយ។

ដោយសារមានតម្រូវការឲ្យប្រើប្រាស់ និងគ្រប់គ្រងទឹកតាមទម្រង់ខុសៗគ្នាបែបនេះជម្រើសនានាខាងផ្នែកទឹកអាចមានឥទ្ធិពលមកលើចំណាប់អារម្មណ៍ និងកង្វល់របស់អ្នកពាក់ព័ន្ធជាច្រើន។ អ្នកដែលមានអារម្មណ៍ថាស្ថិតក្រោមឥទ្ធិពលនៃជម្រើសនានាទាំងនេះក៏មានភាពខុសគ្នាផងដែរ ដោយអាស្រ័យទៅលើបញ្ហានានា និងការប្រើប្រាស់ទឹកដែលពាក់ព័ន្ធ និងថាតើបញ្ហា និងការប្រើប្រាស់ទាំងនោះស្ថិតក្នុងបរិបទ បែបណាដូចជានៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ កម្រិតអាងទន្លេថ្នាក់តំបន់ឬពិភពលោក។ នៅក្នុងទីជម្រាលតូចៗដែលកសិករនិងគ្រួសារនានាត្រូវស្វែងរកវិធីនានាដើម្បី ចែករម្លែកទឹកតាមរយៈការសម្រេចនានានៅតាមមូលដ្ឋានដែលទាក់ទងនឹងទឹកក៏អាចមានឥទ្ធិពលមកលើ ក្រុមនានាដូចជា ស្ត្រីអ្នកចិញ្ចឹមសត្វ អ្នកនេសាទ និងកសិករផងដែរ។ ក្នុងករណីដែលទាក់ទងជាមួយផែនការ និងយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍអាងទន្លេក្រុមខុសៗគ្នាអាចមានចំណាប់អារម្មណ៍របស់ខ្លួន។ ក្រុមទាំងនេះអាចរាប់បញ្ចូល

ក្រុមហ៊ុនផ្គត់ផ្គង់ទឹក ក្រុមហ៊ុនប្រតិបត្តិការ ស្ថានីយ៍ថាមពលវារីអគ្គិសនី កសិករខ្នាតតូច ក្រុមហ៊ុនផ្តល់សេវាស្រោចស្រពតាមបែបពាណិជ្ជកម្ម ឧស្សាហកម្ម ឬអ្នកគ្រប់គ្រងតំបន់ដីសើមនានាដែលទ្រទ្រង់ជីវៈចម្រុះជលផល និងទឹកស្អាត។ ការសម្រេចមិនបានល្អលើករណីណាមួយដែលបង្កឲ្យមានកំហឹងដែលមិនគិតគូរអំពីសិទ្ធិ ឬធ្វើឲ្យប្រជាពលរដ្ឋបាត់បង់សិទ្ធិប្រើប្រាស់ទឹកអាចនាំឲ្យមានវិវាទ និងទំនាស់។ កង្វះការប្តេជ្ញារួមគ្នាឬការទទួលស្គាល់អំពីភាពស្របច្បាប់នៃការសម្រេចនានាអាចមានន័យថាប្រជាពលរដ្ឋជ្រើសរើសយកការមិនគោរពតាមហើយធនធានទឹកត្រូវបានប្រើប្រាស់ហួសកម្រិតក្លាយជាកខ្វក់ ឬមានឱនភាព។ ការធ្វើសេចក្តីសម្រេចដែលមានភាពត្រឹមត្រូវប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាព គឺជាប្រការដែលអាចធ្វើបានប្រសិនបើអ្នកពាក់ព័ន្ធនានាដែលមានចំណាប់អារម្មណ៍លើការសម្រេចនានា អំពីទឹកចូលមកធ្វើការជាមួយដើម្បីស្វែងយល់អំពីភាពមិនចុះសម្រុងគ្នារបស់ពួកគេ និងស្វែងរកដំណោះស្រាយដែលអាចប្រើការបានដែលភាគីនីមួយៗអាចទទួលយកបាន។ ដំណើរការចរចា និងជំនាញក្នុងការបង្កើតដំណើរការនេះ ការសម្របសម្រួល និងការចូលរួមនៅក្នុងការចរចាពហុភាគី មានសារៈសំខាន់ណាស់ដើម្បីធានាឲ្យដំណើរការនេះកើតឡើងបាន (សូមមើលប្រអប់១.១)។

សៀវភៅចរចា មានគោលបំណងជួយអ្នកប្រើប្រាស់ទឹកអ្នកគ្រប់គ្រងទឹក និងអ្នកកសាងគោលនយោបាយដែលពាក់ព័ន្ធនៅក្នុងការចរចាលើការសម្រេចនានាអំពីទឹក ដើម្បីកំណត់អត្តសញ្ញាណ និងបង្កើតឲ្យមានទម្លាប់ចរចាដែលមានប្រសិទ្ធភាព។ កិច្ចព្រមព្រៀងនានាលើកិច្ចការទឹក អាចកើតមានក្រោមរូបភាពខុសគ្នាជាច្រើន និងអាចជាកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនានា ឬពាក់ព័ន្ធជាមួយសង្គមស៊ីវិលបើទោះជាកិច្ចព្រមព្រៀងជាលាយលក្សណ៍អក្សរឬតាមប្រពៃណីក៏ដោយ ប៉ុន្តែការចរចាបានប្រសើរជាងមុនអាចជួយអ្នកពាក់ព័ន្ធនានាឈានដល់ដំណោះស្រាយដែលយកជាការបាន ដែលដំណោះស្រាយបែបនេះមិនអាចសម្រេចបានទេបើពុំមានការចរចាបែបនេះទេ។ ទម្លាប់នៃការចរចាដែលប្រសើរជាងមុនលើការគ្រប់គ្រងទឹកមានច្រើនណាស់។ កិច្ចព្រមព្រៀងវិភាជន៍ទឹក ផែនការគ្រប់គ្រងទីជម្រាល កំណែទម្រង់ច្បាប់ជាតិស្តីពីទឹក គោលនយោបាយរួមស្តីពីទឹក និងសន្ធិសញ្ញាស្តីពីទឹកឆ្លងដែនសុទ្ធតែពាក់ព័ន្ធជាមួយអ្នកពាក់ព័ន្ធជាច្រើន និងត្រូវស្ថិតក្រោមការចរចា។ ឯកសារចរចាមានគោលដៅលើកទឹកចិត្ត និងណែនាំដល់ការចរចាលើកិច្ចព្រមព្រៀងអំពីទឹកដោយស្មើភាព មានប្រសិទ្ធភាព និងដែលមាននិរន្តរភាពជាងមុនដោយផ្អែកលើការដាក់ឲ្យអនុវត្តបច្ចេកទេសនៃការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធនានាប្រកបដោយការស្ថាបនាដែលពង្រឹងជាបន្ថែមលើការវិភាគ និងការយល់ដឹងអំពីភាគលាភ សិទ្ធិ ហានិភ័យ និងការទទួលខុសត្រូវនានាពោលគឺ4Rsនៃការចរចា។

"ឯកសារចរចានេះមានគោលដៅលើកទឹកចិត្ត និងណែនាំឲ្យការចរចាលើកិច្ចព្រមព្រៀងអំពីទឹកធ្វើឡើងដោយស្មើភាពមានប្រសិទ្ធភាព និងដែលមាននិរន្តរភាពជាងមុន"

*ប្រអប់១.១តើមានអ្វីខ្លះជាចំណុចពិសេសៗដែលទាក់ទងនឹងទឹក?*

ដោយ Dipak Gyawali

ហេតុអ្វីត្រូវចរចា? និងតើការចរចាទាក់ទងបែបណាខ្លះជាមួយទឹក? ចម្លើយស្ថិតនៅលើលក្ខណៈធម្មជាតិនៃទឹកទាំងលើស្ថានភាពរូបសាស្ត្រ និងផលប៉ះពាល់ខាងសង្គមផងដែរ។ ដូចជាភាពសំបូរបែបនៃសត្វមានជីវិតនានាផងដែរ សេវាកម្មនានាដែលបានពីទឹកមានច្រើនណាស់ដែលទ្រទ្រង់ជីវៈចម្រុះនៅលើភពផែនដី។ ទឹកត្រូវគេស្គាល់ថាជាធនធាន "មិនស្ថិតស្ថេរ" ដែលមានន័យថាមិនដូចដីធ្លី ដើមឈើ

សារធាតុរ៉ែ ឬ មនុស្សឡើយ នៅពេលដែលទុកចោលមិនប្រើប្រាស់ ទឹកនឹងបន្តហូរចេញដោយព្យាយាមគេចខ្លួន។

ចលនារបស់ទឹកត្រូវគេសង្កេតឃើញយ៉ាងច្បាស់នៅក្នុងទន្លេ ប៉ុន្តែសូម្បីមានវត្តមាននៅមួយន្លែងក៏ដោយដូចជាផែនទឹកកក និងអាងជលសាស្ត្រទឹកកកទាំងនោះរលាយដោយស្ងៀមស្ងាត់ ឬហូតដោយគេមិនអាចមើលឃើញឡើយ។ ទឹកហូរចុះតាមទីជម្រាលដោយមិនអាចឃាត់បានជ្រាបចូលទៅក្នុងដីបន្ទាប់មកក៏លេចចេញមកលើផ្ទៃដីមកវិញ ក្រោមរូបភាពជាទឹកផុស និងកន្លែងដាំទឹកនៅតាមកន្លែងដែលមិនទំនងជាមានទឹកហូតដល់វាវិលត្រឡប់ទៅដល់សមុទ្រវិញហូតទៅក្នុងអាកាស និងធ្លាក់ចុះមកវិញជាទឹកភ្លៀង ឬជាព្រិល។ ដោយសារវត្តមាននៅគ្រប់ទីកន្លែងបែបនេះទឹកទំនងជាជ្រាបចូលនៅក្នុងគ្រប់អ្វីទាំងអស់ដែលញាំងឲ្យទស្សនវិទូក្រិកពីបុរាណ Thales of Miletus ធ្វើការប្រកាសចាត់ទុកទឹកថាជាវត្ថុធាតុដើមមួយនៃគ្រប់វត្ថុធាតុដទៃនានាទាំងអស់ ។

ប៉ុន្តែនៅពេលដែលមនុស្សចូលទៅក្នុងវដ្តនេះ ដែលមានកំណើនខ្លាំងក្លាពុំធ្លាប់មានពីមុនមកនៃតម្រូវការ និងអំណាចលទ្ធផលដែលកើតឡើងគឺសម្ពាធមកលើទឹក។
សម្ពាធនេះកើតឡើងស្រួចស្រាល់បំផុតមកលើអាយុជីវិតសត្វនានាក្រៅពីមនុស្ស និងរវាងសង្គមមនុស្សជាមួយគុណតម្លៃ និងលក្ខខណ្ឌខុសៗគ្នា។សេដ្ឋកិច្ចរបស់មនុស្សមានភាពខុសគ្នាប៉ុន្តែតម្រូវការនេះកាន់តែកើនឡើងដើម្បីបំពេញតម្រូវការសម្រាប់លក្ខខណ្ឌខុសៗគ្នារបស់ទឹក ប៉ុន្តែគេពុំមានទឹកគ្រប់គ្រាន់ដើម្បីបំពេញតាមតម្រូវការឡើយ។ ជាក់ស្តែងចាប់តាំងពីពេលចាប់ផ្តើមអារ្យធម៌មកម្លេះ ភាគច្រើននៃភាពស្ទាត់ជំនាញរបស់មនុស្សត្រូវបានពង្រីកនៅក្នុងការបញ្ឈប់លំហូរដោយធម្មជាតិនៃទឹក និងការបង្វែរទឹកនោះទៅទីកន្លែងផ្សេង ដើម្បីកាត់បន្ថយភាពស្រេកឃ្លានរបស់យើង។វាបាននិងកំពុងក្លាយជាប្រភពនៃបំណងអាក្រក់ ប្រសិនបើមិនមែនជាការប្រយុទ្ធប្រឆាំងទាំងស្រុងរវាងកិច្ចប្រឹងប្រែងខុសៗគ្នា ដែលកើតចេញពីទស្សនវិស័យខុសៗគ្នា៖ ឬ សគល់នៃខ្លឹមសារ "គូប្រជែង" ជាភាសាឡាតាំងត្រូវបានរកឃើញនៅក្នុងចំណោម "អ្នកដែលចែករម្លែកទឹកស្ទឹងជាមួយគ្នា" ។ វិវាទលើតម្រូវការដែលមានទំនាស់គ្នាគឺជាផ្នែកមួយឬចំណែកមួយនៃសិទ្ធិ ហានិភ័យ ការទទួលខុសត្រូវ និងភាគលាភពីធនធានដែលហូរប៉ុន្តែមិនស្ថិតស្ថេរដូចជាទឹក។

ទឹកពាក់ព័ន្ធជាមួយប្រធានបទនានា ដែលរាប់ចាប់ពីវិស្វកម្ម ជលសាស្ត្រ គីមី និងមីក្រូជីសាស្ត្រជាមួយសេដ្ឋកិច្ច ច្បាប់ សង្គមវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ និងទស្សនវិជ្ជា។ ការផ្តល់អភ័យឯកសិទ្ធិលើវិស័យមួយ (ដូចជាវិស្វកម្មស៊ីវិល) ទន្ទឹមនឹងការមិនអើពើដល់វិស័យដទៃ (ដូចជាសេដ្ឋកិច្ចឬសីលធម៌នៅក្នុងការគ្រប់គ្រងទឹកតាមបែបទំនើបបាននឹងកំពុងក្លាយជាឫសគល់នៃវិវាទជាច្រើនលើបញ្ហាទឹកនៅក្នុងដំណាក់កាលបច្ចុប្បន្ននេះ។

អ្វីដែលបានកែប្រែគឺមនុស្សកាន់តែច្រើនឡើងកំពុងទាមទារឲ្យមានអំណាចក្នុងការសំដែងយោបល់កាន់តែច្រើនឡើងអំពីរបៀបប្រើប្រាស់ទឹក ការគ្រប់គ្រងទឹក និងការចែករម្លែក។ ប្រជាពលរដ្ឋទាមទារតាមពាក្យសំដី ការចរចា។ ការចរចាដោយចំហអាចជាអភិក្រមសម័យថ្មីមួយសម្រាប់ដោះស្រាយវិវាទនានាដោយស្ម័គ្រចិត្ត។
ជម្រើសជំនួសគឺអំណាចលប់លើភាគីមួយពីសំណាក់ភាគីមួយផ្សេងទៀតការចុះញ៉ូមការមិនធ្វើសកម្មភាពការដកថយ និងអន្តរាគមន៍របស់ភាគីទីបី។

ការចរចាមានភាពច្របូលច្របល់។ វាទាមទារពេលច្រើន និងជាញឹកញាប់បង្កជាការរំខាន។ ប៉ុន្តែវានៅតែជាដំណើរការតែមួយគត់ដែលអាចដោះស្រាយបញ្ហាជាច្រើនដែលកើតចេញពីវិវាទនានាតាមវិធីមួយដែលបង្កើតឲ្យមានរូបភាពជាគ្រឿងលំអដ៏សំបូរបែប របស់សង្គមមនុស្ស និងបបនីយជីវមណ្ឌលដែលសំបូរបែបជាង និងដែលក្នុងនោះមានបង្កប់នូវអារ្យធម៌ផងដែរ។

### ១.១.១ តើការចរចាជាអ្វី?

យើងរស់នៅក្នុងពិភពលោកមួយដែលមានជម្រើសនានា អំពីវិភាជន៍ និងការប្រើប្រាស់ទឹក និងភាពមិនចុះសម្រុងគ្នាដែលត្រូវដោះស្រាយ។ ជម្រើសទាំងនេះច្រើនតែធ្វើឲ្យមនុស្សចូលមកជួបជុំគ្នាដើម្បីចរចា ពោលគឺ ជជែកតថ្លៃ ចែករម្លែកទស្សនទាន ដោះដូរ ត៉វ៉ា និងស្វែងរកដំណោះស្រាយដែលរួមបញ្ចូលការសម្រេចរួមគ្នាដែលអាចយកជាការបាន។

វចនានុក្រមឲ្យនិយមន័យពាក្យចរចាថាជា ១) ការព្យាយាមស្វែងរកកិច្ចព្រមព្រៀង ឬសម្បទានតាមរយៈការពិភាក្សា ២) ការទទួលបាន ឬ បង្កើតឲ្យមានតាមរយៈការចរចា ឬ ៣) ការស្វែងរកវិធីមួយដើម្បីជំនះ (ឧបសគ្គ ឬ លំនាំផ្លូវដ៏លំបាកមួយ)។ ពាក្យនេះមានប្រភពមកពីឡាតាំង “negotiare” ដែលមានន័យថា "ត្រូវធ្វើនៅក្នុងដំណើរការនៃធុរកិច្ច"។

និយមន័យដែលមានសារៈសំខាន់មួយបានចែងថា ៖

*ការចរចាគឺជាដំណើរការនៃអន្តរអំពើដែលភាគីពីរ ឬច្រើនដែលខ្វែងគំនិតគ្នាត្រូវសម្រុះសម្រួល ឬជម្រើសដែលត្រូវប្រកាន់យក ស្វែងរកការអនុវត្តឲ្យប្រសើរជាងមុន តាមរយៈចំណាត់ការដែលបានសម្រេចរួមគ្នា ជាងការអនុវត្តតាមរយៈសកម្មភាពដាច់ដោយឡែកពីគ្នា។ គោលដៅចំបងនៃការចរចា គឺឈានទៅរកកិច្ចព្រមព្រៀងមួយដែលអាចយកជាការបាន និងទទួលយកបានពីគ្រប់ភាគី។*

ការចរចា គឺជាដំណើរការសកម្ម និងរស់រវើក។ វាមិនត្រឹមតែជាការចូលរួមនៅក្នុងការវាយតម្លៃលើគំនិតរបស់អ្នកដទៃនោះឡើយ។ ការចរចាប្រកបដោយការស្ថាបនា មានន័យថាការរំពឹងទុក និងគោរពក្នុងការនាំយក និងចែករម្លែកយ៉ាងហោចណាស់គំនិតខ្លះៗរបស់អ្នកនៅក្នុង"តុចរចា"។[1]

*"ការចរចាគឺជាដំណើរការសកម្ម និងរស់រវើកមួយ"*

### ១.១.២ អភិបាលកិច្ច និងការចរចា

ចាប់ពីការពិភាក្សានៅក្រោមម្លប់ឈើតាមបែបបុរាណមួយ រហូតដល់ការប្រជុំក្នុងបន្ទប់នៅក្នុងសន្និបាតពេញអង្គនៃអ.ស.ប "តុចរចា" បានបង្កើតជាមូលដ្ឋាននៃការចូលរួមដើម្បីឲ្យមានអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព។ អភិបាលកិច្ចឈានហួសពីនិយមន័យតូចចង្អៀតអំពីមន្ត្រីរដ្ឋនៅក្នុងស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ និងរហូតដល់គ្រប់វិធីដែលសកម្មភាពរបស់មន្ត្រីទាំងនោះ អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងធុរកិច្ច មានភាពត្រួតគ្នាកាន់តែច្រើនឡើង។ វាអធិប្បាយអំពី "គ្រឿងលំអស្មុគស្មាញ" នៃការទាមទារសិទ្ធិអំណាចប្រកួតប្រជែងគ្នារវាងអាជ្ញាធរ"[2]។ និយាយឲ្យជាក់លាក់ជាងនេះ អភិបាលកិច្ចទឹក បង្ហាញអំពី "របាយនៃប្រព័ន្ធនយោបាយ សង្គម សេដ្ឋកិច្ច និងរដ្ឋបាល ដែលមានស្រាប់ដើម្បីបង្កើត និងគ្រប់គ្រងធនធានទឹក និងការផ្តល់សេវាកម្មទឹក នៅលំដាប់ថ្នាក់ខុសៗគ្នានៃសង្គមមនុស្ស"។[3]

*"តុចរចា"បង្កើតឲ្យមានមូលដ្ឋាននៃការចូលរួម ដើម្បីមានអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព"*

ក្នុងន័យនេះ អភិបាលកិច្ច អាចជាដំណើរការបែបស្ថាបនា និងច្នៃប្រឌិត ដែលជាញឹកញាប់ត្រូវបានបង្កើតឡើង និងអនុវត្តតាមរយៈការចរចា។ គេពុំមានអ្នកដើរតួតែមួយ ឬ សមិទ្ធផលតែមួយនោះឡើយ។

ផ្ទុយទៅវិញអភិបាលកិច្ចរាប់បញ្ចូលការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធនានានៅក្នុងទម្រង់ខុសៗគ្នានៃការចរចា និងអាចនាំឲ្យមានកិច្ចព្រមព្រៀងតាមទម្រង់ខុសគ្នា។

ចាប់ពីកម្រិតភូមិ រហូតដល់ថ្នាក់អន្តរជាតិ ការចូលរួម និងការចរចាអាចទាក់ទងនឹង ៖ ការជំទាស់ និងបញ្ចុះបញ្ចូល ការតស៊ូមតិ និងការទូត ការវិភាគ និងការមិនចុះសម្រុង ការប្រកួតប្រជែង និងសហប្រតិបត្តិការ។ ការចរចាលើវិវាទអំពីទឹក អាចជាដំណើរការដែលមានលក្ខណៈច្របូកច្របល់។ ប៉ុន្តែក្រៅពីនោះ ការប៉ុនប៉ងណាមួយក្នុងការដោះស្រាយឲ្យបានពេញលេញនូវភាពស្មុគស្មាញ និងភាពមិនចុះសម្រុងគ្នាបន្តិចបន្តួច ក៏អាចជាប្រការចាំបាច់ផងដែរ។ នៅទីបំផុត គោលដៅធំទូលាយគឺ ការបង្វែរវិវាទដែលអាចកើតមាន ឲ្យក្លាយទៅជាការចូលរួមប្រកបដោយការស្ថាបនា និងបន្ទាប់មកបង្កើនការចូលរួមទូលំទូលាយទាំងនោះទៅក្នុងការចរចាដែលសមស្របបំផុត និងតាមធម្មតា ក្នុងបំណងឈានទៅបង្កើតកិច្ចព្រមព្រៀងដោយស្ម័គ្រចិត្តមួយដែលមានយុត្តិធម៌ និងមានអាយុកាលយូរអង្វែង។

សៀវភៅនេះមានគោលដៅជួយអ្នកគ្រប់គ្រងទឹកនៅគ្រប់លំដាប់ថ្នាក់ នៅក្នុងការកំណត់និយមន័យ និងច្បាមចាប់ឲ្យណែននៅក្នុងដៃនូវភាពស្មុគស្មាញនៃការគ្រប់គ្រងទឹក ទាំងខាងផ្នែកនយោបាយ និងអេកូឡូស៊ី និងធ្វើការឆ្លើយតបទៅនឹងបញ្ហានេះ ជាឱកាសថ្មីមួយ ដើម្បីចូលរួមនៅក្នុងការចរចាប្រកបដោយការយល់ដឹងជាមុន និងតាមទស្សនច្រើនបែប។

*"គោលដៅធំទូលាយគឺការបង្វែរវិវាទដែលអាចកើតឡើងឲ្យទៅជាការចូលរួមប្រកបដោយការស្ថាបនា"*

## ១.២ Rs ទាំងបួន

*"ការចរចាគួរតែមានគោលដៅច្បាស់លាស់អំពី 4Rs"*

លំនាំផ្លូវទៅរកអភិបាលកិច្ចទឹកដោយស្មើភាព មានអាយុកាលយូរអង្វែង និងប្រកបដោយប្រសិទ្ធភាព ទាមទារឲ្យភាគីទាំងអស់ដែលធ្វើសកម្មភាពនៅក្នុងការចរចាដោយ"ស្មោះត្រង់" រក្សាបាននូវការយកចិត្តទុកដាក់លើ 4Rs ពោលគឺ ភាគលាភ ហានិភ័យ សិទ្ធិ និងការទទួលខុសត្រូវ។

អភិក្រមនេះគាំទ្រដល់អភិក្រម "សិទ្ធិ និងហានិភ័យ" ដែល "គណៈកម្មការពិភពលោកស្តីពីទំនប់" បានប្រកាន់យក 4Rs និងដែលត្រូវបានអធិប្បាយជាបន្តបន្ទាប់ថាជា "សិទ្ធិ ហានិភ័យ និងការទទួលខុសត្រូវ"។ ការចរចាបន្ថែមធាតុទីបួន ពោលគឺ "ភាគលាភ" ដើម្បីគូសបញ្ជាក់អំពីការលើកទឹកចិត្តនៅក្នុងការវិភាគអំពី 4Rs។

ភាពចាំបាច់ដើម្បីចងក្រងជាមួយគ្នានូវស្ថានភាពពិត និងទស្សនៈទានខុសៗគ្នាឲ្យទៅជាឯកសារ គឺជាការផ្តួចផ្តើមបឋមមួយ ដើម្បីនាំយកអ្នកពាក់ព័ន្ធទាំងអស់មកជួបជុំគ្នាដើម្បីធ្វើការចរចា។ វាជាការជួយកំណត់អត្តសញ្ញាណអ្នកដើរតួទាំងអស់ដែលមាន "ចំណាប់អារម្មណ៍" នៅក្នុងការចរចា។ វាក៏គូសបញ្ជាក់ប្រកបដោយតម្លាភាពផងដែរអំពីបញ្ហាជាក់ស្តែងដែលជាចំណាប់អារម្មណ៍ជាក់លាក់របស់ភាគីនីមួយៗ។ វាលើកឡើងនូវសំណួរត្រឹមត្រូវអំពីសិទ្ធិរបស់ប្រជាពលរដ្ឋ ដើម្បីកំណត់អំពីថាតើអ្នកណាស្វែងរកភាគលាភ ទាមទារសិទ្ធិរ៉ាប់រងហានិភ័យ ឬរ៉ាប់រងការទទួលខុសត្រូវ។

ការឆ្លើយតបទៅនឹងសំណួរទាំងនេះ គឺជាដំណើរការរស់រវើកដែលកំពុងតែកើតឡើង។ ការវិភាគ 4Rs នៅក្នុងការចរចា អាចជាប់ទាក់ទងជាមួយការស្វែងរក ការសម្ភាសន៍ ការស្តាប់ ការគូសវាស់អំពីទំនាក់ទំនង ការថតយករូបភាព ការកត់ត្រា ការប្រមូលផ្តុំ ការបកស្រាយ និងការពិភាក្សា គេអាចយកវាទៅអនុវត្តនៅក្នុងដំណាក់កាលដំបូងៗនៃការចូលរួមជួយភាគីនានាក្នុងការឈានទៅចរចាឲ្យកាន់តែខ្លាំងក្លា និងដើរតួជាតារាងសម្រាប់ពិនិត្យមើលកម្រិតទទួលយកបាននូវសេចក្តីព្រាងកិច្ចព្រមព្រៀងមួយ នៅក្នុងពេលកំពុងរៀបចំ។ 4Rs ផ្តល់ជាក្របខ័ណ្ឌមួយសម្រាប់បង្កើតរចនាសម្ព័ន្ធ វិភាគនិងស្វែងយល់អំពីចំណាប់អារម្មណ៍របស់អ្នកពាក់ព័ន្ធខុសៗគ្នា។ នៅក្នុងការចរចា ការដោយផ្តោតលើ 4Rs អាចជួយបង្កើតកាលានុវត្តភាពចាំបាច់សម្រាប់អ្នកចរចា ក្នុងការកំណត់អត្តសញ្ញាណអំពីធាតុនានា ដែលត្រូវតែដាក់បញ្ចូលជាមួយគ្នាដើម្បីឆ្លើយតបទៅនឹងចំណាប់អារម្មណ៍ខុសៗគ្នានៅក្នុងកិច្ចព្រមព្រៀងនានា។



រូបថត ១.១ ការវិភាជន៍ និងការគ្រប់គ្រងទឹកត្រូវតែបានមកពីការចរចាក្នុងចំណោមអ្នកពាក់ព័ន្ធនានា (តង់ហ្សានី)។

រូប១.១ 4Rs



*4Rs ផ្តល់នូវក្របខ័ណ្ឌមួយសម្រាប់បង្កើតរចនាសម្ព័ន្ធ វិភាគ និងស្វែងយល់អំពីចំណាប់អារម្មណ៍របស់អ្នកពាក់ព័ន្ធខុសៗគ្នា"។*

## ១.២.១ ភាគលាភ (Rewards)

នៅក្នុងស្ថានភាពនានា ដែលភាពតានតឹងលើបញ្ហាទឹក អាចរីករាលដាល អ្នកចរចាឈ្លាសវៃតែងតែងរក្សាទុកចំណុចមួយនៅជួរមុខនៃការគិតគូររបស់ពួកគេ ពោលគឺ ភាគលាភ។ ភាគលាភទាំងនេះមានរាប់ចាប់ពីការបង្កើត និងចែករំលែកផលចំណេញ រហូតដល់ការចែករំលែក និងការកាត់បន្ថយថ្លៃចំណាយផងដែរ។

ភាគលាភរូបវន្ត និងដែលអាចវាស់បាន រាប់បញ្ចូលប្រព័ន្ធអេកូឡូស៊ីដែលមានសុខភាពល្អជាងមុន, របបថ្មីៗ និងការលើកទឹកចិត្តដែលរីកចម្រើនឡើងជាលំដាប់។ គេលំបាកក្នុងការជំទាស់ទៅនឹងការលើកទឹកចិត្តនានា ដូចជា ភាគចំណែកទឹកស្អាតកាន់តែច្រើនឡើង ដែលអាចផ្គត់ផ្គង់ប្រកបដោយកម្រិតទុកចិត្តបាននៅពេលនិងនៅកន្លែងដែលប្រជាពលរដ្ឋត្រូវការវា។

មិនមែនភាគលាភទាំងអស់សុទ្ធតែអាចមើលឃើញច្បាស់ ដែលអាចមានលក្ខណៈរូបវន្ត ឬ អាចមើលឃើញជាក់ស្តែងនោះឡើយ។ ភាគលាភខ្លះមានលក្ខណៈដែលមិនអាចវាស់វែងបានដោយងាយឡើយ។ ចំពោះមនុស្សជាច្រើន គោលដៅនៃការចរចាគឺសិទ្ធិទទួលបានការគោរព និងការគាំទ្រ ការចែករំលែកហានិភ័យដោយសមធម៌, និងផ្តល់ភាពអង់អាចដល់អ្នកដើរតួនានាក្នុងការរ៉ាប់រងនូវការទទួលខុសត្រូវរបស់ខ្លួនឲ្យមានប្រសិទ្ធភាព។

ការវិភាគអំពីភាគលាភដែលបានពី 4Rs គួរផ្តោតលើទាំងទិដ្ឋភាពរូបវន្ត និងនិយាម តាមរយៈសំណួរគន្លឹះនានាដូចតទៅ:

- សម្រាប់ជម្រើសខុសៗគ្នាតើមានអ្វីខ្លះដែលអាចជាភាគលាភ?
- តើអ្នកណាមានជំហរក្នុងការទទួលផល ឬ ភាគលាភទាំងនេះ? តើអ្នកណានឹងបាត់បង់ផលប្រយោជន៍?
- តើគេអាចបែងចែកភាគលាភជាមួយគ្នាបែបណា?
- តើអ្វីទៅដែលហៅថា ស្មើភាព ប្រសិទ្ធភាពខ្ពស់ និង និរន្តរភាព?

## ១.២.២ ហានិភ័យ (Risks)

ការចរចា ក្នុងបំណងធ្វើឲ្យប្រែប្រួលលើការប្រើប្រាស់ ការគ្រប់គ្រង និងអភិវឌ្ឍន៍ទឹកច្រើនតែនាំមកនូវហានិភ័យខុសៗគ្នា។ ប៉ុន្តែជាបន្តបន្ទាប់ លក្ខណៈធម្មជាតិ និងការយល់ឃើញអំពីហានិភ័យនោះក៏ប្រែប្រួលផងដែរ។ កាលពីអតីតកាល ការយកចិត្តទុកដាក់ភាគច្រើនបានផ្តោតលើហានិភ័យហិរញ្ញវត្ថុ ដែលជាសម្ពាធមកលើវិនិយោគិនក្នុងវិស័យសាធារណៈ និងឯកជន។ ការសម្រេចនានាក្នុងពេលបច្ចុប្បន្ននេះ បានរាប់បញ្ចូលការសង្កត់ធ្ងន់ជាងមុនជាច្រើនមកលើហានិភ័យដែលអ្នកដើរតួទាំងអស់អាចត្រូវរ៉ាប់រង ទោះជាដោយស្ម័គ្រចិត្ត ឬ មិនមែនជាការស្ម័គ្រចិត្តក៏ដោយ។

ហានិភ័យខ្លះអាចត្រូវគេជ្រើសយកឬមិនជ្រើសយកមកបញ្ចូលនៅក្នុងដំណើរការធុរកិច្ចជាធម្មតា។ ក្រុមហ៊ុនមួយអាចសម្រេចធ្វើការវិនិយោគដើមទុនជាហិរញ្ញវត្ថុរបស់ខ្លួនលើទំនប់វារីអគ្គិសនី។ ទីភ្នាក់មួយ

នៃរដ្ឋាភិបាលអាចសម្រេចវិភាជន៍ថវិកាប្រចាំឆ្នាំរបស់ខ្លួនមួយផ្នែកសម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹក។ ភាពជាដៃគូរវាងវិស័យសាធារណៈ-ឯកជននៅក្នុងធុរកិច្ចមួយ អាចសម្រេចទៅបានផ្តោតការចំណាយពេលជាច្រើនឆ្នាំរបស់ខ្លួន ដើម្បីផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍមនុស្សខាងការកសាងផែនការ ការបង្កើតប្លង់ និងការអនុវត្តប្រព័ន្ធស្រោចស្រពមួយ។ អ្នកពាក់ព័ន្ធទាំងនេះទទួលយកហានិភ័យ ប៉ុន្តែពួកគេសុទ្ធតែទទួលយកដោយស្ម័គ្រចិត្ត។

ហានិភ័យដោយមិនស្ម័គ្រចិត្តមានភាពខុសគ្នាគួរឲ្យកត់សំគាល់ និងអាចផ្ទុយពីករណីខាងលើ។ អ្នកនេសាទនៅភាគខាងលើទំនប់វារីអគ្គិសនី អាចត្រូវបង្ខំចិត្តបោះបង់ចោលការនេសាទតាមធម្មតារបស់ខ្លួនខ្លះៗ។ ផ្ទះសំបែងដែលលិចលង់ដោយសារអាងធារាសាស្ត្រដែលបង្កើតឡើងថ្មីសម្រាប់ការផ្គត់ផ្គង់ទឹក អាចបង្ខំគ្រួសារនានាឲ្យបោះបង់ចោលទីលំនៅរបស់ខ្លួន។ ទីជម្រកដែលត្រូវគេបង្ហូរទឹកចេញអស់ ឬត្រូវជន់លិច ដោយសារប្រព័ន្ធស្រោចស្រពថ្មីមួយ អាចនាំឲ្យមានការថយចុះនៃពពួកសត្វព្រៃ។ អ្នកពាក់ព័ន្ធនានាដែលបាត់បង់សិទ្ធិ និងលទ្ធភាពក្នុងការប្រើប្រាស់ទឹក ដោយសារតែការកែប្រែណាមួយ ក៏ត្រូវទទួលយកហានិភ័យនានាផងដែរ ប៉ុន្តែពួកគេត្រូវទទួលយកហានិភ័យទាំងនោះដែលមិនមែនដោយការស្ម័គ្រចិត្តនោះឡើយ។

ការវិភាគ 4Rs នៅក្នុងពេលចរចា មិនគួរមើលរម្លងហានិភ័យដែលទទួលយកដោយស្ម័គ្រចិត្តនោះឡើយប៉ុន្តែគួរតែផ្តោតជាបឋមលើការទទួលយកហានិភ័យដោយមិនស្ម័គ្រចិត្ត បើពុំដូច្នេះទេ គេត្រូវពិនិត្យមើលថា តើគេអាចធ្វើបែបណាដើម្បីឲ្យមានការយកចិត្តទុកដាក់បែបនោះបាន ដោយត្រូវពិនិត្យមើលសំណួរនាំមុខគន្លឹះនានា ដូចតទៅ:

- សម្រាប់ជម្រើសខុសៗគ្នា តើមានអ្វីខ្លះដែលអាចជាហានិភ័យ?
- អ្នកណាខ្លះដែលអាចនឹងទទួលយកហានិភ័យដោយស្ម័គ្រចិត្ត?
- តើអ្នកណាខ្លះដែលនឹងក្លាយជាអ្នកទទួលយកហានិភ័យដោយមិនស្ម័គ្រចិត្ត?
- តើធ្វើបែបណាដើម្បីចែករម្លែកហានិភ័យ និងជាពិសេស ធ្វើបែបណាដើម្បីអាចកាត់បន្ថយហានិភ័យដែលទទួលយកដាយមិនស្ម័គ្រចិត្ត?

### *១.២.៣ សិទ្ធិ (Rights)*

ការវិភាគ 4Rs នាំដោយផ្ទាល់ទៅរកសំណួរអំពីថាតើអ្នកដែលទទួលយកហានិភ័យដោយមិនស្ម័គ្រចិត្តទាំងនោះនឹងចូលមកតុចរចា ដោយប្រកាន់យកជំហរខាងផ្លូវច្បាប់ដែរឬទេ និងធ្វើការចរចាដោយផ្អែកលើជំហរខាងសិទ្ធិមនុស្សចំពោះទឹក ឬ សេវាកម្មនានាដែលទាក់ទងនឹងទឹកដែរឬទេ។

មនុស្សជាច្រើនអះអាងថា អ្នកទាំងនោះភាគច្រើនពិតជាចូលមកកាន់តុចរចាជាមួយជំហរបែបនោះដោយសំដែងឲ្យឃើញច្បាស់អំពី"សិទ្ធិ"ពាក់ព័ន្ធដទៃទៀត ដូចមានចែងនៅក្នុងអត្ថបទខុសៗគ្នាអំពីនិយាម និងគុណតម្លៃជាសកល ដែលមានការពាក់ព័ន្ធជាមួយការចរចាអំពីទឹក។[5] គណៈកម្មាធិការ អ.ស.ប ស្តីពីសិទ្ធិខាងសេដ្ឋកិច្ច សង្គម និងវប្បធម៌ អះអាងថា ដោយសារតែទឹកគឺជាធនធានដែលមានក្នុងកម្រិតកំណត់ និងជាផលិតផលសាធារណៈដែលមានសារៈសំខាន់ជាសារវន្តចំពោះអាយុជីវិត និងសុខភាពៈ "សិទ្ធិមនុស្សចំពោះទឹកមានសារៈសំខាន់មិនអាចខ្វះបាន សម្រាប់ដឹកនាំខ្សែជីវិតទៅរកភាពថ្លៃថ្នូររបស់មនុស្ស។ នេះជាលក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តន៍សិទ្ធិមនុស្ស។ សិទ្ធិមនុស្សចំពោះទឹក ផ្តល់ឲ្យមនុស្សគ្រប់រូបនូវលទ្ធភាពក្នុងការទទួលបានទឹកក្នុងបរិមាណគ្រប់គ្រាន់ ប្រកបដោយសុវត្ថិភាព ដែលអាច

ទទួលយកបាន ជាក់ស្តែង និងដែលអាចជាវបានសម្រាប់ការប្រើប្រាស់ជាលក្ខណៈបុគ្គល និងសម្រាប់គ្រួសារ"។[6]

អ្នកមានអំណាចផ្សេងទៀតដូចជា ស.រ.អា និងស្ថាប័នអន្តរជាតិ ដែលរួមទាំង ធនាគារពិភពលោក មិនឯកភាពចំពោះអត្ថិភាពជាក់ស្តែងនៃសិទ្ធិនេះឡើយ។ អ្នកខ្លះថែមទាំងចាត់ទុកថា សិទ្ធិនេះអាចបង្កការវិនាសផងដែរ។ ប្រយោគជាក់លាក់អំពី "សិទ្ធិមនុស្ស" ធៀបនឹង "តម្រូវការចាំបាច់របស់មនុស្ស" បានធ្វើឲ្យអ្នកការទូតចូលរួម និងជំទាស់ នៅក្នុងវេទិកាពិភពលោកជាសកលនានាស្តីពីទឹកដែលរាប់ចាប់តាំងពីក្រុងម៉ិកស៊ិក រហូតដល់អ៊ីស្តង់ប៊ុល។ ទឹកនៅតែជាបញ្ហាចម្រូងចម្រាស់ ដែលត្រូវបានជជែកវែកញែកនៅក្នុងអភិបាលកិច្ចជាន់ខ្ពស់បំផុតផងដែរ។

ប្រការដែលទំនងជាមិនសូវសំខាន់ដូចប្រយោគជាក់លាក់នៅក្នុងច្បាប់ គឺស្មារតីដែលគ្របដណ្តប់សិទ្ធិមនុស្សរបស់អ្នកដែលត្រូវរ៉ាប់រងហានិភ័យដោយមិនស្ម័គ្រចិត្តផងដែរ។ ក្នុងន័យនេះ អត្ថបទជាច្រើននៅថ្នាក់តំបន់ ជួយកែលម្អបរិបទនេះ ដើម្បីឲ្យមានការចរចាដែលទាក់ទងនឹងទឹក ក្នុងក្របខ័ណ្ឌដែលកាន់តែទូលំទូលាយ និងមានការយល់ដឹងជាមុន ដែលពាក់ព័ន្ធជាមួយប្រជាពលរដ្ឋដែលអាចត្រូវជម្លៀស ឬ រងផលប៉ះពាល់ និងប្រព័ន្ធអេកូឡូស៊ីដែលជាមូលដ្ឋានសម្រាប់ការរស់នៅរបស់ពួកគេ។ នៅអឺរ៉ុប អនុសញ្ញាអាហ៊ីស (Aarhus) ស្តីពីអភិបាលកិច្ចបរិស្ថាន ផ្សារភ្ជាប់គោលការណ៍និរន្តរភាព សិទ្ធិបរិស្ថាន និងសិទ្ធិមនុស្ស។[7]

កិច្ចផ្តួចផ្តើមមួយរបស់អង្គការនៃរដ្ឋនានានៅអាមេរិក បានតម្រូវឲ្យសមាជិកបង្កលក្ខណៈឲ្យមានការចូលរួមពិតប្រាកដពីសំណាក់សង្គមទូទៅនៅក្នុងការធ្វើសេចក្តីសម្រេចរបស់រដ្ឋាភិបាល។ ប្រការស្រដៀងគ្នានេះ ត្រូវបានចែងបង្កប់នៅក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសជាច្រើន ក្រុមអនុវត្តរវាងប្រទេសនានា និងក្របខ័ណ្ឌប្រតិបត្តិការក្រៅផ្លូវការ ឬតាមប្រពៃណីខុសៗគ្នាជាច្រើនផងដែរ។

ជាការបញ្ជាក់ស្ថានភាពស្មុគស្មាញនានាទាមទារឲ្យមានការយល់ដឹងអំពីភាពចម្រុះដើម្បីធ្វើការសម្រេចដោយឈ្លាសវៃ។ និយាមនៅក្នុងឧទាហរណ៍ទាំងនេះផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់កំណត់និយមន័យអំពីសិទ្ធិអភិបាលកិច្ចទឹក។ ការដាក់បញ្ចូលនិយាមទាំងនេះទៅក្នុងការអនុវត្តជាក់ស្តែង អាចជាកិច្ចការស្មុគស្មាញ និងអាចបង្ហាញថាលំបាកអនុវត្ត ប៉ុន្តែសៀវភៅនេះចែងអំពីដំណើរការអន្តរកាលឈានទៅរកការចរចាដែលមានសមធម៌ និងស្មើភាពគ្នាជាងមុន។

ឯកសារចរចានេះ នឹងជួយភាគីនានាឲ្យបានដឹងអំពីទិដ្ឋភាពខុសៗគ្នាជាច្រើននៃសិទ្ធិដែលមានភាពត្រួតគ្នាដែលនឹងត្រូវទាមទារនិងទស្សនៈខុសៗគ្នាអំពីអាទិភាពរបស់ភាគីទាំងនោះដែលនឹងមានឥទ្ធិពលមកលើការចូលរួម, ការចរចានិងកិច្ចព្រមព្រៀងនានា។ សំណួរគន្លឹះអំពីសិទ្ធិរួមមាន ៖

- តើភាគីទាំងអស់មានសិទ្ធិអ្វីខ្លះនៅក្នុងការចរចា?
- តើសិទ្ធិទាំងនោះត្រួតគ្នាដែរឬទេ?
- តើមានទស្សនៈខុសគ្នាអ្វីខ្លះអំពីអាទិភាពនៃសិទ្ធិ?

### *១.២.៤ ការទទួលខុសត្រូវ (Responsibilities)*

បន្ថែមលើភាគលាភ ហានិភ័យ និងសិទ្ធិ ការចរចានានាលើកិច្ចការទឹកត្រូវតែពិចារណាផងដែរអំពីការទទួលខុសត្រូវ។ អ្នកពាក់ព័ន្ធទាំងអស់ បើទោះជាប្រជាពលរដ្ឋធម្មតា ក្រុមហ៊ុនអន្តរជាតិ ឬរដ្ឋាភិបាល

នៅលំដាប់ថ្នាក់ខុសៗគ្នា សុទ្ធតែមានភារៈកិច្ចទទួលខុសត្រូវ។ ឧទាហរណ៍ សិទ្ធិក្នុងការទទួលបានទឹកមកពីទន្លេ ឬ ល្អាងទឹកក្រោមដីក្នុងបរិមាណ និងគុណភាពជាក់លាក់ណាមួយ ទាក់ទងជាមួយការទទួលខុសត្រូវលើការប្រើប្រាស់ទឹកនោះឲ្យមានប្រសិទ្ធភាពខ្ពស់ សម្រាប់គោលបំណងដែលបានឯកភាពរួចមកហើយ។ ប្រសិនបើមើលរម្លងការទទួលខុសត្រូវការពង្រីកផលប្រយោជន៍ទៅតាមបំណងរបស់ភាគីមួយ នឹងក្លាយជាបន្ទុកមិនចាំបាច់សម្រាប់ភាគីមួយផ្សេងទៀត។ ចំណងទាក់ទងរវាងសិទ្ធិ និងការទទួលខុសត្រូវអាចមានជាទម្រង់ផ្លូវការ ឬ មិនផ្លូវការ ប៉ុន្តែដើម្បីរក្សាគុណតម្លៃសម្រាប់រយៈពេលយូរអង្វែង គេត្រូវតែយល់ដឹង និងឯកភាពលើសិទ្ធិ និងការទទួលខុសត្រូវទាំងនោះ នៅក្នុងអំឡុងពេលនៃការចរចា។

ដើម្បីកំណត់ឲ្យបានច្បាស់លាស់អំពីការទទួលខុសត្រូវ និងគូសបញ្ជាក់អំពីវិសាលភាពនៃគណនេយ្យភាព ការវិភាគអំពី 4Rs គួរតែកំណត់ឲ្យបានច្បាស់លាស់នូវតួនាទីករណីយកិច្ច និងកាតព្វកិច្ចរបស់អ្នកដើរតួខុសៗគ្នាលើកិច្ចការទឹកដោយប្រើប្រាស់សំណួរគន្លឹះនានា ដែលរួមទាំង ៖

- តើភាគីទាំងអស់មានការទទួលខុសត្រូវអ្វីខ្លះ នៅក្នុងការចូលរួម និងក្នុងការចរចា?
- តើអ្នកណាខ្លះត្រូវមានគណនេយ្យភាពចំពោះមុខអ្នកណា? គណនេយ្យភាពលើអ្វី?
- តើការទទួលខុសត្រូវទាំងនេះមានទំនាស់នឹងគ្នាដែរឬទេ?

## *១.៣ ជំពូកនានានៅក្នុងសៀវភៅនេះ*

ជំពូកនានានៅក្នុងសៀវភៅចរចានេះថែងបង្ហាញអំពីជំហានចំបងៗក្នុងការឈានទៅសម្រេចឲ្យបានកិច្ចព្រមព្រៀងអំពីទឹក ប្រកបដោយយុត្តិធម៌ និងកាន់តែមានប្រសិទ្ធភាពជាងមុន និងដោយនិរន្តរភាព។

ជំពូក ១ "ហេតុអ្វីចរចា?" ណែនាំឲ្យស្គាល់នូវការចរចាអំពីទឹកនៅក្នុងរូបភាពធំទូលាយនៃអភិបាលកិច្ច។ ជំពូកនេះសង្កត់ធ្ងន់លើការចូលរួមប្រកបដោយការស្ថាបនា និងផ្តល់នូវឧបករណ៍វិភាគចំនួនបួនផ្នែក ដែលគូសបញ្ជាក់ និងបង្ហាញយ៉ាងច្បាស់អំពី ភាគលាភ ហានិភ័យ សិទ្ធិ និងការទទួលខុសត្រូវ។

ជំពូក ២ "ការចូលរួមប្រកបដោយការស្ថាបនា" ពិនិត្យមើលអភិក្រមខុសៗគ្នាជាច្រើន សម្រាប់ការចរចា ដោយរាប់ចាប់ពីភាពប្រកួតប្រជែង រហូតដល់កិច្ចសហការគ្នា ដោយកត់សំគាល់ថា កត្តាទាំងនេះអាច និងពិតជាមានអត្ថិភាពជាមួយគ្នា។ ជំពូកនេះពិភាក្សាបន្ថែមអំពីភាពស្មុគស្មាញខាងផ្នែកសង្គមនៅលើកិច្ចការទឹក និងការវិភាគអំពីបញ្ហាខ្លះៗដែលទាក់ទងនឹងវប្បធម៌ នយោបាយ និងអំណាចនៅជុំវិញទឹក។

ជំពូក ៣ "វេទិកាពហុអ្នកពាក់ព័ន្ធ (MSPs)" បង្ហាញ និងបើកកកាយនូវឧទាហរណ៍មួយ អំពីអភិក្រមនៃការចូលរួមប្រកបដោយការស្ថាបនា ដែលអាស្រ័យលើការវិភាគ។ ជំពូកនេះត្រូវបានរៀបចំឡើងនៅជុំវិញសំណុំលក្ខណៈដែលយើងចង់បាននៃបរិបទ MSPs ដំណើរការ ខ្លឹមសារ និងសមិទ្ធផល។ MSPs មិនមែនជាឱសថទិព្វនោះទេ ប៉ុន្តែបទពិសោធន៍មកពីជុំវិញពិភពលោកបង្ហាញថា វិធាននេះមានប្រយោជន៍ខ្លាំងណាស់ ក្នុងការផ្តល់ព័ត៌មានសម្រាប់ការចរចា និងមានឥទ្ធិពលលើការចរចា។

ជំពូក ៤ "ការបង្កើតឲ្យមានការឯកភាពមតិ" ពន្យល់អំពីវិធីផ្សេងទៀតនៃការចរចា និងការអះអាងថា វាជាវិធីដែលមានប្រយោជន៍ ក្នុងការឈានទៅដល់កិច្ចព្រមព្រៀងអំពីទឹក ដែលកាន់តែមានភាពយុត្តិធម៌ និងកាន់តែមានប្រសិទ្ធភាព។ ជំពូកនេះដែលសំអាងលើហេតុការណ៍ ផ្តល់នូវគំនិតស៊ីជម្រៅ ដែលអាចជួយអ្នកទាំងឡាយដែលនឹងចូលរួមនៅក្នុងការចរចា។

ជំពូក ៥ "កិច្ចព្រមព្រៀង" ផ្តោតលើផលិតផលដែលរំពឹងទុក ថាកើតចេញពីការចរចាអំពីទឹក ក្នុងនោះកិច្ចព្រមព្រៀងជាក់ស្តែង ដែលផ្តល់ការណែនាំឲ្យមានវិភាជន៍កាន់តែមានយុត្តិធម៌ និងការប្រើប្រាស់ទឹកឲ្យកាន់តែមាននិរន្តរភាព។ ជំពូកនេះ ពិភាក្សាអំពីកិច្ចព្រមព្រៀងនៅក្នុងរដ្ឋនានា (នៅថ្នាក់មូលដ្ឋាន ថ្នាក់ក្រោមជាតិ ឬថ្នាក់ជាតិ) រវាងរដ្ឋ (ថ្នាក់តំបន់ អន្តរជាតិ) និងអ្នកដែលធ្វើការហួសព្រំដែននៃប្រទេស (រវាងប្រទេសនានា)។



# ការចូលរួមប្រកបដោយការស្ថាបនា

## ២.១ ការចូលរួមប្រកបដោយការស្ថាបនាសម្រាប់ការធ្វើសេចក្តីសម្រេចដ៏ស្មុគស្មាញ

មួយផ្នែកនៃភាពស្មុគស្មាញអំពីទឹកកើតឡើងដោយសារ ជាញឹកញាប់មានអ្នកពាក់ព័ន្ធជាច្រើនដែលមានចំណាប់អារម្មណ៍ខុសៗគ្នាដែលពួកគេចង់លើកយកមកពិចារណានៅក្នុងការសម្រេចនានាអំពីទឹក។ ជម្រើសដែលបានធ្វើឡើងទាក់ទងនឹងរបៀបវិភាជន៍ ឬគ្រប់គ្រងទឹកមានឥទ្ធិពលមកលើប្រជាពលរដ្ឋផ្សេងទៀត និងការប្រើប្រាស់ទឹកតាមទម្រង់ខុសៗគ្នា។ ជាញឹកញាប់ឥទ្ធិពលទាំងនេះកើតឡើងឆ្លងកាត់កម្រិតនិងលំដាប់ថ្នាក់ ហើយជាលទ្ធផលអ្នកធ្វើសេចក្តីសម្រេចទាំងនោះអាចមើលមិនឃើញ ឬចាត់ទុកថាជាអាទិភាពទាប។ អ្នកស្រោចស្រពនៅខ្សែទឹកខាងលើអាចមិនបានដឹងអំពីឥទ្ធិពលសរុបពីការសម្រេចរបស់ពួកគេ មកលើវិភាជន៍ទឹក ឬមកលើការផលិតថាមពលវារីអគ្គិសនីនៅខ្សែទឹកខាងក្រោមឡើយ។ សេចក្តីសម្រេចនានាលើការដោះទឹកជំនន់ពីទំនប់អាចមិនបានគិតគូរអំពីហានិភ័យដូចជាភាពងាយរងគ្រោះរបស់អ្នកដែលរស់នៅជាប់នឹងទន្លេ និងដែលប្រើប្រាស់ទន្លេនានាដែលការខូចខាតអាចមានទំហំតូចនៅកម្រិតអាងទន្លេប៉ុន្តែមានទំហំធំសម្រាប់អ្នករងគ្រោះនៅក្នុងមូលដ្ឋាន។ ការធ្វើឲ្យមានសេចក្តីសម្រេចដោយយុត្តិធម៌អំពីទឹកមានលក្ខណៈសាំញ៉ាំ ដោយសារតែភាពចាំបាច់ដើម្បីផ្តល់អាទិភាព និងដោះស្រាយផលប្រយោជន៍ និងទស្សនៈដែលទំនាស់គ្នាជាច្រើននៃការចាត់ជាអាទិភាពលើវិធីនៃការបែងចែក4Rs ពោលគឺភាគលាភ ហានិភ័យ សិទ្ធិនិងការទទួលខុសត្រូវ។

អ្នកពាក់ព័ន្ធនានា អាចរួមវិភាគទាន គាំទ្រ ឬ ជំទាស់ចំពោះការសម្រេចនានា តាមរយៈវិធីខុសគ្នាជាច្រើន។ ប្រសិនបើសេចក្តីសម្រេច ឬផែនការនានាត្រូវបានគេយល់ឃើញថាពុំមានលក្ខណៈត្រឹមត្រូវទេនោះ អ្នកពាក់ព័ន្ធនានាអាចជ្រើសយកការជំទាស់។ ពួកគេអាចជំទាស់ ឬ បដិសេធចំពោះចំណាត់ការដែលជាលក្ខខណ្ឌមកលើពួកគេ។អ្នកដែលមានអំណាចអាចជ្រើស យកការគាបសង្កត់ ដើម្បីពង្រឹង ឬ ប្រែក្រឡាស់សេចក្តីសម្រេចនានា។ ការឆ្លើយតបទាំងពីរនេះជួនកាលអាចរាលដាល ដែលរួមមានទាំង ការរំលោភ និងអំពើហឹង្សា ដែលនាំមកនូវលទ្ធផលដែលវិវាទអំពីទឹកអាចបង្ក ឬ ក្លាយជាប្រភពនៃជម្លោះ ជាពិសេស នៅក្នុងករណីដែលមានភាពតានតឹងជាច្រើនរួចមកហើយនៅក្នុងសង្គម។

ការចូលរួមប្រកបដោយការស្ថាបនាគឺជាលំនាំផ្លូវមួយផ្សេងទៀត ដែលមានគោលដៅកែលម្អយុត្តិធម៌ និងប្រសិទ្ធភាព នៃសេចក្តីសម្រេចដែលស្មុគស្មាញ លើកិច្ចការទឹក តាមរយៈដំណើរការបែបសន្តិវិធីដែលមានការយល់ដឹងជាមុន និងពេញលេញ។

> *"ការចូលរួមតាមបែបស្ថាបនាផ្តល់នូវវិធីមួយដែលអាចឆ្លើយតបចំពោះចំណាប់អារម្មណ៍ និងទស្សនទានខុសៗគ្នា"*

ការចូលរួមតាមបែបស្ថាបនា មិនដកហូតបំណងប្រាថ្នាដែលមនុស្សទាំងឡាយនាំមកបញ្ចូលនៅក្នុងវិវាទ និងការសម្រេចនានាអំពីទឹកនោះឡើយ ប៉ុន្តែវាផ្តល់នូវវិធីមួយដើម្បីឆ្លើយតបចំពោះចំណាប់អារម្មណ៍ និងទស្សនទានខុសៗគ្នា ដែលជម្រុញទឹកចិត្តទាំងនោះនៅក្នុងដំណើរការនានា ដើម្បីស្វែងរកវិធីទៅមុខដែលឯកភាពគ្នា។ ប្រអប់ ២.១ ស្វែងយល់អំពីសារៈសំខាន់នៃរបៀបធ្វើការនៅក្នុងភាពចម្រុះបែបនេះ ដើម្បីស្វែងរកដំណោះស្រាយដែលអាចយកជាការបាននៅក្នុងការដោះស្រាយបញ្ហាគ្រប់គ្រងទឹក។ អ្នកពាក់ព័ន្ធនានាដែលជ្រើសយកការចូលរួមប្រកបដោយការស្ថាបនាទទួលស្គាល់ថា ដោយសារតែភាពស្មុគស្មាញដែលទាក់ទងនឹងទឹក សមិទ្ធផលនានាទំនងជាមិនសូវឆ្លើយតបនឹងបំណងប្រាថ្នាឡើយហើយ

បញ្ហានានាកាន់តែរីកដាលដោយសារតែចំណាត់ការដាច់ដោយឡែកពីគ្នា។ ពួកគេទទួលស្គាល់ថាលំនាំផ្លូវដែលចង់បានគឺត្រូវធ្វើការជាមួយអ្នកដទៃដើម្បីស្វែងរកជម្រើសនានាដែលអាចទទួលយកបានទាំងអស់គ្នា។

*"ការចូលរួមប្រកបដោយការស្តាបនាអាចកើតឡើងតាមទម្រង់ខុសៗគ្នាជាច្រើន"។*

ការចូលរួមប្រកបដោយការស្ថាបនា អាចកើតឡើងក្រោមរូបភាពជាច្រើន។ នៅក្នុងទំនាក់ទំនងរវាងរដ្ឋនានាកិច្ចការទូតគឺជាទម្រង់មួយនៃការចូលរួមប្រកបដោយការស្ថាបនា។ការប្រើប្រាស់នីតិវិធីតាមផ្លូវច្បាប់ ដើម្បីដោះស្រាយវិវាទនានា គឺជាវិធីមួយផ្សេងទៀត នៅពេលដែលភាគីនានាប្រើប្រាស់ដំណើរការតាមផ្លូវតុលាការដើម្បីអះអាង ឬ ជជែកវែកញែកអំពី ភាពស្របច្បាប់ និងនិត្យានុកូលភាព ដូចជា នៃកិច្ចការពារសិទ្ធិលើប្រព័ន្ធអភិវឌ្ឍន៍ធនធានទឹក។ ក្រុមនានាអាចចូលរួមដោយការស្ថាបនា ជាមួយ រដ្ឋាភិបាលនានា ឬក្រុមហ៊ុននានា តាមរយៈការតស៊ូមតិ ឬការបញ្ចុះបញ្ចូល។ ឧទាហរណ៍ទាំងអស់នេះ គឺជាមធ្យោបាយ ដើម្បីព្យាយាមមានឥទ្ធិពលទៅលើការសម្រេចនានា ដែលអាចឆ្លើយតបបានល្អជាងគេចំពោះចំណាប់អារម្មណ៍ និងទស្សនទានខុសៗគ្នាជាច្រើន។

ព្រំដែនកំណត់នៃការចូលរួមប្រកបដោយការស្ថាបនា អាចជាការកំហិតលើសិទ្ធិប្រើប្រាស់។ ក្រុមខ្លះអាចស្ថិតក្នុងជំហរល្អជាង ឬអាចប្រើប្រាស់គំរូខ្លះនៃការចូលរួមប្រកបដោយការស្ថាបនា។ឧទាហរណ៍ ការទារសំណងតាមផ្លូវច្បាប់ច្រើនតែមិនអាចធ្វើបានឡើយសម្រាប់ក្រុមអ្នកពាក់ព័ន្ធដែលពុំមាននិត្យានុកូលភាពតាមផ្លូវច្បាប់ ធនធានហិរញ្ញវត្ថុ ឬ គ្មានជំនាញឯកទេស ដែលចាំបាច់ ដើម្បីពួកគេអាចចូលរួមប្រកបដោយប្រសិទ្ធភាពនៅក្នុងដំណោះស្រាយតាមផ្លូវតុលាការ។ សូម្បីតែរកបានធនធាន និងសមត្ថភាពហើយក៏ដោយ ភាគីដែលមានអំណាចខ្លាំងជាង នៅតែអាចទាញយកប្រយោជន៍ តាមរយៈវត្តមានធនធានទាំងនោះច្រើនជាង។ ដូចគ្នានេះដែរ ការតស៊ូមតិអាចផ្តល់ជោគជ័យជាងផងដែរ សម្រាប់អ្នកដែលមានលទ្ធភាពក្នុងការទាក់ទងជាមួយអ្នកដើរតួដែលមានឥទ្ធិពលជាងធ្វើឲ្យក្រុមអ្នកមិនសូវមានអំណាចឬមិនមានតំណាងគ្រប់គ្រាន់ចុះខ្សោយ។ វិសមធម៌បែបនេះ ធ្វើឲ្យមានភាពលំអៀងចំពោះសមិទ្ធផលដែលបានពីការចូលរួម ដែលនាំទៅរកលទ្ធផលមិនត្រឹមត្រូវ ឬ ដែលនាំឲ្យគេយល់ថាលទ្ធផលមិនត្រឹមត្រូវ។

*ប្រអប់ ២.១៖ ភាពរឹងប៉ឹងនៃសង្គម ក្រមួន ស្ទួលអំបោះ និងអណ្តាតភ្លើង វិទ្យាសាស្ត្រ និងសិល្បៈ*

ដោយ Dipak Gyawali

សាមគ្គីភាពនៃសង្គម៖ ទស្សនវិស័យខុសៗគ្នាចំនួនបួន

វិទ្យាសាស្ត្រគីមីទំនើបបង្រៀនយើងថាទឹកផ្សំឡើងដោយ$H_2O$។ ទោះជាយ៉ាងណាក៏ដោយ វិទ្យាសាស្ត្រសង្គមនៅតែប្រាប់យើងថាទឹកបានមកពីការចាប់កំណើតឡើងវិញជាច្រើនលើកដូចជា ការចាប់បដិសន្ធិនៃសង្គមមនុស្សផងដែរ។ ក្នុងពេលដែលសង្គមមនុស្សមានលក្ខណៈសាំញ៉ាំ និងពហុភាពសង្គមទាំងឡាយនៅតែបង្ហាញអំពីទម្រង់រួមខ្លះៗនៃឥរិយាបថដែលកំណត់អំពីថាតើមានការឲ្យតម្លៃទឹកដោយរបៀបណា។ ភាពរឹងប៉ឹងទាំងបួននៅក្នុងសង្គមដែលមានទស្សនៈខុសៗគ្នានៅក្នុងការចរចាអំពីទឹកអាចឃើញមាននៅចាប់ពីកម្រិតភូមិរហូតដល់កម្រិតពិភពលោក៖

- សាមគ្គីភាពនៅក្នុងឋានានុក្រមនៃបទប្បញ្ញត្តិ ដែលនិយមអំណាច និងពួកអ្នកដែលមានឥទ្ធិពល ក្នុងការត្រួតត្រាមកលើស្ថាប័ននានា ដែលជាកន្លែងការពារសិទ្ធិទាំងនោះ និងដើម្បីជៀសវាងហានិភ័យនានា។
- សាមគ្គីភាពជាលក្ខណៈបុគ្គលនៅក្នុងទីផ្សារដែលនិយមទ្រព្យសម្បត្តិ និងពួកអ្នកមានដែលអាចទិញសិទ្ធិហ៊ានប្រថុយ និងទទួលជោគជ័យនៅក្នុងទីផ្សារ
- សាមគ្គីភាពនៃសមភាពនិយមរបស់ប្រជាពលរដ្ឋ ដែលមានគោលដៅចង់បានរបាយនៃ 4Rs ប្រកបដោយសមធម៌ និងសមភាពជាងមុន និង
- សាមគ្គីភាពនៃជំនឿកម្មវាសនា ដែលជឿថាខ្លួនគ្មានរចនាសម្ព័ន្ធស្ថាប័នមើលឃើញថាខ្លួន មិនអាចយកឈ្នះលើអតុល្យភាពនិងវិសមធម៌បានឡើយ និងស្ថិតនៅចាញ់ប្រៀបក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃ4Rs។

សាមគ្គីភាពចំនួនបីខាងដើមនិងសង្គមដែលសកម្ម (ដោយមិនរាប់បញ្ចូលក្រុខាងក្រោយដែល ផ្អែកលើកម្មវាសនាមានមូលដ្ឋានគ្រឹះខុសៗគ្នា ដែលមានឥទ្ធិពលមកលើវិធីដែលពួកគេគិតគូរអំពីទឹក ដែលអាចចាត់ទុកថាជាសម្បត្តិ សាធារណៈ ឯកជនសម្បត្តិរួម។ល។ និងថាតើសមិទ្ធផលនៃការចរចាប្រកបដោយយុត្តិធម៌ គួរតែមានទម្រង់បែបណា ។ ទស្សនវិជ្ជាទាំងនេះមានទំនាស់នឹងគ្នាទៅវិញទៅមក និងមិនអាច "រួមបញ្ចូល" ជាមួយគ្នាដោយងាយស្រួលនោះឡើយ។ ប្រការសំខាន់គឺត្រូវវាយតម្លៃខ្ពស់ ប្រសិនបើយើងត្រូវស្វែងយល់អំពីអ្វីដែលចង់ឲ្យការចរចាបានទទួលជោគជ័យ ឬ ការសង្ស័យនៅក្នុងកែវភ្នែករបស់អ្នកដើរតួខុសៗគ្នា។ ជាការពិត អ្នកទាំងឡាយ និងអង្គការនានា អាចត្រូវពឹងផ្អែកលើសាមគ្គីភាពទាំងនេះច្រើនជាងមួយ។

ក្រមួន ស្ពូលអំបោះ និងអណ្តាតភ្លើង ជំពូកខុសៗគ្នានៃអំណាចទស្សនវិជ្ជាសំខ្យា (Samkhya) ដែលជាខ្សែស្រឡាយចំបងមួយក្នុងចំណោមទស្សនវិជ្ជាចំបងៗទាំង៦ របស់ហិណ្ឌូ ដែលបែងចែកភាពខុសគ្នារវាងអំណាចបង្គាប់បញ្ជា (ច្បាប់ បទប្បញ្ញត្តិ ការប្រតិបត្តិច្បាប់) ដែលអនុវត្តដោយសាមគ្គីភាពតាមឋានានុក្រម (tamasik shakti) អំណាចបញ្ចុះបញ្ចូល (ទឹកប្រាក់ ឬ ការចាត់ចែង) ដែលធ្វើឡើងដោយសាមគ្គីភាពរបស់បុគ្គល (rajasik shakti) និងអំណាចសីលធម៌ ដែលទាមទារ និងប្រើប្រាស់ដោយសហគមន៍ដែលនិយមសមភាព (satwik shakti)។

អធិបតេយ្យខាងផ្នែកទឹកនៅក្នុងប្រទេសនានាអាចប្រើប្រាស់អំណាចបង្គាប់បញ្ជា ហើយពាណិជ្ជកម្ម និងឧស្សាហកម្មសាងសង់គឺជាកន្លែងដែលមានអំណាចបញ្ចុះបញ្ចូល ប៉ុន្តែចលនាជាច្រើន ដែលមាននិន្នាការការពារសង្គម និង បរិស្ថាន បានទទួលការគាំទ្រ ដោយសារតែអំណាចសីលធម៌ និង ការយល់ដឹងរបស់ពួកគេ។ ក្នុងនាមជាសម្លេងរបស់អ្នកក្រដែលរងនូវការរើសអើង ឬភាពស្ងាត់ស្ងៀមនៃធម្មជាតិក្រៅពីមនុស្ស ចលនាការពារសង្គមនិងបរិស្ថានជាច្រើន បានជះឥទ្ធិពលមកលើមនុស្សជាច្រើន ដែលជម្រុញឲ្យពួកគេគាំទ្រដល់ចំណាត់ការរបស់ខ្លួនដែលអាចត្រូវចំណាយរហូតដល់សុខមាលភាពផ្ទាល់ខ្លួនរបស់ពួកគេផងដែរ។

Samkhya ជៀសវាងសុទិដ្ឋិនិយម (Reductionism) ដោយអះអាងថា ការអនុវត្តអំណាចស្របគ្នា ទាមទារឲ្យមានតុល្យភាព និងការរួមបញ្ចូលគ្នានូវសាមគ្គីភាពទាំងបីនេះ។ ការប៉ុនប៉ងរបស់អាស៊ីខាងត្បូងកាលពីមុនមក នៅក្នុងការគិតគូរឲ្យបានគ្រប់ជ្រុងជ្រោយបានអះអាងថា tamasik, rajasik និងsatwik មានលក្ខណៈប្រហែលគ្នាទៅនឹងក្រមួន ស្ពូលអំបោះ និងអណ្តាតភ្លើង ដែលអវត្តមានធាតុណាមួយនឹងមិនអាចផ្តល់ពន្លឺបានឡើយ។ នេះជាអ្វីដែលយើងបានជ្រើសយកដោយដាក់ឈ្មោះថា "ការចូលរួមប្រកបដោយការស្គាបនា" រវាងសាមគ្គីភាពខាងឋានានុក្រម ទីផ្សារ និងសមភាព។

*វិទ្យាសាស្ត្រ និងសិល្បៈ*

ប្រសិនបើជាប់គាំង ហើយការគ្រប់សង្កត់ គឺជាប្រការដែលមិនអាចទទួលយកបានដោយការចរចាគឺជាវិធីដើម្បីឈានទៅមុខនៅក្នុងស្ថានភាពជាក់ស្តែងតើធ្វើបែបណាដើម្បីអាចដោះស្រាយបាន?

អ្នកដែលបានអនុវត្តកិច្ចការនេះបានអះអាងថា វាគឺជាវិទ្យាសាស្ត្រ និងក៏ជាសិល្បៈផងដែរ។ Raiffa អះអាងថា "វិទ្យាសាស្ត្រ" មានន័យថាការវិភាគជាលក្ខណៈប្រព័ន្ធដើម្បីដោះស្រាយបញ្ហាក្នុងនោះផ្នែកប្រព័ន្ធដែលបានបង្កើតឡើង និងបានទទួលការគាំទ្រពីភាពម៉ត់ចត់របស់គណិតវិទូ ជាពិសេស ផ្នែកនានាដូចជា ទ្រឹស្តីល្បែង និងការវិភាគប្រតិបត្តិការ។[7] ផ្នែក "សិល្បៈ" មិនអាចឲ្យគណិតវិទូដែលជាអ្នកម៉ត់ចត់ងាយយល់បានទេ និងរួមបញ្ចូលជំនាញទំនាក់បុគ្គល ពោលគឺសមត្ថភាពក្នុងការបញ្ចុះបញ្ចូល និងការលង់តាមការបញ្ចុះបញ្ចូល សមត្ថភាពក្នុងការប្រើប្រាស់វិធីតថ្លៃខុសៗគ្នាជាច្រើន និងបញ្ញាក្នុងការចង់ដឹងអំពីពេលវេលា និងរបៀបប្រើប្រាស់វា។[9]

នៅរវាងវិទ្យាសាស្ត្រគណិតវិទ្យានៃការចរចា និងសិល្បៈនៃជំនាញទំនាក់ទំនងបុគ្គលគឺ វិទ្យាសាស្ត្រសង្គមនៃការចរចា ដែលពិតជាអះអាងអំពីភាពសមហេតុផល និងភាពហ្មត់ចង់នៅក្នុងការវិភាគ។ ប៉ុន្តែវាក៏បង្ហាញឲ្យឃើញផងដែរអំពីភាពស្រពេចស្រពិលដែលកើតឡើងជាមួយបញ្ហានានាដូចជា វប្បធម៌ និងអំណាច។ ពួកគេទទួលយកសនិទានភាពជាច្រើននៃសាមគ្គីភាពខុសៗគ្នារបស់សង្គម និងជំនឿផ្ទុយគ្នានៃសនិទានភាពទាំងនោះដែលផ្តល់ឲ្យយើងនូវទស្សនៈសំខាន់ៗ ដើម្បីជាមូលដ្ឋានក្នុងការស្វែងយល់អំពីការប្រឈមខាងផ្នែកសង្គម ពោលគឺការចរចា។

ផ្នែកចរចាអំពីទឹក មានបង្រៀនយ៉ាងច្រើនលើសលុបកាលពីអតីតកាលនៅក្នុងមហាវិទ្យាល័យទំនាក់ទំនងអន្តរជាតិ និងវិទ្យាសាស្ត្រនយោបាយដែលធ្វើឲ្យរដ្ឋនានាក្លាយជាអ្នកដើរតួបឋម (តែឯង) ជឿលើប្រសិទ្ធភាពខាងសេដ្ឋកិច្ចថាជាលក្ខណៈវិនិច្ឆ័យបឋមក៏ដូចជាសម្បទាតាមឋានានុក្រមឆ្ពោះទៅរកការបង្កើតរបបតាមរយៈបទប្បញ្ញត្តិ ច្បាប់ បទបញ្ជា និងសន្ធិសញ្ញានានាផងដែរ។ ការកែប្រែឥទ្ធិពលនៃទស្សនទាននានាដើម្បីធ្វើឲ្យការគ្រប់គ្រងទឹកទទួលបានជោគជ័យនៅក្នុងរយៈពេលជាច្រើនឆ្នាំ និងទសវត្សរ៍ខាងមុខ ទាមទារឲ្យមានការដាក់បញ្ចូលកង្វល់នានាអំពីសមធម៌សង្គម និងបរិស្ថាន ក៏ដូចជាការប្រែប្រួលអាកាសធាតុផងដែរ។ ដើម្បីធ្វើបែបនេះបានដំណើរការចរចាត្រូវតែរួមបញ្ចូលនៅក្នុងការចូលរួមរបស់ខ្លួននូវសម្លេងរបស់អ្នកដើរតួដែលមិនមែនជារដ្ឋ ក៏ដូចជាផ្នែកជាវិទ្យាសាស្ត្រសង្គមផ្សេងទៀតផងដែរដូចជា សង្គមវិទ្យា និងនរវិទ្យា ដើម្បីបំពេញបន្ថែមលើទស្សនទានតាមធម្មតាដែលបានពីច្បាប់ និងសេដ្ឋកិច្ច។ នេះមានន័យថាត្រូវបោះបង់ចោលដំណោះស្រាយខាងផ្នែកទឹក ដែលផ្អែកតែលើយន្តការទីផ្សារ និងអន្តរាគមន៍របស់រដ្ឋាភិបាល ប៉ុន្តែឈានទៅឲ្យហួសពីភាពជាដៃគូតែរវាងវិស័យសាធារណៈ ឯកជន និងបង្កើតឲ្យមានការចូលរួមប្រកបដោយការស្ថាបនាដែលផ្តោតលើភាគីចំនួនបី ដែលរួមមានទាំង ចលនារបស់ក្រុមជនអ្នកទន់ខ្សោយ និងចលនាការពារបរិស្ថាន ដែលអាចដើរតួប្រកបដោយភាពច្នៃប្រឌិត ប្រសិនបើពួកគេត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងតុចរចា។

## ២.២ ការចូលរួមជាសាធារណៈប្រកបដោយប្រសិទ្ធភាព

ការទាមទារឲ្យមានការចូលរួមជាសាធារណៈនៅក្នុងការកសាងផែនការ និងការធ្វើសេចក្តីសម្រេចក៏ត្រូវបានផ្សព្វផ្សាយទូលំទូលាយពីសំណាក់រដ្ឋាភិបាល ម្ចាស់ជំនួយ សង្គមស៊ីវិល ឬមានចែងនៅក្នុងច្បាប់ និងគោលនយោបាយផ្ទាល់ផងដែរ។ អភិក្រមនៃការចូលរួមមានន័យថាក្រុមមនុស្សដែលស្ថិតនៅក្រោមក្របខ័ណ្ឌរបស់រដ្ឋឬស្ថាប័នផ្លូវការដទៃទៀតត្រូវចូលរួមតាមវិធីផ្សេងៗគ្នានៅក្នុងដំណើរការអភិបាលកិច្ច។ ទោះជាយ៉ាងណាក៏ដោយ គំនិតអំពីការចូលរួមជាសាធារណៈអាចមានន័យថាជារឿងខុសៗគ្នាសម្រាប់មនុស្សខុសគ្នា។ ការចូលរួមអាចធ្វើឡើងនៅតាមលំដាប់ថ្នាក់ខុសៗគ្នា និងតាមកម្រិតខុសគ្នា។

ប្រការទាំងនេះឆ្លុះបញ្ចាំងអំពីវិសាលភាពនៃឥទ្ធិពល ឬសមត្ថកិច្ចក្នុងការធ្វើសេចក្តីសម្រេចរួមគ្នា។

*"គំនិតអំពីការចូលរួមជាសាធារណៈអាចមានន័យថាជារឿងខុសគ្នាសម្រាប់មនុស្សខុសគ្នា"*

បែបផែននៃការចូលរួមជាសាធារណៈអាចចាត់ជាវិសាលគមន៍មួយ (សូមអានតារាង២.១)។ គិតចាប់ពីឆ្វេងទៅស្តាំវិសាលគមន៍នេះចាប់ផ្តើមពីការចូលរួមតាមការកំណត់ឬជានិមិត្តរូប និងបញ្ចប់ដោយការផ្តល់ភាពអង់អាចដល់សាធារណជន ដែលក្នុងនោះអំណាចធ្វើសេចក្តីសម្រេចស្ថិតនៅក្នុងដៃរបស់សាធារណៈជន។ ការគ្រាន់តែ"ជូនដំណឹង " ឬ " ពិគ្រោះយោបល់" មិនមែនជាគំរូនៃការចូលរួមដែលគ្រប់គ្រាន់ដើម្បីឲ្យមានការចូលរួមប្រកបដោយការស្តាបនាឡើយ ដោយសារអ្នកធ្វើសេចក្តីសម្រេចនៅតែមានសេរីភាពក្នុងការមិនអើពើចំពោះវិភាគទានពីអ្នកពាក់ព័ន្ធនានា។ ការចូលរួមជាសាធារណៈជួយធ្វើឲ្យមានឥទ្ធិពល និងធ្វើឲ្យការសម្រេចនានាមានរូបរាងឡើង ដោយរួមចំណែកជាគំនិត ដែលត្រូវយកមកវិភាគនៅមុនការធ្វើសេចក្តីសម្រេច។ ទោះជាយ៉ាងណាក៏ដោយការអនុវត្តន៍ជាទូទៅតាមរូបភាពនៃចូលរួម "បែបពង្រឹងភាពអង់អាច"មិនអាចធ្វើទៅបានឡើយ ដោយសារទទ្ទឹមនឹងការទទួលខុសត្រូវដើម្បីស្តាប់ និងរៀនសូត្រអាជ្ញាធរក៏មានភារៈទទួលខុសត្រូវក្នុងការសម្រេចនិងអនុវត្តក្នុងនាមសង្គមដែលជាអ្នកតែងតាំងពួកគេឲ្យកាន់តំណាងផងដែរ។ ដូច្នេះនៅក្នុងការចូលរួមប្រកបដោយការស្តាបនាសូម្បីតែការចូលរួមមិនសុទ្ធតែអាចនាំមកនូវការធ្វើសេចក្តីសម្រេចជាចុងក្រោយក៏ដោយ អ្នកពាក់ព័ន្ធនានាបានបង្កើនសមត្ថភាពក្នុងការមានឥទ្ធិពល និងធ្វើឲ្យការសម្រេចនានាមានរូបរាងឡើង។

*"នៅក្នុងការចូលរួមប្រកបដោយការស្តាបនា អ្នកពាក់ព័ន្ធនានាបង្កើនសមត្ថភាពដើម្បីមានឥទ្ធិពល និងធ្វើឲ្យការសម្រេចនានាមានរូបរាងឡើង។"*

តារាង២.១ វិសាលគមន៍នៃការចូលរួមជាសាធារណៈ[10]

| ជូនដំណឹង | ពិគ្រោះយោបល់ | ពាក់ព័ន្ធ | សហការ | ផ្តល់អំណាច |
|---|---|---|---|---|
| គោលដៅនៃការចូលរួម | | | | |
| ផ្តល់ឲ្យសាធារណជននូវព័ត៌មានដែលមានតុល្យភាព និងផ្តោតចំទិសដៅដើម្បីជួយពួកគេឲ្យយល់អំពីបញ្ហា ជម្រើសផ្សេង និងដំណោះស្រាយ | ទទួលបានយោបល់តមកពីសាធារណជនវិញអំពីការវិភាគ ជម្រើសផ្សេង និង ឬដំណោះស្រាយ | ធ្វើការដោយផ្ទាល់ជាមួយសាធារណជននៅទូទាំងដំណើរការនេះ ដើម្បីធានាឲ្យមានការយល់ដឹង និងពិចារណាអំពីបញ្ហា និងកង្វល់របស់សាធារណជនជាដរាប | ធ្វើជាដៃគូជាមួយសាធារណជននៅក្នុងទិដ្ឋភាពនីមួយៗនៃការសម្រេច ដែលរួមទាំងការបង្កើតជម្រើសផ្សេង និងកំណត់អត្តសញ្ញាណដំណោះស្រាយ ដែលជាការចង់បានផងដែរ | ដាក់ដំណោះស្រាយចុងក្រោយទៅក្នុងដៃរបស់សាធារណជន |
| សន្យាឲ្យមានការចូលរួមជាសាធារណៈ | | | | |
| យើងនឹងជូនដំណឹងដល់អ្នកជាប់ជាប្រចាំ | យើងនឹងជូនដំណឹងទៅអ្នក ស្តាប់និងទទួលយកកង្វល់របស់អ្នក និងផ្តល់យោបល់តបអំពីថាតើយោបល់ពីសាធារណជនមានឥទ្ធិពលបែបណាមកលើការសម្រេច | យើងនឹងធ្វើការជាមួយអ្នកដើម្បីធានាថាបញ្ហានិងកង្វល់របស់អ្នកមានឆ្លុះបញ្ចាំងដោយផ្ទាល់នៅក្នុងជម្រើសជំនួសដែលបានបង្កើត និងផ្តល់យោបល់តបអំពីថាតើយោបល់ពីសាធារណជនមានឥទ្ធិពលបែបណាមកលើការសម្រេច | យើងនឹងទទួលយកយោបល់ផ្ទាល់ និងការផ្តួចផ្តើមរបស់អ្នកក្នុងការបង្កើតដំណោះស្រាយនិងបញ្ចូលយោបល់និងអនុសាសន៍របស់អ្នកទៅក្នុងការសម្រេចឲ្យបានច្រើនតាមតែងអាចធ្វើបាន | យើងនឹងអនុវត្តតាមការសម្រេចរបស់អ្នក |
| ឧទាហរណ៍អំពីឧបករណ៍សម្រាប់ការចូលរួម | | | | |
| សន្លឹកព័ត៌មាន វេបសាយការិយាល័យបើកចំហ | យោបល់ពីសាធារណជនក្រុមគោលដៅ ការអង្កេតសវនការជាសាធារណៈ | សិក្ខាសាលា ការបោះឆ្នោតប្រជាមតិ MSPs និងឧបករណ៍ពាក់ព័ន្ធដូចការបង្កើតសេណារីយ៉ូនិងការរុករក | គណៈកម្មការផ្តល់យោបល់របស់ពលរដ្ឋ MSPs ដែលរួមទាំងដំណើរការបង្កើតឲ្យមានការឯកភាពមតិផងដែរ | គណៈវិនិច្ឆ័យរបស់ប្រជាជនសន្លឹកឆ្នោតសេចក្តីសម្រេចតាមរយៈប្រតិភូកម្ម MSPs ។ល។ |

## ២.៣ អភិក្រមនៃការចរចា

ការចរចាដើរតួនាទីជាស្នូលនៅក្នុងធ្វើឲ្យអ្នកពាក់ព័ន្ធជាច្រើនចូលរួមប្រកបដោយការស្ថាបនា។ នៅក្នុងការជ្រើសរើសក្នុងបំណងឲ្យមានឯកភាពលើវិធីនានា ដើម្បីឈានទៅមុខការចរចា គឺជាដំណើរការដែលត្រូវបានប្រើប្រាស់នៅក្នុងការប៉ុនប៉ងដើម្បីសម្រុះសម្រួលភាពមិនចុះសម្រុងគ្នា ក្នុងចំណោមអ្នកពាក់ព័ន្ធនានា។ តាមធម្មតាគោលដៅជាចំបងនៃការចរចាគឺ ការឈានឲ្យដល់កិច្ចព្រមព្រៀងមួយដែលអាចយកជាការបាន ដែលភាគីទាំងអស់អាចទទួលយកបាន។ នៅក្នុងបរិបទនៃការចូលរួមប្រកបដោយការស្ថាបនាលើកិច្ចការសាំញ៉ាំ ដែលទាក់ទងនឹងទឹកគេអាចមានអ្នកពាក់ព័ន្ធនានាពេល គឺបុគ្គលសហគមន៍ រដ្ឋាភិបាល ពាណិជ្ជករ ហិរញ្ញិក អ្នកវិទ្យាសាស្ត្រ អង្គការមិនមែនរដ្ឋាភិបាល និងអន្តរការី ដែលជាអ្នកផ្តល់ចំណេះដឹងដែលធ្វើជាតំណាងឲ្យខ្លួនឯងឬនៅក្នុងក្រុម អង្គការឬសម្ព័ន្ធភាពខុសៗគ្នា។អភិក្រមដែលប្រើប្រាស់សម្រាប់ការចរចាត្រូវតែសមស្របសម្រាប់បរិបទនេះនិងសម្រាប់អ្នកដើរតួខុសៗគ្នា។ ក្រៅពីនេះក៏មានវេទិកាខុសៗគ្នាផងដែរ (សូមមើលប្រអប់២.២)។

*"គោលដៅចំបងនៃការចរចាគឺឈានឲ្យដល់កិច្ចព្រមព្រៀងដែលយកជាការបាន និងដែលភាគីទាំងអស់ទទួលយកបាន*

*ប្រអប់២.២ វេទិកាចរចាជាសកលអំពីទឹក*

នៅក្នុងការជជែកវែកញែកជាសកលជុំវិញបញ្ហាទឹកមានវេទិកាខុសៗគ្នាចំនួនបួនដែលអាចអធិប្បាយដូចតទៅៈ

អន្តរដ្ឋាភិបាលៈ កិច្ចប្រឹងប្រែងផ្លូវការបែប អ.ស.ប ក្នុងការបង្កើតរបបគ្រប់គ្រងផ្លូវទឹកដែលការិយាធិបតេយ្យខាងផ្នែកទឹកនៅជុំវិញពិភពលោកគាំទ្រ និងចូលរួម។

វេទិកាទាំងនេះភាគច្រើនគឺជាវេទិកាអំពីការបង្កើតបទបញ្ញាដែលត្រូវបង្កើតឲ្យទៅជាសន្ធិសញ្ញានានា និងត្រូវប្រតិបត្តិរួមគ្នាតាមរយៈ "ឆន្ទៈអន្តរជាតិ"។

នាំមុខដោយទីផ្សារៈ កិច្ចប្រឹងប្រែងពិភពលោកដែលអនុញ្ញាតឲ្យអ្នកដើរតួនៅក្នុងទីផ្សារស្វែងរកសមតុល្យរបស់ខ្លួនផ្ទាល់តាមរយៈឯកជនភាវូបនីយកម្ម ដែលនាំមុខដោយក្រុមហ៊ុនទឹកឯកជនពហុជាតិ និងគាំទ្រដោយហិរញ្ញប្បទានអភិវឌ្ឍន៍ និងធនាគារអភិវឌ្ឍន៍។

សង្គមស៊ីវិលៈ មានវេទិកាទីបីមួយប្រកបដោយឥទ្ធិពលដែលចូលរួមភាគច្រើនដោយចលនាសង្គម ដែលនិយមសមភាពជាញឹកញាប់ គឺជាអ្នកធ្វើការជំទាស់ទៅនឹងទំនប់ធំៗ ការបង្វែរទឹកជាទ្រង់ទ្រាយធំៗ។ល។ ដែលក្រុមនេះមើលឃើញថាបង្កគ្រោះថ្នាក់ចំពោះសង្គម និងបរិស្ថាន។

នាំមុខដោយអ្នកជំនាញការៈ អ្នកជំនាញការ និងជំនាញវិជ្ជាជីវៈខាងផ្នែកទឹកមកពីក្នុងចំណោមក្រុមអ្នកទាំងបីខាងលើ ដែលព្យាយាមស្វែងរកការឯកភាពមតិក្នុងចំណោមកម្លាំងទាំងបីរបស់រដ្ឋ ទីផ្សារ និងចលនាសង្គមតាមរយៈវិធានការនានាដូចជាការគ្រប់គ្រងធនធានទឹកចម្រុះ (IWRM)។

ដើម្បីផ្តល់ជាវិធានស្របច្បាប់មួយសម្រាប់ដោះស្រាយជាមួយគ្នានូវភាពមិនចុះសម្រុងគ្នា ការចរចាដើម្បីឈានទៅសម្រេចលើបញ្ហាស្មុគស្មាញអំពីទឹកត្រូវតែធ្វើឡើងដោយតម្លាភាព និងលើកទឹកចិត្តឲ្យមានសុច្ឆន្ទៈចូលរួម។ វេទិកានេះមិនធ្វើឲ្យការចរចាប្រព្រឹត្តទៅដោយងាយស្រួលនោះទេ។ ការពិនិត្យមើលសិទ្ធិ និងការទទួលខុសត្រូវទន្ទឹមនឹងហានិភ័យនិងភាគលាភ កម្រកើតឡើងដោយត្រង់ៗណាស់។ ប៉ុន្តែ ប្រសិនបើគេអាចចាត់ចែងឲ្យមានការចរចាតាមវិធីហ្មត់ចត់ និងប្រកបដោយការស្ថាបនា វាអាចលើកទឹកចិត្តឲ្យមានការស្វែងយល់ និងការដោះស្រាយបញ្ហារួមគ្នា ការគោរពគ្នាកាន់តែច្រើនឡើងចំពោះផលប្រយោជន៍ និងគុណតម្លៃខុសៗគ្នា និងអាចធ្វើឲ្យមានការរួមបញ្ចូលប្រការទាំងនេះទៅក្នុងសមិទ្ធផលដែលមាននិរន្តរភាព ដែលផ្តល់ផល និង

ដែលអាចយកជាការបានផងដែរ។

*"ការចរចាទាមទារឲ្យមានលក្ខខណ្ឌដែលអ្នកដើរតួនានាមានចំណាប់អារម្មណ៍ខុសគ្នា"*

## ២.៣.១ លក្ខខណ្ឌដំបូងដើម្បីឲ្យមានការចរចា

មានលក្ខខណ្ឌដំបូងសំខាន់ៗខ្លះដែលនាំទៅរកការចរចា។ ការចរចាទាមទារឲ្យមានលក្ខខណ្ឌដែលអ្នកដើរតួនានាមានចំណាប់អារម្មណ៍ខុសៗគ្នា" ប៉ុន្តែអ្នកដើរតួទាំងនោះទទួលស្គាល់ថាមានការពឹងផ្អែកលើគ្នាទៅវិញទៅមកក្នុងការដោះស្រាយបញ្ហាទាំងនោះ ហើយអ្នកដើរតួនានាអាចទំនាក់ទំនងជាមួយគ្នាដោយសេរីផងដែរ ៖

- ចំណាប់អារម្មណ៍ខុសគ្នា៖ ការចង់បានខុសគ្នាក្នុងចំណោមអ្នកដើរតួនានា អាចជាកត្តាជម្រុញ ដូចជា ការមិនចុះសម្រុងគ្នាលើថាតើអ្នកណាជាម្ចាស់កម្មសិទ្ធិ ការប្រើប្រាស់ ការគ្រប់គ្រង ឬ ការកំណត់ថ្លៃសម្រាប់អាងទឹកមួយ។ ភាពខុសគ្នាក្នុងចំណោមអ្នកដើរតួនានា អាចជាឫសគល់នៃការយល់ឃើញខុសគ្នាអំពីទឹក និងគុណតម្លៃអរូបិយរបស់វា ឬឥរិយាបថខុសគ្នាចំពោះការអភិវឌ្ឍន៍។ ភាពខុសគ្នាក្នុងការឲ្យតម្លៃ និងការគិតគូរអំពីទឹក នាំឲ្យមានការរំពឹងទុកខុសគ្នាពីការចរចា។
- ការពឹងផ្អែកលើគ្នាទៅវិញទៅមក៖ ប្រសិនបើគ្មានការទទួលស្គាល់ខ្លះៗពីសំណាក់អ្នកពាក់ព័ន្ធ អំពីការពឹងផ្អែកលើគ្នាទៅវិញទៅមកទេនោះ ហេតុផលក្នុងការចរចាអាចមិនមានឥទ្ធិពលគ្រប់គ្រាន់ឡើយ។ ដំណើរការចរចាផ្ទាល់គឺជាការប៉ុនប៉ងមួយ ដើម្បីធ្វើអ្វីម៉្យាងជាមួយអ្នកដទៃ ដោយសារមិនអាចធ្វើតែឯងបាន រួមផ្សំជាមួយសក្តានុពលក្នុងការកែលម្អសមិទ្ធផល (ដែលរួមទាំងទំនាក់ទំនងសង្គមផងដែរ) ឬយ៉ាងហោចណាស់ពុំបង្កគ្រោះថ្នាក់ដល់គ្នាទៅវិញទៅមក។ ប្រការនេះត្រូវផ្អែកលើការយល់ថា វាសនារបស់បុគ្គល ឬក្រុមនានាមានជាប់ជំពាក់ជាមួយគ្នា ដែលជាការប្រឈមចំពោះទស្សនៈ ដែលថាទឹកនិងការប្រើប្រាស់ទឹកគឺជាការពុះពារប្រកបដោយភាពប្រកួតប្រជែងជាប់ជានិច្ច។
- ការប្រាស្រ័យឆ្លើយឆ្លង៖ សមត្ថភាពដើម្បីប្រាស្រ័យឆ្លើយឆ្លង គឺជាមូលដ្ឋានដ៏សំខាន់មួយសម្រាប់ការចរចាប្រកបដោយការស្ថាបនា។ ប្រការនេះពាក់ព័ន្ធនឹងការស្តាប់រៀនសូត្រ បានទទួលការគោរព ភាពច្បាស់លាស់ និងការប្រឹងប្រែង ដើម្បីដោះស្រាយនូវការយល់ខុសនានា។ ការប្រាស្រ័យទាក់ទងតាមកម្រិតគុណភាពបែបនេះនាំឲ្យមានកំណើនការយល់ដឹងក្នុងចំណោមអ្នកចូលរួមដោយជួយពួកគេដើម្បីធ្វើការវាយតម្លៃ និងធ្វើការសម្រេចរវាងជម្រើសនានា និងដើម្បីផ្តោតលើការស្វែងរកដំណោះស្រាយចំពោះភាពមិនចុះសម្រុងគ្នា និងមាគ៌ាឈានទៅមុខ។

វាក៏ជាប្រការសំខាន់ផងដែរ ដែលការចរចាប្រព្រឹត្តទៅនៅក្នុងករណីដែលមានលទ្ធភាពក្នុងការបង្កើតឲ្យមានចំណាត់ការ ឬ ការស្វែងរកជំនួយគាំទ្រ និង ឬការសើរើ (ដូចជា ទម្រង់ការច្បាប់) ប្រសិនបើមិនអាចឈានដល់ការព្រមព្រៀង ឬ ប្រសិនបើជួបការប្រឈមនានា។ ប្រការនេះគឺជាការជម្រុញអ្នកចូលរួមធ្វើការចរចា ក៏ដូចជា ផ្តល់វិធីជំនួសសម្រាប់ដោះស្រាយផងដែរ ប្រសិនបើមិនអាចឈានដល់ការព្រមព្រៀង ឬប្រសិនបើភាគីខ្លះមិនត្រូវបានរាប់បញ្ចូល ឬ ផ្តាច់ខ្លួនចេញពីកិច្ចព្រមព្រៀង។

### ២.៣.២ ប្រភេទនៃការចរចា

*"ការចរចាក៏ពាក់ព័ន្ធផងដែរជាមួយការអនុវត្តន៍អំណាចដែលឆ្លុះបញ្ចាំងអំពីទំនាក់ទំនងនិង ដំណើរការដ៏ស្មុគស្មាញមួយឈុត"*

ការចរចា ធ្វើឡើងតាមអភិក្រមខុសៗគ្នា។ អភិក្រមទាំងនេះមានឥទ្ធិពលទៅលើការបង្កើតឲ្យមានវិធីចរចា គំរូនៃដំណើរការដែលយកមកប្រើប្រាស់ ជំហរដែលអ្នកចរចាប្រកាន់យក កម្រិតនៃភាពតានតឹង និងការបើកចំហឲ្យមានអន្តរអំពើ និងប្រភេទនៃសមិទ្ធផលដែលអាចទទួលបាន។ បន្ថែមលើនេះគឺភាពខុសគ្នានៃរបៀបចាត់ចែង និងឥរិយាបថដែលបង្ហាញឲ្យឃើញ ពីសំណាក់អ្នកដើរតួនៅក្នុងការចរចា។

មានកត្តាខុសៗគ្នាមួយចំនួនដែលមានឥទ្ធិពលមកលើរបៀបដែលបុគ្គល ក្រុមអង្គការ ឬ រដ្ឋាភិបាលធ្វើការចរចាដូចជា គោលបំណង ចេតនា ឋានានុក្រមនៅក្នុងសង្គម និងស្មារតីនៃការទទួលខុសត្រូវរបស់ពួកគេចំពោះដំណើរការនេះ ឬ ចំពោះភាគីដែលពាក់ព័ន្ធនៅក្នុងដំណើរការនេះ។ វាអាស្រ័យផងដែរលើអ្វីដែលលើកយកមកចរចា ប្រវត្តិនៃទំនាក់ទំនង និងបញ្ហានានាដែលនៅពុំទាន់ដោះស្រាយ និងបរិបទខាងផ្លូវច្បាប់ នយោបាយ និងនីតិវិធីផងដែរ។ ការចរចាអាចពាក់ព័ន្ធជាមួយការអនុវត្តន៍អំណាច ដែលការអនុវត្តន៍អំណាចនេះផ្ទាល់ឆ្លុះបញ្ចាំងអំពីទំនាក់ទំនង និងដំណើរការស្មុគស្មាញមួយឈុត ទាំងនៅកម្រិតបុគ្គល និងសង្គម។ របៀបនៃការអនុវត្តន៍អំណាចតែងតែមានឥទ្ធិពលមកលើយុទ្ធសាស្ត្រនានា ដែលភាគីទាំងនេះប្រើប្រាស់នៅក្នុងការចរចា។ ឧទាហរណ៍ ៖ នៅពេលដែលភាគីណាមួយសម្រេចប្រើប្រាស់អំណាចមកលើភាគីមួយផ្សេងទៀត ពួកគេអាចមានគោលដៅធ្វើឲ្យភាគីមួយទៀតចុះចាញ់ ដោយបង្ហាញឲ្យឃើញថា ពួកគេមានប្រៀប (ឋានានុក្រម ធនធាន សមត្ថភាព ឥទ្ធិពល ឬ និត្យានុកូលភាព) លើ "ដៃគូរបស់ខ្លួន" ដើម្បីសម្រេចគោលដៅរបស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ គេអាចអនុវត្តអំណាចរបស់ខ្លួនដោយសារតែមូលហេតុ និងលទ្ធផលខុសៗគ្នា ដែលរួមទាំងការស្វះស្វែងដើម្បីធ្វើសហប្រតិបត្តិការផងដែរ។ ដូច្នេះ អន្តរអំពើដែលមានចរិតស្មុគស្មាញខាងផ្នែកសង្គម និងខាងសរីរសាស្ត្រ គឺជាមូលដ្ឋានគ្រឹះនៃការចរចា។ អ្នកសម្របសម្រួល និងអ្នកចូលរួមនៅក្នុងការចរចាត្រូវតែស្វែងរកការចូលរួមប្រកបដោយការស្ថាបនា។ ដូច្នេះ ប្រការសំខាន់ជាអាយុជីវិតគឺពួកគេត្រូវតែបង្កើតឲ្យមានការយោគយល់គ្នាអំពីអភិក្រម និងឥរិយាបថ ដែលទំនងបំផុតថានឹងនាំទៅរកសមិទ្ធផលដែលចង់បាន និងដែលអាចទទួលយកបានទាំងអស់គ្នា។ ភាពខុសគ្នារវាងប្រភេទនៃការចរចាគួរតែជាមូលដ្ឋានសម្រាប់តម្រង់ទិសការយល់ដឹងនេះ។ គេមានវាក្យស័ព្ទ និងទស្សនទានខុសៗគ្នាមួយចំនួនដែលអាចយកមកអនុវត្តនៅក្នុងការចរចា។ វាក្យស័ព្ទ និងទស្សនទានទាំងនោះអាចចាត់បញ្ចូលទៅក្នុងជំពូកនៃការចរចាពីរបែបចំបងៗ។

- ការចរចាបែបប្រកួតប្រជែង ដែលជាទូទៅ ផ្តោតជាខ្លាំងលើពាណិជ្ជកម្ម ការតថ្លៃតឹងតែង និងការចែកចាយ។
- ការចរចាបែបសហប្រតិបត្តិការ ដែលជាទូទៅផ្តោតជាខ្លាំងលើកិច្ចសហការស្វែងរកការឯកភាពមតិ និងការធ្វើសមាហរណកម្ម។

*"នៅក្នុងការអនុវត្តន៍ជាក់ស្តែងជំហរប្រកួតប្រជែង និងសហប្រតិបត្តិការកើតមាន ក្នុងពេលជាមួយគ្នានៅក្នុងពេលចរចា"*

ភាពផ្ទុយគ្នារវាងប្រភេទនៃការចរចា មានសង្ខេបនៅក្នុងតារាង ២.២។ ក្នុងស្ថានភាពជាក់ស្តែង ជំហរប្រកួតប្រជែង និងជំហរសហប្រតិបត្តិការកើតមាននៅក្នុងពេលជាមួយគ្នានៅក្នុងអំឡុងពេលចរចា។ ការចរចាអាចចាត់ចែងឡើង និងអនុវត្ត ទៅតាមគោលការណ៍សហប្រតិបត្តិការ ប៉ុន្តែនៅក្នុងពេលខ្លះ ភាគីនានាប្រើប្រាស់ឥរិយាបថដែលបង្ហាញពីភាពប្រកួតប្រជែង ឬមួយក្រោមរូបភាពជាផែនការមធ្យោបាយ ឬជាការមិនសូវយកចិត្តទុកដាក់។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងស្ថានភាពស្មុគស្មាញ ប្រសិនបើការចរចាបែបប្រកួតប្រជែងកើតមានលើសលុប សមិទ្ធផលអាចទទួលបានកម្រិតទាប។ ការចរចាបែបសហប្រតិបត្តិការអាចពង្រឹងការចូលរួមប្រកបដោយការស្ថាបនា។

*"ការចរចាតាមបែបសហប្រតិបត្តិការជួយពង្រឹងឲ្យមានការចូលរួមប្រកបដោយការស្ថាបនា"។*

*តារាង២.២៖ការបង្ហាញពីភាពផ្ទុយគ្នា និងការសន្មតនៅក្នុងការចរចា*

| *ការចរចាបែបប្រកួតប្រជែង* | *ការចរចាបែបសហប្រតិបត្តិការ* |
|---|---|
| ការសង្កត់ធ្ងន់លើពាណិជ្ជកម្ម ការតថ្លៃតឹងតែង ការបែងចែក | បង្កើនការយកចិត្តទុកដាក់លើកិច្ចសហការ ស្វែងរកការឯកភាពមតិ ការធ្វើសមាហរណកម្ម |
| ភាគីនានាទំនងជាប្រកាន់យក "ជំហរ" ពោលគឺ "ដំណោះស្រាយ" ជាក់លាក់ | ភាគីនានាបានទទួលការលើកទឹកចិត្តឲ្យផ្តោតលើ "ចំណាប់អារម្មណ៍ "របស់ពួកគេ ពោលគឺ ផលប្រយោជន៍ដែលជាមូលដ្ឋាននៃ "ជំហរ" របស់ពួកគេ |
| ដំណើរការទំនងជាប្រកាន់យកគុណតម្លៃមិនប្រែ ប្រួល និងការបែងចែក "គុណភាព" ឬ "ផលិតផល" ឥតប្រែប្រួលទាំងនោះ | អ្នកចរចាផ្តោតលើការបង្កើតគុណតម្លៃ មុននឹងមានកិច្ចព្រមព្រៀងលើការបែងចែក |
| អ្នកចរចាប្រឹងប្រែងដើម្បីបង្កើនផលចំណូលផ្ទាល់ខ្លួន (ឬកាត់បន្ថយការខាតបង់) និងទទួលយក" "ការរីកចម្រើនរបស់ខ្ញុំ គឺជាការខាតបង់របស់អ្នក" | អ្នកចរចាកំណត់អត្តសញ្ញាណជម្រើសនានា ដែលរួមទាំង ពាណិជ្ជកម្ម បច្ចេកទេស ឬលក្ខណៈវិនិច្ឆ័យខុសៗគ្នា ដែលអាចផ្តល់ផលប្រយោជន៍បន្ថែមដល់មនុស្សគ្រប់គ្នា |
| ការសន្មតថាជម្រើសនានាឥតមានការប្រែប្រួល | សន្មតថាជម្រើសនានានឹងអាចប្រែប្រួល ដោយសារតែការយល់ដឹងបន្ថែមទៀត |
| ជាញឹកញាប់ត្រូវបានមើលឃើញថាផ្តល់បុព្វសិទ្ធិដល់ផ្នែកជាក់លាក់នានានៃចំណេះដឹង | ការសង្កត់ធ្ងន់លើការបង្កើនចំណេះដឹងខុសៗគ្នា |
| អាចបង្កើនវិសមភាព និងវិសមធម៌ដែលមានស្រាប់ | ដំណើរការនានាទំនងជាកាត់បន្ថយអតុល្យភាពអំណាច យ៉ាងហោចណាស់បានមួយកម្រិត មួយផ្នែកដោយសារការសង្កត់ធ្ងន់លើការវិភាគ និងការពន្យល់អំពីជម្រើស និងរបៀបទទួលបានគុណសម្បត្តិពីជម្រើស ឬចំណង់ចំណូលចិត្ត។ |

*ការចរចាបែបប្រកួតប្រជែង*

ការចរចាបែបប្រកួតប្រជែង តំណាងឲ្យការសន្មតមួយឈុតអំពីទំនាក់ទំនងក្នុងចំណោមភាគីនានា និងប្រតិបត្តិការដែលត្រូវចរចា ៖

- ភាគីនានាប្រកាន់យកជំហរដែលបើទោះជាមានទស្សនៈខុសគ្នាបែបណាក៏ដោយ ក៏ភាគីផ្សេងទៀតអាចជាការគំរាមកំហែង ឬអ្នកប្រកួតប្រជែង ក្នុងការទទួលបានលទ្ធផលចុងក្រោយណាមួយ។ ការសន្មតនេះគឺថា គេមានគោលដៅ ឬ គោលបំណងមិនស្របគ្នា ឬ ជំទាស់ចំពោះការចរចាចាប់តាំងពីដើមដំបូង។

- តើមានបញ្ហាអ្វីដែលអាច (ឬត្រូវតែ)បែងចែក ឬ ចែកចាយ។ គោលដៅនៃការចរចាគឺក្នុងបំណង បង្កើនជាអតិបរមានូវភាគចំណែកច្រើនបំផុតនៃភាគលាភដែលឥតប្រែប្រួល។ តាមធម្មតា កំណើន នេះបានមកពីការបង់ខាតរបស់ "ភាគីម្ខាងទៀត" ឬយ៉ាងហោចណាស់មិនធ្វើឲ្យខូចប្រយោជន៍ របស់អ្នក។ ភាសាដែលនិយមតាមធម្មតាមានលក្ខណៈជាសត្រូវ ដោយភាគីម្ខាងទៀតត្រូវគេមើល ឃើញថាជាភាគីជំទាស់ គំរាមកំហែង ឬគូប្រជែងចំពោះធនធានដែលស្ថិតនៅក្នុងទំនាស់ ឬ ដែលមានក្នុងកម្រិតកំណត់។ ចាប់តាំងពីដើមដំបូងនិន្នាការនេះ គឺដោយសារការសន្មតថា "ផល ចំណូលរបស់គាត់គឺជាការបង់ខាតរបស់ខ្ញុំ"។ ការយកចិត្តទុកដាក់ទំនងជានៅតែលើកតម្កើងហានិភ័យ និងទាមទារភាគចំណែកនៃអ្វីដែលនៅជាប់ពាក់ព័ន្ធក្នុងជម្លោះនោះ។

ការចរចាបែបប្រកួតប្រជែងត្រូវគេមើលឃើញថា ភាគច្រើនទាក់ទងនឹងការតថ្លៃ ដែលពាក់ព័ន្ធនឹង ការដោះស្រាយ លើប្រការដែលថា តើភាគីនីមួយៗលះបង់អ្វី និងទទួលយកអ្វី ឬបោះបង់ចោល ឬទទួល បានអ្វី។ ជាទូទៅមានការយកចិត្តទុកដាក់លើការកំណត់អត្តសញ្ញាណដំណោះស្រាយជាក់លាក់មួយដែល បន្ទាប់មកត្រូវគេស្វែងរក។ វត្តមានដំណោះស្រាយជាក់លាក់ណាមួយ នៅក្នុងពេលចាប់ផ្តើមដំបូង ត្រូវគេ ស្គាល់ថាជាការបង្កើត "ជំហរ"មួយ ដែលបន្ទាប់មកត្រូវបានភាគីនានាការពារ និងប្រើប្រាស់ជាចំណុចដៅ អំពីអ្វីដែលត្រូវសម្រេចឲ្យបាននៅក្នុងការចរចា។ បន្ទាប់មក ការពិភាក្សានេះបានកំហិតនៅត្រឹមចំណុច យោងនេះ។

ក្នុងពេលដែលភាគីនានាប្រកាន់យកជំហរខុសគ្នា ដែលស្ថិតក្រោមកិច្ចការពារ និងស្វែងរកការ ចរចាបានក្លាយជាដំណើរការធ្វើសម្បទាន។ ប្រការនេះអាចពាក់ព័ន្ធជាមួយភាគីនីមួយៗដោយប្រយោល ឬ ដោយផ្ទាល់ តាមរយៈ "របត់" នៃការតថ្លៃរវាងអ្វីដែលពួកគេចង់បានជាងគេ និងអ្វីដែលពួកគេមិនអាច ទទួលយកបាន ដោយមានចំណុចសមស្របបំផុតមួយ ឬ "កម្រិតអប្បបរមា" មួយដែលស្ថិតនៅរវាង ចំណុចខ្ពស់ជាងគេទាំងពីរនេះ។

របត់នៃការតថ្លៃអាចកំណត់បានក្រោមរូបភាពជាថ្លៃ៖ "ខ្ញុំចង់បាន ៦០.០០០ ដុល្លារប៉ុន្តែអាចទទួល យកត្រឹម ៥០.០០០ ដុល្លារ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំមិនទទួលយកអ្វីដែលទាបជាង ៤០.០០០ ដុល្លារ ឡើយ!ឬអាចគិតជាជំពូកនៃសកម្មភាព៖"ខ្ញុំចង់ឲ្យអ្នកបញ្ឈប់ការបូមទឹកឬយ៉ាងហោចណាស់កាត់បន្ថយ មកត្រឹមកម្រិតនេះ ឬបើពុំនោះទេ..."។ តាមរយៈរបត់នេះនៅក្នុងចិត្ត ការរំពឹងទុកជាមូលដ្ឋាននៅក្នុង ការចរចា និងយុទ្ធសាស្ត្រគឺ សេចក្តីស្នើផ្តល់ និងសេចក្តីស្នើតប (ឬការទាមទារមួយចំនួន) រហូតអាច ឈានដល់កិច្ចព្រមព្រៀងមួយដែលអាចយកជាការបាន។ ប្រសិនបើមិនអាចសម្រេចបានបែបនេះទេក្នុង ករណីនោះការ "ពិភាក្សា" អាចត្រូវពន្យាពេល ឬ បញ្ឈប់។

វត្តមានរបត់នៃការតថ្លៃ មិនមែនគ្មានប្រយោជន៍នោះឡើយ ប៉ុន្តែវាអាចកំហិតលើអ្វីដែលបានពិភាក្សា និងលទ្ធផលដែលអាចសម្រេចបាន។ អភិក្រមបែបប្រកួតប្រជែង ដោយផ្តោតលើជំហរដែលបានកំណត់ ជាមុន ការបែងចែក និងការបង្កើនជាអតិបរមានូវភាគផល ការកាត់បន្ថយមកត្រឹមអប្បបរមានូវការខាត បង់យ៉ាងច្រើនបំផុតទំនងជាអាចផ្តល់ផលនៅក្នុងកម្រិតសម្បទានមួយ។ គ្មានការបន្ថែម ឬមានការបន្ថែម ត្រឹមតិចតួចប៉ុណ្ណោះមកលើវិសាលភាពនៃការពិភាក្សា និងសមិទ្ធផលនានា។ គោលបំណង គឺទាមទារ យកវត្ថុខ្លះ (ដែលមានតម្លៃ) នៅក្នុងរបត់នៃជម្រើសដែលបានកំណត់ទុកជាមុន។ ជំហររបស់ភាគីនានា ត្រូវបានប្រកួតប្រជែងមកលើគ្នាទៅវិញទៅមក ដោយផ្តល់ផលចុងក្រោយដែលអាចមិនជាទីពេញចិត្តដល់ គ្នាទៅវិញទៅមក ឬផ្តល់ផលដល់ភាគីមួយ ដែលជាការខូចខាតដល់ភាគីម្ខាងទៀត។ ភាគីនានាទំនង

ជាធ្វើការប្រឆាំងគ្នាទៅវិញទៅមក ដោយស្ទង់មើលកម្លាំងគ្នាទៅវិញទៅមក។ ការប្រាស្រ័យទាក់ទងបានឈានទៅជាការជជែកតែពីភាគីម្ខាង អំពីមូលហេតុដែលអះអាងថា ជំហរ ឬសមិទ្ធផលមួយល្អជាងជំហរ ឬសមិទ្ធផលរបស់ភាគីម្ខាងទៀត។ព័ត៌មានដែលប្រើប្រាស់តាមទម្រង់ខុសៗគ្នាទំនងជាពង្រឹងជំហររបស់ភាគីមួយលើភាគីមួយផ្សេងទៀត និងក្លាយជាប្រភពនៃជម្លោះ។ សម្រាប់ការផ្តោះប្តូរ ប្រតិបត្តិការ ការសម្រេចងាយៗ ប្រការនេះអាចមានប្រសិទ្ធភាពខ្ពស់ និងអាចទទួលយកបាន។ ទោះជាយ៉ាងណាក៏ដោយ សម្រាប់ស្ថានភាពស្មុគស្មាញ ដែលក្នុងនោះទំនាក់ទំនងស្រាប់នានាមានសារៈសំខាន់ណាស់ វិធីនៃការចរចាបែបនេះមាននិន្នាការដែលមិនពង្រឹង ឬមិនរក្សាទំនាក់ទំនងនេះឡើយហើយអាចធ្វើឲ្យមានការលំបាកកាន់តែខ្លាំងឡើងក្នុងការឈានទៅសម្រេចបានលទ្ធផលប្រសើរបំផុតជារួមដូចដែលអាចមើលឃើញនៅក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិនៅក្នុងអាងសមុទ្រអារ៉ាល់ (ករណី ២.១) ដែលអភិរក្សតំបន់អេវើគ្លេដផ្លរីដា (សូមអានជំពូក ៤ ករណី ៤.២) និងការគ្រប់គ្រងសំណល់រាវ នៅកំពង់ផែ ខូហ្វ (Coffs) ប្រទេសអូស្ត្រាលី។

*"ការចរចាបែបប្រកួតប្រជែងកើតចេញពីឥរិយាបថឬសកម្មភាពជាក់លាក់ខ្លះៗ"*

ការចរចាបែបប្រកួតប្រជែងកើតចេញពីឥរិយាបថឬសកម្មភាពជាក់លាក់ខ្លះៗ។ភាគីនានាទំនងជាគ្របសង្កត់ ឬវាយឬក ដែលអ្នកទាំងនោះព្យាយាមបង្កើនទំនុកចិត្ត បញ្ចុះបញ្ចូល បញ្ចេញឥទ្ធិពលសម្របសម្រួល អះអាង គំរាមកំហែង ឬតថ្លៃតឹងតែង ដើម្បីបង្កើនផលចំណេញ ឬតម្រូវតាមការប្រាថ្នា ឬធ្វើសម្បទាន ដែលជាការទាមទារយកភាគផលខ្លះៗ ដើម្បីបង្កើនយ៉ាងហោចណាស់មួយផ្នែកនៃអ្វីដែលត្រូវការ ឬយ៉ាងហោចណាស់កិច្ចប្រឹងប្រែងត្រូវផ្តោតលើការបង្ការកុំឲ្យខាតបង់ច្រើនពេក ហើយរបៀបនៃការតថ្លៃក៏អាចជាការលះបង់ បញ្ចៀសការប្រឈមមុខដាក់គ្នា ឬអវិភាព ការចុះចាញ់ ឬការដកថយផងដែរ។ របៀបនីមួយៗនៃឥរិយាបថនេះ ឆ្លុះបញ្ចាំងអំពីគោលដៅ និងគុណតម្លៃខុសគ្នា ក៏ដូចជាបរិបទខុសៗគ្នាផងដែរ (ដែលរួមទាំងប្រភេទនៃទំនាក់ទំនង) ដែលពាក់ព័ន្ធ។[12]

មានយុទ្ធសាស្ត្រមួយចំនួនដែលអាចយកមកប្រើប្រាស់នៅក្នុងការចរចា។ ជាក់ស្តែង ការដោះដូរដែលក្នុងនោះមានការលះបង់វត្ថុខ្លះឬផ្តល់ឲ្យជាការដោះដូរដើម្បីទទួលបានភាគលាភជារបស់មួយផ្សេងទៀត ឬ ការលើកសំណើដែលភាគីម្ខាងទៀតអាចទទួលយកឬមិនទទួលយក ឬការផ្តល់នៅក្នុងពេលជាក់លាក់ណាមួយ។ ការព្យាយាមស្វែងរកព័ត៌មានអំពីរបត់នៃការចរចារបស់ភាគីម្ខាងទៀត ឬមិនបើកចំហរ ឲ្យដឹងអំពីរបត់នៃការតថ្លៃរបស់ខ្លួនឯង ក៏អាចជាស្នៀតដ៏មានប្រយោជន៍មួយផងដែរ។ ព័ត៌មានជាទូទៅ នឹងក្លាយទៅជាផ្នែកមួយនៃការពុះពារ ឬល្បែងផងដែរ ដូច្នេះវាមានតម្លៃជាធនធានសម្រាប់ការប្រើប្រាស់បង្កើនភាគលាភ ការបិទបាំង ឬ ការសម្របសម្រួល។[13] ការទិញ ឬ លក់ផ្ទះ គឺជាឧទាហរណ៍ងាយមួយអំពី និយាមនៃការតថ្លៃបែបប្រកួតប្រជែង និងតានតឹង។ ផ្ទះមានភាពខុសប្លែកពីទឹកដែលមានភាពស្មុគស្មាញ។

*ករណី២.១៖ ភាពតានតឹងនៅអាងសមុទ្រអារ៉ាល់*

សមុទ្រអារ៉ាល់ ដែលជាអាងទឹកធំជាងគេទីបួនលើពិភពលោកនៃដែនទឹកក្នុងទ្វីបបានរួមតូចមកនៅត្រឹមតែ១០%នៃទំហំរបស់វាពីដំបូង និងបានរងឥទ្ធិពលពីការឡើងជាតិប្រៃ និងការបំពុល។ ភាពប្រកួតប្រជែងដើម្បីទឹកកំពុងបន្ថែមភាពតានតឹងមកលើអ្វីដែលក្លាយជាតំបន់មិនងាយស្រួលរួចមកហើយ។

ទោះជាយ៉ាងណាក៏ដោយ ការរួមតូចនៃសមុទ្រអារ៉ាល់មិនមែនជាកង្វល់តែមួយនោះទេ ហើយផលប៉ះពាល់នៃបញ្ហាពិតប្រាកដគឺការប្រើប្រាស់ទឹកច្រើនហួសហេតុដែល បង្កដោយការប្រើប្រាស់ទឹកដោយគ្មានប្រសិទ្ធភាព។ មនុស្សជាច្រើនគិតថាសមុទ្រអារ៉ាល់ផ្ទាល់ គឺជាវត្ថុបំណងដែលគ្មានសង្ឃឹម។ ការកែលម្អវិធីប្រើប្រាស់ទឹក ដើម្បីធ្វើឲ្យមានទឹកកាន់តែច្រើនឡើងសម្រាប់ការចែករំលែកមិនមែនជាគោលបំណងដែលគ្មានសង្ឃឹមនោះឡើយ។

បញ្ហានៃកំណើនតម្រូវការនិងការថយចុះនៃការផ្គត់ផ្គង់ទឹកកាន់តែមានសភាពធ្ងន់ធ្ងរដោយសារតែប្រទេសនានានៅក្នុងតំបន់នេះមិនអាចធ្វើការជាមួយគ្នាបាន។ បើទោះជាមានកិច្ចព្រមព្រៀង នៅឆ្នាំ១៩៩២ ក្នុងចំណោមរដ្ឋចំនួនប្រាំដើម្បីចូលរួមសហប្រតិបត្តិការលើការគ្រប់គ្រងសមុទ្រនេះហើយក៏ដោយក៏វិវាទបានកើតឡើងវិញប្រចាំឆ្នាំរវាងប្រទេសចំនួនបីនៅខ្សែទឹកខាងក្រោមពោលគឺកាហ្សាក់ស្ថង់ ទួមេនីស្ថង់ និងអ៊ូស្បេគីស្ថង់ដែលសុទ្ធសឹងជាប្រទេសដែលប្រើប្រាស់ទឹកច្រើនសម្រាប់ដាំកប្បាស និងស្រូវសាលីហើយប្រទេសនៅខ្សែទឹកខាងលើពោលគឺគៀរហ្គីស្តង់ និងតាជីគីស្តង់មានធនធានទឹកយ៉ាងច្រើន និងសក្តានុពលសម្រាប់ថាមពលវារីអគ្គិសនីប៉ុន្តែមានសក្តានុពលតិចតួចសម្រាប់ការធ្វើកសិកម្ម។

ការគ្រប់គ្រងទឹកនៅអាស៊ីកណ្តាលបានរងគ្រោះយ៉ាងធ្ងន់ធ្ងរដោយសារកេរ្តិ៍ដំណែលនៃការត្រួតត្រាតាមប្រព័ន្ធពីលើមកក្រោមនៃអតីតសហភាពសូវៀត និងភាពប្រកួតប្រជែងរវាងរដ្ឋទាំងនេះ។ អង្គការអន្តររដ្ឋាភិបាលដែលទទួលបន្ទុកលើការគ្រប់គ្រងអាងទន្លេនេះពោលគឺគណៈកម្មការសម្របសម្រួលការប្រើប្រាស់ទឹកអន្តររដ្ឋបានទទួលការរិះគន់អំពីប្រតិបត្តិការដែលមានតម្លាភាពត្រឹមតិចតួចដោយគ្មានតំណាងមកពីអ្នកប្រើប្រាស់ ផលិតផលកសិកម្មឬឧស្សាហកម្ម អង្គការមិនមែនរដ្ឋាភិបាលនិងភាគីដទៃទៀតនិងជាទូទៅពុំបានបំពាក់បរិក្ខារសមស្របដើម្បីដោះស្រាយបញ្ហាស្មុគស្មាញទាំងនេះឡើយ។ ការចោទប្រកាន់អំពីភាពអនុគ្រោះនិយមបានធ្វើឲ្យកិច្ចសហប្រតិបត្តិការនេះកាន់តែចុះខ្សោយ។

នៅពេលដែលប្រទេសនីមួយៗចាប់ផ្តើមចាត់ទុកបញ្ហានេះថាជាល្បែងដែលមានអ្នកចំណេញនិងអ្នកខាតគណៈកម្មការនេះបានចាត់វិធានការ ដើម្បីបង្កើនអំណាចត្រួតត្រាលើទឹក និងថាមពលដែលជាញឹកញាប់ធ្វើឲ្យខូចផលរបស់អ្នកដទៃ។ គេឃើញមានកំណើនភាពមិនប្រាកដប្រជាដែលទាក់ទងនឹងផែនការកសាងអាងជលសាស្ត្រ និងទំនប់ថ្មីៗឬដើម្បីបង្កើនការស្រោចស្រព និងការពិគ្រោះយោបល់តិចតួចលើគម្រោងទាំងនេះភាគ ច្រើនបាននាំឲ្យមានកំណើនការសង្ស័យរវាងរដ្ឋនានា។

ភាពតានតឹងខាងផ្នែកទឹក និងថាមពលបានរួមចំណែកជាទូទៅដល់បរិយាកាសនយោបាយមិនល្អនៅអាស៊ីកណ្តាល។ ប្រទេសទាំងនេះមិនត្រឹមតែបង្កឲ្យមានវេហាសាស្ត្រ អរិភាពរវាងគ្នាប៉ុណ្ណោះទេប៉ុន្តែថែមទាំងជម្រុញឲ្យមានយោបល់នានាដែលថាប្រទេសទាំងនេះមានឆន្ទៈការពារផលប្រយោជន៍របស់ខ្លួនដោយប្រើប្រាស់កម្លាំងប្រសិនបើចាំបាច់។ការប្រកួតប្រជែងដើម្បីទឹកអាចកើនឡើងហើយភាពតានតឹង នឹងបន្តកើនឡើងផងដែរលើកលែងតែមានការដាក់ឲ្យអនុវត្តយន្តការប្រសើរជាងមុនដើម្បីគ្រប់គ្រងបញ្ហាទាំងនេះ។[14]

*"ការចរចាបែបសហប្រតិបត្តិការគឺជាកាលានុវត្តភាពមួយដើម្បីឲ្យមានការសន្ទនា និងដោះស្រាយបញ្ហា"*

## *ការចរចាតាមបែបសហប្រតិបត្តិការ*

ការចរចាបែបសហប្រតិបត្តិការ គឺជាកាលានុវត្តភាពមួយដើម្បីធ្វើឲ្យមានការសន្ទនា និងដោះស្រាយបញ្ហាដើម្បីបង្កើតបានសមិទ្ធផល ដែលផ្តល់ជាប្រយោជន៍ដល់គ្នាទៅវិញទៅមកដល់អ្នកពាក់ព័ន្ធទាំងអស់។ គោលដៅនេះអាចសម្រេចបានតាមរយៈកិច្ចប្រឹងប្រែង ដើម្បីសម្រុះសម្រួលភាពមិនចុះសម្រុងគ្នា និង ឬ ផលប្រយោជន៍របស់ភាគីដែលពាក់ព័ន្ធនៅក្នុងកញ្ចប់ចម្រុះនានា។ ទាំងមធ្យោបាយនៃការចរចា និងលទ្ធផលចុងក្រោយដែលកំពុងស្វែងរក ត្រូវគេមើលឃើញថាមានចំណងទាក់ទងគ្នា និងជាផ្នែករួមមួយដើម្បីឈានដល់សមិទ្ធផលដែលមាននិរន្តរភាព ភាពពេញចិត្ត និងអត្ថប្រយោជន៍។

*"ការចរចាបែបសហប្រតិបត្តិការ ផ្តោតលើផលប្រយោជន៍ជាងលើភាពមិនចុះសម្រុងគ្នា"*

ការចរចាបែបសហប្រតិបត្តិការផ្តោតលើផលប្រយោជន៍ជាងលើភាពខុសគ្នានៃជំហរ។ ផលប្រយោជន៍ត្រូវបានឲ្យនិយមន័យនៅក្នុងន័យទូលាយនានា ដូចជា គុណតម្លៃ តម្រូវការចាំបាច់ ការចង់បានឬ ការភ័យខ្លាច[15] ឬគូសបញ្ជាក់អំពីកង្វល់នានា (អំពីខ្លឹមសារនៃការចរចា) និងទំនាក់ទំនងជាមួយភាគីផ្សេងទៀត។ នៅក្នុងករណីនីមួយៗទាំងនេះគេយល់ថាផលប្រយោជន៍មានការទាក់ទងជាមួយអ្វីដែលស្ថិតនៅពីក្រោយជំហរដែលបានប្រកាសឲ្យដឹង ពោលគឺ មូលហេតុនានាទាក់ទងនឹងការស្វែងរកអ្វីមួយ។ ឧទាហរណ៍ នៅក្នុងបរិបទនៃការកំហិតលើលំហូរទឹកនៅក្នុងទន្លេ ដោយសារតែទំនប់ក្រុមគាំទ្របរិស្ថានមួយអាចប្រកាន់យកជំហរនេះ ដោយគេត្រូវតែបើកចំហរទ្វារទឹកទំនប់នៅក្នុងរដូវទឹកជំនន់ ប៉ុន្តែផលប្រយោជន៍ជាមូលដ្ឋានរបស់ពួកគេ គឺការធានាថា លំហូរកម្រិតខ្ពស់បំផុត កើតឡើងនៅក្នុងរដូវដែលប្រភេទត្រីជិតផុតពូជធ្វើចរាចរទៅតំបន់ដីសើមដើម្បីពងកូន។ ប្រតិបត្តិករទំនប់អាចប្រកាន់យកជំហរដែលថា ការដោះទឹកជំនន់គួរតែកំណត់តាមរយៈតម្រូវការថាមពល និងកម្រិតកំពស់ទឹកនៅក្នុងអាងជលសាស្ត្រ។ ផលប្រយោជន៍ជាក់ស្តែងរបស់ពួកគេអាចទាក់ទងកាន់តែច្រើនឡើង ជាមួយការបញ្ចៀសនូវការខាតបង់ប្រាក់ចំណូល និងការបញ្ចៀសនូវកង្វះខាតថាមពលអគ្គិសនី។ ការចរចារវាងភាគីទាំងពីរដែលផ្តោតតែទៅលើជំហររបស់ពួកគេបន្សល់ទុកឱកាសតិចតួចប៉ុណ្ណោះសម្រាប់ការស្វែងរកដំណោះស្រាយ។ ម្យ៉ាងវិញទៀតការយល់ដឹងអំពីផលប្រយោជន៍រៀងៗខ្លួនតាមរយៈការចរចាតាមបែបសហប្រតិបត្តិការ បើកចំហរឲ្យមានឱកាសសម្រាប់ការពិភាក្សាអំពីគំនិត និងការបង្កើតថ្មី តាមរបៀបដែលទំនប់មួយអាចត្រូវបានគ្រប់គ្រង និងទទួលហិរញ្ញវត្ថុ និងវិធីនៃការវិភាជន៍ទឹក ដែលភាគីទាំងពីរនេះអាចទទួលយកបាន។

ការចរចាបែបសហប្រតិបត្តិការ បានបង្ហាញឲ្យឃើញច្បាស់អំពីគោលដៅនៃការចរចា ដែលជាដំណើរការរួមគ្នា បែបស្តាបនា និងផ្តល់ផលឲ្យគ្នាទៅវិញទៅមក។ ដំណើរការនេះនាំទៅរកការធ្វើសេចក្តីសម្រេចបែបសមាហរណកម្ម ដែលផ្អែកលើការគោរពគ្នាទៅវិញទៅមក និងសហអត្ថិភាពនៃផលប្រយោជន៍ និងគុណតម្លៃ។ ជួនកាល ប្រការនេះត្រូវបានអធិប្បាយថាជាអភិក្រម"ឈ្នះ-ឈ្នះ" "ទទួលភាគផលជាមួយគ្នា" ឬ "ការបង្កើតគុណតម្លៃ"។

គេឃើញមានការសន្មតនានា ដែលគូសបញ្ជាក់អំពីការចរចាបែបសហប្រតិបត្តិការ ដែលទាក់ទងនឹងជំហររបស់ភាគីនានា វិធីរបស់ពួកគេក្នុងការបង្ហាញពីទំនាក់ទំនង និងសមិទ្ធផលដែលកំពុងស្វែងរក ៖

- ភាពមិនចុះសម្រុងគ្នាត្រូវបានគេចាត់ទុកថាមិនអាចជៀសវាងបាន និងមិនបានចាប់ផ្តើមតាំងពីដំណាក់កាលដំបូងដែលឆ្លុះបញ្ចាំងអំពីភាពមិនស្របគ្នា ឬគោលបំណងផ្ទុយគ្នាឡើយ។ ដូច្នេះ ភាគីដទៃទៀតអាចមិនមែនជាគូប្រជែងដែលមានសក្តានុពលហើយគោលដៅ ឬផលប្រយោជន៍របស់ពួកគេអាចមិនមែនជាការគំរាមកំហែងឡើយ។ ផ្ទុយទៅវិញ ភាពខុសគ្នាដែលកើតឡើង អាចផ្តល់កាលានុវត្តភាពឲ្យមានវិធីមួយផ្សេងទៀតនៃការងារ ឬ ស្វែងយល់អំពីអ្វីៗ ឬជាកម្លាំងជម្រុញឲ្យមានការកែប្រែ និងការធ្វើសេចក្តីសម្រេច។
- ដោយសារមានការពឹងផ្អែកលើគ្នាទៅវិញទៅមកខ្លះៗ គេឃើញមានលទ្ធភាពនៃកិច្ចសហការ ជាងការប្រកួតប្រជែង។ គេក៏ឃើញមានការសន្មតផងដែរថា អ្នកទាំងឡាយមានសមត្ថភាពដើម្បីធ្វើការដោះស្រាយភាពមិនចុះសម្រុងគ្នាទាំងនេះប្រកបដោយការស្ថាបនា ស្របជាមួយការទទួលស្គាល់ថាអត្ថប្រយោជន៍របស់គ្នាទៅវិញទៅមកមិនសុទ្ធតែអាចសម្រេចបាននោះឡើយ។ ភាគីដទៃទៀត

ត្រូវគេមើលឃើញថាជាផ្នែករួមមួយ នៅក្នុងការដោះស្រាយបញ្ហា ឬស្ថានភាពមួយ។ ដូច្នេះគេឃើញមានការសង្កត់ធ្ងន់លើការកែលម្អវិធីនានានៅក្នុងការទាក់ទង និងផ្តោតការយកចិត្តទុកដាក់លើទំនាក់ទំនងនេះ។ ប្រការនេះអាចត្រូវគេមើលឃើញថាជាកម្លាំងជម្រុញមួយដោយសារតែការមើលឃើញប្រយោជន៍អ្នកដទៃឬជាក់ស្តែង ដោយសារតែតម្រូវការចាំបាច់ក្នុងការបង្កើតលក្ខខណ្ឌដើម្បីឈានទៅសម្រេចឲ្យបានកិច្ចព្រមព្រៀងដែលយកជាការបាន។ បញ្ហាទំនុកចិត្ត ការប្រាស្រ័យឆ្លើយឆ្លងដោយចំហ ឬប្រកបដោយប្រសិទ្ធភាព និងពង្រឹងការសន្ទនាមានសារៈសំខាន់ជាស្នូល។

- បញ្ហាណាមួយអាចទាក់ទងជាមួយមិនត្រឹមតែគុណតម្លៃតតប្រេប្រួលឬភាគលាភសរុបនោះទេ តែជាការធានាឲ្យមានវិធីនានាដើម្បីដោះស្រាយអ្វីដែលភាគីនានាកំពុងស្វែងរក។ ការចរចាមិនមែនត្រឹមតែជាការតថ្លៃប៉ុណ្ណោះទេ ប៉ុន្តែក៏ទាក់ទងនឹងការគ្រប់គ្រង និងការវាយតម្លៃទំនាក់ទំនងនានាផងដែរ។ បើទោះជាអត្ថប្រយោជន៍យ៉ាងច្រើនត្រូវបានចាត់ទុកថាសំខាន់ក៏ដោយផលប្រយោជន៍ផ្សេងទៀតក៏ត្រូវបានចាត់ទុកថាសំខាន់ដូចគ្នាផងដែរ ដូចជា ការទទួលបាននូវការយកចិត្តទុកដាក់ត្រឹមត្រូវ និងប្រកបដោយការគោរពមានឱកាសដើម្បីនិយាយ និងត្រូវគេស្តាប់ឮ និងវត្តមានគុណតម្លៃ និងតម្រូវការចាំបាច់ដែលត្រូវបានទទួលស្គាល់ និងដោះស្រាយ។

តាមរយៈការឈានទៅហួសពីគ្រាន់តែមើលឃើញស្ថានភាព និងបញ្ហានានា ថាជាតួលេខថេរ ឬតតប្រែប្រួល គេក៏អាចបន្ថែមតម្លៃទៅលើស្ថានភាពនេះផងដែរ ដោយមិនគ្រាន់តែអាចបង្ហាញច្បាស់ពីដំបូងឡើយ។ ជាក់ស្តែង គេអាចមានវិធីខុសៗគ្នាដើម្បីវាស់តម្លៃដែលភាគីនានាកំពុងស្វែងរក ដោយអាចបំបែកទៅជាផ្នែកតូចៗ និង ឬ ជារបស់ថ្មី ឬខុសគ្នាពីមុន តាមរយៈការស្វែងយល់មូលហេតុដែលនាំឲ្យមានការចង់បាន ឬ ការប៉ងប្រាថ្នាលើរបស់នោះ។ ការរួមបញ្ចូលនូវសេចក្តីសម្រេចនានា គឺជាការបើកចំហឲ្យមានលទ្ធភាពដើម្បីបង្កើតជម្រើសថ្មីៗ ឬអាចចាត់ចែងឲ្យមានកិច្ចព្រមព្រៀង។ ដូច្នេះការចរចាមួយ និងសមិទ្ធផលពីការចរចានោះអាចមានមិនត្រឹមតែជាការបែងចែកជាផ្នែកតូចៗ ឬ នាំឲ្យមានសេណារីយ៉ូនៃការចំណេញ-ខាតនោះទេ។ វាក៏អាចមិនបង្កើតឲ្យមានសម្បទានផងដែរទេ ដោយសារអាចមានលទ្ធភាពក្នុងការបង្កើតរបស់ថ្មីៗ ដែលពុំបានពិចារណាឃើញពីដំបូង ធៀបនឹងការគ្រាន់តែផ្តល់ឲ្យនិងទទួលយក។[16]

ដូច្នេះ ការចរចាបែបសហប្រតិបត្តិការឈានហួសពីការដោះស្រាយត្រឹមតែជំហរ និងផ្តោតការយកចិត្តទុកដាក់លើដំណើរការ នៃការស្វែងយល់អំពីបញ្ហា។ គេត្រូវចំណាយពេលដើម្បីនាំយកភាពខុសគ្នាទាំងនោះទៅក្នុងវេទិកាបើកចំហដោយស្នើឲ្យភាគីនានាពន្យល់គ្នាទៅវិញទៅមក ៖

- ហេតុអ្វីពួកគេប្រកាន់យកជំហរណាមួយតាំងពីដើមដំបូង
- តើមានហេតុផលអ្វីដែលពួកគេឈានដល់ការសម្រេចបែបនេះ
- តើអាចធ្វើបែបណាដើម្បីអាចផ្តល់សេវាដល់ពួកគេប្រសើរជាងមុន
- តើមានទិដ្ឋភាពដទៃផ្សេងទៀតនៃស្ថានភាពមួយ ដែលត្រូវឲ្យមានការយកចិត្តទុកដាក់ ឬការដោះស្រាយដែរឬទេ។

ដំណើរការនេះមានសារៈសំខាន់ណាស់ដោយសារវាផ្តល់ឱកាសសម្រាប់ភាគីនានាស្វែងយល់ពីគ្នាកាន់តែប្រសើរថែមទៀត នូវអ្វីដែលពួកគេពុំបានដឹងពីមុនមក ឬការយល់ខុសអំពីភាគីដទៃ។ ប្រការនេះផ្តល់លទ្ធភាពសម្រាប់បង្កើតលំនាំផ្លូវ និងជម្រើសថ្មីៗដើម្បីធ្វើសេចក្តីសម្រេច និងសមិទ្ធផលដែលប្រើការបានត្រឹមត្រូវ និងមានប្រសិទ្ធភាពជាងមុន។ ករណី ២.២ តំណាងឲ្យការប្រែប្រួលជាវិជ្ជមាន ទៅរកការ

ចូលរួមប្រកបដោយការស្តាបនា នៅក្នុងវិស័យថាមពលវារីអគ្គិសនីនៅប្រទេសនេប៉ាល់។ ករណី ២.៣ អធិប្បាយអំពីជំហាននានាដែលបានអនុវត្ត ដើម្បីពិនិត្យមើលឲ្យបានល់អិតនូវប្រតិបត្តិការនៅអណ្តូងរ៉ែ

*ករណី២.២ ផ្តើមចេញពីជម្លោះឈានទៅរកការចូលរួមប្រកបដោយការស្តាបនា ក្នុងវិស័យថាមពលវារីអគ្គិសនីនៅនេប៉ាល់*

ប្រពៃណីនៃនយោបាយថាមពលវារីអគ្គិសនីនៅប្រទេសនេប៉ាល់ស្ថិតក្រោមការប្រឈមមុខដាក់គ្នារវាងសកម្មជនបរិស្ថាន និងសង្គម និងអ្នកលើកសំណើសាងសង់ទំនប់ខ្នាតធំ។ ទោះជាយ៉ាងណាក៏ដោយ យុទ្ធនាការដើម្បីបញ្ឈប់គម្រោងវារីអគ្គិសនីអារុណ៣នៅទសវត្សរ៍ឆ្នាំ១៩៩០បានកត់សំគាល់អំពីការប្តូរពីការប្រឈមមុខដាក់គ្នាទៅជាការចូលរួមប្រកបដោយការស្តាបនាជាងមុន។

សម្ព័ន្ធភាពជាតិនិងអន្តរជាតិមួយនៃសកម្មជនរួមជាមួយសហគ្រិនថាមពលវារីអគ្គិសនីខ្នាតតូចបានធ្វើយុទ្ធនាការដោយជោគជ័យដើម្បីបញ្ឈប់គម្រោង២០១ មេហ្គាវ៉ាត់ដែលត្រូវចំណាយរាប់ពាន់លានដុល្លានៅភាគខាងកើតនៃប្រទេសណេប៉ាល់។យុទ្ធនានេះបានប្រើប្រាស់សេដ្ឋកិច្ច និងវិទ្យាសាស្ត្រដើម្បីបង្ហាញថាសំណើគម្រោងនេះដែលត្រូវទទួលហិរញ្ញប្បទានពីធនាគារពិភពលោក និងម្ចាស់ជំនួយមួយក្រុមពុំមានលក្ខណៈសមស្របឡើយបើផ្អែកលើកត្តាហិរញ្ញវត្ថុ។ សមាសភាគសំខាន់មួយនៃយុទ្ធនាការនេះគឺសំណើឲ្យមានជម្រើស ជំនួសដែលមានប្រសិទ្ធភាពខ្ពស់ជាងមុនខាងការចំណាយ និងឲ្យទាន់ពេលវេលាជាងគ្រាន់តែការ ជំទាស់នឹងទំនប់ "មិនល្អ" មួយគេបានចាត់ចែងឲ្យមានការតស៊ូមតិដើម្បីឲ្យមានទំនប់ "ល្អ" មួយដែលមានភាពសមស្របទាំងខាងបរិស្ថាន និងសង្គម។

ជោគជ័យរបស់សកម្មជននៅក្នុងការបញ្ឈប់ទំនប់អារុណ-៣បានកែប្រែនយោបាយអំពីទឹកនៅនេប៉ាល់។ រដ្ឋាភិបាលលែងមើលស្រាលចំពោះសកម្មជន និងការអំពាវនាវរបស់ពួកគេទៀតហើយដើម្បីឲ្យមានការសន្ទនាប្រកបដោយការស្តាបនា។ នយោបាយទឹកក៏មានការកែប្រែ ទូទាំងពិភពលោក ផងដែរ មានការចេញរបាយការណ៍របស់គណៈកម្មការពិភពលោកស្តីពីទំនប់(WCD) នៅឆ្នាំ២០០០។

ដោយមើលឃើញពីតម្រូវការចាំបាច់ដើម្បីឈានទៅហួសពីជំហរ"គាំទ្រឲ្យមានទំនប់"និង"ការប្រឆាំងនឹងទំនប់" រដ្ឋាភិបាលនេប៉ាល់បានផ្តួចផ្តើមឲ្យមានដំណើរការចរចាពហុអ្នកពាក់ព័ន្ធនៅក្នុងឆ្នាំ២០០៣ ដែលក្នុងនោះអ្នកដើរតួនៅក្នុងស្ថាប័នរដ្ឋ និងស្ថាប័នមិនមែនរដ្ឋបានឯកភាពចូលមកជួបគ្នាដើម្បីស្វែងយល់ពីជម្រើសនានា និងស្វែងរកវិធីដែលអាចជម្រុញឲ្យទៅមុខបាន។ ដោយផ្អែកលើការងាររបស់គណៈកម្មការ WCD ក្រុមការងារពហុជំនាញ និងពហុវិស័យបានធ្វើការដើម្បីកែលម្អការយល់ដឹងរួមគ្នាអំពីភាពស្មុគស្មាញនៃបញ្ហានេះក្នុងគោលដៅកែសម្រួលអនុសាសន៍របស់WCDដើម្បីផ្តល់ជាអនុសាសន៍សម្រាប់វិស័យថាមពលវារីអគ្គិសនីនៅនេប៉ាល់។

អ្នកចូលរួមនៅក្នុងដំណើរការសន្ទនានេះរួមមានតំណាងមកពីអាជ្ញាធរអគ្គិសនីរបស់រដ្ឋាភិបាលនិងក្រសួងធនធានទឹក (អ្នកគ្រប់គ្រងទំនប់) វិស័យឯកជន (អ្នកសាងសង់ទំនប់) និងអង្គការមិនមែនរដ្ឋាភិបាលដែលតំណាងឲ្យសហគមន៍ជនរងគ្រោះដោយសារគម្រោងនេះ និងដែលមានកង្វល់អំពីបញ្ហាផ្សេងទៀតខាងផ្នែកសង្គម និងបរិស្ថាន។[17]



រូបថត២.១ ការប្រជុំរបស់ស្ត្រីដើម្បីពិភាក្សាកិច្ចព្រមព្រៀងបន្តអាជីវកម្មរ៉ែរបស់សហគមន៍ជាមួយអូតេឌីម៉ាញ (ភូមិសេគី ប៉ាពួញហ្គីនេ)អុក តេដា ក្នុងប្រទេស ប៉ាពួញហ្គីនេ ការកែប្រែគំរូនៃការចូលរួម និងបង្កើតទំនុកចិត្តដែលចាំបាច់ដើម្បីចរចាឲ្យមានការទូទាត់សំណងបានសមស្របជាងមុនដល់សហគមន៍ជនរងគ្រោះ។

## *ករណី២.៣៖ អណ្តូងរ៉ែអូកតេឌីនៅប៉ាពួញហ្គីនេ  ការកែប្រែបែបផែននៃការចរចា*

ក្រុមហ៊ុនអាជីកម្មរ៉ែអូកតេឌីនៅប៉ាពួញហ្គីនេស្ថិតក្នុងចំណោមអណ្តូងរ៉ែមាសទង់ដែងធំជាងគេលើពិភពលោកដែលជាប្រភពចំបងមួយនៃផលចំណូលសម្រាប់រដ្ឋាភិបាលប៉ាពួញហ្គីនេ និងជាប្រភពមួយនៃការងារ និងផលចំណូលសម្រាប់ប្រជាជននៅខេត្តដាច់ស្រយាលភាគខាងលិចនៃប៉ាពួញហ្គីនេ។

នៅពេលសាងសង់ទំនប់ស្តុកទឹកសំណល់ពីអណ្តូងរ៉ែត្រូវបានបង្ហាញឲ្យឃើញថា  គ្រាន់តែជាការបោកប្រាស់ប្រតិបត្តិករអណ្តូងរ៉ែពោលគឺក្រុមហ៊ុនអណ្តូងរ៉ែអូកតេឌី (OTML) បានទទួលការអនុញ្ញាតនៅក្នុងឆ្នាំ១៩៨៤  ពីរដ្ឋាភិបាលដើម្បីបញ្ចេញសំណល់រ៉ែ៩០.០០០តោន  ដោយផ្ទាល់ទៅក្នុងទន្លេនៅក្នុងមូលដ្ឋាននេះជារៀងរាល់ថ្ងៃ។  សំណល់រាវរវាងនេះ  បានបង្កការខូចខាតយ៉ាងច្រើនចំពោះបរិស្ថាននៅអូកតេឌី  និងប្រព័ន្ធទន្លេហោះ  និងបានបង្កការប៉ះពាល់ធ្ងន់ធ្ងរចំពោះការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋច្រើនជាង ៩០.០០០នាក់ ដែលរស់នៅតំបន់ខ្សែទឹកខាងក្រោម។ ចំណាត់ការតាមផ្លូវច្បាប់ជាបន្តបន្ទាប់នៅអូស្ត្រាលីជាកន្លែងដែលក្រុមហ៊ុន BHP ចុះបញ្ជីពោលគឺក្រុមហ៊ុនអាជីវកម្មរ៉ែពហុជាតិនិងជាម្ចាស់ភាគហ៊ុនភាគច្រើនរបស់ OTML ដែលនាំឲ្យមានការបង់ប្រាក់ជាលើកដំបូងទៅឲ្យម្ចាស់ដីទាំងនៅក្នុងដំណោះស្រាយតាមតុលាការ និងក្រៅតុលាការ និងក្រោយមកចំណាត់ការមិនបានទទួលជោគជ័យមួយចំនួនក្នុងនាមម្ចាស់ដី។

រហូតដល់ឆ្នាំ២០០០  ការវាយតម្លៃថ្មីមួយអំពីការខូចខាតនៅអណ្តូងរ៉ែនោះបាននាំឲ្យធនាគារពិភពលោកលើកអនុសាសន៍ឲ្យបិទការដ្ឋានអាជីវកម្មរ៉ែដោយគ្មានការពន្យាពេលហើយក្រុមហ៊ុន  BHP  ត្រូវតែដកខ្លួនថយចេញពីគម្រោងនេះ។ រដ្ឋាភិបាលដែលជាម្ចាស់ភាគហ៊ុនមួយនៃក្រុមហ៊ុន OTML បានឯកភាពរក្សាទុកប្រតិបត្តិការអាជីវកម្មរ៉ែព្រោះបានបាត់បង់ប្រាក់ចំណូលជាតិរួចមកហើយពីអាជីកម្មរ៉ែទង់ដែងនៅប៊ូហ្គែនវីលដោយសារតែសង្គ្រាមស៊ីវិល។

ដោយសារប្រវត្តិនៃចំណាត់ការតាមផ្លូវច្បាប់បែបនេះ  និងតម្រូវការឲ្យមានការគាំទ្រពីសហគមន៍រងគ្រោះដើម្បីបន្តការធ្វើអាជីវកម្មរ៉ែក្រុមហ៊ុន OTML បានចរចាឲ្យមានកិច្ចព្រមព្រៀងជាមួយសហគមន៍ដើម្បី

បន្តអាជីវកម្មរ៉ែ (CMCAs) នៅក្នុងឆ្នាំ២០០១។ កិច្ចព្រមព្រៀងទាំងនេះស្វែងរកការឯកភាពមតិពីសហគមន៍ដើម្បីបន្តប្រតិបត្តិការស្របជាមួយការចាត់ចែងទូទាត់សំណងដែលអាចទទួលយកបាន។ កិច្ចព្រមព្រៀង CMCAs មិនបានទទួលការគាំទ្រពីអ្នកភូមិឡើយដោយអ្នកភូមិខ្លះ ដែលបានចូលរួមនៅក្នុងចំណាត់ការតាមផ្លូវច្បាប់បានបដិសេធការចុះហត្ថលេខា។ CMCAs បានរួមបញ្ចូលប្រការនានាសម្រាប់ការពិនិត្យនៅពាក់កណ្តាលអាណត្តិនៅក្នុងឆ្នាំ២០០៥ និងកាតព្វកិច្ចមួយពីខាងក្រុមហ៊ុនអាជីវកម្មរ៉ែដើម្បីធ្វើសេចក្តីរាយការណ៍អំពីការប្រែប្រួលចំបងៗ លើការព្យាករណ៍អំពីបរិស្ថានដែលជាមូលដ្ឋាននៃកិច្ចព្រមព្រៀងទាំងនេះ។ ការពិនិត្យនេះបានក្លាយជាចំណុចស្នូលមួយសម្រាប់បង្ហាញឲ្យដឹងអំពីទំនាស់ កង្វល់ សេចក្តីសង្ឃឹម និងតម្រូវការចាំបាច់ និងជាវេទិកាមួយសម្រាប់កែលម្អលទ្ធផលដែលទាក់ទងនឹងសមាសភាគនៃការទូទាត់សំណងនៅក្នុងគម្រោងអភិវឌ្ឍន៍ដោយចីរភាព។ គេឃើញមានការពឹងពាក់គ្នាទៅវិញទៅមកក្នុងចំណោមក្រុមអ្នកពាក់ព័ន្ធចំបងៗ៖ ក្រុមហ៊ុនអាជីវកម្មរ៉ែមានបំណងចង់ឲ្យសហគមន៍ព្រមព្រៀងបន្តប្រតិបត្តិការ ចំណែកអ្នកភូមិមានជម្រើសផ្សេង តិចតួចក្រៅពីចង់ធ្វើការនៅក្នុងក្រុមហ៊ុនដើម្បីកាត់បន្ថយការលំបាកខាងផ្នែកសង្គម បរិស្ថាននិងសេដ្ឋកិច្ចរបស់ពួកគេ។ ទោះសម្រាប់សហគមន៍នានាគឺផលប្រយោជន៍ជាក់ស្តែងខាងផ្នែកសង្គម និងបរិស្ថានដែលកើតចេញពីអាជីវកម្មរ៉ែ និងការពឹងផ្អែករបស់ពួកគេលើអាជីវកម្មនេះ ដែលត្រូវធ្វើឲ្យមានតុល្យភាពទល់នឹងការខូចខាតជាបន្តបណ្តាលពីសំណល់ពីអាជីវកម្មរម្លែកការចិញ្ចឹមជីវិតរបស់ពួកគេ ពោលគឺ ប្រព័ន្ធទន្លេហោះ។

ការពិនិត្យនេះផ្តោតលើការទទួលបានមកវិញនូវការគាំទ្រពីសហគមន៍ដើម្បីអាចបន្តការធ្វើអាជីវកម្មរ៉ែ និងសមិទ្ធផលនៃការអភិវឌ្ឍដោយចីរភាពដែលប្រសើរជាងមុន។

បរិបទខាងបរិស្ថាន និងសង្គមមិនអាចកាត់ផ្តាច់ចេញពីគ្នាបានឡើយហើយដំណើរការមួយនៃការចរចាគឺជាលក្ខខណ្ឌដែលអាចនាំទៅរកកេរ្តិ៍ដំណែលយូរអង្វែង និងវិជ្ជមានសម្រាប់ជនរងគ្រោះទាំងអស់។ ការចរចាពាក់កណ្តាលអាណត្តិនៅក្រោម CMCA បានចំណាយពេល១៨ខែ ដែលមានការប្រជុំចំនួន៥០០លើក និងអ្នកពាក់ព័ន្ធជាច្រើនពាន់នាក់មកពីភូមិចំនួន១៥០បានចូលរួម។

ការពិនិត្យឡើងវិញនេះបានប្រឈមនឹងការលំបាកមួយចំនួន៖ ១) ការប្រាស្រ័យឆ្លើយឆ្លង និងភាពខុសគ្នាខាងភាសា ២) ចម្ងាយផ្លូវ និងភូមិមួយចំនួនដែលមិនអាចចូលដល់ ៣) បញ្ហាវប្បធម៌ដែលទាក់ទងនឹងការចូលរួមរបស់ស្ត្រី ៤) ការធ្វើជាតំណាង ទំនុកចិត្ត និងសមត្ថភាព ដើម្បីចូលរួម និង ៥) ធ្វើបែបណាដើម្បីឲ្យមានការឯកភាពមតិប្រកបដោយការយល់ដឹងជាមុន និងដោះស្រាយបញ្ហា ដែលទាក់ទងនឹងព័ត៌មានបច្ចេកទេស។ អាជ្ញាកណ្តាលមួយ ដែលមានតម្លាភាពពេញលេញ និងសហការសម្រាប់ស្ថានភាពនេះ ត្រូវបានកំណត់ថាជាវិធីប្រសើរបំផុតសម្រាប់ឈានទៅមុខដើម្បីជំនះកង្វះទំនុកចិត្តជ្រាលជ្រៅនិងអតុល្យភាពខាងអំណាចជាក់ស្តែង និងដែលជាការយល់ឃើញ។ ក្រុមហ៊ុនអាជីវកម្មរ៉ែ OTML អ្នកផ្តល់យោបល់របស់ខ្លួន និងអ្នកដទៃទៀត បានបង្កើតឲ្យមានដំណើរការចរចា និងការប្រាស្រ័យឆ្លើយឆ្លង ដោយផ្អែកលើគោលការណ៍នៃការចរចាដែលផ្តោតលើផលប្រយោជន៍។ អាជ្ញាកណ្តាលនៃការឯកភាពមតិដោយមានការយល់ដឹងជាមុន ដែលបានប្រកាន់យកក៏បានឆ្លុះបញ្ចាំង អំពីប្រពៃណីរបស់ប្រជាពលរដ្ឋនៅ ប៉ាពួញូហ្គីន នៅក្នុងការពិភាក្សានៅក្នុងផ្ទះវែងផងដែរដើម្បីឈានដល់ការឯកភាពមតិនៅក្នុងសហគមន៍។

ដំណើរការពិនិត្យឡើងវិញបាននាំឲ្យមានការចុះហត្ថលេខាលើអនុស្សរណៈនៃកិច្ចព្រមព្រៀងពីសំណាក់ភាគីទាំងអស់នៅក្នុងឆ្នាំ២០០៧ដែលបាននាំឲ្យមានកំណើនបួនដងនៃប្រាក់ទូទាត់សំណងដល់សហគមន៍ជនរងគ្រោះ និងមូលនិធិអភិវឌ្ឍន៍ដោយចីរភាពថ្មីមួយសម្រាប់សហគមន៍អូកតេឌី និងទន្លេហោះដែលស្ថិតក្រោមការត្រួតពិនិត្យដោយសហគមន៍រងគ្រោះ និងទទួលមូលនិធិពីស្វយសារលើអាជីវកម្មរ៉ែ។ ការវាយតម្លៃនៅក្នុងការពិនិត្យឡើងវិញនេះ បានរាយការណ៍ថាទំនាក់ទំនងការងាររវាងភាគីទាំងអស់បានកែលម្អឡើងយ៉ាងច្រើន។[18]

## ២.៩ ការបង្កើតឲ្យមានបែបផែននៃដំណើរការចរចា

*"ដំណើរការចរចាគួរផ្តោតការយកចិត្តទុកដាក់លើតម្រូវការចាំបាច់របស់អ្នកទាំងឡាយ ដែលមិនសូវអាចបង្ហាញពីការទាមទាររបស់ខ្លួន"*

ភាពតានតឹងខ្លាំងក្លា អាចកើតមានរវាងភាពបត់បែនបាន និងរចនាសម្ព័ន្ធដែលបង្កើតឡើងនៅក្នុងដំណើរការចរចា។ ដោយសារតែការប្រែប្រួលនៃបរិបទសង្គម នយោបាយ និងសេដ្ឋកិច្ច ដូច្នេះដំហារ និងឥរិយាបថរបស់អ្នកដើរតួសំខាន់ៗក៏ប្រែប្រួលផងដែរ។ ឧទាហរណ៍ បញ្ហាខ្លះមិនអាចចរចាបានឡើយ ដូចជា សិទ្ធិមនុស្សជាមូលដ្ឋាន ប៉ុន្តែការប្រែប្រួលដទៃទៀត អាចទាមទារឲ្យមានអ្នកសម្របសម្រួល និងការកែតម្រូវពីអ្នកចូលរួម។

នៅក្នុងលក្ខខណ្ឌធម្មតានៃការធ្វើឲ្យមានការចូលរួមប្រកបដោយការស្តាបនាគេតែងតែមានឧបសគ្គ។ ឧទាហរណ៍ គេអាចត្រូវការឲ្យមានកិច្ចប្រឹងប្រែងជាពិសេស ដើម្បីធានាថាអ្នកពាក់ព័ន្ធនានាដែលពុំមានមធ្យោបាយ ឬធនធានសំខាន់ៗ អាចចូលរួមបានពិតប្រាកដ។ ដំណើរការចរចាគួរតែផ្តោតការយកចិត្តទុកដាក់លើតម្រូវការចាំបាច់របស់អ្នកដែលមិនសូវអាចបង្ហាញពីការទាមទាររបស់ខ្លួន ដោយស្វែងយល់អំពីសិទ្ធិអំណាចរបស់ពួកគេ ឬធ្វើឲ្យពួកគេមានតំណាងគ្រប់គ្រាន់។

លទ្ធផលទាបជាងធម្មតា អាចបង្កឲ្យមានបញ្ហាដទៃទៀតផងដែរ។ ឧទាហរណ៍ ៖ ប្រការសំខាន់គឺមិនត្រូវមើលស្រាលអំពីទំនាក់ទំនងអំណាច ឬធ្វើមិនដឹងមិនឮចំពោះបរិបទនយោបាយ និងវប្បធម៌ ដែលផ្តល់ការអនុគ្រោះដល់ក្រុមខ្លះៗនោះឡើយ។ ការវាយតម្លៃគឺជាផ្នែកមួយផ្សេងទៀត ដែលជាញឹកញាប់បង្កើតឲ្យមានកំហុសឆ្គង។ ជាញឹកញាប់គេ ឃើញមានទស្សនៈខុសៗគ្នាជាខ្លាំងអំពី"វិធីត្រឹមត្រូវ"នៃការវាយតម្លៃ ហើយគេក៏ត្រូវប្រុងប្រយ័ត្នផងដែរដោយត្រូវជៀស វាងការប្រើប្រាស់ខ័ណ្ឌនានាដែលផ្តល់ការអនុគ្រោះមិនត្រឹមត្រូវដល់ជម្រើសខ្លះៗ។ ការបង្កើតដំណើរការចរចាឲ្យបានសមស្រប និងកែតម្រូវនៅពេលចាំបាច់ និងកែលម្អវិធីជជែកវែកញែក គឺជាគន្លឹះក្នុងការកែលម្អ និងស្វែងយល់អំពីទស្សនវិស័យខុសៗគ្នា។

វេទិកាពហុអ្នកពាក់ព័ន្ធ (MSPs) (សូមអានជំពូក ៣) និងការបង្កើតឲ្យមានការឯកភាពមតិ (សូមអានជំពូក ៤) គឺជាទម្រង់នានានៃការចូលរួមប្រកបដោយការពិចារណា និងការស្តាបនា ដែលកំពុងត្រូវបានប្រើប្រាស់សម្រាប់បញ្ហា និងការសម្រេចដ៏ស្មុគស្មាញដែលទាក់ទងនឹងទឹក ពីសំណាក់អ្នកដែលលើកទឹកចិត្តឲ្យមានការធ្វើសេចក្តីសម្រេចដោយផ្អែកលើហេតុផលសមស្រប។ ដូចដែលបានបង្ហាញនៅក្នុងជំពូកបន្ទាប់ការចរចាតាមគំរូខុសៗគ្នាបានដាក់បញ្ចូលយ៉ាងច្បាស់លាស់នូវវិធីខុសៗគ្នាសម្រាប់បង្កើនយុត្តិធម៌ និងប្រសិទ្ធភាពនៃកិច្ចព្រមព្រៀងការអនុវត្តន៍ និងសមិទ្ធផល។


IN GOD WE TRUST

# វេទិកាពហុអ្នកពាក់ព័ន្ធ (MSPs)

## *៣.១ វេទិកាពហុអ្នកពាក់ព័ន្ធ ៖ មូលដ្ឋានមួយសម្រាប់អភិបាលកិច្ចទឹកបានត្រឹមត្រូវជាងមុន*

វេទិកាពហុអ្នកពាក់ព័ន្ធ គឺជាផ្នែកមួយនៃអភិបាលកិច្ច ដែលក្នុងនោះមានការកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធខុសៗគ្នា និងតាមធម្មតាតាមរយៈតំណាងនានាដែលបានទទួលការអញ្ជើញ និងជួយឲ្យមានអន្តរអំពើនៅក្នុងវេទិកា វិភាគមួយដែលផ្តោតលើ ៖

- ការចែករំលែកចំណេះដឹង និងទស្សនវិស័យ
- ការបង្កើត និងពិនិត្យជម្រើស
- ការជូនដំណឹង និងបង្កើតឲ្យមានការចរចា និងការសម្រេចនានា។

វេទិកាពហុអ្នកពាក់ព័ន្ធ (MSPs) មិនមែនជាកន្លែងតែមួយដែលអាចអនុញ្ញាតឲ្យមានការជជែកពិភាក្សានោះទេ។ MSPs និងការសន្ទនា គឺជាពាក្យដែលច្រើនតែត្រូវបានប្រើប្រាស់ជំនួសគ្នាទៅវិញទៅមក។ ប្រការនេះអាចជាកំហុសឆ្គង។ រាល់ "ដំណើរការសន្ទនា" ពាក់ព័ន្ធនឹងប្រការដែលថា ការសញ្ជឹងគិតមានសារៈសំខាន់ជាស្នូល។ នៅក្នុងអង្គការដែលធ្វើការលើការតស៊ូមតិ កិច្ចការទូត ប្រតិបត្តិការនៅក្នុងគណបក្ស សភា ការធ្វើសេចក្តីព្រាងកិច្ចសន្យា កិច្ចប្រជុំក្រុមប្រឹក្សានៃក្រុមហ៊ុន ឬគណៈកម្មការភូមិ អាចមានបង្កប់នូវការសន្ទនា និងការពិចារណាជាច្រើន។ ទោះជាយ៉ាងណាក៏ដោយ ដូចដែលឈ្មោះនេះបានគូសបញ្ជាក់ MSPs សំដៅលើករណីដែលការពិចារណាត្រូវបានពង្រឹងក្នុងចំណោមអ្នកពាក់ព័ន្ធខុសៗគ្នាជាច្រើន។

MSPs គឺជាអភិក្រមមួយសម្រាប់ការចូលរួមប្រកបដោយការស្តាបនា និងការរៀនសូត្រអំពីបញ្ហាស្មុគស្មាញ ដែលភាពពិត និងគុណតម្លៃអាចមានទំនាស់រវាងគ្នា។ ជម្រើសអំពីទឹក ច្រើនតែទាក់ទងនឹងកត្តាវិវាទនៅក្នុងសង្គម ដូចជា វិធីដែលមានប្រសិទ្ធភាពបំផុតសម្រាប់ផ្គត់ផ្គង់ទឹក ការទទួលបានមកវិញនូវថ្លៃចំណាយសម្រាប់ផ្គត់ផ្គង់ទឹក និងផ្តល់ការលើកទឹកចិត្តដែលសក្តិសិទ្ធិ។ ជម្រើសអំពីទឹក ច្រើនតែទាក់ទងនឹងគុណតម្លៃដែលមានភាពចម្រូងចម្រាស់ដែលអាទិភាព និងតម្រូវការចាំបាច់គឺជាកិច្ចការដែលពាក់ព័ន្ធបំផុតនៅពេលពុំមានទឹកគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការទាំងអស់។

MSPs អាចនាំទៅរកការបង្កើតឬពង្រឹងចំណងទាក់ទងនៃការយោគយល់គ្នារវាងអ្នកដើរតួនានាដែលតំណាងឲ្យផលប្រយោជន៍ខុសៗគ្នាជាច្រើន និងដំណោះស្រាយជាទីពេញចិត្តយ៉ាងហោចណាស់សម្រាប់ភាពខុសគ្នាខ្លះៗ។ MSPs មួយអាចនាំឲ្យមានការបង្កើនការយកចិត្តទុកដាក់លើភាពខុសគ្នាសំខាន់ៗនៃអភិក្រម និងអាទិភាព ដែលមិនងាយនឹងសម្រុះសម្រួលបាន។ តាមរយៈការបង្ហាញឲ្យដឹងអំពីភាពខុសគ្នាទាំងនេះនៅក្នុងវេទិកាសាធារណៈ MSPs មួយអាចរួមចំណែកក្នុងការផ្តល់ជាមូលដ្ឋានសមស្របជាមុនមួយសម្រាប់ការចរចា និងការធ្វើសេចក្តីសម្រេច។

*"MSPs គឺជាអភិក្រមមួយសម្រាប់ការចូលរួមប្រកបដោយការស្តាបនា និងការសិក្សាអំពីបញ្ហាស្មុគស្មាញ"*

MSPs អាចមានឥទ្ធិពល ដោយធ្វើឲ្យអ្នកពាក់ព័ន្ធនានាមកជួបជុំគ្នា នៅក្នុងទម្រង់ថ្មីមួយនៃការប្រាស្រ័យឆ្លើយឆ្លង និងការស្វែងរកសេចក្តីសម្រេច។ តាមរបៀបនេះ ពួកគេអាចធានាឲ្យមានការគោរពចំពោះ

ទស្សនៈខុសគ្នា ឬយ៉ាងហោចណាស់បានយល់ដឹង ទន្ទឹមនឹងការពុះពារស្វែងរកកិច្ចព្រមព្រៀងដែលបានការត្រឹមត្រូវ និងមានប្រសិទ្ធភាពជាងមុន សម្រាប់ដោះស្រាយបញ្ហាស្មុគស្មាញ។

ឥទ្ធិពលមានភាពខុសគ្នាចំពោះអាជ្ញាធរនានា។ MSPs ជាច្រើនមិនសុទ្ធតែអាចប្រើប្រាស់លក្ខខណ្ឌទាំងអស់បាន ឬជាកន្លែងសម្រាប់ទាមទារសិទ្ធិដើម្បីធ្វើការសម្រេចនោះឡើយ។ ការធ្វើបែបនេះអាចនាំឲ្យមានការប្រឆាំងតប និងមិនផ្តល់ផលឡើយ។ បើទោះជាមិនមែនគ្រប់របបមិនយោបាយគាំទ្រ ឬអនុញ្ញាតឲ្យមាន MSPs ក៏ដោយ នៅកន្លែងជាច្រើន MSPs គឺជាផ្នែកមួយនៃនិន្នាការរួម ឆ្ពោះទៅបង្កើតទម្រង់ថ្មីៗនៃអភិបាលកិច្ច ដោយផ្អែកលើកិច្ចសហការដែលពង្រឹងជាបន្ថែម និងដែលពឹងផ្អែកលើមូលធនសង្គម។

វិធីមួយដើម្បីផ្តោតលើវិភាគទានពី MSPs ទៅក្នុងការចរចាអំពីទឹកគឺត្រូវប្រើប្រាស់ 4Rs (ដែលបង្ហាញនៅក្នុងជំពូក ១) ដែលជាផ្នែកមួយនៃអភិក្រមប្រព័ន្ធ និងពាក់កណ្តាលរៀបចំស្រេច។ ជាការរម្លឹកឡើងវិញ 4Rs សំដៅលើ ភាគលាភ ហានិភ័យ សិទ្ធិ និងការទទួលខុសត្រូវ។ ឧទាហរណ៍ ៖

- ភាគលាភដែលកំពុងស្វែងរកពីការថែរក្សា ប្រើប្រាស់ និងការអភិវឌ្ឍធនធានទឹកជាបន្ថែមទៀត និងការបែងចែកនូវវិសាលគមន៍ទាំងមូលនៃភាគលាភ រឺ អត្ថប្រយោជន៍ រឺ ថ្លៃខូចខាតដែលអាចកើតឡើងដោយសារតែជម្រើសខុសៗគ្នា
- ហានិភ័យដោយស្ម័គ្រចិត្ត និងមិនស្ម័គ្រចិត្ត ដែលទាក់ទងនឹងទឹក
- សិទ្ធិដែលទាក់ទងនឹងទឹក
- ការទទួលខុសត្រូវខុសៗគ្នារបស់រដ្ឋ និងអ្នកដើរតួមិននៅក្នុងស្ថាប័នរដ្ឋ ដែលទាក់ទងនឹងទឹក។

ក្នុងពេលដែល 4Rs តែងតែមានប្រយោជន៍សម្រាប់ជាចំណុចយោង គេមិនសុទ្ធតែត្រូវអនុវត្ត MSPs តាមបែបផែន និងរចនាសម្ព័ន្ធដូចគ្នាឡើយ។ MSPs មានតាមទម្រង់ និងទំហំខុសគ្នា។ ប៉ុន្តែ មានសំណុំលក្ខណៈ MSPs ដែលយើងចង់បានផងដែរ។ សំណុំលក្ខណៈទាំងនោះមានបង្ហាញនៅក្នុងរូប ៣.១ និងពន្យល់នៅក្នុងផ្នែក ៣.២-៣.៥ ដើម្បីផ្តល់ជាទម្រង់រួមសម្រាប់ "គំរូធម្មតា" មួយនៃ MSPs ដែលអាចរួមចំណែកធ្វើឲ្យមានអភិបាលកិច្ចទឹកប្រកបដោយប្រសិទ្ធភាព និងស្មើភាពជាងមុន។

"MSPs មាននៅក្នុងទម្រង់និងទំហំខុសៗគ្នា"

រូបទី៣.១ក្របខ័ណ្ឌគោលគំនិតនៃ MSPs និងសំណុំលក្ខណៈដែលចង់បាន



## ៣.២ បរិបទនៃវេទិកាពហុអ្នកពាក់ព័ន្ធដែលចង់បាន

### ៣.២.១គោលបំណង និងវិសាលភាពច្បាស់លាស់

គោលបំណងរបស់ MSP ត្រូវតែចែងឲ្យបានច្បាស់ នៅក្នុងបរិបទនយោបាយ និងជាក់ស្តែង នៃការសាកសួរ ការទាញហេតុផល វិសាលភាព និងអំឡុងពេលនៃអាណត្តិរបស់ខ្លួន និងយុត្តិកម្មអំពីថាតើ MSP អាចកែលម្អអភិបាល កិច្ចដែលមានស្រាប់បែបណា។

សំណួរសម្រាប់ការពិចារណា រួមមាន ៖

- តើ MSP ព្យាយាមបង្កើតឲ្យមានសេចក្តីថ្លែងការណ៍នៅលំដាប់ថ្នាក់ខ្ពស់នៃបរិយាកាសនយោបាយ និងស្ថាប័នធំទូលាយដែរឬទេ ពោលគឺ "បរិបទធំទូលាយ"? ឧទាហរណ៍ គឺ MSP ដែលផ្តោតលើការប្រែប្រួលអាកាសធាតុ និងការពាក់ព័ន្ធរបស់វា (ដែលរួមទាំង សម្រាប់វដ្តជលសាស្ត្រនៅលើផែនដី) ការពិនិត្យមើលកត្តាជម្រុញនៅ លើពិភពលោក និងវិធានការនានាដែលសង្គមអាចឆ្លើយតប ដូចជា អភិក្រមកាត់បន្ថយ ហិរញ្ញប្បទាន សម្រាប់ការបន្សាំ និងការបង្កើតទីផ្សារកាបូនសមធម៌។ MSPs ដទៃទៀតរួមមាន ការពិចារណានៅមុន ក្នុងអំឡុងពេល និងក្រោយវេទិកាពិភពលោក ដូចជា វេទិកាទឹកពិភពលោក និងសមាជពិភពលោកស្តីពីទឹក។
- តើ MSP ផ្តោតលើការកសាងបណ្តាញបង្កើតគោលនយោបាយ និងឱកាសសម្រាប់ការជជែកវែកញែកនៅក្នុងសហគមន៍ ឬកន្លែងណាមួយជាក់លាក់ដែរឬទេ ក្នុងបំណងសម្រួលឲ្យមានការឆ្លុះបញ្ចាំង និងចំណាត់ការលើបញ្ហារួមខ្លះៗ? ឧទាហរណ៍មួយគឺ MSP ធ្វើការជាមួយអ្នកដើរតួ និងស្ថាប័នជាច្រើនដែលចង់ឲ្យមានការ កែលម្អអភិបាលកិច្ចអាងទន្លេនៅ ណាមីប៊ី និងតំបន់ដីសើមអូកាវ៉ាន់ហ្គោនៅបូតស្វាណា ឬតំបន់មេគង្គ (សូមអានករណី ៣.១)។
- តើ MSP ផ្តោតលើការជូនដំណឹង និងការបង្កើតដំណើរការចរចាជាក់លាក់ណាមួយដែរឬទេ? ឧទាហរណ៍ ការគិតគូរឲ្យមានវិភាជន៍ទឹក និងរបបគ្រប់គ្រងទឹកឲ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព នៅក្នុងប្រព័ន្ធស្រោចស្រពនៅដែនដីសណ្តក្នុងប្រទេសវៀតណាម ឬ MSP ផ្តល់ជាមូលដ្ឋានសម្រាប់ការចរចា និងការពិនិត្យមើលកិច្ចព្រមព្រៀងនានា ដើម្បីអាចឲ្យមានការបន្តអាជីវកម្មរ៉ែ ដោយតម្រូវឲ្យមានការត្រួតពិនិត្យលើការបំពុលនៅក្នុងទន្លេហោះឲ្យកាន់តែតឹងរ៉ឹងជាងមុន និងការបែងចែកភាគលាភ នៅក្នុងបណ្តាខេត្តនៅភាគខាងលិច នៃប្រទេសប៉ាពូញ៉ូហ្គីនេ។[20]

ចម្លើយទៅនឹងសំណួរនានាគួរតែកំណត់អំពីគំរូនៃ MSP និងយុទ្ធសាស្ត្រនានា ដើម្បីបង្កើនការចូលរួមជាពិសេសដែលទាក់ទងនឹងជម្រើសយកអ្នកកោះប្រជុំ អ្នកសម្របសម្រួល អ្នកទទួលការអញ្ជើញរបៀបវារៈ និងឧបករណ៍នានា។ គេមានគំនិតជាច្រើនថែមទៀតអំពីរបៀបដើម្បីគូសបញ្ជាក់អំពីគោលបំណង និងវិសាលភាពនៃ MSP នៅភាគខាងក្រោយក្នុងជំពូកនេះ។

*ករណី៣.១ "ការស្វែងយល់ជាមួយគ្នាអំពីអនាគតនៃទឹក" នៅក្នុងតំបន់មេគង្គ*

នៅក្នុងតំបន់មេគង្គដែលលាតសន្ធឹងគ្របដណ្តប់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ វៀតណាម និងភាគខាងត្បូងនៃប្រទេសចិន គេត្រូវការគំរូថ្មីមួយនៃអភិបាលកិច្ចទឹក។ នៅលើដងទន្លេមេ និងដៃទន្លេគេឃើញមានវិវាទដែលកើតចេញពីអន្តរាគមន៍នានាលើរបបលំហូរដោយធម្មជាតិ និងការសម្រេចអំពីវិភាជន៍ទឹក

ដែលបង្ហាញឲ្យឃើញច្បាស់ ឬដែលជាការរំលោភបំពាន។ អន្តរាគមន៍ទាំងនេះត្រូវគេបកស្រាយដោយផ្អែកលើមូលដ្ឋាននៃៈ ការគ្រប់គ្រងទឹកជំនន់ កំណើនការស្រោចស្រពដើម្បីផលិតស្បៀង ឬ រុក្ខជាតិសរសៃ ការផ្គត់ផ្គង់ទឹកដល់ទីក្រុង ឬដល់ឧស្សាហកម្ម ការកែលម្អនាវាចរ ឬកំណើនការផលិតថាមពលតាមរយៈវារីអគ្គិសនី។ ក្រៅពីនេះក៏មានវិវាទដែលពាក់ព័ន្ធផងដែរជាមួយការប្រែប្រួលនៃកំទេចកំណាក និងបន្ទុកសាធាតុចិញ្ចឹម ជលផល ជម្រើសក្នុងរបចិញ្ចឹមជីវិត ការប្រើប្រាស់ទឹកក្រោមដី ការប្រើប្រាស់ទឹកឡើងវិញ និងការបង្វែរទឹក (រវាងរដ្ឋ នៅក្នុងរដ្ឋតែមួយរវាងអាង និងនៅក្នុងអាងតែមួយ)។

សម្ព័ន្ធភាពមួយនៃអ្នកដើរតួនានានៅក្នុងអាងទន្លេមេគង្គបានសហប្រតិបត្តិការដើម្បីកោះប្រជុំនិងអនុវត្ត MSP មួយដែលបានធ្វើឡើងនៅកម្រិតជាតិ និងតំបន់។ សម្ព័ន្ធភាពដែលបានកោះប្រជុំនេះរួមមានៈ IUCN វិទ្យាស្ថានបរិស្ថានប្រទេសថៃ (TEI) ដែលជាអង្គការជាតិមួយ ផ្តោតលើនិរន្តរភាពវិទ្យាស្ថានអន្តរជាតិគ្រប់គ្រងទឹក (IWMI) អង្គការស្រាវជ្រាវអន្តរជាតិមួយ និងបណ្តាញចំណេះដឹងថ្នាក់តំបន់ M-POWER ដែលសមាជិកស្នូលមានប្រភពមកពីនិងផ្តោតលើប្រទេសទាំង៦នៅក្នុងតំបន់មេគង្គ។

គោលបំណងនិងវិសាលភាពគឺធ្វើឲ្យវេទិកានេះប្រព្រឹត្តទៅជាទៀងទាត់នៅក្នុងតំបន់មេគង្គសម្រាប់ជម្រើស និងការសម្រេចសំខាន់ៗនៅថ្នាក់ជាតិ និងរវាងជាតិនានាដែលទាក់ទងនឹងទឹក ដែលត្រូវពិនិត្យនៅក្នុងវេទិកាសាធារណៈ ដោយផ្អែកលើទស្សនវិស័យខុសៗគ្នាជាច្រើន។ MSP មានគោលដៅបង្ហាញអំពីការអនុវត្តនេះ។[21]

## ៣.២.២ អ្នកកោះប្រជុំដែលជាទីទុកចិត្ត និងមានសមត្ថភាព

អ្នកកោះប្រជុំគឺជាអ្នកដែលកោះហៅមនុស្សទាំងឡាយឲ្យមកជួបជុំគ្នា និងចូលរួមជាមួយគ្នានៅក្នុងកិច្ចការណាមួយ។ គេអាចមានអ្នកកោះប្រជុំជាច្រើនសម្រាប់ MSP ហើយពួកគេអាចមកពីក្នុង ឬក្រៅរដ្ឋាភិបាល (សូមអានប្រអប់៣.១)។ ទំនុកចិត្ត និងសមត្ថភាព មានសារៈសំខាន់ណាស់។ ទំនុកចិត្តមានការផ្សារភ្ជាប់ជាមួយ"មូលធនសង្គម" របស់អ្នកកោះប្រជុំ ឬសម្ព័ន្ធភាពនៃអ្នកកោះប្រជុំ។ បើគ្មានសមត្ថភាពដើម្បីបង្កើតឲ្យមានទំនាក់ទំនងថ្មី ឬដែលពង្រឹងទំនាក់ទំនងដែលមានស្រាប់ អ្នកកោះប្រជុំមិនអាចបង្កើតមណ្ឌលអ្នកគាំទ្រ MSP ណាមួយបានឡើយ។ ប្រសិនបើគ្មានសមត្ថភាព អ្នកកោះប្រជុំនឹងមិនអាចរក្សាការគាំទ្រនៅក្នុងមណ្ឌលរបស់ខ្លួន ឬ មានការចូលរួមប្រកបដោយប្រសិទ្ធភាពឡើយ។

*ប្រអប់៣.១ MSPs និងលំនាំនៃការសន្ទនា១, ២, ៣*

វាក្យស័ព្ទលំនាំនៃការសន្ទនា១-៣គឺជាវិធីមួយក្នុងការបង្ហាញភាពខុសគ្នារវាងវេទិកាអភិបាលកិច្ចទឹកដែលក្នុងនោះវេទិកាខ្លះមានលក្ខណៈជា MSPs និងលទ្ធភាពខុសៗគ្នាក្នុងការកោះប្រជុំ។

លំនាំទី១ សំដៅលើដំណើរការនានារបស់រដ្ឋាភិបាល និងការិយាធិបតេយ្យដែលពាក់ព័ន្ធ ដែលរួមទាំងវេទិកាអន្តររដ្ឋ និងនៅក្នុងរដ្ឋផងដែរ។ តាមការយល់ឃើញរបស់រដ្ឋនានា ទាំងនេះគឺជាអ្នកកោះប្រជុំដែលមានលក្ខណៈ "ផ្លូវការ" និងស្របច្បាប់បំផុត។ ក្នុងករណីភាគច្រើនគំនិតភាគច្រើនលើសលុបនៅតែជាការទទួលយកឥរិយាបថសមហេតុផល និងចំណាប់អារម្មណ៍ផ្ទាល់ខ្លួនឯងដែលពុំបានថែងច្បាស់លាស់ ជាពិសេសនៅក្នុងកិច្ចការអន្តរជាតិ។ ការសន្ទនានៅក្នុងលំនាំ១ ត្រូវបានកោះប្រជុំពីសំណាក់អ្នកដើរតួនៅក្នុងរដ្ឋ និងសម្រាប់អ្នកដើរតួនៅក្នុងរដ្ឋ។ សន្និបាតអ.ស.បគឺជាឧទាហរណ៍មួយ។ ការសន្ទនាបែបនេះអាចមានលក្ខណៈអាចជាការជជែកពិភាក្សាប៉ុន្តែមិនមានការចូលរួមពីសំណាក់ពហុអ្នកពាក់ព័ន្ធឡើយ។

លំនាំទី២សំដៅលើដំណើរការអភិបាលកិច្ចដែលទាក់ទងនឹងរដ្ឋស្ថាប័ននានានៃ អ.ស.ប ម្ចាស់ជំនួយ ម្ចាស់បំណុល សង្គមស៊ីវិល និងធុរជន។ វេទិកាអន្តរអំពើបែបនេះតាមធម្មតាត្រូវបានកោះប្រជុំ និងដឹកនាំដោយ

អ្នកដើរតួម្នាក់ឬសម្ព័ន្ធភាពមួយដែលបន្សីគ្នាជាមួយរដ្ឋនានា ដោយធានាថាតំណាងពីរដ្ឋាភិបាលនៅតែជាអ្នកដើរតួដែលមានសិទ្ធិពិសេសដូចជា ការវាយតម្លៃអន្តរជាតិនៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាកសិកម្មសម្រាប់អភិវឌ្ឍ (IAASTD)។ តាមធម្មតាអ្នកកោះប្រជុំបានផ្តោតលើការពង្រឹងប្រសិទ្ធភាពរបស់រដ្ឋដោយពង្រីកវិសាលភាពនៃគំនិតនិងឥទ្ធិពល។ លំនាំទី២នៃ MSPs អាចត្រូវកោះប្រជុំពីសំណាក់អ្នកដើរតួនៅក្នុងរដ្ឋឬមិនមែនក្នុងរដ្ឋ ប៉ុន្តែតាមធម្មតាក្នុងបំណងពង្រីកការចូលរួម នៃអ្នកពាក់ព័ន្ធនានា។

លំនាំទី៣ នៃការសន្ទនាសំដៅលើកិច្ចប្រឹងប្រែងស្រាវជ្រាវ ការសន្ទនា និងការតស៊ូមតិដែលដឹកនាំដោយសង្គមស៊ីវិល ឬធុរជនដោយមិនស្ថិតក្រោមការរារាំង ឬ ក្រោមឥទ្ធិពលរបស់អ្នកដើរតួនៅក្នុងរដ្ឋឡើយ។ វេទិកាទាំងនេះមានការប្តេជ្ញាក្នុងការពង្រីកឱកាសខាងនយោបាយ និងច្រើនតែមានសុទិដ្ឋិនិយមអំពីសក្តានុពលនៃ MSPs ក្នុងការស្វែងរក និងជួយនៅក្នុងការធ្វើឲ្យការចរចាប្រព្រឹត្តទៅមុខបានល្អជាងមុនសម្រាប់សង្គមមនុស្ស។ ការកោះប្រជុំច្រើនតែដឹកនាំដោយអ្នកដើរតួនៅក្រៅរដ្ឋ ហើយវេទិកាតាមទម្រង់បែបនេះអាចមកនូវអ្នកពាក់ព័ន្ធនានា និងអាចមានទាំងអ្នករួមវិភាគទានផងដែរ នៅក្នុងការដោះស្រាយបញ្ហាណាមួយ។ ការកោះប្រជុំដោយសម្ព័ន្ធភាពច្រើនតែជាវិធីមួយនៃការប្រមូលផ្តុំមូលធនសង្គម នៃអ្នកកោះប្រជុំម្នាក់ៗ។ បច្ចុប្បន្នលំនាំទី២ និង៣ច្រើនតែប្រឈមនឹងគំនិតនិងការអនុវត្តជាក់ស្តែងនៅក្នុងការបង្កើត MSPs។ ការអនុវត្តអាចមិនសូវសមស្របប៉ុន្តែមានកិច្ចព្រមព្រៀងជាច្រើនដែលផ្តល់ផលល្អនៅជុំវិញពិភពលោក ដែលលំនាំទី២ និង៣កំពុងព្យាយាមកែលម្អគុណភាពនៃ MSPs របស់ពួកគេដើម្បីជាមូលដ្ឋានសម្រាប់ការកែលម្អគុណភាពនៃ MSPs ដើម្បីជូនដំណឹងនិងបង្កើតឲ្យមានការជជែកវែកញែកដែលទាក់ទងនឹងទឹក ការបង្កើតជម្រើសនានា និងជាមូលដ្ឋានសម្រាប់បង្កើតឲ្យមានការចរចា។

## *៣.២.៣ កម្រិត និងលំដាប់ថ្នាក់សមស្រប*

ការគូសបញ្ជាក់អំពីគោលបំណង និងទំហំ គឺជាជំហានដំបូងមួយក្នុងការគិតគូរអំពីវិសាលភាពនិងកម្រិត។[22] កម្រិត គឺជាទីកន្លែង កាលវេលា និងបរិមាណ ឬ ការវិភាគ ដែលប្រើប្រាស់សម្រាប់វាស់ ចាត់ជាលំដាប់ និងការសិក្សាបញ្ហាណាមួយ (សូមអានរូបទី ២.៣)។ កម្រិតគឺជាឯកតានៃការវិភាគដែលស្ថិតនៅកម្រិតជំហរខុសៗគ្នានៅក្នុងកម្រិតណាមួយ។

ការគ្រប់គ្រងទឹកច្រើនតែត្រូវបានចាត់ចែងក្នុងក្របខ័ណ្ឌស្ថាប័ននៅជុំវិញកម្រិតភូមិសាស្ត្ររបស់រដ្ឋាភិបាល (ពោលគឺ រដ្ឋបាល) ឬជលសាស្ត្រ។ កម្រិតរបស់រដ្ឋាភិបាល ក៏ស្ថិតនៅក្នុងលំដាប់ថ្នាក់ខុសៗគ្នាផងដែរ ដូចជា ស្រុក ខេត្ត ជាតិ តំបន់ ពិភពលោក។ កម្រិតជលសាស្ត្រក៏មានលំដាប់ថ្នាក់ខុសគ្នាផងដែរ ដូចជា អណ្តូង ល្អាងទឹក ស្ទឹង បឹង អាងជលសាស្ត្រ ទីជម្រាលតូចៗ អាងទន្លេធំៗនៅថ្នាក់ជាតិ ឬអាងទន្លេអន្តរជាតិ។ អ្នកកោះប្រជុំ MSP ត្រូវតែដឹងថា ជាការល្អបំផុត ការវិភាគ និងចំណាត់ការត្រូវតែធ្វើឡើងនៅក្នុងកម្រិត និងលំដាប់ថ្នាក់ខុសៗគ្នា ពោលគឺ តែមួយ ឬច្រើន។ សម្រាប់បញ្ហាទឹកដែលមានលក្ខណៈស្មុគស្មាញ តាមធម្មតាត្រូវស្ថិតនៅក្នុងកម្រិត និងច្រើនលំដាប់ថ្នាក់។ ភាពខ្លាំងនៃ MSP គឺវាមានភាពបត់បែនបាន ដែលត្រូវគ្នាទៅនឹងកម្រិត ឬលំដាប់ថ្នាក់ណាមួយ ប៉ុន្តែក៏អាចអនុញ្ញាតឲ្យមានការពិចារណានៅរវាងលំដាប់ថ្នាក់ និងរវាងកម្រិតខុសៗគ្នាផងដែរ។

*"ភាពខ្លាំងនៃ MSP គឺវាមានភាពបត់បែនបានដើម្បីឲ្យត្រូវគ្នាទៅនឹងកម្រិតឬលំដាប់ថ្នាក់ណាមួយ ប៉ុន្តែក៏អាចអនុញ្ញាតឲ្យមានការពិចារណានៅរវាងលំដាប់ថ្នាក់ និងរវាងកម្រិតខុសៗគ្នាផងដែរ*

រូបទី៣.២ កម្រិត និងលំដាប់ថ្នាក់




រូបទី៣.២[23] បង្ហាញពីឧទាហរណ៍ខ្លះៗនៅលំដាប់ថ្នាក់ជាក់លាក់នៅលើកម្រិតខុសៗគ្នាចំនួនប្រាំ (កម្រិតកាលមួយ និងកម្រិតលំហាចំនួន ៤)។ ឧទាហរណ៍អំពីអន្តរកម្មនៅរវាងលំដាប់ថ្នាក់ និងរវាងកម្រិតត្រូវបានបង្ហាញផងដែរ សម្រាប់កម្រិតលំហាមួយគូ។ ដំណើរការនៅពហុលំដាប់ថ្នាក់ខ្លះ ក៏មានបង្ហាញក្នុងកម្រិតប្រព័ន្ធអេកូឡូស៊ីផងដែរ។

អ្នកដើរតួធ្វើការអះអាងទៅតាមកម្រិត និងលំដាប់ថ្នាក់ ជាពិសេសតាមរយៈការជជែកវែកញែក ការប្រកាសព័ត៌មាន ការបញ្ចុះបញ្ចូល និងការជំទាស់ និងជាទ្រង់ទ្រាយតូចៗជាងនេះ តាមរយៈការប្រើប្រាស់ និងការត្រួតត្រាលើបច្ចេកវិទ្យា សូចនាករ ការពិចារណាលើរង្វាស់នានា និងការត្រួតត្រាលើទីតាំង ភូមិ-សាស្ត្រនយោបាយ។ ដូច្នេះ អ្នកដើរតួដដែលនេះជម្រុញឲ្យមានកម្រិតជលសាស្ត្រ ពោលគឺ ទីជម្រាលរហូតដល់អាងទន្លេ ដែលជាលំដាប់ថ្នាក់ឆ្លើយតបទៅនឹងឯកតាដែលអាចគ្រប់គ្រងបាន នៅក្នុងម៉ូដែលនានា ឬហេដ្ឋារចនាសម្ព័ន្ធនានា ដែលពួកគេប្រតិបត្តិការ។ អ្នកដើរតួដទៃទៀតជម្រុញឲ្យមានឋានានុក្រមរដ្ឋបាលតាមបែបសាមញ្ញដែលផ្អែកលើវិសាលភាពភូមិសាស្ត្រ ពោលគឺ ស្រុករហូតដល់តំបន់ ដោយអះអាងថាទីនេះជាកន្លែងដែលមានសមត្ថភាព គណនេយ្យភាព និងនិត្យានុកូលភាព។ ភាពខុសគ្នា ដូចជា រវាងកម្រិតរដ្ឋបាល និងជលសាស្ត្រ គឺជាប្រភពរួមនៃភាពតានតឹងនៅក្នុងអភិបាលកិច្ចទឹក។

ការជំទាស់អាចកើតឡើងនៅក្នុង MSP ដោយសារតែអ្នកដើរតួខុសគ្នា ចង់បានកម្រិត និងលំដាប់ថ្នាក់ជាក់លាក់នៅក្នុងការវិភាគ អំណះអំណាង និងការឆ្លើយតបរបស់ខ្លួន។ អ្នកកោះប្រជុំអាចចាត់វិធានការនៅក្នុងការជ្រើសរើសយកអ្នកចូលរួម និងប្រភេទវេទិកា ដើម្បីធានាឲ្យមានការផ្លាស់ប្តូរយោបល់ប្រកបដោយការស្ថាបនា និងការជជែកវែកញែកនៅក្នុង និងរវាងកម្រិត និងលំដាប់ថ្នាក់ខុសៗគ្នា។

កម្រិត និងលំដាប់ថ្នាក់ដែលប្រើប្រាស់នៅក្នុង MSP ណាមួយ គួរតែជាលទ្ធផលរួមគ្នានៃដំណើរការជីវភូមិសាស្ត្រនិងសង្គម។ វាកម្រកើតឡើងបាន និងមិនទំនងជាការចង់ឲ្យមាន MSP ណាមួយចាត់ចែងឡើងសម្រាប់បញ្ហាទឹកដែលមានលក្ខណៈស្មុគស្មាញ ដែលត្រូវមានភាពហ្មត់ចត់ខ្លាំងពេក ឬត្រូវមានជម្រើស

អំពីកម្រិត និងលំដាប់ថ្នាក់នៅក្នុងដំណាក់កាលដំបូងពេកនោះឡើយ។

រូបសាស្ត្រនៃលំហូរ និងឌីណាមិកនៃប្រព័ន្ធអេកូឡូស៊ី ឬស្ថាប័នសង្គម ច្រើនតែអាចស្ថិតក្រោមការយល់ដឹងរួមគ្នាបានល្អជាង ប្រសិនបើព្រំប្រទល់នៃកម្រិត និងលំដាប់ថ្នាក់ មិនកំហិតតែនៅក្នុងពេលចាប់ផ្តើម MSP ណាមួយ។ ឧទាហរណ៍៖ ឌីណាមិកប្រចាំរដូវនៃរបបទឹកមានសារៈសំខាន់ណាស់សម្រាប់ត្រី( និងអ្នកនេសាទ ) នៅក្នុងលំដាប់ថ្នាក់នៃពេលវេលាខុសៗគ្នា ជាងហេតុផលខាងប្រតិបត្តិការ និងការកសាងផែនការផលិតថាមពល, ការស្រោចស្រព និងការគ្រប់គ្រងហានិភ័យនៃទឹកជំនន់។

## *៣.២.៤ ធនធាន ការគាំទ្រនយោបាយ និងពេលវេលាគ្រប់គ្រាន់*

ដោយគ្មានធនធានគ្រប់គ្រាន់ ពោលគឺ ធនធានមនុស្ស ហិរញ្ញវត្ថុ ព័ត៌មាន និងបញ្ញា MSP មួយនឹងមិនឈានដល់សក្តានុពលរបស់ខ្លួនឡើយ។ គេត្រូវការមនុស្សដែលមានសមត្ថភាពដើម្បីគាំទ្រដល់ប្រតិបត្តិការនៃ MSP ។ ការចំណាយនឹងកើតមាន ហើយគេក៏ត្រូវចាត់ចែងផ្តល់មូលនិធិផងដែរ។ ភាពមិនប្រាកដប្រជាក៏នឹងត្រូវដោះស្រាយផងដែរ ក្នុងនោះព័ត៌មាន និងមនុស្សដែលមានចំណេះដឹង គឺជាអ្នកដែលអាចជួយឲ្យដំណើរការឈានទៅមុខ។

ប្រការសំខាន់ជាស្នូលគឺថា MSP មានឱកាសនយោបាយគ្រប់គ្រាន់ និងចលនាដើម្បីអនុញ្ញាត ឬលើកទឹកចិត្តឲ្យមានការបង្កើត និងការគាំទ្រ។ ភាពចាំបាច់ឲ្យមានការគាំទ្រខាងនយោបាយក្នុងកម្រិតខ្លះៗនោះគឺជាប្រការដែលមិនអាចជៀសវាងបាន។ ភាពចាំបាច់នេះមិនត្រឹមតែសំដៅលើការគាំទ្ររបស់រដ្ឋខាងផ្នែកនយោបាយប៉ុណ្ណោះទេ ប៉ុន្តែគឺជាការរម្លឹកមួយផងដែរថា MSP មួយត្រូវតែមានមណ្ឌលអ្នកពាក់ព័ន្ធគាំទ្រ រួមជាមួយឥទ្ធិពល ឬ អំណាចដែរឬទេ។ នៅក្នុងករណីតំបន់ខេបយក នៃប្រទេសអូស្ត្រាលី ( សូមអានករណី ៣.២ ) ការគាំទ្រខាងនយោបាយមានភាពមិននឹងន់ ប៉ុន្តែមានរយៈពេលវែងគ្រប់គ្រាន់ ដើម្បីធានាថា MSP បានទទួលឱកាសមួយ ដើម្បីធ្វើវិភាគទានប្រសើរបំផុតរបស់ខ្លួន។

*"ប្រការសំខាន់ជាអាយុជីវិតសម្រាប់ MSP គឺត្រូវមានឱកាស និងកម្លាំងជម្រុញគ្រប់គ្រាន់ខាងគោលនយោបាយ"*

### *ករណី៣.២៖ការវាយកំទេចជញ្ជាំងនៅខេបយកនៃប្រទេសអូស្ត្រាលី*

MSPនៅ CYPLUS (យុទ្ធសាស្ត្រប្រើប្រាស់ដីនៅជ្រោយឧបទ្វីបខេបយក)បានកើតឡើងនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ រយៈពេល២០ឆ្នាំក្រោយកំណើននៃជម្លោះលើសំណើអភិវឌ្ឍន៍ចំបងៗ អាជីវកម្មរ៉ែ សិទ្ធិលើដីធ្លីការលែងសត្វឲ្យស៊ីស្មៅ និងសិទ្ធិរបស់ជនជាតិដើមលើដីធ្លីនៅក្នុងជ្រោយឧបទ្វីបខេបយកនៅភាគឦសាន្តនៃប្រទេសអូស្ត្រាលី។ CYPLUS គឺជា MSP ខ្លាំងក្លា និងធំទូលាយដើម្បីបង្កើតយុទ្ធសាស្ត្រអំពីការប្រើប្រាស់ដីដែលមិនផ្តោតលើទឹកប៉ុន្តែពិតជាមានលក្ខណៈស្មុគស្មាញនៅក្នុងទីដាច់ស្រយាលនៅភាគខាងជើងនៃប្រទេសអូស្ត្រាលីដែលគ្របដណ្តប់ ១៣៧.០០០គម² ប៉ុន្តែជាកន្លែងមានប្រជាជនរស់នៅត្រឹមតែ ១៨.០០០ នាក់ប៉ុណ្ណោះក្នុងនោះភាគច្រើនគឺជាជនជាតិដើមឬពលរដ្ឋដែលមានដើមកំណើតជាអ្នកដែនដីកោះនៅច្រកសមុទ្រទ័ររ៉េស។ រដ្ឋាភិបាលនៅគ្រប់លំដាប់ថ្នាក់មានការចូលរួមយ៉ាងសកម្ម។

អ្នកដែលសិក្សា CYPLUS ត្រូវអ្នកចូលរួមម្នាក់បានប្រាប់ថា៖ "នៅមុន CYPLUS មានជញ្ជាំងឥដ្ឋរវាងអ្នកលែងសត្វស៊ីស្មៅ (កសិករជាអ្នកចិញ្ចឹមសត្វ) បែតងនិងពលរដ្ឋជាជនជាតិដើមនៅខេបយក ពួកគេសុទ្ធតែបានប្រឹងប្រែងកាត់តំបន់ខេបឲ្យក្លាយជាផ្នែកតូចៗសម្រាប់ខ្លួនឯង ប៉ុន្តែពុំមានទំហំធំគ្រប់គ្រាន់សម្រាប់ឲ្យ

សត្វស៊ីស្មៅឡើយ។ CYPLUS បានកំទេចជញ្ជាំងនេះ"។ អ្នកស្រាវជ្រាវក៏បានព្រមានអំពីតម្រូវការចាំបាច់ឲ្យមានការប្ដេជ្ញាសម្រាប់រយៈពេលវែងដើម្បី CYPLUS ត្រូវគេមើលឃើញនៅក្នុងរយៈពេលយ៉ាងហោចណាស់១០ឆ្នាំផងដែរ ដែលក្នុងអំឡុងពេលនោះ(នៅក្នុងប្រព័ន្ធនយោបាយអូស្ត្រាលី)អាចមានយ៉ាងហោចណាស់ការបោះឆ្នោតបីលើក និងការកែប្រែរាប់មិនអស់ខាងនយោបាយ កម្មវិធីនិងអ្នកដើរតួនានាដែលពាក់ព័ន្ធនៅក្នុងកិច្ចប្រឹងប្រែងនេះ"។

*"ប្រសិនបើអ្នកធ្វើសេចក្ដីសម្រេចមិនអនុវត្តជាបន្តឬគិតគូរអំពី MSP ទេនោះអ្នកចូលរួមជាច្រើននឹងត្រូវស្រងាកចិត្ត"*

ការពោលថា "ក្រុងរ៉ូម មិនមែនសាងសង់ឡើងត្រឹមមួយថ្ងៃនោះឡើយ" ក៏ត្រូវផងដែរសម្រាប់ MSP ដែលទាមទារឲ្យមានការវិនិយោគជាពេលវេលា និងការអត់ធ្មត់ កម្រិតខ្លះនៃភាពតជាប់គ្នា និងបន្ទាប់មកការបន្តអនុវត្ត ប្រសិនបើពេលវេលាដែលអនុញ្ញាតឲ្យមានរយៈពេលខ្លីពេក វាជាការលំបាកសម្រាប់ MSP ក្នុងការអនុវត្តន៍ការងាររបស់ខ្លួន។ ប្រសិនបើអ្នកធ្វើសេចក្ដីសម្រេចមិនអនុវត្តបន្ត ឬមិនគិតគូរអំពី MSP នោះទេអ្នកចូលរួមជាច្រើននឹងខកចិត្ត ហើយការចូលរួមឡើងវិញជាមួយពួកគេទៅអនាគតនឹងទំនងជាប្រឈមការលំបាក។[24] មេរៀនសំខាន់មួយដែលអ្នកសង្កេតការណ៍ម្នាក់បានកត់សំគាល់នៅក្នុង MSP នៅកាណាដា (សូមអានករណី ៣.៣) គឺថា៖ "ការរិះគន់ចំបងមួយដែលផ្ដោតលើប្រព័ន្ធសហការក្នុងអភិបាលកិច្ច គឺថា នៅពេលដែលពួកគេផ្ដល់កាលានុវត្តភាពសម្រាប់ការពិចារណា និងការចូលរួមបានទូលំទូលាយនៅក្នុងការធ្វើសេចក្ដីសម្រេច ពួកគេច្រើនតែបរាជ័យក្នុងការអនុវត្តន៍ ដោយសារតែមានការយកចិត្តទុកដាក់មិនគ្រប់គ្រាន់លើលទ្ធផល ដែលនឹងមានឥទ្ធិពលមកលើបញ្ហានៅចំពោះមុខ។ ជាលទ្ធផល អ្នកចូលរួមនានាអាចបាត់បង់ទឹកចិត្តសម្រាប់ការពិចារណាទៅអនាគត ប្រសិនបើមានសញ្ញាត្រឹមតិចតួចដែលថាកិច្ចប្រឹងប្រែងរបស់ពួកគេ ផ្ដល់ឥទ្ធិពលវិជ្ជមាន"។[25]

*ករណី៣.៣៖ ការធ្វើឲ្យមានតុល្យភាពអំណាចក្នុងក្រុមប្រឹក្សាអាងទន្លេហ្វ្រេហ្ស័រនៅកាណាដា*

អាងទន្លេហ្វ្រេហ្ស័រគ្របដណ្ដប់ទីជម្រាលចំនួន១៣នៅភាគខាងលិចនៃប្រទេសកាណាដា និងផ្ដល់ការគាំទ្រដល់ប្រជាពលរដ្ឋច្រើនជាង ២,៥លាននាក់ ដែលមានសេដ្ឋកិច្ចផ្អែកលើធនធានធម្មជាតិ។ ភាពចាំបាច់ឲ្យមានអភិក្រមចម្រុះជាងមុនក្នុងការគ្រប់គ្រងធនធានដីដោយប្រសិទ្ធភាព និងនិរន្តរភាពត្រូវបានទទួលស្គាល់ជាយូរមកហើយ។

ក្រុមប្រឹក្សាអាងទន្លេហ្វ្រេហ្ស័រត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៧ ក្រោមរូបភាពជា MSP មួយដើម្បីស្វែងរកការអភិវឌ្ឍន៍ដោយចីរភាពតាមរយៈការកសាងផែនការ និងការគ្រប់គ្រងអាងទន្លេចម្រុះ។ ក្រុមប្រឹក្សានេះបានទទួលជោគជ័យលើកម្មវិធីគ្រប់គ្រងអាងទន្លេហ្វ្រេហ្ស័រ ដែលត្រូវបានមើលឃើញថាស្ថិតក្រោមឥទ្ធិពលលើសលប់នៃផលប្រយោជន៍របស់រដ្ឋាភិបាល។

ក្រុមប្រឹក្សានេះ គឺជាអង្គការមិនស្វែងរកផលចំណេញដែលមានរចនាសម្ព័ន្ធរួម និងមានគោលដៅដោះស្រាយបញ្ហាយុត្តិកម្មជាច្រើននៅក្នុងការដោះស្រាយជម្លោះនានាដោយប្រើប្រាស់ការឯកភាពមតិជាងអភិក្រមច្បាប់ និងការិយាធិបតេយ្យ។ ក្រុមប្រឹក្សានេះត្រូវបានបង្កើតឡើងជាពិសេសដើម្បីបំពេញបន្ថែម ដែលមិនបង្កឲ្យមានភាពត្រួតគ្នានៃមុខងារគ្រប់គ្រងរបស់រដ្ឋាភិបាលឡើយ។ ធម្មនុញ្ញមួយសម្រាប់និរន្តរភាពត្រូវបានបង្កើតឡើងជាដំបូងសម្រាប់ជាមធ្យោបាយដើម្បីបង្កើតការយល់ដឹងរួមក្នុងចំណោមក្រុមខុសៗគ្នា។ ធម្មនុញ្ញនេះបង្ហាញពីបញ្ហានានាក៏ដូចជាចក្ខុវិស័យ និងបង្ហាញពីគុណតម្លៃនានា គោលការណ៍ និងបទបញ្ជានានាដើម្បីតម្រង់ទិសឲ្យមានចំណាត់ការរួមគ្នា។

រចនាសម្ព័ន្ធស្ថាប័ននៃក្រុមប្រឹក្សានេះត្រូវបានបង្កើតឡើងដោយប្រុងប្រយ័ត្ន ដើម្បីបង្កើតកាលានុវត្តភាពសម្រាប់ការជជែកពិភាក្សាក្នុងចំណោមក្រុមអ្នកពាក់ព័ន្ធខុសៗគ្នា ដើម្បីមានឥទ្ធិពលមកលើគោលនយោបាយ និងការសម្រេចនានាលើកម្មវិធី។គេមានការទទួលស្គាល់ថាការប្រឈមជាគន្លឹះមួយសម្រាប់អភិបាលកិច្ចបែបសហការគឺការធ្វើយ៉ាងណា ដើម្បីអាចឲ្យមានតំណាងដោយស្មើភាពបើទោះជាគេតែងតែឃើញមានអតុល្យភាពអំណាចខាងសេដ្ឋកិច្ច និងនយោបាយរវាងក្រុមនានាក៏ដោយដែលមាននិត្យាកូលភាពក្នុងការទទួលប្រយោជន៍ក្រោមទម្រង់ខុសៗគ្នានៃការគ្រប់គ្រងអាងទន្លេ។

ក្រុមប្រឹក្សានេះរួមមាននាយកចំនួន៣៦នាក់ដែលជ្រើសរើសពីក្នុងចំណោមរដ្ឋាភិបាលនៅបីលំដាប់ (សហព័ន្ធ ខេត្តនិងមូលដ្ឋាន) ជនជាតិដើម ក្រុមសហគមន៍ ធុរកិច្ចក៏ដូចជាក្រុមដែលមានផលប្រយោជន៍ខាងសង្គម សេដ្ឋកិច្ច និងបរិស្ថានផងដែរ។ ដើម្បីធានាឲ្យមានការចូលរួមដោយត្រឹមត្រូវនៅមូលដ្ឋាន គណៈកម្មាធិការតំបន់ចំនួនប្រាំ ត្រូវបានបង្កើតឡើងសម្រាប់ទីជម្រាលជាក់លាក់ដែលសមាសភាពជាតំណាងនានាមកពីរដ្ឋាភិបាលថ្នាក់មូលដ្ឋានជនជាតិដើម និងផលប្រយោជន៍តាមវិស័យ។

## *៣.២.៥ នយោបាយ និងអំណាចដែលបានទទួលស្គាល់*

នៅពេលកំណត់វិសាលភាពនៃ MSP គេចាំបាច់ត្រូវពិចារណាអំពីនយោបាយ និងអំណាចឲ្យបានច្បាស់។ នយោបាយគឺជាគោលគំនិតដ៏រសើបមួយ។ យោបល់ពីជិត៥០ឆ្នាំមុននៅតែមានប្រយោជន៍៖ "នយោបាយ ទាក់ទងនឹងគោលនយោបាយ ហើយគោលនយោបាយគឺជាអ្វីមួយដែលជាបំណងប្រាថ្នាធ្វើឲ្យមានការកែប្រែឬបំណងប្រាថ្នាការពារទៅនឹងការកែប្រែ "ហើយ" នយោបាយគឺជាដំណើរឆ្លុះត្រឡប់ដោយធម្មជាតិនៃភាពខុសគ្នារវាងសមាជិកនៅក្នុងសង្គមមួយ ...[ដែល]... មានភាពមិនចុះសម្រុងគ្នាជានិរន្តរន៍តាមទម្រង់ខុសៗគ្នាដែលកើតចេញពីភាពខុសគ្នាជាមូលដ្ឋាននៃលក្ខខណ្ឌ ឋានានុក្រម អំណាច គំនិត និងគោលដៅ"។[26] ការចែករម្លែកទឹកមិនត្រឹមតែទាក់ទងទៅនឹងជម្រើសបច្ចេកទេសឡើយ។ ទស្សនៈខុសៗគ្នាដែលទាស់គ្នាគឺជាវិស័យនយោបាយ។ MSP គឺជាកន្លែងមួយសម្រាប់ការជំទាស់នេះ។ MSP គឺជាវិធីមួយដែលធានាថាការប្រកួតប្រជែងខាងនយោបាយរួមបញ្ចូលភស្តុតាង និងការស្វែងយល់អំពីគុណតម្លៃ និងទស្សនៈវិស័យខុសៗគ្នាផងដែរ។

ទស្សនៈពិបាកយល់មួយផ្សេងទៀតគឺអំណាច។ គេអាចមើលឃើញថាជាសមត្ថកិច្ច ដើម្បីបង្កើតបរិបទ និងការប្រព្រឹត្តរបស់អ្នកដទៃ។ នេះជាប្រការដែលមានប្រយោជន៍ ប៉ុន្តែវាអាចត្រឹមតែមានឥទ្ធិពលមកលើរូបអ្នកប៉ុណ្ណោះ។ វាក៏មានប្រយោជន៍ផងដែរ និងមានការពាក់ព័ន្ធបំផុតចំពោះ MSP ដើម្បីគិតគូរអំពីអំណាចដែលទាក់ទងនឹងទំនាក់ទំនងរវាងទ្រព្យសម្បត្តិ និងអំណាច (សូមមើលរូប ៣.៣)។ ការគិតគូរអំពីប្រការទាំងពីរ អាចជួយធ្វើឲ្យយល់ដឹងអំពីបរិបទនេះ។

*"នៅពេលកំណត់អំពីវិសាលភាពរបស់ MSP មួយប្រការចាំបាច់គឺត្រូវពិចារណាអំពីនយោបាយ និងអំណាចឲ្យបានច្បាស់លាស់"*

MSP ទំនងជាមានឥទ្ធិពលកាន់តែច្រើនឡើង ប្រសិនបើវាមានជំនួយគាំទ្រគ្រប់គ្រាន់ពី"ទ្រព្យសម្បត្តិ" ដែលរួមទាំង៖ ធនធាន អ្នកចូលរួមនៅក្នុងជំហរយុទ្ធសាស្ត្រ បុគ្គលនានាដែលមានសមត្ថភាពដឹកនាំ និងការហូរចូលនូវគំនិតយ៉ាងសំបូរបែប។

សម្រាប់អ្នកខ្លះ នយោបាយ និងការវិភាគខាងនយោបាយបានផ្តោតលើការវិភាគអំណាច ពោលគឺ ការកំណត់អត្តសញ្ញាណ និងការចោទសួរអំពីរបាយនៃអំណាច លំហាត់ និងផលវិបាកនានា។ ទំនាក់ទំនងនៃអំណាចអាចកើតឡើងបែបណានោះ ក៏មានសារៈសំខាន់ដូចគ្នានឹងថាតើអ្នកដើរតួជាក់លាក់មានអំណាចគ្មានផងដែរ ពោលគឺ "អំណាចដើម្បីធ្វើសកម្មភាព" "អំណាចជាមួយអ្នកដទៃ" "អំណាចគ្របសង្កត់" និង "អំណាចដើម្បីដឹកនាំ"[27] ដែលទាំងអស់នេះសុទ្ធសឹងតែមានសារៈសំខាន់ ប្រៀបដូចជា ការអធិដ្ឋាននៃទៀនប្រេះ និងអណ្តាតភ្លើង នៅក្នុងប្រអប់ ២.១ ក្នុងជំពូក ២ ផងដែរ។ MSPs អាចក្លាយជាភ្នាក់ងារដែលធ្វើឲ្យមានការចូលរួមប្រការដោយការស្លាបនា អាស្រ័យលើទំនាក់ទំនងអំណាចដែលកើតឡើងផងដែរ គឺជាភាពចម្រុះសមស្របនៃទម្រង់ខុសៗគ្នាទាំងនេះ។ កត្តាដែលសំខាន់បំផុត និងជោគជ័យនៃ MSPs អាចជាជួយបង្កើនការទទួលយកពីសំណាក់អ្នកចូលរួមជាច្រើន ដែលមានអំណាចថ្មី និងបន្ថែមនៅក្នុងការអនុវត្តការងាររួមជាមួយគ្នា។

*រូប៣.៣៖ អំណាច ទ្រព្យធនដែលកសាងទំនាក់ទំនងរវាងអំណាច*

**អំណាចជាទ្រព្យ**

**ធនធាន៖** វិសាលភាពនៃធនធានដែលមានសម្រាប់ជម្រុញបុព្វហេតុណាមួយជាក់លាក់ដែលរួមទាំងធនធានមនុស្ស បញ្ញា ហិរញ្ញវត្ថុ ច្បាប់ និងកម្លាំងរូបវន្ត (ដូចជា ឧបករណ៍របស់រដ្ឋ យោធាសម្បត្តិ)
**ជំហរ ៖** ការស្ថិតក្នុងឋានានុក្រមខ្ពស់ ឬវត្តមានជំហរយុទ្ធសាស្ត្រ អាចផ្តល់អំណាចដល់អ្នកដើរតួម្នាក់កាលានុវត្តភាព អាជ្ញាធរ (ដូចជាមហាក្សត្រ មេដឹកនាំសាសនា មេដឹកនាំនយោបាយក្រុមសំខាន់ៗនៅក្នុងបណ្តាញមួយ)
**បុគ្គល ៖** មេដឹកនាំពិសេស ឬ គុណភាពដែលមានឥទ្ធិពល (ដូចជា មេដឹកនាំលេចធ្លោ ដែលបង្កើតឲ្យមានទំនុកចិត្ត ការលើកទឹកចិត្តឲ្យមានការប្តេជ្ញា មានសមត្ថកិច្ច ប៉ុន្តែ អំពើផ្តាច់ការផងដែរ!)
**យោបល់៖** គំនិត,ការសន្ទត់ ការវិនិច្ឆ័យ ការនិយមដែលមានឥទ្ធិពលមកលើរបៀបដែលយើងមានទស្សនៈ និងធ្វើសកម្មភាពលើពិភពលោក។

→ **អំណាច**

សមត្ថភាពក្នុងការមានឥទ្ធិពលមកលើការប្រព្រឹត្តនិងបរិបទរបស់អ្នកដទៃដោយផ្ទាល់ ឬដោយប្រយោល →

**ទំនាក់ទំនងអំណាច**

**អំណាចដើម្បីធ្វើសកម្មភាព** ៖ ដូចជាកំណត់**របៀបវារៈ** ធ្វើការសម្រេច បង្កើតឲ្យមានការនិយម (ដែលហៅថា "មុខមាត់នៃអំណាច")
**អំណាចគ្របសង្កត់៖** ដូចជា ដោយផ្ទាល់ ត្រួតកំហិត ការដាក់ទណ្ឌកម្ម ការធ្វើឲ្យចុះខ្សោយ
**អំណាចដើម្បីដឹកនាំ** ៖ ដូចជា លើកទឹកចិត្តជម្រុញទឹកចិត្ត សម្រួល ពង្រឹងភាពអង់អាច
**អំណាចជាមួយអ្នកដទៃ៖** ដូចជាអំណាចរួមគ្នាដោយធ្វើសកម្មភាពជាមួយអ្នកដទៃ

## ៣.៣ ធាតុផ្សំនានានៃដំណើរការល្អ

MSPs បានទទួលនិត្យានុកូលភាព យ៉ាងហោចណាស់មួយផ្នែកដោយបង្ហាញអំពីដំណើរការដែលមានគុណភាពខ្ពស់។ ដើម្បីធ្វើបែបនេះបាន ទាមទារឲ្យមានការទទួលបាន និងការរក្សាស្តង់ដារកម្រិតខ្ពស់នៃការជជែកពិភាក្សា ការសម្រួល ភាពពេញលេញ ការផ្លោះប្តូរព័ត៌មាន និងការប្រាស្រ័យឆ្លើយឆ្លងជាមួយអ្នកចូលរួម និងមណ្ឌលគាំទ្រធំទូលាយ។

### ៣.៣.១ ការពិចារណា

ការពិចារណាគឺជាផ្នែករួមមួយ ដែលយើងមានន័យថា ៖ "ការជជែកពិភាក្សា គឺជាការជជែកវែកញែក

និងការពិភាក្សាក្នុងគោលដៅបង្កើតចេញជាគំនិតសមហេតុផល និងដោយដឹងឮជាមុន ដែលក្នុងនោះអ្នកចូលរួមនានាមានឆន្ទៈក្នុងការកែសម្រួលចំណូលចិត្តតាមរយៈការពិភាក្សាព័ត៌មានថ្មីៗ និងការទាមទារពីសំណាក់អ្នកចូលរួមដទៃទៀត។ បើទោះជាការឯកភាពមតិត្រូវតែជាគោលដៅចុងក្រោយនៃការជជែកពិភាក្សា ហើយអ្នកចូលរួមត្រូវគេរំពឹងថានឹងស្វែងរកផលប្រយោជន៍របស់ខ្លួនក៏ដោយ តាមធម្មតាផលប្រយោជន៍ជារួមនៃសមិទ្ធផលស្របច្បាប់ (ដែលត្រូវគេចាត់ទុកថាជាហេតុផលសម្រាប់ជនរងគ្រោះគ្រប់រូប) គឺជាការឆ្លុះបញ្ចាំងអំពីជជែកពិភាក្សានោះ"។

MSPs មានឫសគល់នៅក្នុងជំនឿមួយលើគុណតម្លៃនៃ"ការជជែកពិភាក្សាពិតប្រាកដ"[28] រវាងក្រុមមនុស្សដែលមានទស្សនៈខុសៗគ្នា។ តាមវិធីនេះ MSPs ផ្តល់ឱកាសដើម្បីបង្កើនការអះអាង ការពន្យល់ និងអនុញ្ញាតឲ្យប្រើប្រាស់ហេតុផលនេះច្រើនជាងហេតុផលផ្សេងទៀត។ អាស្រ័យហេតុនេះ ប្រការសំខាន់គឺត្រូវកត់សំគាល់ថា អ្នកពាក់ព័ន្ធនានាដែលមិនមានភាសា និងជំនាញប្រាស្រ័យឆ្លើយឆ្លងអាចត្រូវចាញ់ប្រៀបលើកលែងតែមានតំណាងគ្រប់គ្រាន់។

*"MSPs ផ្តល់ឱកាសដើម្បីបង្កើនការអះអាងការពន្យល់ និងអនុញ្ញាតឲ្យប្រើប្រាស់ហេតុផលនេះច្រើនជាងហេតុផលផ្សេងទៀត"*

## ៣.៣.២ ប្រកបដោយការសម្របសម្រួល

ដើម្បីអាចឲ្យមានការជជែកពិភាក្សា, ការសម្របសម្រួលយ៉ាងល្អ គឺជាសំណុំលក្ខណៈដ៏សំខាន់មួយដើម្បីឲ្យ MSPs អាចបង្កើនការផ្សព្វផ្សាយទៅតាមសក្តានុពលរបស់ខ្លួន។ តាមធម្មតា នៅក្នុងក្រុមអ្នកសម្រួល MSPs នឹងមានវត្តមានបុរស និងស្ត្រី តាមអត្រាខុសៗគ្នា ដែលមានប្រវត្តិខុសៗគ្នាខាងវប្បធម៌ និងដែលរួបរួមគ្នា តាមរយៈស្មារតីបើកចំហរ។ អ្នកសម្រួលទាំងនេះត្រូវតែមានសំណុំលក្ខណៈសមស្របដូចតទៅ៖

***អ្នកស្តាប់*** ៖ សមត្ថភាពដើម្បីស្តាប់ និងបង្កើតបរិយាកាស ដែលអ្នកដទៃទៀតអាចស្តាប់បាន (មិនត្រឹមតែនិយាយប៉ុណ្ណោះទេ)។

***អ្នកផ្តល់លក្ខខណ្ឌអំណោយផល៖*** សមត្ថភាពដើម្បីមើលឃើញថាអ្នកណាដែលចូលរួម និងអ្នកណាមិនចូលរួម និងដើម្បីស្វែងរកវិធីនានា ដែលអាចឲ្យអ្នកចូលរួមទាំងអស់ រួមវិភាគទានដោយពិតប្រាកដ។ ចំណុចនេះរួមមាន ការបញ្ឈប់បុគ្គល ឬ ក្រុមណាមួយជាក់លាក់ ពីការមានឥទ្ធិពលលុបលើ MSP ណាមួយ។

***អ្នកផ្សារភ្ជាប់៖*** ឆន្ទៈដើម្បីត្រៀមខ្លួន ដោយគិតគូរតាមរយៈកម្មវិធី និងសាវតារបស់អ្នកចូលរួម ការរំពឹងទុក អំពីអ្វីដែលអាចកើតឡើង។ ប្រការសំខាន់គឺអ្នកសម្របសម្រួលត្រូវផ្សារភ្ជាប់ជំហាននានានៅក្នុងដំណើរMSP ការរក្សាទិសដៅ ការយកចិត្តទុកដាក់ខ្លះៗ ទន្ទឹមនឹងអាចបន្សាំបានទៅនឹងតម្រូវការចាំបាច់របស់អ្នកចូលរួមផងដែរ។

***ទទួលបាននូវការគោរព៖*** ការគោរព និងការយល់ចិត្ត សម្រាប់មនុស្សខុសៗគ្នា និងទស្សនៈខុសៗគ្នាអំពីពិភពលោករបស់ពួកគេ។ ប្រការនេះរួមបញ្ចូលការគោរពចំពោះបែបផែនខុសៗគ្នានៃចំណេះដឹងពោលគឺ វិស្វកម្ម កសិកម្ម អេកូឡូស៊ី សេដ្ឋកិច្ច វប្បធម៌ សង្គម នយោបាយជាតិ អ្នកភូមិនៅមូលដ្ឋាន។

***ភាពស្វាហាប់៖*** ដើម្បីរក្សាភាពមោះមុតរបស់អ្នកចូលរួម ក្នុងការព្យាយាម និងជំនះបានលើអ្វីដែលអាចជាកិច្ចការដ៏លំបាក តាមធម្មតាអ្នកសម្របសម្រួលទាមទារឲ្យមានថាមពលផ្ទាល់ខ្លួនយ៉ាងច្រើន។

***ការយល់ដឹងអំពី "បច្ចេកទេសសម្របសម្រួល" សមស្រប៖*** មានបច្ចេកទេសជាច្រើន ដើម្បីលើកទឹកចិត្តឲ្យមានការសំដែងមតិតាមបែបច្នៃប្រឌិតដូចជាការឲ្យដំណឹងការគូសវាសអំពីគំនិត រូបភាពសំប៉ូរបែប។ អ្នកសម្របសម្រួលដែលមានជំនាញអាចផ្អែកលើកត្តាទាំងនេះសម្រាប់ជាសមាសភាគនៃវិធី MSP។[29]

*"ដើម្បីសម្រួលឲ្យមានការជជែកពិភាក្សាតម្រូវការចាំបាច់ជាសារវន្ត គឺការសម្របសម្រួលដ៏ល្អមួយ"*

### *៣.៣.៣ ភាពពេញលេញ*

MSPs គួរតែផ្តល់លទ្ធភាពឲ្យមានតំណាងពីក្នុងចំណោមអ្នកពាក់ព័ន្ធខុសៗគ្នាជាច្រើនដែលមានចំណាប់អារម្មណ៍ខុសគ្នា តាមរយៈដំណើរការបត់បែន ដែលអាចមានបែបផែនខុសៗគ្នាជាច្រើន។ ភាពពេញលេញមានន័យថា ការគោរពនូវក្រមសីលធម៌ខុសៗគ្នាវិធីនានានៃការពិចារណារកហេតុផល ទស្សនៈពិភពលោក និងអាទិភាពរបស់អ្នកដើរតួនានា។

### *៣.៣.៤ យល់ដឹងជាមុន និងមានការប្រាស្រ័យទាក់ទង*

MSPs គួរប្រើប្រាស់ និងចែករំលែកព័ត៌មានល្អបំផុតដែលមាន បង្កើតមូលដ្ឋានចំណេះដឹង។ អ្នកចូលរួមនៅក្នុង MSPs គួរតែមានភាពជិតស្និតជាមួយវេទិកាពាក់ព័ន្ធ ផែនការ របៀបវារៈដទៃទៀត។ល។ MSPs ក៏ត្រូវប្រាស្រ័យទាក់ទងឲ្យមានប្រសិទ្ធភាពជាមួយសាធារណជនទូទៅផងដែរ ប្រសិនបើមានបំណងបង្កើត និងរក្សាមណ្ឌលគាំទ្ររបស់ខ្លួន។

## *៣.៤ ខ្លឹមសារ MSP ដែលជាការចង់បាន*

MSPs មិនសុទ្ធតែដូចគ្នាទាំងអស់នោះទេ។ រូបទី ៣.៤ ផ្តល់ជាឧទាហរណ៍ជាក់ស្តែងអំពី MSPថាជាសម្មតិកម្ម ដែលបង្ហាញអំពីលំនាំដែលគួរជឿបាន ចាប់ពីការទទួលស្គាល់នូវកង្វល់មួយ រហូតដល់ការពិចារណា និងការព្រមព្រៀងអំពីជំហានបន្ត។

MSPs អាចពាក់ព័ន្ធផងដែរជាមួយការប្រជុំជាទៀងទាត់រវាងអ្នកចូលរួមសំខាន់ៗ។ ការប្រជុំទាំងនោះអាចជាការជួបជុំមិនផ្លូវការ នៅជិតប្រឡាយស្រោចស្រព ជិតតំបន់ដីសើមណាមួយ ឬនៅលើច្រាំងទន្លេ។ គេក៏អាចចាត់ចែងជាសន្និសីទ ការពិភាក្សា ដែលបើកចំហរដល់សាធារណជន ទស្សនកិច្ចនៅតាមទីតាំងជាក់ស្តែងដែលចាត់ចែងដោយអ្នកនៅក្នុងមូលដ្ឋាន ការផ្លោះប្តូរតាមប្រព័ន្ធអេឡិចត្រូនិក ការពន្យល់ខ្លីៗពីសំណាក់រដ្ឋាភិបាល ភាពយន្ត ការសំដែង អត្ថបទអំពីប្រវត្តិសាស្ត្រ ឬការចាត់ចែងឲ្យមានការស្រាវជ្រាវផងដែរ។

បើទោះជាមានភាពខុសគ្នាលើរបៀបដែលមានការបង្កើត និងការអនុវត្តន៍ក៏ដោយឧទាហរណ៍អំពីខ្លឹមសារដែលចង់បាន ក៏អាចលើកស្នើបង្ហាញបានផងដែរ។

រូប៣.៤៖ កាលវេលា និងលំដាប់លំដោយនៃ MSPs សម្មតិកម្ម[31]




### *៣.៤.១ វិធីការរៀបចំ*

វិធីរៀបចំសំដៅលើជំហានជាក់ស្តែងនានា ដែលត្រូវតែពិចារណានៅក្នុងការបង្កើត MSP ដែលមានប្រសិទ្ធភាព។[31] ជំហានសំខាន់ៗមាន ៖

- ការបង្កើតក្រុមប្រឹក្សាភិបាលបណ្តោះអាសន្នសម្រាប់ MSP
- ការបង្ហាញហេតុផលបានច្បាស់លាស់អំពី MSP
- ការបង្កើតមណ្ឌលគាំទ្រសម្រាប់ MSP នោះ
- ការពិនិត្យមើលជាដំបូងអំពីបរិបទទូទៅនៃ MSP
- ការប៉ាន់ប្រមាណអំពីបែបផែន និងអាណត្តិដែលមានសក្តានុពលសម្រាប់ MSP។

ការបង្កើតក្រុមប្រឹក្សាភិបាលបណ្តោះអាសន្នសម្រាប់ MSP

បច្ចុប្បន្ននេះមានឧទាហរណ៍ជាច្រើនរយនៅជុំវិញពិភពលោកអំពី MSP ដែលទាក់ទងនឹងទឹក។ តាមធម្មតាដើម្បីចាប់ផ្តើម គេត្រូវការឲ្យមានក្រុមប្រឹក្សាភិបាល MSP មួយ។ អ្នកខ្លះនិយាយថា "បណ្តោះអាសន្ន" អ្នកដទៃទៀតហៅថា "ដំបូង" ឬ "មិនផ្លូវការ"។ អ្នកខ្លះចូលចិត្តហៅ "ក្រុមការងារ" ឬ "គណៈកម្មាធិការ" ជាងក្រុមប្រឹក្សាភិបាល។ទោះជាយ៉ាងណាក៏ដោយប្រការសំខាន់គឺមិនត្រូវចំណាយពេលច្រើនពេកលើដំណាក់កាលដំបូងនេះឡើយ។ ប្រការសំខាន់គឺត្រូវចាប់ផ្តើមនៅត្រង់ណាមួយ។ ការកោះប្រជុំ និងនៅទីបំផុតការគ្រប់គ្រង និងការទទួលខុសត្រូវលើការសម្របសម្រួលឲ្យមាន MSP ត្រូវបានកំណត់ និងកែសម្រួលនៅក្នុងអំឡុងពេលនៃការបង្កើត( សូមអានករណី៣.៤ )។

*ករណី៣.៨៖ ការកែលម្អចំណេះដឹង វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាកសិកម្ម*

ទាហរណ៍លេចធ្លោមួយនៅពេលថ្មីៗនេះពី MSP មួយគឺការប៉ាន់ប្រមាណជាអន្តរជាតិអំពីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអភិវឌ្ឍន៍ (IAASTD)។ នេះជាដំណើរការរយៈពេលប្រាំឆ្នាំពីឆ្នាំ ២០០៣-២០០៨។ ទោះបីមិនបានផ្តោតលើទឹកក៏ដោយវាជាឧទាហរណ៍ដ៏ល្អមួយ។

នៅក្នុងពេលចាប់ផ្តើមគណៈកម្មាធិការដឹកនាំមួយដែលមានតំណាងចំនួន៤០នាក់ មកពីរដ្ឋាភិបាលទីភ្នាក់ងារនានា ឧស្សាហកម្ម កសិករ និងផលិតករដទៃទៀតនៅជនបទ អ្នកប្រើប្រាស់អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការខាងបរិស្ថាន និងអង្គការដទៃទៀតបានបង្កើតឯកសារងាយមួយ នៅខែសីហាឆ្នាំ ២០០៣ ដែលអំពាវនាវឲ្យមានការវាយតម្លៃជាអន្តរជាតិ។ ពួកគេសម្រេចដោះស្រាយចំណោទនេះៈតើធ្វើបែបណាទើបយើងអាចកាត់បន្ថយភាពអត់ឃ្លាន និងភាពក្រីក្រកែលម្អការចិញ្ចឹមជីវិតនៅជនបទ និងសម្រួលឲ្យមានការអភិវឌ្ឍន៍ដោយចីរភាពបរិស្ថានសង្គម និងសេដ្ឋកិច្ចប្រកបដោយសមធម៌តាមរយៈការផលិតការចូលដល់ការប្រើប្រាស់ចំណេះដឹង វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាកសិកម្ម?

ដំណើរការបង្កើតមួយនឹងត្រូវអនុវត្តជាបន្ត។ ការប្រជុំលើកដំបូងនៃភាគីនានា (រដ្ឋាភិបាល)ទីភ្នាក់ងារ អ.ស.ប ចំនួនប្រាំផ្តល់ការឧបត្ថម្ភរួមគ្នា ធនាគារពិភពលោក និងតំណាងពីសង្គមស៊ីវិលបានធ្វើឡើងនៅក្នុងឆ្នាំ២០០៤។ តំណាងពីរដ្ឋាភិបាល (ប្រទេសចំនួន៤៥ចូលរួម) បានសម្រេចបន្តទៅការប៉ាន់ប្រមាណនេះ។ ពួកគេឯកភាពលើខ្លឹមសារ និងវិសាលភាពនៃការប៉ាន់ប្រមាណ និងបានអនុម័តលើទម្រង់រួម និងនីតិវិធី កាលវិភាគមួយ និងថវិកាចំនួន១០,៧លានដុល្លារអាមេរិច។

ដំណើរការនេះបានក្លាយជាដំណើរការអន្តររដ្ឋាភិបាលនៃ អ.ស.ប ដែលមានន័យថាតំណាងនានារបស់រដ្ឋជាសមាជិកដែលចូលរួមបានធ្វើការសម្រេចជាចុងក្រោយ និងត្រូវបានស្នើសុំឲ្យអនុម័តលើរបាយការណ៍ចុងក្រោយមួយ។ គណៈកម្មាធិការដឹកនាំដំបូងត្រូវបានបម្លែងទៅជាការិយាល័យពហុអ្នកពាក់ព័ន្ធដែលមានតំណាងចំនួន៦០នាក់មកពីរដ្ឋាភិបាល(៣០នាក់) សង្គមស៊ីវិល (២២នាក់) និងគ្រឹះស្ថានអន្តរជាតិ(៨នាក់) ដើម្បីពិនិត្យមើលដំណើរការនេះ។

បន្ទាប់មក IAASTD បានធ្វើការវាយតម្លៃទូលំទូលាយមួយនៅកម្រិតពិភពលោកដែលរាប់បញ្ចូលរបាយការណ៍ពិស្តារនៅថ្នាក់អនុតំបន់អំពីតួនាទីនៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាកសិកម្មនៅក្នុងការអភិវឌ្ឍដែលនាំទៅរកកិច្ចប្រជុំពេញអង្គនៅទីក្រុងចូហាណេស្បឺកក្នុងខែមេសា ឆ្នាំ២០០៨ដែលនៅទីនោះរបាយការណ៍សំយោគមួយ និងសេចក្តីសង្ខេបសម្រាប់អ្នកធ្វើសេចក្តីសម្រេចត្រូវបានបង្ហាញជូនដល់អ្នកពាក់ព័ន្ធទាំងអស់។

## *ការបង្ហាញហេតុផលច្បាស់លាស់សម្រាប់ MSP*

ភាពចាំបាច់ឲ្យមាន MSP ត្រូវតែមានពន្យល់ និងទទួលយកមុននឹងមានការឯកភាពដើម្បីវិនិយោគលើពេលវេលា និងកិច្ចប្រឹងប្រែង។ តើ MSP ព្យាយាមដោះស្រាយបញ្ហានិងកាលានុវត្តភាពអ្វីខ្លះ? តើ MSP មួយនឹងបំពេញភាពខ្វះចន្លោះឬបន្ថែមតម្លៃទៅក្នុងកិច្ចប្រឹងប្រែងដែលកំពុងអនុវត្តស្រាប់ដោយរបៀបណា? គោលដៅខុសៗគ្នាបានជម្រុញឲ្យមាន MSPs ថ្មីៗនេះនៅថ្នាក់មូលដ្ឋានជាតិ តំបន់ និងពិភពលោកដែលរួមទាំង៖

- ការបញ្ចូលនូវធាតុខ្លះៗនៃការជជែកពិភាក្សាជាសាធារណៈ ទៅក្នុងការធ្វើសេចក្តីសម្រេចអំពីចំណងទាក់ទងដែលអាចមានរវាងទន្លេធំៗទាំង ៣៧ នៅទូទាំងឥណ្ឌា (សូមអានករណី ៣.៦)។
- ការចែករម្លែករវាងទីជម្រាលតូចៗ ដោយសមធម៌នូវធនធានទឹកសម្រាប់ការស្រោចស្រពនៅទីជម្រាលលីងមូតីជូ ប្រទេសប៊ុយតង់ (សូមអានករណី ៣.៧ ម៉ូដែលរួមផ្សំ)។
- ការរួមផ្សំនូវការថែរក្សាសំណុំលក្ខណៈនៃជំនន់ដោយធម្មជាតិ ជាមួយការផលិតថាមពលវារីអគ្គិសនីនៅក្នុងការចរចាអំពី "លំហូរបរិស្ថាន" នៅក្នុងអាងទន្លេសេណេហ្គាល់ (សូមអានករណី ៣.៩)

- ថាមពលទៅអនាគត ការប្រើប្រាស់ចំណាត់ការនៅថ្នាក់ជាតិបន្តពីគណៈកម្មការពិភពលោកស្តីពីទំនប់ដើម្បីដោះស្រាយភាពចម្រូងចម្រាស់អំពីការសាងសង់ទំនប់ខ្នាតធំនៅប្រទេសនេប៉ាល់(សូមអានករណី ៣.១០)។
- ការប្រើប្រាស់ និងថែទាំបានប្រសើរជាងមុនសម្រាប់ជាប្រភពទឹកក្រោមដី នៅភូមិអ៊ូម៉ាទីឡា ស.រ.អា។[32]
- ការកែលម្អកិច្ចសហប្រតិបត្តិការ ក្នុងចំណោមក្រុមដែលមានចំណាប់អារម្មណ៍ និងការចរចាលើធម្មនុញ្ញទឹក ដើម្បីតម្រង់ទិសការគ្រប់គ្រងដី និងទឹក នៅអាងកូម៉ាឌូហ្គូ យ៉ូបេ នៃបឹងឆាត ភាគខាងជើងនៃប្រទេសនីហ្សេរីយ៉ា។[33]

*"ភាពចាំបាច់ឲ្យមាន MSP មួយត្រូវតែបានពន្យល់ និងទទួលយកមុននឹងមានការឯកភាពគ្នាដើម្បីវិនិយោគលើពេលវេលា និងកិច្ចប្រឹងប្រែង"*

## *កសាងមណ្ឌលគាំទ្រមួយសម្រាប់ MSP*

ដើម្បីឈានដល់សក្តានុពលរបស់ខ្លួន MSP មួយត្រូវការឲ្យមានមណ្ឌលគាំទ្រមួយដែលមានអ្នកគាំទ្រខុសៗគ្នា។ ការផ្តល់កាលានុវត្តភាពដើម្បីឲ្យមានការចូលរួមនៅក្នុងដំណាក់កាលដំបូង មានសារៈសំខាន់ណាស់។ បើទោះជាអ្នកទាំងឡាយអាចចូលរួម ប្រកបដោយការស្ទាបនាក៏ដោយសម្រាប់បុព្វហេតុខុសៗគ្នា អ្នកទាំងនោះភាគច្រើននឹងចង់ឲ្យមានការបញ្ចុះបញ្ចូលថា MSP គឺជាកិច្ចប្រឹងប្រែងពិតប្រាកដ និងដែលមានតម្លៃ ដើម្បីស្វែងរកវិធីដើម្បីឈានទៅមុខយ៉ាងត្រឹមត្រូវ និងមានប្រសិទ្ធភាព។ ការបង្កើតឲ្យមានមណ្ឌលគាំទ្រមួយ មានន័យថា កសាងមូលដ្ឋានមួយដែលមានអ្នកគាំទ្រដល់ MSP ដែលមានការប្តេជ្ញាចូលរួមនៅក្នុងដំណើរការរួមមួយ។ វាមិនមែនត្រឹមតែជា "ការចូលរួមជាមួយអ្នកពាក់ព័ន្ធនានា" ឬ នៅក្នុង "ការវិភាគអំពីអ្នកពាក់ព័ន្ធ" ប៉ុណ្ណោះទេ (មានពិភាក្សាខាងក្រោម)។

*"ដើម្បីឈានដល់សក្តានុពលរបស់ខ្លួន MSP មួយត្រូវតែមានមណ្ឌលមួយដែលមានអ្នកគាំទ្រខុសៗគ្នា"*

## *ការពិនិត្យដំបូងអំពីបរិបទ MSP ធំទូលាយ*

ក្រុមដឹកនាំបណ្តោះអាសន្នត្រូវតែធានាថា អ្នកចូលរួមមានការយល់ដឹងអំពីបរិបទធំទូលាយនៃ MSP។ អ្នកខ្លះហៅប្រការនេះថាជា "បរិយាកាសប្រតិបត្តិការ" ឬ "សេដ្ឋកិច្ចនយោបាយ "ធំទូលាយ"។ ប្រការសំខាន់គឺត្រូវពិនិត្យមើលទិដ្ឋភាពសំខាន់ៗនៃប្រវត្តិបច្ចុប្បន្ន និងដែលពាក់ព័ន្ធ ដែលរួមទាំង ការយល់ដឹងជាដំបូងអំពីទស្សនវិស័យជាច្រើនរបស់អ្នកពាក់ព័ន្ធនៅក្នុង MSP ផងដែរ។ ប្រការនេះនឹងផ្តល់ជាការណែនាំអំពីផ្នែកនានាដែលត្រូវស្វែងយល់ឲ្យបានពិស្តារបន្ថែមទៀត។

## *ការប៉ាន់ប្រមាណអំពីរចនាសម្ព័ន្ធប្រតិបត្តិការប្រកបដោយសក្តានុពលរបស់ MSP*

តាមធម្មតា មានជម្រើសខុសៗគ្នាចំនួនបី សម្រាប់រចនាសម្ព័ន្ធប្រតិបត្តិការនៃ MSP ដែលនឹងក្លាយជាកត្តាកំណត់អំពីមុខងារ និត្យានុកូលភាព និងសមត្ថកិច្ច។ គេក៏ត្រូវបង្ហាញឲ្យបានច្បាស់លាស់ផងដែរអំពីចំណងទាក់ទងជាមួយរចនាសម្ព័ន្ធរបស់អាជ្ញាធរដែលមានស្រាប់។ ឧទាហរណ៍ តើមានអ្វីខ្លះដែលត្រូវផ្សារ

ភ្ជាប់ទៅនឹងកម្រិតដែលមានស្រាប់នៃរដ្ឋាភិបាល (ប្រសិនបើមាន)? ការចំណាយពេលដើម្បីស៊ើបអង្កេត និងណែនាំឲ្យស្គាល់អំពីរចនាសម្ព័ន្ធសមស្របមានសារៈសំខាន់ជាស្នូល។

*ការប៉ាន់ប្រមាណអំពីទម្រង់ និងអាណត្តិរបស់ MSP*

តាមការអធិប្បាយរបស់អ្នកជំនាញ Jeroen Warner "បច្ចុប្បន្ននេះ ការហៅ MSP តាមឈ្មោះផ្សេងទៀត គឺជា "ប្រធានបទក្តៅ" នៅក្នុងវិស័យទឹក ដែលទាក់ទាញអ្នកដើរតួខុសៗគ្នាចូលរួមប្រតិបត្តិការជាមួយគ្នាយ៉ាងហោចណាស់សម្រាប់អំឡុងពេលមួយ "នៅក្នុងស្ថានភាពចម្លែកនិងអស្ចារ្យ" នៃដំណើរការខុសៗគ្នារបស់ពហុអ្នកពាក់ព័ន្ធ។[34]

នោះមានន័យថា គេមានជម្រើសជាច្រើនសម្រាប់បង្កើត MSP ណាមួយ ដែលត្រូវតែស្របគ្នាជាមួយគោលបំណង និងវិសាលភាពនេះ។ ការបង្កើតបែបផែននេះ រួមបញ្ចូលរចនាសម្ព័ន្ធប្រតិបត្តិការ និងផែនការនានាសម្រាប់អនុវត្ត MSP។ ដំណាក់កាលបង្កើត មានសារៈសំខាន់ណាស់ នៅក្នុងការចរចាឲ្យមានបែបផែន និងអាណត្តិសមស្រប ដើម្បីឲ្យ MSP ណាមួយ អាចបំពេញបានតាមតម្រូវការរបស់សង្គមដែលតស៊ូដើម្បីបុព្វហេតុជាក់លាក់មួយ ដោយសង្ឃឹមថាធ្វើឲ្យអភិបាលកិច្ចកាន់តែស្មើភាព និងកាន់តែមានប្រសិទ្ធភាព តាមរយៈវេទិកាដែលមានចេតនាល្អ។

## *៣.៤.២ ការវិភាគអ្នកពាក់ព័ន្ធ*

ការវិភាគអ្នកពាក់ព័ន្ធ មានសារៈសំខាន់ជាសារវន្ត ដើម្បីបង្កើត និងអនុវត្តឲ្យបានត្រឹមត្រូវនូវ MSP ណាមួយ។ វាជួយបង្ហាញអំពី ថាតើគួរឲ្យអ្នកណាខ្លះចូលរួមនៅក្នុង MSP ណាមួយ និងតាមវិធីណា។ វាគួរតែផ្តល់ជាមូលដ្ឋានគ្រឹះ និងផែនការមួយសម្រាប់ការចូលរួមនៅទូទាំង MSP ដែលធ្វើឲ្យកាន់តែមានភាពងាយស្រួលសម្រាប់អ្នកពាក់ព័ន្ធក្នុងការចូលរួម បានទទួលការគោរព និងរៀនសូត្រពីគ្នាទៅវិញទៅមក។

កត្តាជម្រុញ ពោលគឺ អ្នកកោះប្រជុំ ឬក្រុមអ្នកដឹកនាំ ត្រូវតែឯកភាពលើលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់អំពីអ្នកពាក់ព័ន្ធនានា។ សម្រាប់ MSP ជាច្រើន 4Rs គឺជាចំណុចចាប់ផ្តើមដ៏មានប្រយោជន៍។ តើអ្វីខ្លះជាផលប្រយោជន៍និងតើអ្នកណាអាចពាក់ព័ន្ធនៅក្នុងការទាញយកផលជាភាគលាភឬជាអ្នករ៉ាប់រងការចំណាយ? តើមានអ្វីខ្លះជាហានិភ័យ និងអ្នកណាខ្លះដែលជាអ្នករ៉ាប់រងហានិភ័យដោយស្ម័គ្រចិត្ត ឬដោយមិនស្ម័គ្រចិត្ត? តើអ្នកណាមាន ឬ អាចទាមទារសិទ្ធិដើម្បីបានចូលរួម ដោយទទួលស្គាល់ថាអ្នកខ្លះតែងតែពោលអំពី "សិទ្ធិរបស់ខ្លួនក្នុងការចូលរួម" មានធំជាងសិទ្ធិរបស់អ្នកដទៃ? អ្នកណាមានការទទួលខុសត្រូវដើម្បីចូលរួម ពោលគឺ តាមផ្លូវច្បាប់ ឬអាចដោយសារតែ"កាតព្វកិច្ចជាពលរដ្ឋ" ដោយសារតែទស្សនៈរបស់ពួកគេ និងលទ្ធភាពរបស់ពួកគេក្នុងការរួមវិភាគទាន?

ត្រូវចុះឈ្មោះមនុស្ស និងអង្គការទាំងអស់ដែលអាចស្របគ្នាជាមួយលក្ខណៈវិនិច្ឆ័យទាំងនេះ។ គេគួរកែសម្រួលតារាងនេះជាច្រើនលើក ដើម្បីធានាថា គ្រប់ក្រុម និងមនុស្សសំខាន់ៗទាំងអស់បានទទួលឱកាសដើម្បីចូលរួម ឬមួយដោយផ្ទាល់ ឬមួយតាមរយៈតំណាង។ ការអនុញ្ញាតឲ្យអ្នកពាក់ព័ន្ធដើម្បីប្រកាសខ្លួនឯង ក៏អាចធានាថាអ្នកដែលមានចំណាប់អារម្មណ៍ មិនត្រូវបានបដិសេធការចូលរួមឡើយ។ ត្រូវធ្វើការសម្រេចនានាអំពីរបៀបល្អបំផុតសម្រាប់ធ្វើឲ្យអ្នកទាំងឡាយបានចូលរួម។ ជាការល្អគឺត្រូវស្តាប់ឮពីគ្រប់ភាគីទាំងអស់ដែលទំនងជាមានចំណាប់អារម្មណ៍លើ MSP ដើម្បីឲ្យដឹងថាតើពួកគេគិត

ថាពួកគេអាចចូលរួមពាក់ព័ន្ធតាមវិធីណាទើបមានប្រសិទ្ធភាពខ្ពស់។

ឧបករណ៍ខុសៗគ្នាក៏អាចយកមកប្រើប្រាស់ផងដែរ ដើម្បីសិក្សាអំពីអ្នកពាក់ព័ន្ធនានា និងទំនាក់ទំនងរបស់ពួកគេ ដូចជា ៖ ការបំផុសគំនិត ការបង្ហាញពីទំនាក់ទំនងរបស់អ្នកដើរតួនានា ការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ឬ ការបង្កើត "រូបភាពសំបូរបែប" ជាមួយក្រុមគោលដៅ។

ការបង្កើតតារាងម៉ាទ្រិកអំពីអ្នកពាក់ព័ន្ធ នៅតាមអ័ក្សមួយ និងលក្ខណៈវិនិច្ឆ័យ 4Rs នៅលើអ័ក្សមួយផ្សេងទៀត អាចមានប្រយោជន៍ (សូមអានតារាង ៣.១)។ នៅក្នុងស្ថានភាពស្មុគស្មាញ ជាញឹកញាប់គេអាចមានទស្សនៈផ្ទុយគ្នា។ ការប្រើប្រាស់ 4Rs អាចជួយនៅក្នុងការស្រាវជ្រាវអំពីតួនាទីរបស់អ្នកពាក់ព័ន្ធខុសៗគ្នា នៅក្នុងបញ្ហាគន្លឹះនានានៃ MSP។

ការពិនិត្យឡើងវិញជាមួយមនុស្សខុសៗគ្នាអាចកាត់បន្ថយហានិភ័យនៃការមើលរម្លងឬភាពលំអៀង។ ប្រសិនបើមិនជាការបង្កហេតុខ្លាំងក្លាពេកនោះទេ ការរៀបចំសេចក្តីសង្ខេបដំបូងមួយអំពីឥទ្ធិពល និងអំណាចរបស់អ្នកដើរតួខុសៗគ្នា ក៏អាចមានប្រយោជន៍ផងដែរ។ ដោយទទួលស្គាល់អំពីលក្ខណៈឌីណាមិកនៃទំនាក់ទំនងរវាងអ្នកដើរតួនានា ការប្រើប្រាស់ 4Rs ដើម្បីឆ្លុះបញ្ចាំងអំពីអំណាច (ឥទ្ធិពល និង ឬ សមត្ថកិច្ចរបស់អ្នកពាក់ព័ន្ធខុសៗគ្នា) ក៏មានប្រយោជន៍ផងដែរ។



រូបថត៣.១៖ កិច្ចប្រជុំសន្ទនាអំពីទំនប់ និងការអភិវឌ្ឍ (ប្រទេសនេប៉ាល់)

## តារាង៣.១ ការវិភាគអ្នកពាក់ព័ន្ធដោយប្រើប្រាស់ 4Rs នៅក្នុងគម្រោងសម្បតិកម្មទឹក

| 4Rs → | ភាគលាភៈ ផលចំណេញដែលអាចមាន | ហានិភ័យៈ ហានិភ័យដែលទទួលយកដោយស្ម័គ្រចិត្តឬ កើតឡើងដោយមិនស្ម័គ្រចិត្ត | សិទ្ធិៈ សិទ្ធិដែលទាមទារ | ការទទួលខុសត្រូវៈ ការទទួលខុសត្រូវផ្លូវការឬមិនផ្លូវការ |
|---|---|---|---|---|
| អ្នកពាក់ព័ន្ធ (ឧទាហរណ៍) ↓ | ឧទាហរណ៍អំពីភាគលាភ ហានិភ័យ សិទ្ធិ និងការទទួលខុសត្រូវ ដែលគួរតែស្វែងយល់នៅក្នុងពេលវិភាគអំពីអ្នកពាក់ព័ន្ធ ↓ | | | |
| ប្រជាជនរងគ្រោះក្នុងមូលដ្ឋាន | ត្រូវវាយតម្លៃអំពីភាគលាភនៅក្នុងមូលដ្ឋាន។ វាអាចរាប់បញ្ចូលៈ សមធមិក្នុងការទទួលបានទឹកដែលមានគុណភាពខ្ពស់, ឬ ធនធានដែលពាក់ព័ន្ធការទូទាត់សំណងចំពោះការបាត់បង់លទ្ធភាពទទួលបានទឹក ការបញ្ឈប់ ឬកែប្រែគ្រោងដែលបង្កផលប៉ះពាល់អវិជ្ជមាន | អ្នកជាអ្នករ៉ាប់រងហានិភ័យដោយមិនស្ម័គ្រចិត្ត។ ឧទា រួមមានៈផលប៉ះពាល់អវិជ្ជមានទាក់ទងនឹងការថយចុះនៃគុណភាពនិងបរិមាណទឹក, ប្រព័ន្ធអេកូឡូស៊ីសន្តិសុខនៃរបរចិញ្ចឹមជីវិតត្រូវរងការគំរាមកំហែង។ល។ | សិទ្ធិទទួលការពិគ្រោះ យោបល់ជាមុនដោយ គ្មានការបង្ខិតបង្ខំ (សិទ្ធិ ក្នុងការមិនផ្តល់ការឯកភាពត្រូវមន្ត្រីរដ្ឋជំទាស់ យ៉ាងខ្លាំងក្លា), សិទ្ធិក្នុងការធ្វើឲ្យស្ថានភាព ប្រសើរជាងមុនឬ យ៉ាងហោចណាស់មិនអាក្រក់ជាងមុន។ | ការទទួលស្គាល់សិទ្ធិរបស់អ្នកដទៃក្នុងកិច្ច ប្រឹងប្រែងកែលម្អការរស់នៅរបស់ពួកគេ។ |
| ក្រុមហ៊ុនអភិវឌ្ឍន៍ | ទទួលផលចំណេញពីការសាងសង់ ឬប្រតិបត្តិការសម្បទានថ្មីណាមួយ | ថ្លៃសាងសង់ខ្ពស់ពេក ឬប្រតិបត្តិការមិនចំណេញហានិភ័យពីកំចីប្រាក់ ឬការវិនិយោគ | អនុលោមតាមកិច្ចសន្យាដែលបានធ្វើឡើង | អនុវត្តតាមច្បាប់បើកចំហពេញលេញអំពីផលប៉ះពាល់ដែលរំពឹងថានឹងកើតឡើងការសាងសង់និងប្រតិបត្តិការទៅតាមកិច្ចព្រមព្រៀង |
| អ្នកជំនាញការ | ប្រាក់ឈ្នួល និងជូនកាលភាគចំណែកនៃផលចំណេញថាត្រឹមត្រូវ | តិចតួច លើកលែងតែកេរ្តិ៍ឈ្មោះ ប្រសិនបើបង្ហាញធ្វើសេចក្តីសម្រេច យកទៅពិចារណា | សិទ្ធិផ្តល់យោបល់ដោយគ្មានលំអៀងសម្រាប់អ្នក | ប្រតិបត្តិការក្នុងវិស័យជំនាញរបស់ពួកគេ និងផ្តល់ការណែនាំច្បាស់លាស់ និងមិនលំអៀង |
| តំណាងពីអង្គការមិនមែនរដ្ឋាភិបាល | ជាញឹកញាប់អាចផាត់ចោលបាន ប៉ុន្តែដូចសម្រាប់អ្នកដទៃដែរ គួរតែយកមកពិនិត្យ។ ការបញ្ចូលបញ្ហាដែល ពួកគេគិតថាសំខាន់។ | ហានិភ័យនៃការទុកឲ្យនៅក្រៅសៃវៀននៃនយោបាយឬដំណើរការតាមផ្លូវច្បាប់ បើមិនមែនជាអ្នករងផលប៉ះពាល់ដោយផ្ទាល់កេរ្តិ៍ឈ្មោះ បើត្រូវគេមើលឃើញថាចូលរួមតិចតួចជាង MSP ធម្មតា ឬផ្តល់សម្បទានច្រើនខ្លាំងពេក | សិទ្ធិក្នុងការស្វែងយល់, សាកសួរ និងបង្ហាញគំនិត និងយោបល់របស់ខ្លួន | គណនេយ្យភាពខាងនយោបាយចំពោះមុខ មណ្ឌលនៃអ្នកពាក់ព័ន្ធរបស់ពួកគេ |
| ហិរញ្ញិក | ផលចំណូលសម្រាប់ការវិនិយោគ | ខាតបង់ពីការវិនិយោគ | អនុញ្ញាតត្រឹមកម្រិតដែលមានចែងនៅក្នុងច្បាប់ | ប្រុងប្រយ័ត្ន គោរពតាមគោលការណ៍ផ្ទៃក្នុង និងឧស្សាហកម្ម រួមទាំងក្រមអនុវត្តផងដែរ |
| មន្ត្រីរដ្ឋាភិបាល | ផលចំណេញគួរតែមានការកំហិតត្រឹមដូចដែលពលរដ្ឋទូទៅទទួលបាន | តិចតួច លើកលែងតែបានបង្ហាញថាគាំទ្រដល់ការអភិវឌ្ឍមិនសមស្រប ឬមិនត្រឹមត្រូវ | អនុវត្តកិច្ចការរបស់ខ្លួនតាមការអនុញ្ញាត និងឲ្យពលរដ្ឋចូលជានិយោជិត | ធ្វើការវិនិច្ឆ័យរឿងដោយឈ្លាសវៃគោរពតាមស្មារតីនៃច្បាប់និងបទបញ្ញត្តិណែនាំ |

### ៣.៤.៣ *កិច្ចសន្យាសង្គមរវាងអ្នកចូលរួមនានា*

កិច្ចសន្យាសង្គមគឺជាសេចក្តីសង្ខេបមួយអំពីបទបញ្ញានៃការចូលរួមនៅក្នុង MSP ។ គេត្រូវបង្កើតឲ្យមានកិច្ចសន្យាសង្គម[35] រវាងអ្នកកោះប្រជុំ និងតំណាងអ្នកពាក់ព័ន្ធទាំងអស់ដែលទាមទារឲ្យឈានដល់កិច្ចព្រមព្រៀងដែលអាចយកជាការបានខ្លះៗលើគោលបំណង វិសាលភាព ឱកាសខាងនយោបាយ ធនធាន ពេលវេលា និងដំណើរការដើម្បីឲ្យអ្នកចូលរួមនៅក្នុង MSP បានយល់អំពីតួនាទី និងការទទួលខុសត្រូវរបស់ទាំងអស់គ្នា។

កិច្ចសន្យាសង្គមដែលតាមធម្មតាកើតឡើងពីការចរចាគួរតែធ្វើឲ្យ "ការសន្យារបស់អ្នកចូលរួម" បង្ហាញពីភាពច្បាស់លាស់ដើម្បីកាត់បន្ថយឱកាសនៃភាពមិនស្របគ្នារវាងភាពជាក់ស្តែង និងការរំពឹងទុក។ ឧទាហរណ៍៖ តើតំណាងរបស់អ្នកពាក់ព័ន្ធនានាបានទទួលការអញ្ជើញដើម្បី៖

- ចូលមកជួបជុំគ្នាដើម្បីបង្កើតទំនាក់ទំនង និងចែករំលែកព័ត៌មានជាមួយគ្នាដែរឬទេ?
- បង្កើតរបៀបវារៈសម្រាប់ចំណាត់ការជាសាធារណៈ ឬដោយវិស័យឯកជននៅពេលក្រោយមកដែរឬទេ?
- ដើម្បីបំផុសគំនិត និងដោះស្រាយបញ្ហាដែរឬទេ?
- ចូលរួមនៅក្នុងកិច្ចផ្តួចផ្តើមដើម្បីបង្កើតឲ្យមានការឯកភាពមតិដែរឬទេ?
- ផ្តល់អនុសាសន៍ ឬ ធ្វើសេចក្តីសម្រេចដែរឬទេ?

កិច្ចសន្យាសង្គមត្រូវតែមានលក្ខណៈច្បាស់លាស់ និងចងក្រងជាលាយលក្ខអក្សរ ដូចជាសម្រាប់វេទិកាវាយតម្លៃនិរន្តរភាពថាមពលវារីអគ្គិសនីផងដែរ (សូមអានករណី ៣.៥)។

*"កិច្ចសន្យាសង្គមគឺជាសេចក្តីសង្ខេបមួយអំពីបទបញ្ញាសម្រាប់ការចូលរួមនៅក្នុងMSPនោះ"*

*ករណី៣.៥ "កិច្ចសន្យាសង្គម" នៃវេទិកាវាយតម្លៃនិរន្តរភាពថាមពលវារីអគ្គិសនី*

នៅឆ្នាំ ២០០៤ សមាគមថាមពលវារីអគ្គិសនីអន្តរជាតិ (IHA) បានអនុម័តគោលការណ៍ណែនាំស្តីពីនិរន្តរភាពបន្ទាប់មកនៅឆ្នាំ ២០០៦ មានការអនុម័តពិធីសារសម្រាប់ការវាយតម្លៃនិរន្តរភាព (SAP)។ នៅក្នុងអំឡុងឆ្នាំ ២០០៨-២០០៩ វេទិកាវាយតម្លៃនិរន្តរភាពថាមពលវារីអគ្គិសនី (HSAF)[36] បានពិនិត្យមើលថាតើគេអាចបង្កើតឧបករណ៍វាយតម្លៃនិរន្តរភាពមួយដែលមានការគាំទ្រទូលំទូលាយ ដែរឬទេ សម្រាប់វាស់វែង និងណែនាំដល់ការអនុវត្តន៍នៅក្នុងវិស័យថាមពលវារីអគ្គិសនី ដោយផ្អែកលើ SAP របស់ IHA។ HSAP ត្រូវបានបញ្ចូលនៅក្នុងការវាយតម្លៃនៅតាមភូមិសាស្ត្រជាក់ស្តែង និងការប្រជុំនៅ ស.រ.អា ហ្សំប៊ី ចិន ប្រេស៊ីល អាយស្លេន និងទួគី។ នៅពាក់កណ្តាលឆ្នាំ ២០០៩ មានការបញ្ចេញសេចក្តីព្រាងពិធីសារសម្រាប់ការវាយតម្លៃ និរន្តរភាពថាមពលវារីអគ្គិសនី (HSAP)។

សមាជិកភាពនៅក្នុងវេទិកានេះរួមមាន តំណាងនានានៃប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសជឿនលឿនដែលពាក់ព័ន្ធនៅក្នុងវិស័យថាមពលវារីអគ្គិសនី ក៏ដូចជាមកពីអង្គការមិនមែនរដ្ឋាភិបាល វិស័យហិរញ្ញវត្ថុ និងឧស្សាហកម្មផងដែរ។ នៅពេលចាប់ផ្តើមវេទិកានេះ អ្នកចូលរួមបានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់មួយ និងបានឯកភាពលើសេចក្តីលំអិតនៃ "នីតិវិធីប្រាស្រ័យឆ្លើយឆ្លង និងប្រតិបត្តិការ" ដែលរួមទាំង ដូចជា ៖

- HSAP ត្រូវតែមានតម្លាភាព អនុវត្តដោយសុច្ឆន្ទៈ និងត្រូវស្វែងរកការឯកភាពមតិ
- នៅក្នុងករណីដែលមិនអាចឈានដល់ការឯកភាពមតិត្រូវកត់ត្រាទុក និងទទួលស្គាល់ភាពមិនចុះ

សម្រុងគ្នា នៅក្នុងគ្រប់ឯកសាររបស់ HSAP

- HSAP អាចប្រើប្រាស់ឈ្មោះ និងឃីហោរបស់អ្នកចូលរួមក្នុងឯកសារសាធារណៈក្រោយបានទទួលការអនុញ្ញាតតែប៉ុណ្ណោះ
- ការគាំទ្រលើលទ្ធផលចុងក្រោយនឹងត្រូវធ្វើឡើងដោយអ្នកចូលរួមម្នាក់ៗ នៅចុងនៃដំណើរការនេះក្រោយ មានការពិគ្រោះយោបល់ជាមួយមណ្ឌលគាំទ្ររៀងៗខ្លួន
- អ្នកចូលរួមរក្សាសិទ្ធិក្នុងការដកខ្លួនចេញពី MSP នៅក្នុងអំឡុងពេលនៃដំណើរការនេះ។ ប្រសិនបើមាន ចំណាត់ការបែបនេះ អ្នកចូលរួមដែលត្រូវដកខ្លួនចេញ ត្រូវផ្តល់ការពន្យល់ជាលាយលក្សអក្សរទៅប្រធាន។

*"កិច្ចសន្យាសង្គមត្រូវតែមានភាពច្បាស់លាស់ និងចងក្រងជាលាយលក្សណ៍អក្សរ"*

## *៣.៤.៤ ការវាយតម្លៃទូលំទូលាយ*

មានឧបករណ៍ជាច្រើនសម្រាប់គាំទ្រឲ្យមានការពិចារណា ដែលអាចមានប្រយោជន៍នៅពេលដែលចរចាអំពីការប្រើប្រាស់ធនធានដែលទាក់ទងនឹងទឹក និងការអភិវឌ្ឍន៍ជាបន្ត។ ជាការពិត MSPs គួរតែប្រឹងប្រែងដើម្បីធានាឲ្យមានការវាយតម្លៃបញ្ហានានាបានទូលំទូលាយ ដែលមានន័យថា "មានលក្ខណៈលំអិតគ្រប់គ្រាន់" ដែលអ្នកពាក់ព័ន្ធទាំងអស់អាចយល់ដឹងជាមុន និងយល់អំពីការប្រើប្រាស់។ បច្ចុប្បន្ននេះគេមានបទពិសោធន៍ទូលំទូលាយក្នុងការអនុវត្ត MSPs ដោយមានការប្រមូលផ្តុំចំណេះដឹងយ៉ាងច្រើន ដែលជាសមាសភាគទំនាស់នឹងគ្នា និងសមាសភាគសំខាន់ៗដែលជាមូលដ្ឋានគ្រឹះ។

### *ករណី៣.៦៖ ការសន្ទនាដែលនាំមុខដោយសង្គមស៊ីវិលដែលវាយតម្លៃប្រព័ន្ធផ្សារភ្ជាប់ទន្លេនៅក្នុងប្រទេសឥណ្ឌា*

ការបង្វែរទឹកទន្លេ និងការផ្ទេរទឹករវាងអាងទន្លេគឺជាបញ្ហាខ្លះៗដែលមានលក្ខណៈប្រកួតប្រជែងទាក់ទងនឹងការប្រើប្រាស់ទឹកនៅក្នុងពិភពលោក។គម្រោងចំណងទាក់ទងគ្នានៃអាងទន្លេធំៗនៅឥណ្ឌា (ILR) បានលើកស្នើឲ្យផ្តល់ ទឹក ១៧៣ ពាន់លានម³សម្រាប់ស្រោចស្រពផ្ទៃដីទំហំ ៣៧ លានហិកតា តាមរយៈបណ្តាញចំនួន ៣១ នៃទន្លេនានានៅតំបន់ហេមពាន្ត និងជ្រោយឧបទ្វីបហេមពាន្ត និងទំនប់ពាក់ព័ន្ធខ្នាតធំ អាងជលសាស្ត្រ និងប្រឡាយនានា។

អ្នកលើកសំណើនេះបានអះអាងអំពីផលប្រយោជន៍ដែលអាចទទួលបានពីការបង្វែរទឹកពីទន្លេដែលមាន "អតិរេក" ទៅទន្លេដែលមាន "ឱនភាព" ដើម្បីបង្កើនការស្រោចស្រព ដែលអាចបង្កើនផលិតកម្មធញ្ញជាតិសម្រាប់ជាស្បៀង កាត់បន្ថយទឹកជំនន់ និងគ្រោះរាំងស្ងួត និងកាត់បន្ថយអតុល្យភាពនៃវត្តមានទឹកប្រចាំតំបន់។ អ្នករិះគន់លើកឡើងអំពីការខូចខាតខាងអេកូឡូស៊ី សេដ្ឋកិច្ច និងសង្គមនិងបានអះអាងដើម្បីឲ្យមានវិធីកាន់តែមានប្រសិទ្ធភាពសម្រាប់ដោះស្រាយបញ្ហាសន្តិសុខស្បៀង។

សម្ព័ន្ធភាពក្រុមសង្គមស៊ីវិល ដែលដឹកនាំដោយអង្គការមូលនិធិពិភពលោកសម្រាប់អភិរក្សធម្មជាតិ (WWF) បានផ្តួចផ្តើមឲ្យមាន MSP មួយ នៅក្នុងឆ្នាំ ២០០៣ ដើម្បីធ្វើការវាយតម្លៃទូលំទូលាយនូវផលប្រយោជន៍ និងហានិភ័យនៃគម្រោងនេះ និងស្វែងយល់អំពីជម្រើសជំនួសការតភ្ជាប់ទន្លេនានា។ក្រុមការងារដំបូង ដែលរួមទាំង សង្គមស៊ីវិល តំណាងពីរដ្ឋាភិបាល មេដឹកនាំនយោបាយ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន បានចំណាយពេលប្រាំបីខែ ដើម្បីចរចាអំពីការបង្កើតវេទិកានេះ និងជាពិសេសអំពីសមាជិករបស់

ខ្លួន។ "គណៈកម្មាធិការជាតិសង្គមស៊ីវិល"(NCSC) ដែលបានបង្កើតឡើង និងមានសមាសភាពជាបុគ្គលល្បីៗ ដែលតំណាងឲ្យទស្សនៈខុសៗគ្នា។ NCSC ត្រូវគេរំពឹងថា ៖ បង្កើតឲ្យមានការចរចាជាសាធារណៈ សម្របសម្រួល និងកែលម្អការចែករំលែកព័ត៌មានរវាងសង្គមស៊ីវិល និងរដ្ឋាភិបាល ចងក្រងចំណេះដឹង និងបទពិសោធន៍ដែលមានពីអតីតកាល និងបង្កើតចំណេះដឹងថ្មីៗអំពីគម្រោងនេះ តាមរយៈការសិក្សាដោយឯករាជ្យ។

NCSC បានបង្កើតឲ្យមានការជជែកវែកញែកប្រកបដោយជោគជ័យលើបញ្ហានានា និងមានឥទ្ធិពលមកលើរដ្ឋាភិបាល ដើម្បីគិតគូរឡើងវិញអំពីនីតិវិធី និងចំណាត់ការនានារបស់ខ្លួន។ បើទោះជាការបង្កើតវេទិកានេះបានចំណាយពេលវែងជាងការរំពឹងទុកក៏ដោយក៏សមត្ថកិច្ច និងនិត្យានុកូលភាពនៃដំណើរការនេះច្រើនតែកើតឡើងដោយសារតែភាពចម្រុះនៃទស្សនៈទាននានាដែលមានតំណាង និងភាពពេញលេញនៃការវិភាគនេះ។[37]

## ៣.៤.៥ សេណារីយ៉ូ

សេណារីយ៉ូគឺជារឿងរ៉ាវ ដែលគូសបញ្ជាក់អំពីអនាគតដែលអាចកើតឡើង។ សម្រាប់ស្ថានភាពស្មុគស្មាញដែលពាក់ព័ន្ធជាមួយភាពមិនប្រាកដប្រជា ការបង្កើតសេណារីយ៉ូនៅក្នុង MSP អាចជួយអ្នកចូលរួមទាំងអស់គិតគូរតាមបែបច្នៃប្រឌិត និងស្វែងយល់អំពីផលប្រយោជន៍ខុសៗគ្នាទៅវិញទៅមក គុណតម្លៃ អាទិភាព ការសន្មត ឧបសគ្គ និងជម្រើសនានា។

ការវិភាគសេណារីយ៉ូមានប្រវត្តិតាំងពីទសវត្សរ៍ឆ្នាំ ១៩៦០មក នៅក្នុងយោធា និងធុរកិច្ច។ នៅក្នុងពេលថ្មីៗនេះ នៅពេលដែលទាំងជំហាននៃការប្រែប្រួល និងភាពមិនប្រាកដប្រជាបានកើនឡើង គេឃើញមានចំណាប់អារម្មណ៍ឡើងវិញ លើការវិភាគសេណារីយ៉ូ និងការកសាងផែនការ។

គោលការណ៍ជាមូលដ្ឋាននៃការកសាងផែនការសេណារីយ៉ូ គឺត្រូវព្យាយាម និងស្វែងយល់អំពីនិន្នាការដែលអាចកើតមានទៅអនាគត ដើម្បីជួយធ្វើការសម្រេចជាយុទ្ធសាស្ត្រ ដោយផ្អែកលើការវិភាគផលវិបាកនានាដែលអាចកើតមាន។ ទម្រង់ខ្លះៗនៃការវិភាគសេណារីយ៉ូ មានការពាក់ព័ន្ធជាខ្លាំងទៅនឹង MSP ជាច្រើន (សូមមើលប្រអប់ ៣.២)។

សេណារីយ៉ូនានា គឺជាការបកស្រាយអំពីបច្ចុប្បន្នកាល ក៏ដូចជារូបភាពអំពីអនាគតដែលអាចកើតមានផងដែរ។ ខ្សែរឿងនៃសេណារីយ៉ូ គួរតែមានសង្គតិភាពផ្ទៃក្នុង និងអធិប្បាយអំពីលំនាំផ្លូវពីបច្ចុប្បន្នទៅអនាគតដែលអាចមាន។ នៅក្នុងករណីមានទិន្នន័យ ការបង្កើតម៉ូដែលបរិមាណ គឺជាវិធីមួយនៃការបង្កើតសេណារីយ៉ូដែលមានលក្ខណៈជាការពន្យល់ ក៏ដូចជាបង្ហាញចំណងទាក់ទងសំខាន់ៗឲ្យកាន់តែច្បាស់ផងដែរ។

*"ទម្រង់ខ្លះៗនៃការវិភាគសេណារីយ៉ូមានការពាក់ព័ន្ធជាខ្លាំងជាមួយ MSPs ជាច្រើន"*

### *ប្រអប់៣.២៖ ជំហាននានាដែលប្រើប្រាស់នៅក្នុងការបង្កើតសេណារីយ៉ូ*

ជំហានទី១៖ កំណត់អត្តសញ្ញាណកត្តាជម្រុញ ទោះពីប្រភពណាមួយក៏ដោយ៖នយោបាយ សេដ្ឋកិច្ច សង្គមឬការប្រែប្រួលអេកូឡូស៊ី ការទម្លុះទម្លាយភាពទ័លច្រកខាងបច្ចេកទេស។ល។

ជំហានទី២៖ កំណត់អត្តសញ្ញាណកត្តាដែលបានកំណត់ទុកជាមុន - ការប៉ាន់ប្រមាណនូវអ្វីដែលមិនអាច

ជៀសវាងបានទៅអនាគត
ជំហានទី៣៖ កំណត់អត្តសញ្ញាណភាពមិនប្រាកដប្រជាសំខាន់ៗ ការប៉ាន់ប្រមាណអំពីវិស័យនានាដែលមានភាពមិនប្រាកដប្រជាទៅអនាគត និងដែលអាចចាត់ជាអាទិភាពអនុលោមតាមសារៈសំខាន់ និងកម្រិតនៃភាពមិនប្រាកដប្រជា
ជំហានទី៤៖ បង្កើតខ្សែរឿងសេណារីយ៉ូ ជម្រើសជំនួសល្អៗដែលចង់បានទៅអនាគត
ជំហានទី៥៖ ប៉ាន់ប្រមាណអំពីការពាក់ព័ន្ធនៃសេណារីយ៉ូខុសៗគ្នា សម្រាប់បញ្ហានានា អង្គការនានា និងទីកន្លែងនានា ឬវិស័យនានាដែលជាកង្វល់
ជំហានទី៦៖ កំណត់អត្តសញ្ញាណ និងប្រើប្រាស់សូចនាករ - ដើម្បីអាចឲ្យមានការប៉ាន់ប្រមាណនិងការបន្សាំជាប់ជាបន្ត។

ទម្រង់ និងបរិបទអាចដាក់ក្រោមការពិសោធន៍ប្រកបដោយភាពច្នៃប្រឌិត។ ឧទាហរណ៍គម្រោងអនាគតនៃអាងទន្លេជចជៀបានផ្អែកលើចំណេះដឹងរបស់អ្នកជំនាញ និងយោបល់ពីសហគមន៍ដើម្បីបង្កើតឧបករណ៍ និងល្បែងមួយដើម្បីស្វែងយល់អំពីប្រភេទសេណារីយ៉ូ តើមានអ្វីកើតឡើងប្រសិនបើសម្រាប់អាងមួយនៅឆ្នេរខាងលិចនៃប្រទេសកាណាដា។ ការបង្កើតចក្ខុវិស័យត្រូវបានប្រើប្រាស់ជាទូទៅនៅក្នុងការបង្កើតសេណារីយ៉ូ និងការធ្វើសេចក្តីសម្រេចដូចជាពីសំណាក់អ្នកធ្វើសេចក្តីសម្រេច និងយុវជននៅអឺរ៉ុប[38] និងសម្រាប់រយៈពេលវែងជាងនេះដោយពលរដ្ឋជនជាតិដើមដែលពុះពារនៅក្នុងការបែងចែកទឹកនៅភ្នំហៃអាត្លាស់ និងតំបន់វាលខ្សាច់នេហ្សេវ។

ល្បែងសំដែងតួក៏អាចជួយអ្នកពាក់ព័ន្ធនានា ដើម្បីស្វែងយល់អំពីទស្សនទានរបស់គ្នាទៅវិញទៅមកអំពីជម្រើសគ្រប់គ្រងទឹកផងដែរ។ ករណី៣.៧ បង្ហាញពីម៉ូដែលរួមផ្សំដែលបញ្ចូលល្បែងសំដែងតួជាមួយការបង្កើតម៉ូដែលតាមកុំព្យូទ័រដើម្បីស្វែងយល់អំពីសេណារីយ៉ូនានា។

*"ការបង្កើតចក្ខុវិស័យត្រូវបានប្រើប្រាស់ជាទូទៅនៅក្នុងការកសាងសេណារីយ៉ូ និងការធ្វើសេចក្តីសម្រេច"*

*ករណី៣.៧៖ ការបង្កើតម៉ូដែលរួមផ្សំ*

ការបង្កើតម៉ូដែលរួមផ្សំបញ្ចូលល្បែងសំដែងតួជាមួយការធ្វើត្រាប់ម៉ូដែលតាមកំព្យូទ័រដើម្បីសម្រួលឲ្យមានការសិក្សារួមគ្នា និងស្វែងយល់អំពីសេណារីយ៉ូនានាក្នុងបំណងជួយឲ្យមានការធ្វើសេចក្តីសម្រេចរួមគ្នា។

អភិក្រមនេះត្រូវបានដាក់ឲ្យអនុវត្តប្រកបដោយជោគជ័យដើម្បីដោះស្រាយវិវាទក្នុងចំណោមអ្នកភូមិអំពីវិភាជន៍ទឹកសម្រាប់ការស្រោចស្រពស្រូវនៅប៊ូយតង់ និងប្រទេសថៃ។ កសិករនៅក្នុងទីជម្រាលលីងមូតីជូនៅប៊ូយតង់បានអនុវត្តវគ្គមួយចំនួននៅក្នុងល្បែងនេះដើម្បីពិនិត្យមើលសមិទ្ធផលពីយុទ្ធសាស្រ្តខុសៗគ្នាសម្រាប់ការបែងចែកទឹកក្នុងករណីបានអនុវត្តទាំងនៅក្នុងភូមិរបស់ពួកគេ និងនៅក្នុងអភិក្រមរួមគ្នាមួយរវាងភូមិនានាផងដែរ។ ការប្តូរតួមានប្រសិទ្ធភាពដោយឡែកនៅក្នុងការបង្កើតឲ្យមានការយល់ដឹងជារួមក្នុងចំណោមអ្នកចូលរួមអំពីស្ថានភាពនានារបស់ភាគីដទៃ។

ម៉ូដែលពហុភ្នាក់ងារតាមរយៈកុំព្យូទ័រអនុញ្ញាតឲ្យមានការត្រាប់តាមយ៉ាងឆាប់រហ័សនូវសេណារីយ៉ូដែលមានលក្ខណៈទូលំទូលាយជាងមុនអំពីបទបញ្ហាបែងចែកទឹក។ ម៉ូដែលនេះពិនិត្យមើលអន្តរអំពើក្នុងចំណោមអ្នកដើរតួ (ឬ "ភ្នាក់ងារ") ខុសៗគ្នា និងរវាងអ្នកដើរតួទាំងនេះ និងធនធានរួមដែលត្រូវចែករំលែក។ អ្នកស្រាវជ្រាវ និងអ្នកចូលរួមអាចពិភាក្សាអំពីសមិទ្ធផលនៃសេណារីយ៉ូនេះ និងប្រកាន់យកម៉ូដែលនេះ

ដើម្បីឲ្យសេណារីយ៉ូទាំងនោះឆ្លុះបញ្ចាំងអំពីស្ថានភាពនៅក្នុងមូលដ្ឋាន។

អ្នកចូលរួមបានពាក់ព័ន្ធជាលើកដំបូងនៅក្នុងល្បែងនានាដែលជាលំហាត់មួយប៉ុន្តែភ្លាមនោះបានយល់អំពីអំណាចនៃឧបករណ៍សម្រាប់ការវិភាគរួមគ្នាលើបញ្ហាស្មុគស្មាញ។ ការពិភាក្សាក្នុងវគ្គពេញអង្គក្នុងចំណោមវគ្គនានានៅក្នុងល្បែងនេះបាននាំឲ្យមានការពិចារណាដែលបានពីការវិភាគគ្រាប់ទៅជាការពិចារណាអំពីស្ថានភាពជាក់ស្តែង។ អ្នកភូមិនៅប៉ុយតង់បានបញ្ចប់វគ្គនានារបស់ខ្លួនដោយកិច្ចព្រមព្រៀងជាផ្លូវការមួយអំពីរបៀបរិភាជន៍ទឹកឲ្យកាន់តែស្មើភាពជាងមុនដែលរួមទាំងការបង្កើតគណៈកម្មាធិការគ្រប់គ្រងទឹក និងជំហាននានាដើម្បីបង្កើតបទបញ្ជា និងនីតិវិធីនានាផងដែរ។[39]

## *ករណី៣.៨៖ សេណារីយ៉ូនៅក្នុងការវាយតម្លៃប្រព័ន្ធអេកូឡូស៊ីសហស្សវត្សរ៍*

ការវាយតម្លៃប្រព័ន្ធអេកូឡូស៊ីសហស្សវត្សរ៍ (MA)[40] ប៉ាន់ប្រមាណអំពីផលវិបាកនានាអំពីការប្រែប្រួលនៃប្រព័ន្ធអេកូឡូស៊ី សម្រាប់សុខុមាលភាពរបស់មនុស្ស។ ចាប់ពីឆ្នាំ ២០០១-២០០៥ MA ពាក់ព័ន្ធជាមួយការងាររបស់អ្នកជំនាញការច្រើនជាង ១.៣៦០នាក់ នៅទូទាំងពិភពលោក។ របកគំហើញរបស់ពួកគេផ្តល់ជាការវាយតម្លៃតាមបែបវិទ្យាសាស្ត្រតាមបែបទំនើប អំពីលក្ខខណ្ឌ និងនិន្នាការនៃប្រព័ន្ធអេកូឡូស៊ីនៅលើពិភពលោក និងសេវានានាដែលរបកគំហើញនោះផ្តល់ឲ្យ ក៏ដូចជា មូលដ្ឋានវិទ្យាសាស្ត្រសម្រាប់ចំណាត់ការដើម្បីអភិរក្ស និងប្រើប្រាស់ប្រព័ន្ធអេកូឡូស៊ីទាំងនោះឲ្យមាននិរន្តរភាពផងដែរ។

ក្រុមការងារសេណារីយ៉ូ MA បានចាត់ទុកការបង្កើតសេណារីយ៉ូថាជាឧបករណ៍មួយដើម្បីស្វែងយល់អំពីលទ្ធភាពសម្រាប់អនាគត ដែលមិនអាចព្យាករណ៍បាន តាមរយៈការធ្វើអិចស្ត្រាប៉ូលេសិនពីនិន្នាការពីអតីតកាល និងបច្ចុប្បន្ន។

MA បានចាត់ទុកលទ្ធភាពវិវត្តន៍នៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី នៅក្នុងអំឡុងទសវត្សរ៍ទី ២១ ដោយបង្កើតសេណារីយ៉ូពិភពលោកចំនួនបួនដែលស្វែងយល់អំពីការប្រែប្រួលទៅអនាគតនៃកត្តាជម្រុញប្រព័ន្ធអេកូឡូស៊ី សេវាកម្មបព័ន្ធអេកូឡូស៊ី និងសុខុមាលភាពរបស់មនុស្ស ៖

- សេណារីយ៉ូកំណើនទូទាំងពិភពលោក ដែលស្រង់យកសង្គមដែលមានភាពតជាប់គ្នានៅទូទាំងពិភពលោកដែលក្នុងនោះ មានការបង្កើតទីផ្សារពិភពលោកបានល្អ និងដែលមានកម្រិតខ្ពស់នៃកិច្ចសហប្រតិបត្តិការលើពិភពលោក។
- លំដាប់ចាប់ពីសេណារីយ៉ូនៃភាពខ្លាំង ដែលពិនិត្យមើលពិភពលោកដែលមានលក្ខណៈជាតំបន់ និងដាច់ពីគ្នាជាផ្នែក ដែលជាប់ជំពាក់ជាមួយសន្តិសុខ និងកិច្ចការពារទល់នឹងសកលភាវូបនីយកម្ម។
- សេណារីយ៉ូបន្សាំតាមកន្លែង ដែលស្វែងយល់អំពីពិភពលោកដែលនៅដាច់គ្នាជាដុំដែលកើតចេញពីស្ថាប័នពិភពលោក ដែលពុំមាននិត្យានុកូលភាព ដែលនៅក្នុងនោះ យុទ្ធសាស្ត្រគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីនៅមូលដ្ឋានមានការវិវត្តន៍និងត្រូវស្ថាប័នមូលដ្ឋានដែលរឹងមាំជាងមុនបានប្រកាន់យក។
- សេណារីយ៉ូសួនបច្ចេកវិទ្យា ដែលតំណាងឲ្យពិភពលោកទាំងមូលដែលតជាប់គ្នាដែលពឹងផ្អែកជាខ្លាំងលើបច្ចេកវិទ្យា និងប្រព័ន្ធអេកូឡូស៊ីដែលស្ថិតក្រោមការគ្រប់គ្រងសកម្ម និងជាញឹកញាប់ជាលទ្ធផលនៃវិស្វកម្ម ដើម្បីផ្តល់ផលិតផល និងសេវាកម្ម ដែលត្រូវការជាចាំបាច់។តំបន់ដីសើម និងទឹក គឺជាផ្នែកគន្លឹះមួយនៃការវិភាគ MA ហើយសារគន្លឹះជាច្រើនដែលផ្អែកលើភស្តុតាង ត្រូវបានចម្រាញ់យកសម្រាប់អ្នកកសាងគោលនយោបាយ។ ឧទាហរណ៍ ដោយកត់សំគាល់ និងស្វែងយល់អំពីការសម្រេចខាងគោលនយោបាយដែលបានធ្វើឡើង មានការពាក់ព័ន្ធជាមួយការដេញដូរ រវាងផលិតកម្មកសិកម្ម និងគុណភាពទឹកការប្រើប្រាស់ដី និងជីវៈចម្រុះការប្រើប្រាស់ទឹក និងជីវៈចម្រុះក្នុងទឹក និងការប្រើប្រាស់ទឹកក្នុងពេលបច្ចុប្បន្ននេះសម្រាប់ការស្រោចស្រព និងផលិតកម្មកសិកម្មទៅអនាគត។

## ៣.៤.៦ ការប្រើប្រាស់ឧបករណ៍មួយចំនួន

គេមានឧបករណ៍ជាច្រើនសម្រាប់គាំទ្រឲ្យមានការចរចាអំពីទឹក ដែលរួមទាំងការវិភាគអំពីអ្នកពាក់ព័ន្ធនានា ដូចដែលបានបង្ហាញជូនពីខាងដើម ការប៉ាន់ប្រមាណទូលំទូលាយ និងសេណារីយ៉ូ។ ឧបករណ៍ដទៃទៀតក៏ត្រូវបានស្វែងយល់ផងដែរ នៅក្នុងសៀវភៅរួមផ្សំ ដើម្បីចរចា ដូចជា លំហូរ ការបង់ថ្លៃ ការចែករំលែក និងបទបញ្ញា។[41]

លំហូរ បង្ហាញដល់អ្នកប្រើប្រាស់អំពីសារៈសំខាន់ជាយុទ្ធសាស្រ្តនៃលំហូរបរិស្ថាន។ ការអនុវត្តលំហូរបរិស្ថាន ទាមទារឲ្យមានការបង្កើតរបបលំហូរទឹក ដែលទទួលស្គាល់អំពីតម្រូវការសម្រាប់ប្រព័ន្ធអេកូឡូស៊ី ទន្ទឹមនឹងកិច្ចប្រឹងប្រែងដើម្បីបំពេញតាមតម្រូវការខាងសង្គម និងសេដ្ឋកិច្ចផងដែរ (សូមអានករណី៣.៩)។ ឯកសារលំហូរ ស្វែងយល់អំពីរបៀបដែលសង្គមមនុស្សកំណត់ និយមន័យអំពីលក្ខខណ្ឌលំហូរការកែតម្រូវនានា ដែលអាចចាំបាច់សម្រាប់បែបផែន និងប្រតិបត្តិការនៃហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ និងការលើកទឹកចិត្ត ក្របខ័ណ្ឌគោលនយោបាយនិងច្បាប់ និងភាពចាំបាច់ដើម្បីបង្កើតនិងរក្សាចលនាខាងនយោបាយ។ ការងារលំហូរបរិស្ថានទាមទារឲ្យមានសមាហរណកម្មនៃមុខវិជ្ជាយ៉ាងច្រើនដែលរួមទាំងវិស្វកម្ម ច្បាប់ អេកូឡូស៊ី សេដ្ឋកិច្ច ជលសាស្រ្ត វិទ្យាសាស្រ្តនយោបាយ និងការប្រាស្រ័យទាក់ទងផងដែរ។ អភិក្រម MSP មួយមានលក្ខណៈសមស្របបំផុតសម្រាប់ជាមូលដ្ឋាននៃការចរចា និងការធ្វើសេចក្តីសម្រេចអំពីថាតើមនុស្សបង្កការរំខានបែបណាមកលើរបបលំហូរដោយធម្មជាតិ។

*ករណី៣.៩៖ ការចរចាអំពីលំហូរបរិស្ថាននៅអាងទន្លេសេនេហ្កាល់*

កិច្ចសហប្រតិបត្តិការឆ្លងដែននៅក្នុងអាងទន្លេសេនេហ្កាល់បាននាំមុខដោយ “អង្គការអភិវឌ្ឍន៍អាងទន្លេសេនេហ្កាល់” (OMVS) ដែលផ្តល់វេទិកាមួយសម្រាប់កិច្ចប្រឹងប្រែងរួមគ្នាពីសំណាក់ប្រទេសម៉ាលីម៉ូរីទីណា និងសេនេហ្កាល់ (និងនៅពេលថ្មីៗនេះ ប្រទេសហ្គីណេដែលស្ថិតនៅខ្សែទឹកខាងលើ) ដើម្បីឆ្លើយតបទៅនឹងការប្រឈមនានានៃការអភិវឌ្ឍ ក្នុងពេលប្រតិបត្តិការលើការងារគ្រប់គ្រងធនធានទឹកចម្រុះ។

នៅឆ្នាំ ២០០២ ប្រទេសជាសមាជិក OMVS បានអនុម័តធម្មនុញ្ញទឹកក្នុងអាងទន្លេនេះជាលើកដំបូងពុំធ្លាប់មានពីមុនមក នៅក្នុងតំបន់អាហ្វ្រិកក្បែរសាហារ៉ា ដែលបាននាំមុខនៅក្នុងឆ្នាំ ២០០០ ដោយការបង្កើតមណ្ឌលសង្កេតការណ៍មួយខាងបរិស្ថានដែលមានភារកិច្ចទទួលខុសត្រូវលើការពិនិត្យតាមដានស្ថានភាពបរិស្ថាននៅក្នុងអាងទន្លេនេះ និងផលប៉ះពាល់នៃអន្តរាគមន៍អភិវឌ្ឍន៍។ ធម្មនុញ្ញនេះ និងមណ្ឌលសង្កេតការណ៍ បានកើតចេញពីដំណើរការមួយដែលមានរយៈពេលពីរទសវត្សរ៍ និងដែលបង្ហាញឡើងតាមរយៈការសិក្សានិងការជជែកវែកញែកនានាអំពីវិធីសមស្របបំផុតនៃការគ្រប់គ្រងទឹកទន្លេ និងការវិនិយោគលើគម្រោងហេដ្ឋារចនាសម្ព័ន្ធទឹកធំៗ។

គោលបំណងនៃធម្មនុញ្ញនេះ គឺផ្តល់ឲ្យមានវិភាជន៍ទឹកប្រកបដោយប្រសិទ្ធភាពសម្រាប់ទន្លេ សេនេ-ហ្កាល់ ក្នុងចំណោមវិស័យខុសៗគ្នាជាច្រើន ដូចជា ការប្រើប្រាស់តាមផ្ទះ, ការផ្គត់ផ្គង់ទឹកតាមទីក្រុង និងជនបទ ការស្រោចស្រព និងកសិកម្ម ការផលិតវារីអគ្គិសនី នាវាចរ ជលផល ទន្ទឹមនឹងផ្តោតការយកចិត្តទុកដាក់លើកម្រិតអប្បបរមានៃលំហូរនៅក្នុងទន្លេ និងកិច្ចការបរិស្ថានផ្សេងទៀតផងដែរ។ វាក៏បង្កើតជាដំណើរការមួយសម្រាប់អនុម័តគម្រោងថ្មីៗដែលអាចមានផលប៉ះពាល់ធ្ងន់ធ្ងរមកលើវិស័យទាំងនោះផងដែរ ដោយផ្អែកលើការផ្តល់ព័ត៌មានដល់អ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់ជាមួយ អ្នកពាក់ព័ន្ធទាំងអស់នៅតាមដងទន្លេដែលរួមទាំងអ្នកប្រើប្រាស់នៅក្នុងមូលដ្ឋានផងដែរ។

ធម្មនុញ្ញនេះបានផ្អែកលើការវិភាគពិស្តារអំពីឥទ្ធិពលនានានៃទំនប់ ឌីយ៉ាម៉ា និង ម៉ាណាន់តាលី និងការស្វែងយល់អំពីជម្រើសជំនួសនានាធៀបនឹងប្រតិបត្តិការរបស់ពួកគេនៅក្នុងពេលបច្ចុប្បន្ននេះផង

ដែរ។ ការសិក្សានានាបានបង្ហាញឲ្យដឹងអំពីអត្ថប្រយោជន៍ជាច្រើន និងខុសៗគ្នា នៃប្រព័ន្ធជំនន់តាមធម្មជាតិ ដែលទាក់ទងនឹងតំបន់ដីសើម ជលផល កសិកម្ម ការចិញ្ចឹមសត្វ ព្រៃឈើ និងការផ្តល់ទឹកក្រោមដី ដែលជាអត្ថប្រយោជន៍ចាំបាច់ ដោយត្រូវគិតបញ្ចូលនៅក្នុងប្រតិបត្តិការទំនប់ផងដែរ និងនៅក្នុងការកសាងផែនការសម្រាប់អន្តរាគមន៍អភិវឌ្ឍន៍ទៅអនាគត។ ប្រការនេះមានសារៈសំខាន់ជាសារវន្តដោយសារអ្នករងគ្រោះភាគច្រើន ពឹងផ្អែកជាខ្លាំងលើការធ្វើអាជីវកម្មធនធានធម្មជាតិដែលអាស្រ័យនឹងទឹក (កសិកម្មតាមប្រពៃណី ជលផល ការចិញ្ចឹមសត្វ និងការធ្វើអាជីវកម្មព្រៃឈើ និងផលិតផលពីតំបន់ដីសើម)។

ជាលទ្ធផល ធម្មនុញ្ញទឹករួមបញ្ចូលមាត្រាជាក់លាក់សម្រាប់ការបើកទឹកចេញពីទំនប់ ដើម្បីជួយស្តារទំនាបលិចទឹក និងការបង្កើតឲ្យមានជំនន់ប្រចាំឆ្នាំ អាស្រ័យហេតុនេះជាការទទួលស្គាល់អំពីគុណតម្លៃនៃប្រព័ន្ធអេកូឡូស៊ីទំនាបលិចទឹក និងយុទ្ធសាស្រ្តចិញ្ចឹមជីវិតតាមប្រពៃណី។[42]

*"គេត្រូវស្វែងរកអនុសាសន៍ដែលអាចប្រើការបានសម្រាប់ចំណាត់ការដែលផ្តល់ផល"*

## *៣.៤.៧ អនុសាសន៍ដើម្បីចំណាត់ការ*

ខ្លឹមសារនៃ MSP ត្រូវផ្តល់អនុសាសន៍សម្រាប់ចំណាត់ការ។ គេពុំចាំបាច់បង្កើតឲ្យមានការឯកភាពមតិឡើយ ប្រសិនបើមិនអាចឈានដល់ការឯកភាពមតិទេនោះ គេត្រូវស្វែងរកអនុសាសន៍ដែលអាចប្រើការបានសម្រាប់ចំណាត់ការទៅខាងមុខ បើពុំនោះទេ MSP នោះអាចបញ្ចប់ដោយពុំមានអ្វីច្រើនជាងការពិភាក្សាដែលជាទីចាប់អារម្មណ៍នោះឡើយ។ ប្រសិនបើផ្តល់នូវភាពអង់អាចដើម្បីធ្វើបែបនោះបាន MSP នឹងអាចបង្កើត និងអនុវត្តសេចក្តីសម្រេចនានាផងដែរ ប៉ុន្តែប្រការនេះអាស្រ័យលើវិសាលភាពនៃអាណត្តិ។ គណៈកម្មការពិភពលោកស្តីពីទំនប់ (WCD)(សូមអាន ករណី ៣.១០) គឺជាឧទាហរណ៍មួយនៃMSPមួយដែលផ្តល់អនុសាសន៍ទូលំទូលាយសម្រាប់ចំណាត់ការ ដោយពុំទាមទារឲ្យមានសមត្ថកិច្ចធ្វើសេចក្តីសម្រេចឡើយ។

*ករណី៣.១០៖ គណៈកម្មការពិភពលោកស្តីពីទំនប់*

ជៀសវាងការលើកផែនការ សាងសង់ ជំទាស់ ដាក់ឲ្យប្រតិបត្តិការ កំទេចចោល បញ្ឈប់ការប្រើប្រាស់ លើកស្នើ ប្រឆាំង ឬពិភាក្សាអំពីទំនប់មួយ ដោយគ្មានទំនប់! រហូតដល់ឆ្នាំ ២០០០ ពិភពលោកបានសាងសង់ទំនប់ខ្នាតធំចំនួន ៤៥.០០០ សម្រាប់ស្រោចស្រពមួយភាគបីនៃផ្ទៃដីដំណាំសរុប ផលិតមួយភាគប្រាំនៃថាមពលសរុប គ្រប់គ្រងជំនន់នៅក្នុងរដូវវស្សា និងតំកល់ទឹកទុកសម្រាប់រដូវប្រាំង។ ប៉ុន្តែនៅក្នុងសតវត្សរ៍កន្លងទៅនេះ ទំនប់ខ្នាតធំក៏បានរំខានដល់អេកូឡូស៊ីនៃទន្លេចំនួនច្រើនជាងពាក់កណ្តាលផងដែរ នៅលើពិភពលោក ធ្វើឲ្យមនុស្សច្រើនជាង៤០លាននាក់ ចាកចោលផ្ទះសំបែង និងបន្សល់ទុកនូវបំណុលសម្រាប់ប្រទេសនានា (Earthscan បានឃោសនាសម្ភារៈដោយផ្សព្វផ្សាយរបាយការណ៍របស់ WCD)។

គណៈកម្មការពិភពលោកស្តីពីទំនប់ (WCD) គឺជា MSP កម្រិតខ្ពស់មួយ ដែលបានកើតចេញពីកំណើនការរិះគន់ជាសាធារណៈលើទំនប់ខ្នាតធំ។ ដំណើរការនេះមានគោលដៅធ្វើការពិនិត្យឡើងវិញ [sic: ហ្មត់ចត់]ទូលំទូលាយមួយ អំពីប្រសិទ្ធភាពអភិវឌ្ឍន៍នៃទំនប់ខ្នាតធំ ដើម្បីប៉ាន់ប្រមាណអំពីជម្រើសជំនួស និងលើកស្នើគោលការណ៍ណែនាំជាក់ស្តែងសម្រាប់ការធ្វើសេចក្តីសម្រេចទៅអនាគត។ WCD បានប៉ុនប៉ងអនុវត្តដំណើរការសិក្សាជាគំរូមួយដែលមានលក្ខណៈជាការពិចារណារបស់ពហុអ្នកពាក់ព័ន្ធ។ រដ្ឋាភិបាលចូលរួម ប៉ុន្តែបានប្រកាន់ជំហរដូចជាសង្គមស៊ីវិលដែរ។ មានអ្នកដើរតួជាច្រើនចូលរួមនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងអន្តរជាតិ ពោល

គឺ "ប្រតិបត្តិករខាងផ្នែកទំនប់ សេដ្ឋវិទូ សង្គមវិទូ អ្នកឯកទេសអេកូឡូស៊ី អ្នកវិទ្យាសាស្ត្រនយោបាយ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។ ដំណើរការនេះបានទទួលការគាំទ្រជាសាធារណៈទូលំទូលាយនិងការទទួលស្គាល់ជាអន្តរជាតិផងដែរ។ តាមសំដីរបស់ខ្លួន ដំណើរការនេះបានផ្តល់នូវវេទិកាដោយឡែកមួយសម្រាប់ការស្វែងយល់អំពីជម្រើសស្មុគស្មាញនានាដែលប្រឈមចំពោះសង្គមមនុស្ស នៅក្នុងការបំពេញតាមតម្រូវការរបស់ពួកគេខាងផ្នែកទឹក និងថាមពល"។

សមាជិកគណៈកម្មការ WCD បានបង្កើតរបាយការណ៍ "ឯកភាពមតិ" មួយ ដែលជាវិភាគទានខាងព័ត៌មាន និងអំពីការចរចា ដែលត្រូវបានប្រកាសនៅក្នុងចំណោមសាធារណជនយ៉ាងច្រើននៅក្នុងឆ្នាំ ២០០០ ដែលបង្កឲ្យមានចម្លើយតបជាច្រើន។[43] តាំងពីពេលនោះមក "ក្របខ័ណ្ឌសម្រាប់ការសម្រេចរបស់ WCD" ត្រូវបានលើកយកមកវាយតម្លៃ សម្រាប់ការប្រើប្រាស់ជាឧបករណ៍អនុវត្ត និងឧបករណ៍តស៊ូមតិ។ វាមានលក្ខណៈស្មុគស្មាញ។ ក្របខ័ណ្ឌនេះរួមបញ្ចូល និយាមសកលលោកជាមូលដ្ឋានគ្រឹះចំនួនបី គុណតម្លៃស្នូលចំនួនប្រាំ ចំណុចសម្រេចជាគន្លឹះចំនួនប្រាំ អាទិភាពយុទ្ធសាស្ត្រចំនួនប្រាំពីរ គោលការណ៍ចំនួន ៣៣ ដែលពាក់ព័ន្ធនឹងគោលនយោបាយ និងគោលការណ៍ណែនាំចំនួន ២៦។ កិច្ចខិតខំការប្រឹងប្រែងដើម្បីដាក់បញ្ចូលយោបល់ណែនាំទាំងនេះបញ្ចូលគ្នា នៅតែជាការប្រឈមមួយសម្រាប់សកម្មភាពនៅក្រោយ WCD។

ក្រោយការចេញផ្សាយរបាយការណ៍ WCD មានសកម្មភាពជាបន្តជាច្រើន ដែលរួមទាំង MSPs ដែលបានអនុវត្តនៅជុំវិញពិភពលោកផងដែរ។ ការសន្ទនាអំពីទំនប់ និងការអភិវឌ្ឍនៅនេប៉ាល់[44] គឺគ្រាន់តែជាឧទាហរណ៍មួយ ដែលអ្នកពាក់ព័ន្ធខុសៗគ្នាបានប្រមូលផ្តុំ និងព្យាយាមអស់រយៈពេលជាច្រើនឆ្នាំ ដើម្បីស្វែងយល់អំពីបញ្ហារសើបនៃទំនប់ខ្នាតធំនៅក្នុងបរិបទនៃប្រទេសនេប៉ាល់។

## *៣.៥ សមិទ្ធផល និងឥទ្ធិពល*

មានសមិទ្ធផលជាច្រើនដែលអាចកើតចេញពី MSPs ដែលបានគ្រប់គ្រងដោយជោគជ័យសម្រាប់អាន និងឆ្លើយតបទៅនឹងបរិបទនេះបង្កើតដំណើរការសមស្រប និងមានសុវត្ថិភាពមួយ និងបង្ហាញជាទូទៅអំពីសំណុំលក្ខណៈដែលជាការចង់បាន ដូចដែលបានគូសបញ្ជាក់នៅក្នុងផ្នែកខាងមុខរួចមកហើយ។

នៅកន្លែងខ្លះ អភិក្រម MSP បានក្លាយជាទម្លាប់ធម្មតាទៅហើយ ប៉ុន្តែនៅកន្លែងដទៃទៀត MSP មួយគឺជាលទ្ធភាពថ្មីមួយ។ នៅក្នុងឧទាហរណ៍មួយមកពីប្រទេសប៉េរូ មានការអះអាងថា MSP មួយ បានផ្តល់បទពិសោធន៍វិជ្ជមាន និង "ដែលពុំធ្លាប់មានពីមុនមក"៖ "វេទិកាពហុអ្នកពាក់ព័ន្ធ គឺជាយន្តការដែលពុំធ្លាប់មានពីមុនមកទេនៅក្នុងប្រទេសនេះ។ ប្រវត្តិរបស់ខ្លួនប៉េរូ បានបង្កើតឲ្យមានវប្បធម៌មួយ ដោយផ្អែកលើការប្រឈមមុខដាក់គ្នា ជាងផ្អែកលើការចរចា។ ដូច្នេះ បទពិសោធន៍នានា ដូចជា បទពិសោធន៍ពីយ៉ាគុនជីក មានន័យថាជា "ការរៀនធ្វើការចរចា" ក្រោយប្រពៃណីយ៉ាងវែងមួយនៃការគ្របសង្កត់ ការចុះញ៉ម និងអំពើហឹង្សា"។ (MSP "យ៉ាគុនជីក" បន្ទាប់ពីពាក្យ គេចា ដែលមានន័យថា "ទឹករបស់យើង" ត្រូវបានបង្កើតឡើងនៅចុងឆ្នាំ ១៩៩៨ នៅតំបន់ខ្ពង់រាបនៃប្រទេសប៉េរូ)។

មានការអះអាងបន្ថែមទៀតថា ៖ "ដោយសារតែកិច្ចផ្តួចផ្តើមនៅក្នុងវេទិកានេះ ការស្រោចស្រពត្រូវបានបញ្ចូលទៅក្នុងវេទិកាប្រចាំតំបន់ និងបាននាំឲ្យមានការពិភាក្សាអំពីកិច្ចការដទៃទៀតផងដែរ ដូចជាទំនាក់ទំនងរវាងជនបទនិងទីក្រុង ការចរចាដោះស្រាយទំនាស់ បញ្ហាដែលទាក់ទងនឹងការចាត់ចែងនិងស្ថាប័នគ្រប់គ្រងទឹក និងការអភិវឌ្ឍន៍ជនបទ។ ម្យ៉ាងទៀត វេទិកានេះក៏រួមចំណែកមិនត្រឹមតែក្នុងការបង្កើតឲ្យមានរចនាសម្ព័ន្ធសង្គមថ្មីមួយប៉ុណ្ណោះទេ ប៉ុន្តែក៏ធ្វើឲ្យរបៀបវារៈនៃការអភិវឌ្ឍន៍នៅកម្រិតតំបន់ ត្រូវបានលើកឡើងមកពិភាក្សាវិញផងដែរ។"

នៅទីនេះមានការប៉ុនប៉ងដើម្បីអះអាងផងដែរថាបទពិសោធន៍ពី MSPs សុទ្ធតែមានលក្ខណៈវិជ្ជមានប៉ុន្តែ

មានការសិក្សាពីមេរៀននានា មានភស្តុតាងគ្រប់គ្រាន់មកពីជុំវិញពិភពលោក ដើម្បីសន្និដ្ឋានដូចតទៅ ៖

- MSPs អាចនាំទៅរកការពង្រីកតំណាង និងការចូលរួមរបស់អ្នកពាក់ព័ន្ធនានានៅក្នុងអភិបាលកិច្ច ដែលអាចនាំឲ្យមានកំណើននិត្យានុកូលភាពនៃសេចក្តីសម្រេចជាសាធារណៈផងដែរ។
- MSPs អាចផ្តល់កាលានុវត្តភាពកាន់តែច្រើនឡើង សម្រាប់សេចក្តីថ្លែងការណ៍ និងនិយាមនានា ដែលត្រូវប្រកាស និងជំទាស់ ដែលធានាថា ទស្សនទានថ្មីៗ និងចាស់ ត្រូវបានពិនិត្យដោយផ្អែកលើសមិទ្ធផលនៃ MSPs ទាំងនោះ។
- MSPs អាចជួយឲ្យមានការទទួលស្គាល់ និងការស្វែងយល់អំពីការពឹងផ្អែកលើគ្នាទៅវិញទៅមក។ការរៀនសូត្រក្នុងសង្គមអំពីការពឹងផ្អែកលើគ្នាទៅវិញទៅមក មានសារៈសំខាន់ជាស្នូល ក្នុងចំណោមអ្នកពាក់ព័ន្ធនានា ដែលច្រើនតែមានគុណតម្លៃ ឆន្ទៈការយល់ឃើញ និងអាទិភាពខុសៗគ្នា។[45]
- MSPs ជួយឲ្យមានការឆ្លុះបញ្ចាំងពីសំណាក់តំណាងនានាមកពីមណ្ឌលខុសៗគ្នា ការគូសបញ្ជាក់អំពីកិច្ចព្រមព្រៀងដែលមានស្រាប់ និងភាពខុសគ្នាក្នុងចំណោមអ្នកពាក់ព័ន្ធនានា និងបង្កើតស្មារតីជាសមូហភាព។
- MSPs អាចជួយឲ្យមានការពិចារណាក្លាយជាកិច្ចការដែលអនុវត្តជាប្រចាំ អាចឲ្យមានការពិនិត្យមើលយ៉ាងម៉ត់ចត់លើបញ្ហាស្មុគស្មាញនានា។
- MSPs បង្កើនទិដ្ឋភាពនៃការចរចា ដែលមានការយល់ដឹងបានច្រើនជាងមុន។
- ដោយមានការផ្តល់ជាលំនាំផ្លូវមួយសម្រាប់ការពិចារណា MSPs អាចនាំទៅរកការសម្រេចចិត្ត ការព្រមព្រៀង និងការអនុវត្តដែលប្រសើរជាងមុន។

MSPs អាចជាការបំពេញបន្ថែមរួមគ្នាដ៏មានតម្លៃ សម្រាប់គ្រប់គ្រងទឹក នៅពេលដែលបញ្ហានេះមានលក្ខណៈស្មុគស្មាញ។ គេត្រូវតែសង្កត់ធ្ងន់ថា MSPs គឺជាការបំពេញបន្ថែមមួយចំពោះទម្រង់ដទៃទៀតនៃអភិបាលកិច្ច ប៉ុន្តែមិនមែនជាការជំនួស និងមិនមែនជាឱសថទិព្វឡើយ។ វាមានសក្តានុពលសម្រាប់ការប្រើប្រាស់ឲ្យបានទូលំទូលាយ។

ការបង្កើតចំណងទាក់ទងរវាងការជូនដំណឹងដល់ការកសាងគោលនយោបាយ និងដំណើរការស្វែងរកការសម្រេចចិត្តនៅក្នុង MSPs ការកសាងគោលនយោបាយ និងការធ្វើសេចក្តីសម្រេច នៅតែជាកិច្ចការជំនាញមួយ។ ទោះជាយ៉ាងណាក៏ដោយ តាមរយៈការចង់ឲ្យមានការពិចារណា MSPs អាចផ្តល់ឲ្យប្រជាពលរដ្ឋដែលមានសុច្ឆន្ទៈនូវឱកាសប្រសើរជាងមុន ក្នុងការមានឥទ្ធិពលប្រកបដោយការស្តាប់នាមកលើការសម្រេចនានា ដែលមានឥទ្ធិពលមកលើការរស់នៅរបស់ពួកគេ។

ជំពូក ៩ ផ្តល់ការណែនាំអំពីការបង្កើតឲ្យមានការឯកភាពមតិ ពោលគឺធាតុដែលពិបាកយល់ ប៉ុន្តែជាធាតុគន្លឹះនៃ MSPs។ ការបង្កើត និងការប្រព្រឹត្តទៅរបស់ MSPs និងការឈានទៅបង្កើតការឯកភាពមតិ គឺជាផ្នែកស្នូលមួយនៃការចូលរួមប្រកបដោយការស្តាបនា ការកែលម្អដំណើរការចរចា និងការឈានទៅរកការគ្រប់គ្រងទឹកបានស្មើភាព និងមានប្រសិទ្ធភាពជាងមុន។

*" MSPs គឺជាការបំពេញបន្ថែមលើទម្រង់ដទៃទៀតនៃអភិបាលកិច្ចប៉ុន្តែមិនមែនជាការជំនួស និងជាឱសថទិព្វឡើយ"*


MEKONG RIV
CONGO RIVE
AMAZON RIV

## ជំពូក ៤

# ការបង្កើតឲ្យមានការឯកភាពមតិ

## ៤.១ ការកែលម្អលើទម្លាប់នៃការចរចា

នៅក្នុងតំបន់ជាច្រើនលើពិភពលោកមានការចរចាជាច្រើនកំពុងតែធ្វើឡើង ដែលទាក់ទងនឹងការគ្រប់គ្រងធនធានទឹក។ ការចរចាទាំងនេះពិនិត្យមើលការសម្រេចនានាអំពីវិភាជន៍ទឹក ក៏ដូចជា វិធានការនានាដែលគួរតែធ្វើឡើង ដើម្បីធានារក្សាគុណភាពនិងវត្តមានទឹកផងដែរ។ ជាសំណាងអាក្រក់ការចរចាទាំងនេះជាច្រើនមិនបានបង្កើតចេញជាកិច្ចព្រមព្រៀងដែលស្មើភាព មានប្រសិទ្ធភាព ស្ថេរភាព និងវាងវៃឡើយ។[46] ផ្នែកមួយនៃបញ្ហានេះគឺដោយសារតែកម្រិតខ្ពស់នៃភាពមិនប្រាកដប្រជាខាងវិទ្យាសាស្ត្រ និងបច្ចេកទេសនៅក្នុងការចរចាពហុភាគី ជាពិសេសបញ្ហាជាច្រើនធ្វើឲ្យការចរចាកាន់តែលំបាក។ វាក៏ដោយសារតែមានអ្នកពាក់ព័ន្ធ និងមន្ត្រីជាច្រើនមិនបានអនុវត្តទម្លាប់ល្អក្នុងការរៀបចំនៃការជជែកពិភាក្សា។

ជំពូកនេះផ្តល់ការណែនាំដល់ភាគីនានា ដែលពាក់ព័ន្ធនឹងការចរចា ដែលកំពុងដំណើរការទាក់ទងនឹងវិធីនានាដែលអាចបង្វែរពីបច្ចេកទេសតថ្លៃតឹងតែង ដែលតំណាងឲ្យការចរចា (មិនផ្តល់ប្រយោជន៍) ភាគច្រើនទៅរកអភិក្រមនៃការបង្កើតឲ្យមានការឯកភាពមតិដែលទំនងជាមានប្រសិទ្ធភាពជាង។

ដើម្បីសម្រេចបាននូវទម្លាប់អនុវត្តល្អ គេត្រូវឆ្លើយសំណួរសំខាន់ៗចំនួនប្រាំមួយ ៖

១) តើហេតុអ្វីដែលធ្វើឲ្យមានការលំបាកក្នុងការឈានដល់កិច្ចព្រមព្រៀងអំពីទឹកឲ្យមានសមធម៌ និងនិរន្តរភាព?

២) តើមានយុទ្ធសាស្ត្រ អ្វីខ្លះសម្រាប់អ្នកពាក់ព័ន្ធនានា និងអ្នកគ្រប់គ្រងប្រើប្រាស់នៅក្នុងវិវាទអំពីទឹក?

៣) តើគួរប្រើប្រាស់អភិក្រមសម្រាប់បង្កើតការឯកភាពមតិនៅពេលណា និងដោយរបៀបណា ដើម្បីធ្វើការសម្រេច បង្កើតកិច្ចព្រមព្រៀង និងអនុវត្តភាពជាដៃគូ?

៤) តើត្រូវប្រើប្រាស់ការសម្របសម្រួល ឬ ផ្សះផ្សារ (ពោលគឺ សេវាកម្មរបស់អ្នកជំនាញអាជីពដែលមានអព្យាក្រឹត្យ) នៅពេលណា និងដោយរបៀបណា?

៥) តើអាចធ្វើអ្វីខ្លះ ដើម្បីធ្វើឲ្យអ្នកចរចារក្សាបានតាមការប្តេជ្ញា ដែលពួកគេបានធ្វើឡើង?

៦) តើអង្គការនានាដែលពាក់ព័ន្ធនៅក្នុងការចរចាអំពីទឹកគួរធ្វើបែបណា ដើម្បីកសាងសមត្ថភាពចរចារបស់ពួកគេជាបន្តបន្ទាប់?

## ៤.២ ហេតុអ្វីអភិក្រមធម្មតានៅក្នុងការចរចាអំពីទឹកច្រើនតែបរាជ័យ

ការចរចាពហុភាគីនៅក្នុងវេទិកាសាធារណៈក្នុងប្រទេសនានា ឬរវាងប្រទេសនានា ច្រើនតែបរាជ័យដោយសារតែមានភាគីមិនសមស្របនៅក្នុងតុចរចា ដំណើរការនៃការចរចាត្រូវបានបង្កើតឡើងមិនសមស្រប និងគ្រប់គ្រងមិនបានល្អ ឬកិច្ចព្រមព្រៀងមិនបានរួមបញ្ចូលអភិក្រមបន្សាំសម្រាប់គ្រប់គ្រងធនធានដែលអាចឆ្លើយតបទៅនឹងលក្ខខណ្ឌដែលប្រែប្រួល និងភាពមិនប្រាកដប្រជាខាងវិទ្យាសាស្ត្រ។

នៅពេលមានតែមន្ត្រីជាប់ឆ្នោត និងមន្ត្រីតែងតាំងជាន់ខ្ពស់ និងមិនមែនតំណាងអ្នកពាក់ព័ន្ធទាំងអស់ (ដែលតែងតាំងខ្លួនឯង) នៅក្នុងតុចរចា ការចរចានានាទំនងជាមើលរំលងព័ត៌មានសំខាន់ៗ ឬ បោះបង់ចោលនិត្យានុកូលភាពចាំបាច់សម្រាប់ការអនុវត្តឲ្យមានប្រសិទ្ធភាព។ នៅក្នុងកិច្ចប្រឹងប្រែងដើម្បីបង្កើន "ភាពគ្រប់គ្រងបាន" នៃដំណើរការចរចា មន្ត្រីសាធារណៈច្រើនតែកំហិតលើចំនួនភាគីពាក់ព័ន្ធដែលត្រូវចូលរួម ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើជ្រើសរើសយកតែ "គណៈកម្មាធិការពណ៌បៃតង" សមាជិកភាពអាចមិនមានគ្រប់គ្រាន់ ដើម្បីផ្ដល់ការយកចិត្តទុកដាក់បានគ្រប់គ្រាន់លើគ្រប់ការជជែកពិភាក្សាទាំងមូល ទាំងខាងវិទ្យាសាស្ត្រ និងបច្ចេកទេស និងបទពិសោធន៍នៅតាមមូលដ្ឋាន។ ហើយប្រសិនបើមានតែអ្នកបច្ចេកទេស(ពោលគឺមន្ត្រីបច្ចេកទេសដែលបានទទួលការតែងតាំង)បានចូលរួមកិច្ចព្រមព្រៀងដែលអាចកើតឡើងទំនងជាឆ្លើយតបមិនបានគ្រប់គ្រាន់ទៅនឹងការជជែកពិភាក្សាខាងនយោបាយ ឬការជជែកពិភាក្សានៅមូលដ្ឋាន។ អ្នកពាក់ព័ន្ធនានា ដែលរួមទាំង ក្រុមអ្នកតស៊ូមតិ តំណាងសហគមន៍ មេដឹកនាំធុរកិច្ច និងអ្នកជំនាញការវិទ្យាសាស្ត្រឯករាជ្យ សុទ្ធតែមានឯកទេស ឬចំណេះដឹង "របស់ជនជាតិដើម" ក៏ដូចជា ភាពរសើបខាងនយោបាយ ដែលត្រូវការជាចាំបាច់សម្រាប់បង្កើតកិច្ចព្រមព្រៀង ឬគោលនយោបាយនានា តាមទម្រង់ដែលមានតុល្យភាពសមស្របផងដែរ។ លើសពីនេះ លើកលែងតែអ្នកពាក់ព័ន្ធទាំងអស់មានវត្តមាននៅក្នុងកិច្ចព្រមព្រៀងអំពីទឹក បើពុំនោះទេការអនុវត្តន៍អាចត្រូវចំណាយកាន់តែច្រើន និងកាន់តែលំបាក ដោយសារក្រុមដែលអល់ឯក ឬដែលមិនសប្បាយចិត្ត ធ្វើការដេញដោលពួកគេ ឬព្យាយាមរារាំងការអនុវត្ត ឬ តែងតែជំទាស់ទៅនឹងអ្វីដែលបានសម្រេចរួចទៅហើយ (ឧទាហរណ៍ សូមអានករណី ៤.២ ស្ដីពី អេវើហ្គេត ហ្វ្លរីដា)។ មានតែនៅពេលដែលភាគីពាក់ព័ន្ធមានការពាក់ព័ន្ធដោយផ្ទាល់ទើបកិច្ចព្រមព្រៀងដែលកើតឡើង ផ្អែកលើចំណេះដឹងសមស្រប និងបានទទួលសិទ្ធិសមស្របខាងនយោបាយ ដើម្បីធានាឲ្យមានការគោរពតាមដោយស្ម័គ្រចិត្ត។

*"ការចរចាពហុភាគីនៅក្នុងវេទិកាសាធារណៈច្រើនតែបរាជ័យដោយសារតែមានភាគីមិនសមស្រប នៅក្នុងតុចរចានោះ"*

ភាគច្រើននៃការចរចាអំពីទឹកពិចារណាបញ្ហាតែមួយនៅក្នុងពេលណាមួយ។ នេះអាចជាកំហុសឆ្គង។ ជាញឹកញាប់ គេអាចទទួលបានកិច្ចព្រមព្រៀងមួយនៅពេលមានការដោះដូររវាងបញ្ហាខុសៗគ្នាជាច្រើន។ ពោលគឺ លើកលែងតែក្រុមនីមួយៗដឹងថា ខ្លួនបានទទួលផលប្រយោជន៍ដែលខ្លួនគិតថាសំខាន់បំផុត បើពុំនោះទេ ពួកគេមិនទំនងជាឆ្លើយតបដោយអនុគ្រោះទៅនឹងសំណើនានាពីអ្នកចរចារបស់ភាគីផ្សេងឡើយ សូម្បីតែទាក់ទងនឹងបញ្ហាដែលខ្លួនគិតថាមិនសូវសំខាន់ក៏ដោយ។ ដូច្នេះ ការដោះដូរ គឺជាគន្លឹះដើម្បីបង្កើតគុណតម្លៃនៅក្នុងការចរចានានា។[47]

របៀបវារៈនៃការចរចា គួរតែបានកំណត់តាមទម្រង់មួយដែលធានាថា អ្នកចូលរួមទាំងអស់ដែលយល់ឃើញថា បញ្ហានានាដែលជាចំណាប់អារម្មណ៍របស់ខ្លួនត្រូវបានដោះស្រាយជាផ្នែកមួយក្នុងកញ្ចប់នៃដំណោះស្រាយនេះ។ ប្រការនេះនឹងមិនកើតឡើងឡើយ ប្រសិនបើវេទិកានៃការចរចាលើកយកតែកង្វល់នយោបាយបន្ទាន់បំផុតនៅក្នុងសម័យកាលនោះ ពោលគឺភាពបន្ទាន់នៃការគ្រប់គ្រងធនធានដែលងាយមើលឃើញបំផុត ឬ បញ្ហាណាក៏ដោយ ដែលជាកង្វល់ខ្ពស់បំផុតរបស់សមាជិកដែលមានអំណាចនយោបាយខ្លាំងបំផុតនៅក្នុងក្រុមនេះ។ កង្វល់ទាំងអស់របស់ក្រុមនេះទាំងមូល ត្រូវតែលើកយកមក

ពិចារណាជាមួយគ្នា។ ក្រុមនេះទាំងមូលត្រូវតែពាក់ព័ន្ធនៅក្នុងការបង្កើតរបៀបវារៈសម្រាប់រយៈពេលវែង (និងគោរពទៅតាមរបៀបវារៈនោះ) ហើយមិនគួរធ្វើការចរចាដែលទងនឹងបញ្ហាណាមួយឡើយ រហូតដល់ពេលមានការស្វែងយល់អំពីកញ្ចប់បញ្ហាជាច្រើន។ ការពិនិត្យមើលបញ្ហាតែមួយនៅក្នុងពេលមួយ ដែលផ្ទុយពីការពិនិត្យមើលចំណងទាក់ទងក្នុងចំណោមបញ្ហានានា ឬ ការប្រឹងប្រែងក្នុងការដាក់បញ្ហានានាឲ្យជាប់ជាលក្ខខណ្ឌជាមួយគ្នា តាមធម្មតា នឹងនាំមកនូវកិច្ចព្រមព្រៀងដែលមានលទ្ធផលទាបជាងអ្វីដែលគួរតែទទួលបាន (ឬគ្មានកិច្ចព្រមព្រៀងទាល់តែសោះ) ដូចមានបង្ហាញនៅក្នុងករណី ៤.១ ស្តីពីអាងទន្លេដានូបេ នៅអឺរ៉ុប។

*ករណី៤.១៖ ការកំណត់របៀបវារៈសម្រាប់ការចរចាស្តីពីកិច្ចព្រមព្រៀងគ្រប់គ្រងទឹកដោយនិរន្តរភាពនៅអាងដានូបេ*[48]

នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៨០ ប្រទេសនានានៅដានូបេ បានចាប់ផ្តើមធ្វើសហប្រតិបត្តិការដើម្បីបង្កើតមូលដ្ឋានច្បាប់ សម្រាប់ការគ្រប់គ្រងទឹករួមគ្នា។ ប្រការនេះបាននាំឲ្យមានអនុសញ្ញាការពារទន្លេដានូបេ នៅក្នុងឆ្នាំ១៩៩៤(DRPC)។[49] កេរ្តិ៍ដំណែលនៃការមិនទុកចិត្តគ្នាដែលបន្សល់មកពីសម័យសង្គ្រាមត្រជាក់ និងបំណងប្រាថ្នារបស់អ្នកចរចា ក្នុងការបង្កើតឲ្យមានកិច្ចព្រមព្រៀងឯកភាពមតិមួយដែលយកជាការបាន នៅក្នុងរយៈពេលសមស្រប បាននាំឲ្យមានការបង្រួមវិសាលភាពនៃកិច្ចព្រមព្រៀងនេះ។ ភាគីនានាបានសម្រេចផ្តោតការយកចិត្តទុកដាក់លើទិដ្ឋភាពបរិស្ថាននៃការគ្រប់គ្រងទឹក និងកិច្ចការនានាដែលមិនបានលើកឡើងនៅក្នុងកិច្ចព្រមព្រៀងដែលមានស្រាប់ និងមិនរាប់បញ្ចូលបញ្ហាទាំងឡាយដែលមានភាពចម្រូងចម្រាស់ ឬ ដែលមិនមានឥទ្ធិពលមកលើអាងនេះទាំងមូលឡើយ។

បើទោះជាផ្តល់នូវភាពជោគជ័យក្នុងរូបភាពជាច្រើនក៏ដោយ ភាពមិនចុះសម្រុងគ្នាខាងចក្ខុវិស័យអំពីថាតើគួរប្រើប្រាស់ទន្លេនេះដោយរបៀបណា មិនត្រូវបានដោះស្រាយឡើយ។ ភាពមិនចុះសម្រុងគ្នានេះបានរួមចំណែកធ្វើឲ្យមានការដាក់បញ្ចូលអាងទន្លេដានូបេទៅក្នុងបញ្ជីរបស់ WWF ឆ្នាំ២០០៧ នៃទន្លេចំនួន១០ដែលមានហានិភ័យច្រើនជាងគេដែលបង្កដោយហេដ្ឋារចនាសម្ព័ន្ធនាវាចរ។[50] ឧទាហរណ៍ ការសម្របសម្រួលរបស់គណៈកម្មការអន្តរជាតិសម្រាប់ការពារទន្លេដានូបេ (ICPDR មានភារៈទទួលខុសត្រូវលើការអនុវត្ត DRPC ឆ្នាំ ១៩៩៤) អាចនាំទៅរកសកម្មភាពនានា ដោយផ្តោតលើការស្តារតំបន់ទំនាបលិចទឹក និងការពារទីជម្រកសម្រាប់ត្រីពងកូន នៅក្នុងកន្លែងដដែលនេះ ដែលកិច្ចសហប្រតិបត្តិការនៅក្រោមគណៈកម្មការដោយឡែក និងគណៈកម្មការដានូបេដែលមានអាយុចំណាស់ជាង51 មានគោលដៅកែលម្អទន្លេនេះសម្រាប់នាវាចរ ដែលទាមទារឲ្យមានការជីកស្តារឲ្យកាន់តែជ្រៅ និងពង្រឹកច្រាំងទន្លេនេះបន្ថែមទៀត។ ការប្រើប្រាស់សក្តានុពលទាំងពីរនេះមិនអាចធ្វើទៅបាននៅក្នុងពេលតែមួយ និងនៅក្នុងទីតាំងតែមួយនោះបានឡើយ។ ជាលទ្ធផល គម្រោងអភិវឌ្ឍខ្លះដូចជាផ្លូវទឹកប៊ីស្រ្តូឆ្លងកាត់ដែនដីសណ្តទន្លេដានូបេត្រូវបានគេដឹងឮតាមរយៈបញ្ហានៃការអភិវឌ្ឍន៍សេដ្ឋកិច្ច ធៀបនឹងកិច្ចការពារបរិស្ថាន។ បើគ្មានដំណើរការណាមួយសម្រាប់បង្កើតចក្ខុវិស័យចម្រុះសម្រាប់ទន្លេដានូបេ ដែលរួមបញ្ចូលការចូលរួមរបស់អ្នកពាក់ព័ន្ធទាំងអស់ និងដោះស្រាយបញ្ហាសំខាន់ៗទាំងអស់នោះទេ វិវាទទាំងនេះនឹងរីករាលដាលនៅពេលដែលប្រទេសនៅតាមដងទន្លេនេះមិនអាចផ្សារភ្ជាប់បញ្ហានានា និងបង្កើតគុណតម្លៃតាមរយៈពាណិជ្ជកម្មនៅក្នុងចំណោមការពេញចិត្តរបស់ពួកគេ។

បច្ចុប្បន្ននេះ ប្រទេសនៅតាមដងទន្លេនេះកំពុងស្ថិតក្នុងដំណាក់កាលនៃការដោះស្រាយដែនកំណត់នៃកិច្ចសហប្រតិបត្តិការ។ ឧទាហរណ៍ តាមរយៈការចូលរួមរបស់ ICPDR ការពិភាក្សាអំពីគម្រោងអភិវឌ្ឍប្រឡាយប៊ីស្រ្តូល ត្រូវបានរីកធំឡើងដើម្បីបញ្ចូលអ្នកចូលរួមដទៃទៀត និងវិស័យនៃកិច្ចការនានាផ្សេងទៀត។ វេទិកានៃពហុអ្នកពាក់ព័ន្ធ ត្រូវបានបង្កើតឡើង ដែលក្នុងនោះ រដ្ឋាភិបាលនៅថ្នាក់ជាតិអាចជួបប្រជុំជាមួយ NGOs ដើម្បីធ្វើការស្រាវជ្រាវ ចែករម្លែកទិន្នន័យ និងបង្កើតចក្ខុវិស័យរួម សម្រាប់ការគ្រប់គ្រងដែនដីសណ្ត។ ដូចគ្នានេះដែរ វេទិកាមួយសម្រាប់កិច្ចសហប្រតិបត្តិការនៅក្នុងអនុអាងសាវ៉ាអន្តរជាតិ

ត្រូវបានបង្កើតឡើង នៅក្រោមក្របខ័ណ្ឌនៃ ICPDR ដែលអាចឲ្យអ្នកចូលរួមនានាដោះស្រាយបញ្ហាជាច្រើន ដែលរួមទាំង នាវាចរ ស្របជាមួយការប្រើប្រាស់ទឹកដោយនិរន្តរភាពផងដែរ។ នៅកម្រិតអាងទន្លេ ICPDR កំពុងព្យាយាមដោះស្រាយបញ្ហានេះតាមរយៈពង្រីកកិច្ចសហប្រតិបត្តិការជាមួយគណៈកម្មការដានូបេ។

ឥឡូវនេះ កិច្ចប្រឹងប្រែងបែបនេះ និងវេទិកាដែលផ្តោតលើកិច្ចការនេះបានធ្វើឲ្យអ្នកពាក់ព័ន្ធជាច្រើនបានចូលរួមពិភាក្សាលើបញ្ហាទូលំទូលាយ។ NGOs អាចក្លាយជាអ្នកសង្កេតការណ៍ផ្លូវការនៅក្នុង ICPDR និងផ្តល់វិភាគទានទៅក្នុងការធ្វើសេចក្តីសម្រេច។ ឧទាហរណ៍ វេទិកាបរិស្ថានដានូបេ គឺជាអ្នកសង្កេតការណ៍ និងបានសម្របសម្រួលឲ្យមានការចូលរួមជាសាធារណៈនៅក្នុងការធ្វើសេចក្តីសម្រេចអំពីបរិស្ថាន និងការអភិវឌ្ឍន៍ដោយចីរភាពនៅក្នុងអាងទន្លេនេះ។ រួមបញ្ចូលជាមួយគ្នា បង្កើតបានជាក្រុមអ្នកចូលរួមយ៉ាងធំនេះ ដើរតួនាទីដូចជាអគ្គរដ្ឋទូត សម្រាប់ដំណើរការនេះ និងដើរតួនាទីជាអន្តរការីរវាងវេទិកាអន្តរជាតិ និងរដ្ឋាភិបាល ឬ អង្គការរបស់ខ្លួន ដោយបានចូលរួមនៅក្នុង និងជូនដំណឹងដល់ក្រុមអ្នកពាក់ព័ន្ធយ៉ាងធំមួយទាក់ទងនឹងបញ្ហាជាច្រើនបែប។

ការចរចាអំពីទឹកកាន់តែមានការលំបាកជាងអ្វីដែលធ្លាប់មានកន្លងមក នៅពេលដែលបានបង្កើតឡើងនៅក្នុងលក្ខខណ្ឌដែលមានអ្នកឈ្នះនិងអ្នកចាញ់៖ ដោយភាគីម្ខាងចង់បានទឹក ប្រសិនបើភាគីរបស់គេចង់បាន ឬភាគីដទៃខ្លះទៀតក៏ចង់បានដូចគ្នាដែរ។ នេះជាការពិត នៅពេលដែលអ្នកកោះប្រជុំមិនបានផ្តោតការយកចិត្តទុកដាក់បានគ្រប់គ្រាន់ ដើម្បីធ្វើឲ្យមានភាគីសមស្របចូលរួមនៅក្នុងតុចរចា បង្កើតរបៀបវារៈនានា និងបទបញ្ជាផ្ទៃក្នុងឲ្យបានសមស្រប និងធានាឲ្យមានការសម្រួលនៅក្នុងការប្រជុំឲ្យមានប្រសិទ្ធភាព។ ឧទាហរណ៍ នៅក្នុងករណីនេះ អ្នកចរចាអាចមិនមានលទ្ធភាពក្នុងការបង្កើត "គុណតម្លៃ" ដោយផ្សារភ្ជាប់បញ្ហានានាជាមួយគ្នាឡើយ។ ប្រសិនបើការចរចាត្រូវបានបង្កើតឡើងក្រោមរូបភាពជាជម្រើសរវាងអ្នកឈ្នះ "ខាងបរិស្ថាន" និងការបោះបង់ការអភិវឌ្ឍសេដ្ឋកិច្ច ឬក៏ធ្វើឲ្យសេដ្ឋកិច្ចលូតលាស់ទន្ទឹមនឹងភាពខ្វាយខ្វល់អំពីបរិស្ថាន និងសុខភាពឲ្យនៅដាច់ដោយឡែកពីគ្នា នៅពេលនោះពួកគេពិតក្លាយជាសមរភូមិមួយ ដែលមានអ្នកឈ្នះ និងអ្នកចាញ់។ ក្រុមនានាដែលមានអំណាចនយោបាយខ្លាំងជាងនឹងព្យាយាមដណ្តើមនូវជ័យជំនះឲ្យបានច្រើន ចំណែកក្រុមអ្នកទន់ខ្សោយជាង នឹងទទួលបានតិចតួច ឬគ្មានទទួលបានអ្វីសោះ។

*"ការចរចាអំពីទឹកពិតជាកាន់តែលំបាកជាងអ្វីដែលគួរតែមាននៅពេលដែលការចរចាទាំងនោះត្រូវបានបង្កើតឡើងនៅក្នុងលក្ខខណ្ឌដែលមានអ្នកឈ្នះ និងអ្នកចាញ់"*

កាលានុវត្តភាព ដើម្បីបង្កើតផលប្រយោជន៍សម្រាប់ទាំងអស់គ្នា ពោលគឺបង្កើតតម្លៃដោយគ្រប់គ្រងធនធានរួមសម្រាប់ជាប្រយោជន៍ទាំងអស់គ្នា ទាមទារឲ្យមានអភិក្រមមួយដែលខុសគ្នាទាំងស្រុង។ នេះជារឿងពិតនៅថ្នាក់មូលដ្ឋាន ក៏ដូចជានៅកម្រិតអន្តរជាតិផងដែរ។ ជាក់ស្តែង នៅពេលដែលប្រទេសអធិបតេយ្យ ចូលរួមនៅក្នុងតុចរចា ហើយជម្រើសដែលមានតែមួយគត់ គឺកិច្ចព្រមព្រៀងដោយស្ម័គ្រចិត្ត (ដោយសារគ្មានប្រទេសអធិបតេយ្យណាមួយ អាចត្រូវបានគេបង្ខំឲ្យទទួលយកលក្ខខណ្ឌណាមួយឡើយ ប្រសិនបើប្រទេសនោះយល់ថាគួរតែបដិសេធ) កិច្ចព្រមព្រៀងត្រូវតែឆ្លើយតបនឹងកង្វល់នានារបស់ភាគីទាំងអស់ បើពុំនោះទេ ប្រទេសទាំងអស់នឹងមិនឯកភាពអំពីការជាប់កាតព្វកិច្ចតាមកិច្ចព្រមព្រៀងនោះឡើយ។[52] ដូចគ្នានេះដែរ នៅក្នុងការចរចានៅថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធនឹងអ្នកដើរតួខុសៗគ្នានៅក្នុងកិច្ចការទឹក អ្នកពាក់ព័ន្ធទាំងអស់ត្រូវតែមានចំណាប់អារម្មណ៍ថាផលប្រយោជន៍របស់ខ្លួនត្រូវបានដោះ

ស្រាយ។ បើទោះជាដំណើរការនេះអាចជួបការលំបាកក៏ដោយ លើកលែងតែភាគីនីមួយៗចាប់អារម្មណ៍ថា យ៉ាងហោចណាស់កង្វល់ខ្លះៗរបស់ខ្លួនត្រូវបានដោះស្រាយ បើពុំនោះទេ ពួកគេនឹងមិនចុះហត្ថលេខាលើកិច្ចព្រមព្រៀងនោះឡើយ។

ជាញឹកញាប់ អ្នកចរចាអំពីទឹកភាគច្រើន បានគាបសង្កត់គ្នាទៅវិញទៅមក ធ្វើហាក់ដូចជាគ្មានវិធីផ្សេងដែលភាគីទាំងអស់អាច ឬនឹងទទួលផលបានឡើយ តាមរយៈការគ្រប់គ្រងធនធានទឹកឲ្យមានប្រសិទ្ធភាព។ ប៉ុន្តែជាក់ស្តែងពិតជាមានផលប្រយោជន៍សម្រាប់ភាគីទាំងអស់ ប្រសិនបើមានការប្តេជ្ញា ដើម្បីផ្តល់ឲ្យភាគីទាំងអស់នូវអ្វីដែលពួកគេចង់បាន និងត្រូវការជាចាំបាច់(ពោលគឺឆ្លើយតបនឹងផលប្រយោជន៍របស់ពួកគេ)។ ឧទាហរណ៍ តាមរយៈកិច្ចព្រមព្រៀងដើម្បីអនុម័តយកវិធានការអភិរក្សទឹក បច្ចុប្បន្ននេះភាគីទាំងអស់ត្រូវមានទឹកដើម្បីឆ្លើយតបតាមតម្រូវការ(ដែលកើនឡើងរបស់ពួកគេទៅអនាគត។ ឬ ប្រទេសនៅខ្សែទឹកខាងលើអាចត្រូវសន្យាថា ពួកគេមានសិទ្ធិទទួលបានស្បៀងដែលផលិតបានតាមរយៈទឹកដែលហូរចុះមកខាងក្រោម មុននឹងពួកគេឯកភាព នៅក្នុងកិច្ចព្រមព្រៀងមួយដែលអនុញ្ញាតឲ្យមានទឹកហូរចុះមកភាគីនៅខ្សែទឹកខាងក្រោម។ ឬការកំណត់ថ្លៃទឹកដែលអ្នកប្រើប្រាស់នៅខ្សែទឹកខាងក្រោមបានទិញ អាចកើនឡើង ដើម្បីធានាថា ភាគីនៅខ្សែទឹកខាងលើអាចរកផលចំណូលគ្រប់គ្រាន់ ដើម្បីបំពេញតាមតម្រូវការទាំងស្រុងរបស់ពួកគេ។ ការចរចាអំពីទឹកដែលមិនផ្តោតលើការដោះដូរបែបនេះ ទំនងជាត្រូវបរាជ័យ។ សូម្បីតែភាគីទន់ខ្សោយក៏ដោយ នឹងស្វែងរកវិធីដើម្បីរុញច្រានត្រឡប់ទៅវិញឲ្យខាងតែបាននៅពេលគេស្ថិតក្រោមការគាបសង្កត់ពីភាគីខ្លាំងខាងនយោបាយដែលព្យាយាមធ្វើអាជីវកម្មធនធានទឹករួមគ្នាមិនបានត្រឹមត្រូវ ។ ជាញឹកញាប់ ពួកគេបង្កើតជាសម្ព័ន្ធភាពជាមួយដៃគូខាងនយោបាយនៃភាគីដែលមានអំណាចខ្លាំង។ ការចរចាអំពីទឹក ដែលបានវែកញែកអាចធ្លាក់ចូលទៅក្នុងសមរភូមិនយោបាយដែលជាបញ្ហាមិនពាក់ព័ន្ធគ្នា ក៏ទំនងជានឹងទទួលបរាជ័យផងដែរ។

ដូចគ្នានេះដែរ ការចរចាអំពីទឹក ដែលផ្តោតតែលើអ្នកណាចង់បានអ្វី និងមិនបានយល់ដឹងអំពីការវិភាគបច្ចេកទេស និងវិទ្យាសាស្ត្រដែលអាចទុកចិត្តបាន ឬចំណេះដឹងពីបទពិសោធន៍នៅមូលដ្ឋាន ក៏នឹងបានទទួលផលតិចតួចប៉ុណ្ណោះ។ គេត្រូវការព័ត៌មានជាចាំបាច់ ដើម្បីធ្វើការសម្រេចប្រកបដោយការពិចារណា។ ប្រសិនបើក្រុមនេះមិនបានបង្ហាញអំពីដំណើរការរួមគ្នាក្នុងការស្វែងរកការពិតមុនការធ្វើសេចក្តីសម្រេចនោះទេ ពួកគេមិនទំនងជាមានទិន្នន័យដែលចាំបាច់ នៅពេលត្រូវធ្វើសេចក្តីសម្រេចនោះឡើយ។ គេអាចឈានដល់កិច្ចព្រមព្រៀង ប៉ុន្តែការប្តេជ្ញានានា នឹងបាត់បង់ទៅយ៉ាងឆាប់រហ័ស នៅពេលគេដឹងច្បាស់ថា ពួកគេសន្មត់ខុសអំពីថាតើនឹងមានទឹកប៉ុន្មាន ឬ តើប្រព័ន្ធអេកូឡូស៊ី នឹងឆ្លើយតបបែបណា។ មានតែតាមរយៈការកំណត់របៀបវារៈតាមបែបប្រព័ន្ធ និងតាមរយៈការបង្កើតផែនការប្រមូលព័ត៌មានស្របគ្នាតែប៉ុណ្ណោះ ទើបអាចធ្វើឲ្យមានសម្បទានរវាងបញ្ហានានា។ ដូចដែលបានកត់សំគាល់ខាងលើ មានតែការដោះដូររវាងបញ្ហានានាតែប៉ុណ្ណោះ ដែលអាចបង្កើតគុណតម្លៃ ពោលគឺ ផ្តល់ការលើកទឹកចិត្តដល់គ្នាទៅវិញទៅមកដើម្បីទទួលយកកម្រិតទាបជាងសមិទ្ធផលដែលអាចទទួលបាននៅក្នុងលក្ខខណ្ឌល្អលើបញ្ហាមួយ ជាការដោះដូរនឹងការទទួលបានអ្វីដែលមានសារៈសំខាន់បំផុត ចំពោះភាគីនោះ លើបញ្ហាខ្លះៗផ្សេងទៀតដែលពាក់ព័ន្ធ។

*"គេត្រូវការព័ត៌មានដើម្បីធ្វើការសម្រេចប្រកបដោយការពិចារណា"*

ភាគច្រើននៃវេទិកាចរចាមិនអនុម័តយកសូម្បីតែបទបញ្ជាផ្ទៃក្នុងងាយៗក៏ដោយ។ ឬប្រសិនបើពួកគេអនុម័តពួកគេមិនយកទៅអនុវត្តឡើយ។ ឧទាហរណ៍ ប្រសិនបើពុំបានស្នើសុំភាគីនានាឲ្យ"រៀបចំខ្លួន" និង "ត្រៀមខ្លួនជាស្រេចដើម្បីធ្វើការប្ដេជ្ញា" (ពោលគឺប្រសិនបើគេពុំបានស្នើសុំឲ្យពិនិត្យមើលសេចក្ដីព្រាងឯកសារនានា នៅផ្ទៃក្នុងមណ្ឌលគាំទ្ររបស់ខ្លួន មុនកិច្ចប្រជុំដែលបានគ្រោងទុក)ទេនោះ ការចរចាអាចបន្តមិនចេះចប់។ ជារឿយៗ កម្មវិធីចរចានានាច្រើនតែសង្កត់ធ្ងន់ទៅលើការថ្លែងសន្ទរកថា ជាជាងធ្វើការដោះស្រាយបញ្ហាឲ្យមានប្រសិទ្ធភាព។ បទបញ្ជាផ្ទៃក្នុងដែលមានចែងរួចហើយ ដែលទាក់ទងនឹងរបៀបចាត់ចែងការប្រជុំ មានសារៈសំខាន់ណាស់ និងគួរតែទទួលបានការអនុម័តពីគ្រប់ភាគី មុននឹងចាប់ផ្ដើមការចរចាណាមួយក៏ដោយ។ អ្នកដែលបានតែងតាំងឲ្យធ្វើជាប្រធាន ឬជាអ្នកសម្របសម្រួលការប្រជុំច្រើនតែពុំមានជំនាញលើបច្ចេកទេសសម្របសម្រួល។ ជាជាងបើកឱកាសឲ្យអ្នកណាម្នាក់ដែលអាចគ្រប់គ្រងការសន្ទនាតឹងតែងបានល្អប្រសើរ បុគ្គលនោះក៏នឹងអាចក្ដាប់អំណាចទាំងស្រុង ដែលធ្វើឲ្យខូចដល់ប្រសិទ្ធភាពរបស់ក្រុមពិភាក្សាផងដែរ។ បើទោះជាមានភាពចាំបាច់ដាក់ស្ដែងដើម្បីឯកភាពលើ ថាតើអ្នកណានឹងរៀបចំសេចក្ដីសង្ខេបជាលាយលក្ខណ៍អក្សរនៅក្នុងវគ្គនីមួយៗនៃការប្រជុំក៏ដោយ ប្រការនេះច្រើនតែត្រូវគេមើលរម្លង។ នេះមានន័យថា អ្នកចូលរួមម្នាក់ៗបង្កើតកំណត់ត្រាផ្ទាល់ខ្លួនអំពីអ្វីដែលបាននិយាយ និងអ្នកណាបានសន្យាអ្វី។ លើកលែងតែក្រុមនេះបង្កើត"អត្ថបទតែមួយ" ដែលភាគីទាំងអស់បានធ្វើការប្ដេជ្ញា បើមិនដូច្នោះទេ ភាពច្របូកច្របល់ពិតជានឹងកើតឡើង។ អ្វីដែលត្រូវរាយការណ៍ត្រឡប់ទៅគាំទ្ររបស់ខ្លួនវិញត្រូវតែឆ្លុះបញ្ចាំងបានសុក្រឹត្យអំពីអ្វីដែលបានពិភាក្សា និងអ្វីដែលបានឯកភាពសូម្បីតែប្រការនោះមិនបំពេញបន្ថែមដល់តំណាងពីគ្រប់ក្រុមក៏ដោយ។

*"អភិក្រមតថ្លៃតឹងតែងអាចនាំទៅរកការសម្រេចនានានៅក្នុងរយៈពេលខ្លីប៉ុន្តែច្រើនតែបង្កើតឲ្យមានផលវិបាករយៈពេលវែងដែលភាគីទាំងអស់យល់ឃើញថាពុំមែនជាទីពេញចិត្ត"*

ដូច្នេះ អភិក្រមតថ្លៃតឹងតែង ដែលកំហិតលើចំនួនភាគីពាក់ព័ន្ធនានាដោះស្រាយបានត្រឹមតែបញ្ហាមួយចំនួនតូចប៉ុណ្ណោះ(តាមធម្មតាដោះស្រាយបញ្ហាម្ដងបានមួយ) ចាត់ទុកការសម្រេចនីមួយៗជាការតថ្លៃជាផ្លូវការខាងនយោបាយដែលមានអ្នកចាញ់ និងអ្នកឈ្នះ (ដោយសង្កត់ធ្ងន់លើនយោបាយឈ្នះ និងចាញ់ ដោយមិនគិតអំពីកិច្ចសហការ) អាចនាំទៅរកការសម្រេចនានានៅក្នុងរយៈពេលខ្លី ប៉ុន្តែច្រើនតែបង្កើតឲ្យមានផលវិបាករយៈពេលវែង ដែលភាគីទាំងអស់យល់ថាមិនជាទីពេញចិត្ត។ ផ្ទុយទៅវិញ អភិក្រមបង្កើតការឯកភាពមតិផ្ដល់នូវឧបករណ៍នានាសម្រាប់ជំនះដែនកំណត់ទាំងនោះ (តារាង ៩.១)។

*តារាង៤.១ការជំនះឲ្យបានលើដែនកំណត់នៃការតថ្លៃតឹងរ៉ឹង*

| ដែនកំណត់នៃការតថ្លៃតឹងតែង | ផលប្រយោជន៍ពីការបង្កើតឲ្យមានការឯកភាពមតិ |
|---|---|
| ភាគីនៅក្នុងតុចរចាមិនត្រឹមត្រូវ | អ្នកពាក់ព័ន្ធនានាត្រូវបានកំណត់អត្តសញ្ញាណតាមរយៈ ការប៉ាន់ប្រមាណស្ថានភាព ឬការជ្រើសតាំងដោយខ្លួនឯង |
| របៀបវារៈមានលក្ខណៈតូចចង្អៀត និងផ្តោតលើជំហរ បញ្ហាតែមួយបង្កើតឲ្យមានស្ថានភាពឈ្នះ ចាញ់ | កំណើនផលដល់គ្នាទៅវិញទៅមកដែលបានបង្កើតឡើងដោយ ផ្តោតលើផលប្រយោជន៍និងការដោះដូរលើបញ្ហាជាច្រើន |
| ការសម្របសម្រួលនិងការគ្រប់គ្រងមិនបានល្អអាចគាបសង្កត់លើគ្នាទៅវិញទៅមក និងបង្កឲ្យការចរចាគ្មានទីបញ្ចប់ ឬឈាន ដល់ការសម្រេចដែលមិនអាចយកជាការបាន | អ្នកសម្របសម្រួលអព្យាក្រឹត្យផ្តល់ការណែនាំដល់ដំណើរការដើម្បី រៀបចំរបៀបវារៈរួមគ្នា កំណត់បទបញ្ជាផ្ទៃក្នុង បង្កើតនិងវាយតម្លៃ ជម្រើសនានា និងប្រើប្រាស់អត្ថបទតែមួយដើម្បីឈានដល់ កិច្ចព្រមព្រៀងដែលយកជាការបាន |
| សេចក្តីសម្រេចនានាច្រើនតែធ្វើឡើង ដោយគ្មានព័ត៌មានដែលគួរ ឲ្យជឿបាន (ឬមិនអាចទុកចិត្តបាន) | ស្វែងរកការណ៍ពិតរួមគ្នា និងការវិភាគទិន្នន័យវិទ្យាសាស្ត្រនិង ចំណេះដឹងពីបទពិសោធន៍នានាជាមូលដ្ឋានសម្រាប់ការចរចា |
| គោលបំណងគឺ "រកភាពឈ្នះឲ្យបានច្រើនបំផុតតាមតែអាចធ្វើបាន" និងឈានដល់ការព្រមព្រៀង | គោលបំណងនានាត្រូវតែសម្រេចឲ្យបាននូវកិច្ចព្រមព្រៀងដែល អាចទទួលយកបានទាំងអស់គ្នា ដែលភាគីទាំងអស់នឹងយកទៅអនុវត្ត |

## *៤.៣ អភិក្រមបង្កើតការឯកភាពមតិ*

គ្មានអ្វីដែលអាចរារាំងអ្នកចរចាអំពីទឹក មិនឲ្យប្រកាន់យកអភិក្រមមួយដែលប្រសើរជាងមុននោះឡើយ ពោលគឺអភិក្រមដែលធានាថាអ្នកពាក់ព័ន្ធទាំងអស់ចូលមកកាន់តុចរចា ធានាថាការចរចាត្រូវបានគ្រប់គ្រងតាមទម្រង់នៃការដោះស្រាយបញ្ហា (ឬការបង្កើនគុណតម្លៃ) និងធានាថាភាគីនានាប្តេជ្ញាចំពោះកិច្ចព្រមព្រៀងដែលអាចយកជាការបាន និងអាចបន្សាំបាន។ អ្នកដែលស្ថិតក្នុងតួនាទីដឹកនាំក្រុមអ្នកចរចា ត្រូវចាត់ទុកថាមានវិធីដែលអាចធ្វើបានក្រៅពីអភិក្រមតថ្លៃតឹងតែង។ អ្នកដទៃទៀតនៅក្នុងក្រុមនេះយ៉ាងហោចណាស់ត្រូវតែយល់ឲ្យបានគ្រប់គ្រាន់អំពីអភិក្រមជំនួសឲ្យការចរចាដើម្បីដឹងថាពួកគេពុំចាំបាច់បោះបង់ចោលអំណាចឡើយ ប្រសិនបើពួកគេឯកភាពដើម្បីប្រតិបត្តិការតាមទម្រង់នៃការបង្កើតការឯកភាពមតិ។ ក្រុមនេះទាំងមូល ត្រូវតែប្តេជ្ញាផ្តល់ពេលវេលា និងធនធានឲ្យបានគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឲ្យដំណើរការចរចាប្រកបដោយប្រសិទ្ធភាពអាចប្រព្រឹត្តទៅដោយជោគជ័យ។

ការបង្កើតឲ្យមានការឯកភាពមតិគឺជាអភិក្រមមួយនៅក្នុងការចរចា ដែលពង្រឹងភាពអង់អាចដល់អ្នកដែលមានការព្រួយបារម្ភណ៍ជាងគេអំពីសមធម៌ ទន្ទឹមនឹងការឆ្លើយតបក្នុងពេលជាមួយគ្នា ទៅនឹងកង្វល់របស់ភាគីដែលមានអំណាចនយោបាយច្រើនជាងគេ អំពីការរក្សាបុព្វសិទ្ធិរបស់ពួកគេ។ គេអាចធ្វើឲ្យមានការឯកភាពមតិតាមរយៈការឯកភាពគ្នានៅក្នុងដំណាក់កាលដើមដំបូង ដើម្បីធ្វើឲ្យមានការព្រមព្រៀងជាឯកច្ឆ័ន្ទប៉ុន្តែដោះស្រាយតាមរយៈការកិច្ចព្រមព្រៀងពីមនុស្សភាគច្រើនលើសលុប ឲ្យតែកិច្ចប្រឹងប្រែងនីមួយៗបានធ្វើឡើងដើម្បីឆ្លើយតបទៅនឹងចំណាប់អារម្មណ៍របស់អ្នកដែលសំដែងកង្វល់អំពីកិច្ចព្រមព្រៀងនៅជិតដំណាក់កាលចុងក្រោយ។[53]

បើទោះជាមានភាពខុសគ្នាយ៉ាងច្រើនរវាងការចរចាអំពីទឹកនៅកម្រិតមូលដ្ឋាន ជាតិនិងអន្តរជាតិក៏ដោយ ជាពិសេស ទោះជាមានការដាក់ឲ្យអនុវត្តក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិខុសៗគ្នាក៏ដោយ អ្នកចូល

រួមនៅក្នុងគ្រប់ស្ថានភាពនឹងទទួលបានប្រយោជន៍ពីការប្រើប្រាស់បទបញ្ញាលើការសម្រេចដែលមានការឯកភាពមតិ។ គេត្រូវធានាថាចំណាប់អារម្មណ៍របស់ភាគីនានាដែលមិនសូវមានអំណាចនយោបាយនឹងត្រូវបានដោះស្រាយ ធានាថាពួកគេនឹងមិនរងការបង្ខិតបង្ខំឲ្យទទួលយកនូវអ្វីដែលពួកគេជំទាស់នោះឡើយ (វិធីដែលពួកគេអាចបង្ខំឲ្យពួកគេទទួលយក ប្រសិនបើដាក់ឲ្យអនុវត្តប្រព័ន្ធបោះឆ្នោតយកតាមសម្លេងភាគច្រើន) ហើយធានាថាសូម្បីតែភាគីដែលមានអំណាចខ្លាំងបំផុតនៅក្នុងតុចរចា បានឯកភាពដើម្បីផ្តល់កិច្ចប្រឹងប្រែងដោយស្មោះត្រង់ ដើម្បីដោះស្រាយកង្វល់របស់ពួកគេក៏ដោយ។ ទន្ទឹមនឹងនេះ ភាគីដែលមានអំណាចនយោបាយខ្លាំងបំផុត ក៏ត្រូវបានទទួលការធានាផងដែរថា ពួកគេនឹងមានសមាមាត្រសម្លេងឆ្នោតមួយផងដែរក្នុងករណីដែលពួកគេផ្តល់នូវកិច្ចប្រឹងប្រែង ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់របស់ភាគីទាំងអស់នៅក្នុងតុចរចា។ នៅក្រោមប្រព័ន្ធបោះឆ្នោតសម្លេងភាគច្រើន ចំណាប់អារម្មណ៍របស់ក្រុមមនុស្សភាគតិចមិនបានទទួលកិច្ចការពារឡើយ។ ហាសិបមួយភាគរយ(៥១%) នៃក្រុមនេះអាចបង្ខំឲ្យអ្នកដែលនៅសល់ ៤៩% ទទួលយកតាមបំណងរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ អភិក្រមនៃការបង្កើតឲ្យមានការឯកភាពមតិ អាចការពារក្រុមជនភាគតិច ដោយបញ្ចៀសសម្លេងឆ្នោតនានា និងធានាថា ក្រុមនេះទាំងមូលទទួលយកការទទួលខុសត្រូវដើម្បីធ្វើអ្វីៗទាំងអស់ដែលខ្លួនអាចធ្វើបាន ដើម្បីឆ្លើយតបទៅនឹងចំណាប់អារម្មណ៍របស់ភាគីទាំងអស់ដែលពាក់ព័ន្ធ។ វត្តមាននៃអ្នកសម្របសម្រួលដែលមានបទពិសោធន៍ និងមានជំហរឥតលំអៀង អាចជាការអះអាងឡើងវិញផងដែរនៅក្នុងករណីនេះ។ អ្នកសម្របសម្រួល(ឬអ្វីដែលគេហៅថាអ្នកសម្រុះសម្រួល ឬអ្នកផ្សះផ្សា) អាចធ្វើឲ្យភាគីទាំងនេះមានគណនេយ្យភាពចំពោះការប្តេជ្ញាបង្កើតការឯកភាពមតិរបស់ពួកគេ។

*"អភិក្រមបង្កើតការឯកភាពមតិអាចការពារក្រុមជនភាគតិច"*

ការបង្កើតឲ្យមានការឯកភាពមតិ អាចជាឧបករណ៍យ៉ាងមានប្រសិទ្ធភាព សម្រាប់បង្កើតឲ្យមានកិច្ចព្រមព្រៀងអំពីទឹកដែលស្មើភាព និងមានប្រសិទ្ធភាពជាងមុន ដោយសារប្រការនេះទាមទារឲ្យមានការប្តេជ្ញាក្នុងការនាំយកវិទ្យាសាស្ត្រ និងចំណេះដឹងដែលបានពីការពិសោធន៍ម៉ឺងម៉ាត់ ក៏ដូចជាផ្តោតទៅលើការសម្រេចបានតាមការព្រមព្រៀងខាងនយោបាយផងដែរ។ ការគ្រប់គ្រងដើម្បីឲ្យមាននិរន្តរភាព ទាមទារឲ្យមានតុល្យភាពរវាងវិទ្យាសាស្ត្រ ចំណេះដឹងនៅមូលដ្ឋាន និងនយោបាយ ក៏ដូចជា ការបង្កើតឲ្យមានកិច្ចព្រមព្រៀងក្នុងចំណោមភាគីប្រឆាំងគ្នាផងដែរ (ដែលត្រូវតែមានការប្តេជ្ញាដើម្បីកែប្រែឥរិយាបថនៃស្ថាប័នរបស់ខ្លួន)។ ការប្រឹងប្រែងដើម្បីបង្កើតឲ្យមានការឯកភាពមតិ មានន័យថា ស្វែងរកកិច្ចព្រមព្រៀងដោយស្ម័គ្រចិត្ត (ពោលគឺ ពុំមានការបោះឆ្នោតណាដែលបង្ខំឲ្យក្រុមមនុស្សភាគតិចទទួលយកនូវអ្វីដែលពួកគេមិនចង់បាននោះទេ)។ ដូច្នេះ ការបង្កើតឲ្យមានការឯកភាពមតិ គឺមានភាពទំនងបំផុតក្នុងការបង្កើតលទ្ធផលឲ្យមានរយៈពេលយូរអង្វែង ដែលលើកទឹកចិត្តដល់បុគ្គល ក្រុម និងសហគមន៍ ដើម្បីគោរពតាមការប្តេជ្ញានានារបស់ពួកគេ។ នៅក្នុងដំណើរការបង្កើតការឯកភាពមតិណាមួយដែលបានរួមបញ្ចូលការស្វែងរកការពិតរួមគ្នា និងរបៀបវារៈមួយដែលរៀបចំឡើងដោយក្រុមនេះទាំងមូលចំណេះដឹងវិទ្យាសាស្ត្រ និងចំណេះដឹងដែលបានពីការពិសោធន៍នានាទំនងជានឹងបានទទួលការយកចិត្តទុកដាក់ជាង។ ក្រុមមនុស្សភាគច្រើន ដែលមានអំណាចមិនអាចបង្ខំឲ្យក្រុមនុស្សភាគតិចទទួលយកជម្រើសនយោបាយរបស់ខ្លួនឡើយ និងមិនអាចមើលរម្លងអ្វីដែលលើកស្នើឡើងដោយភស្តុតាងបច្ចេកទេស និងភស្តុតាងពីបទ

ពិសោធន៍នៅមូលដ្ឋានឡើយ។

ដូចបង្ហាញក្នុងរូបទី ៤.១ ដំណើរការបង្កើតការឯកភាពមតិចែកចេញជាប្រាំមួយជំហាន។[54]

*រូបទី៤.១ ជំហានទាំងប្រាំមួយនៅក្នុងដំណើរការបង្កើតការឯកភាពមតិ*




## *៤.៣.១ ការកោះប្រជុំ ការធ្វើឲ្យមានភាគីសមស្របនៅក្នុងតុចរចា*

ការចរចាអំពីទឹកប្រកបដោយជោគជ័យ ត្រូវផ្អែកលើការធ្វើឲ្យភាគីសមស្របចូលមកក្នុងតុចរចា។ ក្នុងករណីភាគច្រើន នៅក្នុងគំរូនៃការតថ្លៃតឹងតែងតាមបែបពីមុនមកទីភ្នាក់ងារកោះប្រជុំតម្រូវឲ្យភាគីនានាចូលមកជួបជុំគ្នា ទៅតាមការដែលខ្លួនយល់ឃើញថាភាគីនោះមានការពាក់ព័ន្ធ។ ផ្ទុយទៅវិញ តាមធម្មតាការបង្កើតឲ្យមានការឯកភាពមតិ ដែលចាប់ផ្តើមដោយការរៀបចំស្ថានភាពមួយ ឬការប៉ាន់ប្រមាណអំពីវិវាទពីសំណាក់អ្នកមានអាជីពអព្យាក្រឹត ពោលគឺ អ្នកណាម្នាក់ដែលអាចទទួលយកពីភាគីពាក់ព័ន្ធទាំងអស់ និងជាជនដែលគ្មានទំនាក់ទំនងផលប្រយោជន៍ជាមួយលទ្ធផលពីការចរចានេះ ដើម្បីកំណត់អត្តសញ្ញាណថាតើអ្នកពាក់ព័ន្ធណាខ្លះគួរតែបានទទួលការអញ្ជើញឲ្យចូលរួម។ ការជ្រើសរើសអ្នកចូលរួមសម្រាប់ការចរចា ឬការសន្ទនាផ្សេងទៀត ពឹងផ្អែកមួយផ្នែកលើគោលបំណង និងទម្រង់ដែលពួកគេចង់បាន ៖

- នៅពេលបំណងត្រូវបានបង្កើតទំនាក់ទំនង ផ្លោះប្តូរព័ត៌មាន គូសបញ្ជាក់អំពីផ្នែកនានាដែលព្រមព្រៀង និងផ្នែកមិនចុះសម្រុងគ្នា ឬត្រូវកំណត់អត្តសញ្ញាណជម្រើសគោលនយោបាយដែលមានលទ្ធភាព ដើម្បីលើកអនុសាសន៍ទៅអ្នកធ្វើសេចក្តីសម្រេច អ្នកចូលរួមគួរតែទទួលបានការជ្រើសរើស និងអាចនិយាយដោយផ្អែកលើចំណេះដឹង និងជំនាញផ្ទាល់ខ្លួនរបស់ពួកគេ។
- នៅពេលបំណងត្រូវបានកសាងផែនការអំពីអ្វីដែលត្រូវដោះស្រាយនៅក្នុងការចរចា បង្កើតរបៀបវារៈ ឬបង្កើតឲ្យមានកិច្ចព្រមព្រៀងមួយតាមរយៈដំណើរការបង្កើតឯកភាពមតិ នៅពេលនោះអ្នកចូលរួមត្រូវតែមានសមត្ថភាពដើម្បីអនុវត្តការប្តេជ្ញា (ពោលគឺ និយាយក្នុងនាមក្រុមណាមួយជាក់លាក់) ឬមានឥទ្ធិពលយ៉ាងច្រើនមកលើការប្តេជ្ញារបស់មណ្ឌលគាំទ្រណាមួយ។

*"ការចរចាអំពីទឹកប្រកបដោយប្រសិទ្ធភាពផ្អែកលើការនាំយកភាគីសមស្របឲ្យចូលមកក្នុងតុចរចា"*

ទោះជាយ៉ាងណាក៏ដោយ សូម្បីនៅពេលដែលគោលបំណងនៃការសន្ទនាត្រូវគេដឹងហើយក៏ដោយ គេមិនសុទ្ធតែដឹងច្បាស់ទេថាតើអ្នកណាគួរតែចូលរួមនៅក្នុងការចរចានោះ។ ឧទាហរណ៍៖ នៅក្នុងការចរចាអំពីទន្លេដានូប ប្រទេសខុសៗគ្នាបានចូលរួមនៅក្នុងការបង្កើតសន្ធិសញ្ញាពហុជាតិចំនួនពីរ។ ប្រទេសដែលស្ថិតនៅលើដងទន្លេមេបានចូលរួមនៅក្នុងអនុសញ្ញាក្រុងបែលហ្ក្រាតឆ្នាំ១៩៤៨ដោយផ្តោតលើនាវាចរ ដែលអនុវត្តដោយគណៈកម្មការដានូបេ ចំណែកអនុសញ្ញាការពារទន្លេដានូបេ ដែលចូលជាធរមាននៅឆ្នាំ ១៩៩៨ បានប្រកាន់យកអភិក្រមអាងទន្លេទាំងមូល និងបានធ្វើឲ្យមានការចូលរួមពីប្រទេសនានាជាមួយនឹងផ្ទៃដីច្រើនជាង ២០០០គ.ម² នៅក្នុងអាងទន្លេ និងសហភាពអឺរ៉ុបក្នុងនាមជាភាគីសមាជិក។

ការជ្រើសរើសអ្នកចូលរួមបានត្រឹមត្រូវ គឺជាការកំណត់មិនត្រឹមតែដើម្បីឈានទៅដល់កិច្ចកិច្ចព្រមព្រៀងប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការកំណត់ថាតើនឹងត្រូវយកកិច្ចព្រមព្រៀងនោះទៅអនុវត្តបែបណាផងដែរ។ នេះជាប្រការដែលបង្ហាញច្បាស់នៅក្នុងការចរចាក្នុងប្រទេសនានា ដូចជា ការចរចានៅក្នុងដំណាក់កាលដើមដំបូង ដែលទាក់ទងនឹងការគ្រប់គ្រងតំបន់អេវើគ្លេត នៅហ្វ្លរីដា នៅក្នុងករណី ៤.២ ដែលក្នុងនោះអ្នកប្រើប្រាស់ទឹកសំខាន់ៗ ដូចជា ឧស្សាហកម្មផលិតស្ករ និងក្រុមអ្នកមានចំណាប់អារម្មណ៍ ដូចជាក្រុមគាំពារបរិស្ថានមិនត្រូវបានរួមបញ្ចូលឡើយ ហើយនៅពេលក្រោយមក ក្រុមនេះត្រូវបានរាំងខ្ទប់មិនឲ្យមានការអនុវត្តន៍កិច្ចព្រមព្រៀងដំបូង។

*ករណី៤.២ ដំណើរការបង្កើតការឯកភាពមតិសម្រាប់ការស្តារតំបន់អេវើគ្លេតនៅហ្វ្លរីដាខាងត្បូង*[56]

លំហូរទឹកដោយធម្មជាតិនៅតំបន់ដីសើមអេវើគ្លេតនៃរដ្ឋផ្លរីដា ស.រ.អា ត្រូវបានកែប្រែដោយសារគម្រោងសហព័ន្ធដែលបានបង្កើតឡើងដើម្បីត្រួតត្រាលើទឹកជំនន់ និងបង្ហូរទឹកចេញពីតំបន់នេះដើម្បីបម្លែងដីសម្រាប់ធ្វើកសិកម្ម ដូចជា ការដាំអំពៅ និងសម្រាប់ការអភិវឌ្ឍន៍ទីក្រុង។ កិច្ចព្រមព្រៀងអំពីរបៀបស្តារសុខភាពប្រព័ន្ធអេកូឡូស៊ី ដែលមិនបានឆ្លើយតបទៅនឹងផលប្រយោជន៍របស់អ្នកពាក់ព័ន្ធសំខាន់ៗមានជនជាតិដើមនៅអាមេរិក និងក្រុមអ្នកគាំពារបរិស្ថាន ដូចជា ឧស្សាហកម្មផលិតស្ករ ត្រូវបានពន្យាពេលដោយសារបណ្តឹងតាមផ្លូវច្បាប់។ ប្រការនេះបាននាំឲ្យរដ្ឋាភិបាលនៃរដ្ឋហ្វ្លរីដា ធ្វើការកោះប្រជុំគណៈកម្មការអភិបាលរដ្ឋ សម្រាប់និរន្តរភាពផ្លរីដាខាងត្បូង នៅក្នុងឆ្នាំ ១៩៩៤។

ការិយាល័យអភិបាលរដ្ឋធ្វើការជាមួយទីភ្នាក់ងារនានារបស់រដ្ឋ ដើម្បីកំណត់អត្តសញ្ញាណអ្នកចូលរួម និងកំណត់យកអតីតប្រធានសភានៃរដ្ឋនេះធ្វើជាប្រធាន។ ពួកគេបានកំណត់អត្តសញ្ញាណក្រុមអ្នកពាក់ព័ន្ធសំខាន់ៗ និងតំណាងនានាដែលមានប្រសិទ្ធភាព។ ក្រុមបេសកកម្មដែលរួមមាន តំណាងចំនួន ៤០រូបតំណាងក្រុមដែលមានផលប្រយោជន៍សាធារណៈ ក្រុមគាំពារបរិស្ថាន ក្រុមសេដ្ឋកិច្ច និងធុរកិច្ចជនជាតិដើមអាមេរិក និងទីភ្នាក់ងារនៅកម្រិតភូមិ ក្រុង រដ្ឋ និងតំបន់។ នៅអមប្រធានមានក្រុមអ្នកអព្យាក្រឹត្យដែលមានជំនាញវិជ្ជាជីវៈមួយផងដែរ។ អាណត្តិធំទូលាយរបស់ក្រុមបេសកកម្មនេះ គឺពិនិត្យមើលការអភិវឌ្ឍន៍ដោយចីរភាព ទាំងនៅលើវិសាលភាពភូមិសាស្ត្រ និងវិសាលភាពនៃបញ្ហាហើយភាពចម្រុះនៃអ្នកពាក់ព័ន្ធត្រូវបានប្រើប្រាស់ជាមូលដ្ឋាន ដើម្បីជម្រុញអ្នកពាក់ព័ន្ធឲ្យឈានហួសពីភាពមិនចុះសម្រុងគ្នាដែលបានរាំងកិច្ចព្រមព្រៀងកាលពីអតីតកាលលើបញ្ហាគុណភាពទឹក។ គណៈកម្មការនេះបានបង្កើតឲ្យមានកិច្ចប្រឹងប្រែងមួយ ដើម្បីស្វែងរកការឯកភាពមតិពីអ្នកចូលរួមដែលមិនមានសិទ្ធិបោះឆ្នោតមកពីរដ្ឋាភិបាលសហព័ន្ធ និងក៏បានធ្វើការសហប្រតិបត្តិការដោយផ្ទាល់ជាមួយក្រុមការងារស្របគ្នាមួយនៃទីភ្នាក់ងារនានារបស់រដ្ឋាភិបាល។ អនុលោមតាមច្បាប់របស់រដ្ឋនេះ ការជជែកពិភាក្សាបានធ្វើឡើង

ដោយចំហជាសាធារណៈ។ នេះមានន័យថា សាធារណជនអាចចូលរួមនៅក្នុងគ្រប់កិច្ចប្រជុំ និងផ្តល់យោបល់ នៅក្នុងអំឡុងពេលនៃការទទួលយោបល់ពីសាធារណជន ដែលរួមទាំង អនុគណៈកម្មាធិការ និងកិច្ចប្រជុំពិសេស ដែលធ្វើឡើងដើម្បីដោះស្រាយបញ្ហាលំបាកៗផងដែរ។ ភាគីដែលមានចំណាប់អារម្មណ៍ ដែលមិនមែនជាសមាជិកគណៈកម្មការ ក៏អាចក្លាយជាសមាជិកនៃអនុគណៈកម្មការការងារផងដែរ និងអ្នកខ្លះត្រូវបានទទួលការអញ្ជើញដោយចំហដើម្បីឲ្យចូលរួមជាសមាជិកផងដែរ។

បើទោះជា ប្រធានបានទទួលការតែងតាំងពីក្រុមកសាងផែនការដំបូងរបស់អភិបាលនៃរដ្ឋនេះក៏ដោយ ក៏គណៈកម្មការនេះបានទទួលយកនិត្យានុកូលភាពរបស់ប្រធាន ដោយផ្អែកលើអព្យាក្រឹត្យភាពរបស់គាត់ នៅក្នុងការចាត់ចែងការប្រជុំ។ គាត់បានការទទួលស្គាល់បែបនេះ ដោយសារតែគាត់អាចធានាថា អ្នកពាក់ព័ន្ធទាំងអស់មានឱកាសសំដែងចំណាប់អារម្មណ៍របស់ខ្លួន បុគ្គលនានាដែលបានតែងតាំងក្នុងនាមតំណាងឲ្យផលប្រយោជន៍ខុសៗគ្នាជាច្រើន ដើម្បីចូលរួមដឹកនាំអនុក្រុមបានស្តាប់ដោយយកចិត្តទុកដាក់ និងបានបង្ហាញអំពីការប្តេជ្ញាដោយស្មោះស្ម័គ្រចំពោះមុខក្រុម និងក្នុងការឈានដល់ការឯកភាពមតិ។

ប្រធាន និងអ្នកសម្របសម្រួលបានធ្វើការវាយតម្លៃអំពីវិវាទនេះ ប៉ុន្តែនៅទីបំផុតគឺគណៈកម្មការនេះជាអ្នកធ្វើការសម្រេចថាតើបញ្ហាណាខ្លះគួរតែមាននៅក្នុងរបៀបវារៈ និងតើត្រូវបែងចែកបែបណាឲ្យទៅជាអនុគណៈកម្មការតូចៗ និងនៅពេលណា។ ក្រុមនេះអាចឈានដល់ការឯកភាពគ្នាថា បច្ចុប្បន្ននេះផ្លូវីដាខាងត្បូង "មិនមាននិរន្តរភាពឡើយ"។ ក្រុមនេះបានបង្កើតចក្ខុវិស័យរួមមួយអំពីអ្វីដែលអាចជានិរន្តរភាពសម្រាប់រយៈពេលវែងនៅអេវើគ្លេដ និងបានឯកភាពថា របបគ្រប់គ្រងទឹក គួរតែត្រូវកែប្រែដើម្បីទទួលបានអ្វីដែលជាចក្ខុវិស័យរបស់ពួកគេ។ អនុគណៈកម្មការនេះបានធ្វើការលើបញ្ហាជាក់លាក់ដោយបង្ហាញជូនសេចក្តីព្រាងនានាទៅកិច្ចប្រជុំពេញអង្គអំពីឯកសារនៅក្នុងវឌ្ឍនភាពរបស់ខ្លួន ដែលគូសបញ្ជាក់អំពីអនុសាសន៍នានា ក៏ដូចជា ប្រធានបទនានាដែលសមាជិករបស់ខ្លួននៅពុំទាន់បានឯកភាពគ្នាផងដែរ។

គណៈកម្មការនេះកោះប្រជុំអនុគណៈកម្មការផ្តល់យោបល់វិទ្យាសាស្រ្ត ដើម្បីលើកឡើងអំពីបញ្ហាបច្ចេកទេសដែលនៅចម្រូងចម្រាស ជាពិសេស កិច្ចការនានាដែលត្រូវបានចាត់ទុកថាមានភាពមិនប្រាកដប្រជា។ សមាជិកភាពត្រូវបានបើកចំហរសម្រាប់មនុស្សគ្រប់រូបដែលមានចំណាប់អារម្មណ៍ ហើយរបាយ-ការណ៍មួយត្រូវបានរៀបចំឡើង សម្រាប់ប្រើប្រាស់នៅក្នុងកិច្ចប្រជុំពេញអង្គ។ ភាពមិនប្រាកដប្រជាខ្លះដែលមិនអាចដោះស្រាយបានឡើយ ហើយគណៈកម្មការនេះបានសម្រេចឈានទៅមុខជាមួយអភិក្រមគ្រប់គ្រងបែបបន្សាំ ដែលបង្កើតឡើងនូវកម្មវិធីតាមដានមួយ និងការវាយតម្លៃជម្រើសយថាហេតុនានា។

អ្នកសម្របសម្រួលបានប្រើប្រាស់ដំណើរការនៃបច្ចេកទេសអត្ថបទតែមួយ និងការចាត់ជាអាទិភាពដែលបានជួយគណៈកម្មការនេះនៅក្នុងការចរចាលើរបាយការណ៍បឋមចុងក្រោយ។ ក្រោយមានកិច្ចប្រជុំជាបន្តបន្ទាប់អស់រយៈពេលមួយឆ្នាំកន្លះមក គណៈកម្មការនេះបានអនុម័តជាឯកច្ឆ័ន្ទលើរបាយការណ៍នេះ។ បន្ទាប់ពីនោះ គណៈកម្មការនេះបានបន្តកិច្ចសហប្រតិបត្តិការជាមួយទីភ្នាក់ងារសហព័ន្ធ ដើម្បីបង្កើតផែនការទូលំទូលាយមួយសម្រាប់ស្តារប្រព័ន្ធអេកូឡូស៊ី (CERP) និងកំណត់អត្តសញ្ញាណរបៀបកំណត់អាទិភាព និងស្វែងរកមូលនិធិសម្រាប់គម្រោងនេះ។ នៅចុងបញ្ចប់នៃអាណត្តិរបស់គណៈកម្មការនេះ បុគ្គលទាំងឡាយដែលតំណាងឲ្យផលប្រយោជន៍ខាងបរិស្ថាន និងឧស្សាហកម្មស្ករ បានធ្វើការបញ្ចុះបញ្ចូលរដ្ឋាភិបាលឲ្យអនុវត្ត CERP។ នៅទីបំផុត អនុសាសន៍របស់គណៈកម្មការនេះត្រូវបានដាក់បញ្ចូលទៅក្នុង CERP និងដាក់ទៅក្នុងច្បាប់ថ្មីមួយ។ ទំនាក់ទំនងដែលបានបង្កើតឡើងតាមរយៈការចូលរួមនៅក្នុងគណៈកម្មការនេះ ជាទូទៅនៅតែល្អ ហើយអ្នកពាក់ព័ន្ធនានាបានបន្តចូលរួមក្នុងកិច្ចប្រឹងប្រែងចូលរួមជាសាធារណៈដែលផ្សារភ្ជាប់ជាមួយការអនុវត្តន៍ CERP។

ការសម្រេចថាតើគួរតែពិចារណាផលប្រយោជន៍របស់អ្នកណាខ្លះ ក៏អាចពង្រីកទៅភាគីនានាដែលបច្ចុប្បន្ននេះពុំមានបំណងចូលរួមផងដែរ ប៉ុន្តែអាចមានចំណាប់អារម្មណ៍ក្នុងកិច្ចប្រឹងប្រែងសហប្រតិបត្តិការរួមគ្នាទៅអនាគត។ នៅក្នុងករណី៤.៥ ស្តីពីអាងទន្លេមេគង្គ ប្រទេសទាំងបួននៅខ្សែទឹកខាងក្រោមនៃអាងទន្លេនេះ ពោលគឺ កម្ពុជា ឡាវ វៀតណាម និងថៃ បានចរចាឲ្យមានកិច្ចព្រមព្រៀងឆ្នាំ១៩៩៥ ស្តីពី

ការគ្រប់គ្រងទឹកទន្លេមេគង្គ។ សន្ធិសញ្ញានេះអាចមានការពាក់ព័ន្ធសម្រាប់អាងទន្លេនេះទាំងមូល និងឆ្លើយតបចំពោះផលប្រយោជន៍របស់ប្រទេសដែលមិនទាន់ចូលរួមនៅក្នុងភាគខាងលើនៃអាងទន្លេនេះពោលគឺ ចិន និងមីយ៉ាន់ម៉ា ប្រសិនបើប្រទេសទាំងនេះមានបំណងចូលរួមទៅអនាគត។ អ្នកចូលរួមម្នាក់បានកត់សំគាល់ថា ៖

នៅពេលយើងចាប់ផ្ដើមការចរចានៅដើមឆ្នាំ១៩៩៣ អំពីកិច្ចព្រមព្រៀងឆ្នាំ១៩៩៥ ស្ដីពីទន្លេមេគង្គ ប្រទេសទាំងបួនបានឯកភាពថា ខ្លឹមសារនៃកិច្ចព្រមព្រៀងនេះគួរតែមានលក្ខណៈស្មើភាព និងអាចយកទៅអនុវត្តនៅក្នុងប្រទេសទាំងអស់នៅតាមដងទន្លេនេះ សូម្បីតែប្រទេសចំនួនពីរមិនមែនជាសមាជិកក៏ដោយ... អ្នកចូលរួមគ្រប់រូបបានទទួលស្គាល់ថា ការកសាងផែនការ និងការប្រតិបត្តិលើការអភិវឌ្ឍន៍ដោយចីរភាព អាចនឹងទទួលជោគជ័យបាន តែក្នុងករណីដែលមានការពិចារណាអំពីតំបន់ និងផលប៉ះពាល់នៅក្នុងអាងនេះទាំងមូលតែប៉ុណ្ណោះ សូម្បីតែប្រទេសចំនួនពីរនៅខ្សែទឹកខាងលើមិនមែនជាសមាជិកក៏ដោយ។ មានការពិភាក្សា និងយល់ឃើញផងដែរថា ប្រទេសទាំងពីរនេះអាចចូលរួមនៅក្នុងគណៈកម្មការទន្លេមេគង្គ[57] ហើយកិច្ចព្រមព្រៀងឆ្នាំ១៩៩៥ ស្ដីពីទន្លេមេគង្គ មានចែងសម្រាប់ការចូលរួមរបស់ប្រទេសទាំងនេះនៅក្នុង MRC ទៅអនាគត។[58]

ប្រទេសដែលចូលរួមនៅក្នុងការចរចាប្រឹងប្រែង ដើម្បីធ្វើឲ្យកិច្ចព្រមព្រៀងនេះមានលក្ខណៈពេញលេញ ដោយផ្អែកលើគោលការណ៍នៃច្បាប់អន្តរជាតិដែលមានការទទួលយកជាសកល និងពុំមានការរើសអើងចំពោះប្រទេសដទៃទៀតនៅលើដងទន្លេនេះ ដែលមិនមែនជាសមាជិកនៅក្នុងកិច្ចព្រមព្រៀងនេះពីដំបូងឡើយ។[59]

ដូចគ្នានេះដែរនៅក្នុងអាងទន្លេរ៉ុលតាក្រមអនុវត្តដែលបានចុះហត្ថលេខាដោយប៊ូគីណាហ្វាសូ និងហ្គាណារួមបញ្ចូលមាត្រាដែលចែងច្បាស់លាស់ដើម្បីលើកកំពស់ការអនុម័តដោយរដ្ឋដទៃទៀតនៅតាមដងទន្លេនេះ(ករណី៥.៣ក្នុងជំពូក៥)។

ការប៉ាន់ប្រមាណមួយក្នុងបំណងនាំយកភាគីសមស្របចូលមកក្នុងតុចរចា អាចត្រូវរៀបចំឡើងដូចតទៅ ៖

១. តាមការណែនាំពីបណ្ដាភាគីពីដើមដំបូង (អ្នកកោះប្រជុំសម្រាប់ការចរចានេះ) អ្នកសម្របសម្រួលអព្យាក្រឹត្យ ធ្វើការទាក់ទងជាច្រើនជុំជាមួយក្រុមអ្នកពាក់ព័ន្ធដែលអាចមានសក្ដានុពល ដើម្បីសម្ភាសពួកគេអំពីមូលដ្ឋាននៃលក្ខខណ្ឌ និងមិនមែនជាការកំណត់លក្ខខណ្ឌឡើយ។ នៅក្នុងជុំដំបូង ទំនាក់ទំនងត្រូវធ្វើឡើងជាមួយអ្នកដើរតួច្បាស់លាស់ ដែលបានសំដែងចំណាប់អារម្មណ៍ក្នុងការចូលរួម។ នៅពេលអ្នកសម្របសម្រួលធ្វើការសម្ភាសបុគ្គលទាំងនេះ គាត់ស្នើសុំអនុសាសន៍របស់ពួកគេ ដែលទាក់ទងនឹងក្រុមអ្នកពាក់ព័ន្ធដទៃទៀត ដែលអាចសមស្របសម្រាប់ធ្វើការសម្ភាស។ ប្រការនេះនាំទៅរកការទាក់ទងនៅជុំទីពីរដែលមានទ្រង់ទ្រាយធំជាងមុន។ អ្នកកោះប្រជុំក៏ចុះផ្សាយផងដែរនូវប្រការដែលថា ការវាយតម្លៃនេះកំពុងតែប្រព្រឹត្តទៅ។ ក្រុមនានាដែលចង់ចេញមុខអាចទាក់ទងមកអ្នកសម្របសម្រួលដោយផ្ទាល់។ក្រុមនេះអាចចាត់ទុកថាជាជុំទីបី។
២. ដោយផ្អែកលើការសម្ភាសទាំងនេះ អ្នកសម្របសម្រួលគូសបញ្ជាក់អំពីផែនទីស្ដីពីស្ថានភាពដោយរៀបចំជារបាយការណ៍ ដែលកំណត់អត្តសញ្ញាណជំពូកសំខាន់ៗបំផុតនៃក្រុមអ្នកពាក់ព័ន្ធ និងគូសបញ្ជាក់អំពីកង្វល់សំខាន់ៗរបស់ពួកគេ។ កិច្ចការនេះត្រូវធ្វើឡើងដោយពុំមានស្រង់សំដីរបស់អ្នកណាម្នាក់ឡើយ។ "ផែនទីនេះ" ត្រូវបានបញ្ជូនទៅអ្នកដែលបានទទួលការសម្ភាស ដើម្បីពួកគេអាច

ធ្វើការអះអាងថាតើបញ្ហាដែលពួកគេលើកឡើងត្រូវបានស្រង់យកគ្រប់គ្រាន់ដែរឬទេ។

៣. នៅពេលដែលគ្រប់ភាគីបានឆ្លើយតបទៅនឹងរបាយការណ៍នេះ អ្នកសម្របសម្រួលលើកស្នើឲ្យបង្កើតដំណើរការបង្កើតការឯកភាពមតិមួយ ដោយផ្អែកលើលទ្ធផលពីការវាយតម្លៃនេះ។ ពោលគឺអ្នកសម្របសម្រួលលើកស្នើឲ្យមានបញ្ជីមួយអំពីក្រុមអ្នកពាក់ព័ន្ធដែលគួរបានទទួលការអញ្ជើញចូលរួមនៅក្នុងការប្រជុំ និងជ្រើសរើសតំណាងមួយរូប ដើម្បីចូលរួមនៅក្នុងការចរចា។ លើសពីនេះ ការរៀបចំដំណើរការនេះរួមបញ្ចូលសំណើរបៀបវារៈ បទបញ្ជាផ្ទៃក្នុង ផែនការការងារ (ដែលរួមទាំងអាទិភាពដែលបានពីការស្វែងរកការពិតរួមគ្នា) និងថវិកា។ ឯកសារទាំងនេះក៏ត្រូវតែបញ្ជូនទៅមនុស្សគ្រប់រូបដែលបានសម្ភាសដើម្បីសុំយោបល់ពីពួកគេផងដែរ។

៤. ផ្អែកលើប្រតិកម្មរបស់ពួកគេ អ្នកសម្របសម្រួលលើកស្នើថាតើដំណើរការបង្កើតការឯកភាពមតិ (ដែលក្រុមនេះបានបង្កើតឡើង) គួរតែអនុវត្តឬទេ។ នៅត្រង់ចំណុចនេះ ការសម្រេចអំពីការត្រូវអនុវត្តឬមិនអនុវត្ត គឺអាស្រ័យលើអ្នកកោះប្រជុំ។

*"នៅពេលដែលភាគីនានាស្ថិតនៅក្នុងតុចរចាក្រោមរូបភាពជាការបង្កើតការឯកភាពមតិ ហើយនោះប្រការសំខាន់គឺពួកគេត្រូវពិនិត្យនៅក្នុងស្ថានភាពនៃការជជែកទល់មុខគ្នាអំពីអ្វីដែលនឹងក្លាយជាមុខនាទី និងការទទួលខុសត្រូវរបស់ពួកគេ"*

## *៤.៣.២ ការបំភ្លឺអំពីការទទួលខុសត្រូវ មុខនាទី របៀបវារៈ និងបទបញ្ជាផ្ទៃក្នុង*

នៅពេលដែលភាគីនានាស្ថិតនៅក្នុងតុចរចាក្រោមរូបភាពជាការបង្កើតការឯកភាពមតិហើយនោះ ប្រការសំខាន់គឺពួកគេត្រូវធ្វើការពិនិត្យនៅក្នុងស្ថានភាពដោយជជែកទល់មុខគ្នា អំពីអ្វីដែលនឹងក្លាយជាមុខនាទី និងការទទួលខុសត្រូវរបស់ពួកគេ។ នៅពេលជួបប្រជុំជាលើកដំបូង ក្រុមទាំងមូលត្រូវអនុម័តលើការជ្រើសរើសអ្នកសម្របសម្រួល ឬប្រធាន ក៏ដូចជា របៀបវារៈ ផែនការការងារ ថវិកា បទបញ្ជាផ្ទៃក្នុង និងនីតិវិធីនៃការស្វែងរកការពិតរួមគ្នាផងដែរ។ បើទោះជាមានការលំអៀងបែបណាមួយក៏ដោយ អ្នកសម្របសម្រួលគួរតែអាចផ្តល់ជំនួយដោយគ្មានលំអៀងដល់អ្នកចូលរួមនានា។ ប្រសិនបើអ្នកចូលរួមមានកង្វល់ជ្រាលជ្រៅអំពីអព្យាក្រឹត្យភាពនៃការមិនលំអៀង ពួកគេគួរតែអាចចូលរួមជ្រើសរើសអ្នកសម្របសម្រួលផ្សេងណាម្នាក់។

ឧទាហរណ៍ ភ្នាក់ងារប្រតិបត្តិនៃលេខាធិការដ្ឋាននេះសម្របសម្រួលឲ្យមានអន្តរកម្មរវាងអ្នកចូលរួមនៅក្នុងគណៈកម្មាធិការបណ្តោះអាសន្នទន្លេមេគង្គ។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសខ្លះនៅតាមដងទន្លេនេះបានជឿថា រូបគាត់ និងលេខាធិការដ្ឋាននេះបានបាត់បង់អព្យាក្រឹត្យភាពរបស់ខ្លួន។ ដូច្នេះពួកគេបានដាក់លេខាធិការដ្ឋាននៅក្រៅការចរចាក្នុងការស្វែងរកកិច្ចព្រមព្រៀងថ្មីមួយ។ ជាជំនួស UNDP បានដើរតួកាន់តែសកម្ម ដោយទទួលយកតួនាទីជាអ្នកសម្របសម្រួលសម្រាប់លេខាធិការដ្ឋាននេះ ដោយធ្វើការកោះប្រជុំថ្មីមួយ និងធ្វើការចុះកិច្ចសន្យាជាមួយអ្នកសម្របសម្រួលមួយរូបដែលអាចទទួលយកបាន។ ដោយសារភាគីទាំងអស់មានចំណាប់អារម្មណ៍ថាអ្នកសម្របសម្រួលមានជំហរអព្យាក្រឹត្យ UNDP និងអ្នកសម្រុះសម្រួលអាចជម្រុញការពិភាក្សាឲ្យឈានទៅមុខហួសពីកិច្ចសហប្រតិបត្តិការមិនលំអៀង ហើយបន្ទាប់មកតាមរយៈការចរចាឆ្ពោះទៅរកកិច្ចព្រមព្រៀងថ្មីមួយ ដែលអាចដោះស្រាយបញ្ហាសំខាន់ៗរបស់ភាគីទាំងនេះ។

ក្រុមនេះអាចស្នើសុំឲ្យអ្នកសម្របសម្រួលធ្វើការរៀបចំសេចក្តីសង្ខេបពីការប្រជុំ ឬ តែងតាំងសមាជិកណាម្នាក់របស់ខ្លួនឲ្យធ្វើសេចក្តីសង្ខេបបែបនេះ។ ពួកគេអាចជ្រើសរើសមេដឹកនាំ ឬប្រធានក្រុមមួយរូប ដើម្បីធ្វើជាតំណាងឲ្យដំណើរការនេះនៅចំពោះមុខពិភពលោកទាំងមូល បើទោះជាកិច្ចការនេះជួនកាលត្រូវបានដាក់ជាបន្ទុករបស់អ្នកសម្របសម្រួលក៏ដោយ។ នៅទីបំផុត មុននឹងពួកគេចាប់ផ្តើម ពួកគេអាចសម្រេចថាអ្នកពាក់ព័ន្ធជំពូកខ្លះពុំមានតំណាងគ្រប់គ្រាន់ និងឯកភាពក្នុងការទាក់ទាញបុគ្គល ឬក្រុមនានាជាបន្ថែមទៀត ដើម្បីធ្វើជាតំណាងឲ្យភាគីនានានៅក្នុងតុចរចា។ ក្រុមទាំងនេះដែលមានបទពិសោធន៍ ក្នុងកម្រិតកំណត់លើការចរចា អ្នកសម្របសម្រួល និងភាគីទីបីណាម្នាក់ទៀត អាចកសាងសមត្ថភាពរបស់ខ្លួន ដើម្បីត្រៀមខ្លួនសម្រាប់ដំណើរការនេះ និងចូលរួមនៅក្នុងដំណើរការនេះ ដូចដែលឃើញនៅក្នុងករណី ៤.៣ ក្នុងប្រទេសប៉េរូ។

### *ករណី៤.៣ ការបង្កើតរួមគ្នានូវដំណើរការចរចារវាងក្រុមហ៊ុនប៊ីអេជភីប៊ីលីតុន និងសហគមន៍រងគ្រោះនៅអណ្តូងរ៉ែទីនតាយ៉ានៃប្រទេសប៉េរូ*

វិវាទរវាងក្រុមហ៊ុន ប៊ីអេជភី ប៊ីលីតុន និងសហគមន៍ដែលរស់នៅជិតអណ្តូងរ៉ែទិនតាយ៉ា ក្នុងប្រទេសប៉េរូ បានផ្តោតលើការត្រួតត្រា និងគ្រប់គ្រងធនធានធម្មជាតិ (ការដកហូតកម្មសិទ្ធិលើដីធ្លី) ផលប៉ះពាល់ខាងសង្គមកិច្ច និងសេដ្ឋកិច្ច មកលើសហគមន៍នានា (ការរំលោភលើសិទ្ធិមនុស្ស ឱកាសខាងសេដ្ឋកិច្ចពុំគ្រប់គ្រាន់) និងផលប៉ះពាល់បរិស្ថាន (មកលើទឹក និងដី)។ ការសន្ទនាជាបន្តបន្ទាប់បានធ្វើឡើងនៅរវាងឆ្នាំ ២០០១ និង ២០០៤ ដើម្បីនាំយកភាគីសំខាន់ៗមកជួបគ្នា ដើម្បីចរចាស្វែងរកដំណោះស្រាយចំពោះសារទុក្ខដែលមានរយៈពេលយូរមកហើយ និងបង្កើតឲ្យមានទំនាក់ទំនងស្ថាបនាជាងមុនមួយ រវាងសហគមន៍ និងក្រុមហ៊ុនរ៉ែ។ បន្ថែមលើតំណាងមកពីក្រុមហ៊ុនរ៉ែ និងសហគមន៍ជិតខាងចំនួនប្រាំ ដំណើរការពហុអ្នកពាក់ព័ន្ធនេះមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិផងដែរ (គណៈកម្មាធិការសម្របសម្រួលនៅថ្នាក់ជាតិ និងតំបន់ដែលរងគ្រោះដោយសារអាជីវកម្មរ៉ែ (CONACAMI និង CORE-CAMI Cusco), CooperAccion អុកស្វាមអាមេរិក និងការិយាល័យអុំបាត់ស្មែនសម្រាប់អាជីវកម្មរ៉ែនៃអង្គការអុកស្វាម ជំនួយសហគមន៍នៅបរទេស ក្នុងប្រទេសអូស្ត្រាលី) ដែលបានជួយសម្របសម្រួលដល់ដំណើរការនេះ និងពង្រឹងសមត្ថភាពរបស់សហគមន៍ជនជាតិដើម ដើម្បីត្រៀមខ្លួនឲ្យបានគ្រប់គ្រាន់ និងចូលរួមនៅក្នុងការចរចាទាំងនេះ។

MSP ពាក់ព័ន្ធនឹងដំណាក់កាលជាច្រើន ដើម្បីបង្កើតរបៀបវារៈរួមគ្នាមួយ និងដំណើរការពេញលេញមួយសម្រាប់ការចរចា ការកសាងទំនុកចិត្ត ធ្វើការសិក្សារួមគ្នា ដើម្បីបង្កើនការយល់ដឹងអំពីសារទុក្ខ និងចរចាអំពីការប្តេជ្ញាមួយឈុត។

សេចក្តីព្រាងកិច្ចព្រមព្រៀងមួយដែលរៀបចំឡើងដោយគណៈកម្មាធិការស្ទួលមួយ ដែលជាតំណាងឲ្យអ្នកពាក់ព័ន្ធទាំងអស់ និងបានផ្តល់សុពលភាព និងធ្វើវិសោធនកម្ម តាមរយៈសិក្ខាសាលានានា ជាមួយតំណាងជាច្រើនមកពីសហគមន៍ ក្រុមហ៊ុន និងអង្គការមិនមែនរដ្ឋាភិបាល ដែលមានការពិនិត្យអត្ថបទគ្រប់បន្ទាត់។ អត្ថបទចុងក្រោយត្រូវបានបង្ហាញ និងអនុម័តនៅក្នុងកិច្ចប្រជុំពេញអង្គនៅក្នុងសហគមន៍នីមួយៗក្នុងចំណោមសហគមន៍ទាំងប្រាំ និងបានចុះហត្ថលេខាពីសំណាក់ភាគីទាំងអស់។

កិច្ចព្រមព្រៀងនេះលើកឡើងនូវគ្រប់សារទុក្ខ៖ មានចែងអំពីការទូទាត់សំណងដល់សហគមន៍ដែលមានដីធ្លី (ច្រើនជាងអ្វីដែលត្រូវបានដកហូត) រួមជាមួយជំនួយបច្ចេកទេស ដើម្បីជួយបង្កើតឱកាសថ្មីសម្រាប់មុខរបរចិញ្ចឹមជីវិត។ កិច្ចព្រមព្រៀងនេះបង្កើតកម្មវិធីត្រួតពិនិត្យបរិស្ថាន ដែលសមាជិកសហគមន៍ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការតាមដានជាប់ជាប្រចាំលើការគោរពរបស់ក្រុមហ៊ុន នូវវិធានការនានា ដើម្បីកាត់បន្ថយ ឬបន្ធូរបន្ថយផលប៉ះពាល់បរិស្ថាន។ កិច្ចព្រមព្រៀងនេះបានបង្កើតក្រុមការងារមួយ

ដើម្បីត្រួតពិនិត្យលើការគោរពរបស់ក្រុមហ៊ុន ក្នុងការទូទាត់សំណងដល់ជនរងគ្រោះដែលបានបញ្ជាក់ថាបានរងអំពើរំលោភលើសិទ្ធិមនុស្ស និងដើម្បីវាយតម្លៃលើបណ្តឹងថ្មីៗ។ កិច្ចព្រមព្រៀងនេះចែងអំពីជំហានដើម្បីបង្កើត និងផ្តល់មូលនិធិសម្រាប់ផែនការអភិវឌ្ឍន៍ដោយចីរភាព ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍សម្រាប់រយៈពេលមធ្យម និងរយៈពេលវែងនៅក្នុងសហគមន៍រងគ្រោះ និងមានការប្តេជ្ញាពីក្រុមហ៊ុនក្នុងការធ្វើឲ្យមានការព្រមព្រៀងប្រកបដោយការយល់ដឹងជាមុនសម្រាប់សកម្មភាពជីកយករ៉ែទៅអនាគតនៅក្នុងដែនដីថ្មីៗ។

ការសម្របសម្រួលពហុអ្នកពាក់ព័ន្ធ និងគណៈកម្មាធិការបន្ត បានផ្តល់នូវភារៈទទួលខុសត្រូវលើការអនុវត្តន៍ និងត្រួតពិនិត្យលើកិច្ចព្រមព្រៀងនេះ។ ភាគីទាំងអស់បានប្តេជ្ញាបន្តប្រើប្រាស់តុសន្ទនានេះ ដើម្បីលើកឡើង និងដោះស្រាយការលំបាកនានាដែលលេចឡើង។ អ្នកចូលរួមបានទទួលស្គាល់ថា ក្នុងពេលដែលការសន្ទនា និងកិច្ចព្រមព្រៀងដែលទទួលបាន បានកែប្រែយ៉ាងច្រើននូវទំនាក់ទំនងក្នុងចំណោមភាគីដែលធ្លាប់តែមានវិវាទនឹងគ្នា ទំនាក់ទំនងសហការពិតប្រាកដអាចកើតឡើងបាន អាស្រ័យលើការអនុវត្តប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលានូវការប្តេជ្ញា និងការចូលរួមជាប់ជាបន្ត ដើម្បីដោះស្រាយបញ្ហា ដែលលេចឡើងបន្ថែមតែប៉ុណ្ណោះ "ការសម្រេចបាននូវការកែប្រែស៊ីជម្រៅបែបនេះនឹងទាមទារឲ្យមានកិច្ចប្រឹងប្រែងជាប់ជាប្រចាំ ដើម្បីជំនះភាពមិនស្របគ្នាខាងអំណាចដែលបង្ហាញពីទំនាក់ទំនងរវាងកិច្ចសហប្រតិបត្តិការ និងសហគមន៍"។

កិច្ចប្រឹងប្រែងបង្កើតការឯកភាពមតិ នឹងផ្តល់ជាប្រយោជន៍តែនៅពេលណាដែលតំណាងនានា ចូលរួមនៅក្នុងកិច្ចប្រឹងប្រែងជាប់ជាប្រចាំ ដើម្បីរក្សាទំនាក់ទំនងជាមួយមណ្ឌលនានាដែលខ្លួនធ្វើជាតំណាងពេញមុខ។ សម្រាប់ក្រុមខ្លះ ការធ្វើបែបនេះគឺជាកិច្ចការងាយស្រួល ដោយពួកគេបានបង្កើតយន្តការប្រាស្រ័យទាក់ទងផ្ទៃក្នុងបានល្អ។ សម្រាប់ក្រុមផ្សេងទៀត វាមានការលំបាកជាខ្លាំង។ នេះពិតជាករណីមួយសម្រាប់បណ្តាញបណ្តោះអាសន្ននៃបុគ្គល ឬអង្គការនានាដែលបង្កើតឡើងជាមួយគ្នាដោយគ្មានជំនាញជាក់លាក់ក្នុងបំណងចូលរួមនៅក្នុងកិច្ចប្រឹងប្រែងបង្កើតការឯកភាពមតិ។ ក្រុមបែបនេះអាចត្រូវការជំនួយពីសំណាក់អ្នកសម្របសម្រួល ដើម្បីបង្កើតមធ្យោបាយសម្រាប់អន្តរអំពើជាទៀងទាត់។ អ្នកចូលរួមច្រើន តែត្រូវបានស្នើសុំឲ្យបង្កើតបទបញ្ជាផ្ទៃក្នុងដែលចែងច្បាស់លាស់អំពីកាតព្វកិច្ចរបស់អ្នកចូលរួម ដើម្បីរក្សាទំនាក់ទំនងជាមួយ "មណ្ឌល" ដែលខ្លួនត្រូវគេរំពឹងថាសំដែងមតិ "គាំទ្រ" ឬសំដែងមតិ "ដូច"។

## *៤.៣.៣ ការពិចារណា ការចូលរួមនៅក្នុងការស៊ើបអង្កេត ការពិភាក្សា ការសិក្សារៀនសូត្រ*

ដោយសារប្រព័ន្ធអេកូឡូស៊ីជាច្រើនមានលក្ខណៈស្មុគស្មាញ វាជាការលំបាកក្នុងការវាយតម្លៃលក្ខណៈដែលមានស្រាប់ រីឯការបង្កើតចក្ខុវិស័យរួមអំពីថាតើប្រព័ន្ធអេកូឡូស៊ីនេះគួរបំពេញមុខងារបែបណារឹតតែពុំទាន់រីកចម្រើនផងដែរ តាមធម្មតាភាគីនៅក្នុងការចរចា ចូលរួមនៅក្នុងការស្វែងរកការពិតដើម្បីជាមូលដ្ឋានសម្រាប់ការពិភាក្សារបស់ពួកគេ។ ប្រសិនបើអ្នកចូលរួមដឹងថាពួកគេចង់ធ្វើសហប្រតិបត្តិការ ប៉ុន្តែមិនចង់ចូលរួមនៅក្នុងការចរចាឆ្ពោះទៅរកកិច្ចព្រមព្រៀងផ្លូវការមួយ ដោយសារតែពួកគេពុំមានព័ត៌មានគ្រប់គ្រាន់ ពួកគេអាចចាប់ផ្តើមដោយបង្កើតយន្តការនានា ដើម្បីប្រមូលទិន្នន័យរួមគ្នា។

*"ភាគីនៅក្នុងការចរចាចូលរួមនៅក្នុងការស្វែងរកការពិតដើម្បីជាមូលដ្ឋានសម្រាប់ការពិភាក្សារបស់ពួកគេ"*

សកម្មភាពប្រមូលទិន្នន័យភាគច្រើនរបស់ប្រទេសនៅក្នុងអាងទន្លេដានូបេ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ និងរបស់គណៈកម្មាធិការទន្លេមេគង្គក្នុងទសវត្សរ៍ឆ្នាំ ១៩៦០-១៩៨០ បង្ហាញពីរបៀបដែលប្រទេសទាំង

នេះអាចរៀនសូត្រដើម្បីធ្វើការជាមួយគ្នានៅកម្រិតបច្ចេកទេស។ នៅក្នុងករណី ៥.៣ ក្រុមសហគមន៍ និង អង្គការមិនមែនរដ្ឋាភិបាល បានធ្វើការជាមួយក្រុមហ៊ុនអាជីវកម្មរ៉ែ ដើម្បីកំណត់ និងអនុវត្តន៍ការងារស្វែងរកការពិតជាមួយគ្នា លើបញ្ហាគន្លឹះនានា មុននឹងចូលចរចាអំពីចំណាត់ការចាំបាច់។ ដូចគ្នានេះដែរ តំណាងនានាមកពីទាំងក្រុមគាំទ្រ និងក្រុមប្រឆាំងទំនប់នៅនេប៉ាល់ បានធ្វើការសិក្សាជាច្រើន ដើម្បីស៊ើបអង្កេតជាមួយគ្នាអំពីស្ថានភាពនៃបទពិសោធន៍អំពីថាមពលវារីអគ្គិសនីនៅប្រទេសនេប៉ាល់ ដែលជាជំហានដំបូងក្នុងការបង្កើតគោលការណ៍ណែនាំជាក់លាក់ប្រចាំប្រទេសដោយផ្អែកលើរបាយការណ៍របស់ WCD។ បទពិសោធន៍ពីការធ្វើការជាលក្ខណៈសមូហភាព ក៏ដូចជា ទិន្នន័យដែលប្រមូល បានបង្កើនទំនុកចិត្តថា កិច្ចព្រមព្រៀងមួយអាចសម្រេចទៅបាន ដើម្បីការពារផលប្រយោជន៍របស់អ្នកចូលរួម។

ប្រសិនបើអ្នកចូលរួមអាចឯកភាពជាផ្លូវការលើគោលការណ៍រួម ពួកគេអាចសម្រេចដើម្បីពន្យាពេលលើកិច្ចការបច្ចេកទេស ដើម្បីទុកឲ្យស្ថាប័នបច្ចេកទេសធ្វើការអនុវត្តនៅពេលក្រោយ។ ប្រទេសនៅក្នុងអាងទន្លេដេនូបេ បានសម្រេចយកអភិក្រមនេះ ដោយជាដំបូងបានបង្កើតកិច្ចព្រមព្រៀងក្របខ័ណ្ឌមួយ និងបន្សល់ទុកស្តង់ដារគុណភាពទឹកជាក់លាក់ ដើម្បីធ្វើការដោះស្រាយនៅក្នុងរបៀបវារៈរបស់គណៈកម្មការដែលពួកគេបង្កើតឡើង ពោលគឺ ICPDR។ នៅក្នុងករណីនេះ ភាគីនានាត្រូវបង្កើតយន្តការប្រមូលទិន្នន័យដែលនឹងផ្តល់ព័ត៌មានរួមគ្នា ដើម្បីជាមូលដ្ឋានសម្រាប់ការសម្រេចនៅពេលក្រោយ។ អ្នកដែលហៅថា "ភាគីទីបី" អាចដើរតួយ៉ាងសំខាន់នៅក្នុងការផ្តល់ហិរញ្ញប្បទានសម្រាប់យន្តការទាំងនេះ និងកសាងសមត្ថភាពបច្ចេកទេស និងវិជ្ជាជីវៈដែលត្រូវការឲ្យមានជាចាំបាច់។ ទោះជាយ៉ាងណាក៏ដោយ ក្នុងពេលដែលប្រទេសនៅតាមដងទន្លេដានូបេបានរៀនសូត្រមុននឹងពួកគេបានបង្កើតទិន្នន័យរួមគ្នាជាផ្លូវការ លើកលែងតែអ្នកចូលរួមទាំងអស់ឯកភាពលើវិធីប្រមូលទិន្នន័យ គេអាចមិនមានការទទួលស្គាល់លើព័ត៌មានដែលប្រមូលបាន និងថាជាព័ត៌មានដែលមានប្រយោជន៍ឡើយនៅពេលក្រោយមក។

អ្នកចូលរួមក៏អាចដាក់បញ្ចូលការស្វែងរកការពិតរួមគ្នា ទៅក្នុងការចរចាបង្កើតការឯកភាពមតិផងដែរ។ ដូចដែលអធិប្បាយនៅក្នុងករណីទន្លេមេគង្គ ភាគីទីបីក៏អាចជួយធ្វើឲ្យការចរចាឈានទៅមុខផងដែរ។ នៅពេលដែលរដ្ឋទាំងបួននៅក្នុងការចរចា ឈានដល់ "ភាពទ័លច្រក" UNDP បានគាំទ្រដល់ការពិគ្រោះយោបល់មិនផ្លូវការ ដើម្បីជួយឲ្យប្រទេសនីមួយៗលើកឡើងវិញនូវចំណាប់អារម្មណ៍របស់ខ្លួន នៅក្នុងការសហប្រតិបត្តិការនេះ។ ការចូលរួមយ៉ាងសកម្មរបស់ UNDP ដោយធ្វើការកោះប្រជុំ ផ្តល់មូលនិធិសម្រាប់ទីប្រឹក្សាជាន់ខ្ពស់ (អព្យាក្រឹត្យ) និងបំពេញការចំណាយសម្រាប់ការចូលរួមរបស់ប្រតិភូនៃប្រទេសជាអ្នកចូលរួម មានសារៈសំខាន់ណាស់ នៅក្នុងការជម្រុញការចរចាឲ្យឈានឆ្ពោះទៅរកជោគជ័យនៅក្នុងការរៀបចំសេចក្តីព្រាងកិច្ចព្រមព្រៀងក្របខ័ណ្ឌមួយ។

ដូចនៅក្នុងករណីអេវើគ្លេដនៅផ្លរីដាផងដែរ តាមរយៈការជួយពីអ្នកសម្របសម្រួលអព្យាក្រឹត្យ ក្រុមនេះអាចចាប់ផ្តើម ដោយពិនិត្យមើលផលប្រយោជន៍របស់ក្រុមអ្នកពាក់ព័ន្ធនីមួយៗ។ តាមធម្មតា បន្ទាប់មកអ្នកពាក់ព័ន្ធនានា ធ្វើការសម្រេចរួមគ្នាអំពីប្រភេទទិន្នន័យដែលពាក់ព័ន្ធ និងដែលត្រូវការជាចាំបាច់។ អ្នកពាក់ព័ន្ធនានាធ្វើការជាមួយគ្នា ដើម្បីបង្កើតឲ្យមានការសិក្សា និងយុទ្ធសាស្ត្រនានា សម្រាប់ទទួលបានទិន្នន័យ វិភាគទិន្នន័យ និងបង្កើតការព្យាករណ៍ ដែលអាចជាមូលដ្ឋានសម្រាប់ការសម្រេចលើការឯកភាពមតិ។ ជាញឹកញាប់ដើម្បីបំពេញតាមតម្រូវការរបស់ក្រុមអ្នកពាក់ព័ន្ធខុសៗគ្នា គេត្រូវការទិន្នន័យតាមទម្រង់ខុសៗគ្នា ដូចជាក្រោមរូបភាពជាការសិក្សាបច្ចេកទេសលើមុខជំនាញនានា ក៏ដូចជា ចំណេះដឹងនៅមូលដ្ឋាន និងរបស់ជនជាតិដើមផងដែរ (ពោលគឺ អ្វីៗដែលប្រជាពលរដ្ឋដែលរស់នៅក្នុងកន្លែង

មួយដឹង ដែលអ្នកជំនាញការមកពីខាងក្រៅមិនដឹងសោះ)។ ក្រុមបង្កើតការឯកភាពមតិ ជូនកាលព្រមព្រៀងគ្នាដើម្បីអញ្ជើញអ្នកជំនាញការជាច្រើនមកពីខាងក្រៅ ដើម្បីបង្ហាញជូនអំពីកិច្ចការបច្ចេកទេស ដែលជាញឹកញាប់គូសបញ្ជាក់អំពីការមិនចុះសម្រុងគ្នាលើវិធី និងការសន្មត។ អនុគណៈកម្មការបច្ចេកទេសអាចត្រូវបង្កើតឡើងដើម្បីបង្កើតរបាយការណ៍សារតាសម្រាប់ក្រុមនេះ។ ក្រុមអ្នកជំនាញការអាចត្រូវបង្កើតឡើងដើម្បីជួយបង្កើតចំណេះដឹងក្នុងចំណោមសមាជិកខ្លះៗនៅក្នុងក្រុម លើការពិចារណា បច្ចេកទេសខុសៗគ្នាមួយចំនួន។

នៅពេលដែលការស្វែងរកការពិតត្រូវបានបញ្ចប់ហើយនោះ ក្រុមនេះចូលរួមនៅក្នុងដំណើរការបំផុសគំនិត។ ផ្អែកលើលទ្ធផលពីការស្វែងរកការពិតរួមគ្នា គោលដៅនៅទីនេះគឺបង្កើតជម្រើស និងកញ្ចប់អន្តរាគមន៍នានាដែលឆ្លើយតបទៅនឹងកង្វល់របស់ភាគីទាំងអស់។ឧបករណ៍នានាអាចយកមកប្រើប្រាស់ដើម្បីជួយអ្នកចូលរួមនៅក្នុងការវាយតម្លៃជម្រើសនានា និងឈានដល់ការសម្រេច ដូចដែលមានបង្ហាញនៅក្នុងករណី៤.៤ ស្តីពីការកសាងផែនការនៅប្រឹតធីសក្វូឡុំប៊ី នៃប្រទេសកាណាដា។ ផ្អែកលើការពិភាក្សាក្នុងក្រុមទាំងមូល ក៏ដូចជា ការប្រជុំតាមទម្រង់ខុសៗគ្នា អ្នកអព្យាក្រឹត្យរៀបចំអត្ថបទចរចាដែលក្រុមនេះអាចពិនិត្យយ៉ាងលំអិត។ សម្រាប់ការចរចាខ្លះ កិច្ចការនេះអាចពាក់ព័ន្ធជាមួយការពិនិត្យក្នុងពេលជាមួយគ្នា លើអត្ថបទជាច្រើនភាសា។ ជូនកាល ប្រសិនបើក្រុមនេះមានទំហំធំ គេមានជំនួយការសម្រាប់ការធ្វើសេចក្តីសម្រេចតាមប្រព័ន្ធអ៊ីនធឺណិត ដែលអាចប្រើប្រាស់សម្រាប់ជម្រើសខុសៗគ្នា និងវិធីនានាដែលក្នុងនោះអ្នកចូលរួមខុសៗគ្នាដាក់ពិន្ទុលើជម្រើសទាំងនោះ។ ដូចគ្នានេះដែរ ឧបករណ៍តាមវេបសាយក៏អាចយកមកប្រើប្រាស់ផងដែរដើម្បីអនុញ្ញាតឲ្យអ្នកចូលរួមធ្វើអន្តរកម្មរវាងកិច្ចប្រជុំនានាជាមួយមណ្ឌលគាំទ្ររបស់ខ្លួន និងចែករំលែកប្រតិកម្មពិស្តាររបស់ខ្លួន នៅក្នុងអត្ថបទចរចាស្មុគស្មាញ។

*"គោលដៅគឺបង្កើតជម្រើស និងកញ្ចប់អន្តរាគមន៍នានាដែលឆ្លើយតបទៅនឹងកង្វល់នានារបស់ភាគីទាំងអស់"*

### *ករណី៤.៤ ការធ្វើសេចក្តីសម្រេចជារចនាសម្ព័ន្ធនៅក្នុងការកសាងផែនការប្រើប្រាស់ទឹកនៅប្រឺធីសក្វូឡុំប៊ីយ៉ានៃប្រទេសកាណាដា*

ដំណើរការធ្វើសេចក្តីសម្រេចជារចនាសម្ព័ន្ធ នៃកិច្ចផ្តួចផ្តើមកសាងផែនការប្រើប្រាស់ទឹកនៅប្រឹធីស ក្វូឡុំប៊ីយ៉ា គូសបញ្ជាក់អំពីថាតើដំណើរការពិចាណារណាមួយដែលអាចលាតត្រដាង និងស្រង់យកឧទាហរណ៍ខ្លះៗសម្រាប់ការធ្វើសេចក្តីសម្រេចដែលមាន។ និយ័តករ ប៊ីស៊ីហាយដ្រូ និងអ្នកពាក់ព័ន្ធជាច្រើន រួមមានពលរដ្ឋនៅមូលដ្ឋាន តំណាងនៃជនជាតិដើមម្ចាស់ស្រុក អ្នកមានចំណាប់អារម្មណ៍ខាងបរិស្ថាន អ្នកប្រើប្រាស់ធនធាន រដ្ឋាភិបាល និងទីភ្នាក់ងារនិយ័តកម្ម បានកំណត់អត្តសញ្ញាណនៃបញ្ហាជាក់លាក់សម្រាប់បេសកកម្មស្វែងរកការពិតរួមគ្នា តាមរយៈអនុគណៈកម្មការបច្ចេកទេស។ រួមជាមួយគ្នា ក្រុមនេះបានបង្កើតផែនទីបង្ហាញផ្លូវមួយសម្រាប់ដំណើរការមួយដែលតាមរយៈដំណើរការនេះពួកគេអាចលើកឡើង និងពិនិត្យមើលការទាមទាររបស់ពួកគេ ពិនិត្យមើលការដោះដូរ និងការពាក់ព័ន្ធនៃជម្រើសជំនួសនានា និងស្វែងរកជម្រើសជំនួសថ្មីៗដែលអាចទទួលយកបានទៅវិញទៅមក។
ពួកគេមានជំនួយពីឧបករណ៍ធ្វើសេចក្តីសម្រេចជាក់លាក់៖ ១) ឋានានុក្រមនៃគោលបំណង បានជួយឲ្យអ្នកចូលរួមនានារួមចំណែកក្នុងការកំណត់អត្តសញ្ញាណអាទិភាព និងការបង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃជម្រើសជំនួសនានា ២) ដ្យាក្រាមឥទ្ធិពល បានជួយអ្នកចូលរួមក្នុងការប្រើប្រាស់បច្ចេកទេសខុសៗគ្នាក្នុងការស្វែងយល់អំពីផលវិបាកពីជម្រើសខុសៗគ្នា និងកំណត់អត្តសញ្ញាណវិស័យនានាដែល

អាចនាំឲ្យមានផលចំណេញសម្រាប់ទាំងអស់គ្នា និងដែលអាចធ្វើការដោះដូរបាន ៣) ចាត់ជាលំដាប់ និងពិចារណាលើអាទិភាពនៃការដោះដូរ ដែលបានលើកឡើងអំពីភាពខុសគ្នានៃគុណតម្លៃពីក្នុងចំណោមអ្នកពាក់ព័ន្ធ។ តាមរយៈដំណើរការនេះ អ្នកចូលរួមបានបង្កើតអនុសាសន៍អំពីការប្រើប្រាស់ទឹកដែលផ្សារភ្ជាប់ជាមួយយន្តការនានាសម្រាប់ការអនុវត្ត។ នៅទីបំផុត ដំណើការនេះត្រូវបានអនុវត្តជាបន្ត តាមរយៈការតាមដានការកសាងសមត្ថភាព និងការពិនិត្យមើលគោលនយោបាយកំពុងអនុវត្ត ដើម្បីបន្តការរៀនសូត្រក្នុងសង្គម និងការគ្រប់គ្រងទឹកតាមបែបបន្សាំ។

## *៩.៣.៩ ការចរចាដើម្បីបានកិច្ចព្រមព្រៀងមួយដែលមានយុត្តិធម៌ និងប្រសិទ្ធភាពជាងមុន*

ការចរចាដ៏ស្មុគស្មាញអំពីទឹក អាចត្រូវចំណាយពេលជាច្រើនខែ ទើបអាចដោះស្រាយបាន។ ការបង្កើតឲ្យមានការឯកភាពមតិមានដំណើរការល្អបំផុតនៅពេលដែលក្រុមណាមួយកំណត់របៀបវារៈ(និងកាលវិភាគ)និងគោរពទៅតាមរបៀបវារៈនោះ។ក្រុមធំអាចកម្មវិធីប្រជុំប្រចាំខែសម្រាប់រយៈពេលប្រាំមួយទៅប្រាំបីខែនៅក្រោយពេលកម្មវិធីត្រូវបានចាត់ចែងរួច(ដែលនៅក្នុងពេលនោះរបៀបវារៈនិងកាលវិភាគត្រូវបានអនុម័តឯកភាព)និងនៅមុនការប្រជុំចុងក្រោយដើម្បីចុះហត្ថលេខាលើអត្ថបទដែលបានឯកភាពរួចហើយ។ អនុគណៈកម្មការ ឬការប្រជុំនានា អាចកោះប្រជុំប្រចាំខែ ដោយមានជំនួយគាំទ្រពីអ្នកសម្របសម្រួល ដើម្បីរៀបចំសេចក្តីថ្លែងការណ៍ ឬរបាយការណ៍នានាសម្រាប់ក្រុមទាំងមូល។ ការមានពេលវេលាគ្រប់គ្រាន់ គឺមានសារៈសំខាន់ណាស់ក្នុងការបង្កើតឱកាសសម្រាប់ទទួលផលទាំងអស់គ្នា ដែលនឹងត្រូវតែកំណត់រក និងធ្វើការដោះដូររវាងជម្រើសជំនួសខុសៗគ្នា ដូចដែលឃើញនៅក្នុងករណី ៩.៥ ស្តីពីកិច្ចព្រមព្រៀងទន្លេមេគង្គ។

*"ការចរចាដ៏ស្មុគស្មាញអំពីទឹកអាចត្រូវចំណាយពេលជាច្រើនខែ ឬរហូតដល់ច្រើនឆ្នាំទើបអាចដោះស្រាយ"*

*ករណី៩.៥ការដោះដូររវាងជម្រើសជំនួសនានានៅក្នុងអាងទន្លេមេគង្គ[61]*

នៅក្នុងការចរចាអំពីទន្លេមេគង្គ ប្រទេសទាំងបួននៅខ្សែទឹកខាងក្រោម បានឈានដល់កិច្ចព្រមព្រៀងសម្រាប់ការប្រើប្រាស់ និងការអភិវឌ្ឍន៍ទឹកដោយចីរភាព និងបានបង្កើតគណៈកម្មការទន្លេមេគង្គ (MRC)។ នៅក្នុងបរិបទនៃមាត្រាដទៃទៀត នៅក្នុងកិច្ចព្រមព្រៀងមេគង្គ ឆ្នាំ១៩៩៥ ពួកគេបានឯកភាពក្នុងការទទួលយកកញ្ចប់សំណើមួយ ដែលរួមទាំងគោលការណ៍នៃការប្រើប្រាស់ដោយសមហេតុផល និងដោយសមធម៌(មាត្រា៥)។លើសពីនេះប្រទេសទាំងបួនចង់បានកិច្ចព្រមព្រៀងមួយមានភាពបត់បែនបាន ដែលអាចបន្សាំទៅនឹងលក្ខខណ្ឌទៅអនាគត ប៉ុន្តែមានភាពជាក់លាក់គ្រប់គ្រាន់ ដើម្បីអាចទទួលបានផលប្រយោជន៍របស់ពួកគេ ដែលជាកង្វល់ជាអាទិភាពនៅក្នុងប្រទេសនីមួយៗ។

ប្រទេសថៃ មានកង្វល់ពីដំបូងថា ប្រទេសដទៃអាចបោះឆ្នោតជំទាស់លើការអភិវឌ្ឍន៍ បានជម្រុញឲ្យមានជំហរដែលថាប្រទេសនីមួយៗតាមដងទន្លេនេះគួរតែអាចអនុវត្តដោយឯកច្ឆ័ន្ទ ក្នុងការប្រើប្រាស់ទឹកពីដៃទន្លេមេគង្គនៅក្នុងដែនដីរបស់ខ្លួន ដោយពុំចាំបាច់មានការអនុម័តពីប្រទេសដទៃទៀតនៅតាមដងទន្លេនេះឡើយ។ នៅក្នុងការឯកភាពជាមួយកម្ពុជា ឡាវ និងវៀតណាមបានលើកឡើងអំពីការព្រួយបារម្ភក្នុងការការរក្សាកម្រិតលំហូរនៅក្នុងទន្លេមេនៅក្នុងរដូវប្រាំង និងបានលើកឡើងនូវជំហរដែលអំពីការតម្រូវឲ្យមានការឯកភាពពីគណៈកម្មាធិការបច្ចេកទេសរួមមួយ មុនមានគម្រោងណាមួយដែលបង្វែទឹកចេញពីទន្លេមេ។ នៅក្នុងការចរចា វៀតណាមលើកសំណើថា "...ទទួលស្គាល់ជាចំហរថា ការពិគ្រោះយោបល់បែបនេះ មិនមែនជាសិទ្ធិវេតូពីសំណាក់ប្រទេសណាមួយនៅតាមដងទន្លេនេះឡើយ" ដូចមានអធិប្បាយតាមរយៈអត្ថបទនៅពេលក្រោយមកសម្រាប់មាត្រា១៥។ ទោះបីចំណាប់អារម្មណ៍នេះត្រូវបាន

ចាត់ទុកថាមិនចាំបាច់ក៏ដោយ វាគឺជាកិច្ចប្រឹងប្រែងមួយដើម្បីដោះស្រាយកង្វល់របស់ប្រទេសថៃ តាមរយៈការធានាថា គ្មានចំណុចណាមួយនៅក្នុងគោលការណ៍សហប្រតិបត្តិការនេះនឹងត្រូវយកមកប្រើប្រាស់ដើម្បីវេត្វជំទាស់នឹងការប្រើប្រាស់សមហេតុផលពីសំណាក់ប្រទេសណាមួយ នូវភាគចំណែកសមស្របរបស់ខ្លួននៃទឹកទន្លេមេគង្គឡើយ។ ប្រទេសទាំងនេះបានឯកភាពគ្នាជាបណ្តោះអាសន្នលើគោលការណ៍ស្តីពីលក្ខខណ្ឌសម្រាប់ការប្រើប្រាស់ទឹកនៅក្នុងរដូវវស្សា ក្នុងដៃទន្លេនានា និងទន្លេមេនេះ អាស្រ័យលើដំណោះស្រាយអំពីលក្ខខណ្ឌសម្រាប់ការប្រើប្រាស់ទឹកពីទន្លេមេនៅក្នុងរដូវវស្សា។ មាត្រា ៦ នៃកិច្ចព្រមព្រៀងនេះចែងពិស្តារអំពីលក្ខខណ្ឌសម្រាប់ការរក្សាលំហូរគោលនៅក្នុងទន្លេមេ ដែលរួមទាំងនៅក្នុងរដូវប្រាំងផងដែរ។ នៅក្នុងមាត្រា ២៦ ប្រទេសនៅក្នុងការចរចាលើកឡើងអំពីក្របខ័ណ្ឌស្ថាប័ន និងគូសបញ្ជាក់អំពីវិធីដែលគណៈកម្មាធិការរួមរបស់ MRC នឹងបង្កើតបទបញ្ជាសម្រាប់ការប្រើប្រាស់ទឹក និងការបង្វែរទឹកនៅក្នុងអាងទន្លេ។ បទបញ្ជានេះដែលរួមបញ្ចូលទាំងការធានាថាការជូនដំណឹងអំពីសំណើប្រើប្រាស់ ត្រូវតែផ្តល់ពេលវេលាឲ្យបានគ្រប់គ្រាន់សម្រាប់ការកសាងផែនការ នៅមុនរដូវប្រាំងមកដល់។ បទបញ្ជាទាំងនោះក៏ចែងផងដែរអំពីការកែលម្អលើការតាមដាន តាមរយៈស្ថានីយ៍ជលសាស្ត្រ និងយន្តការនានា សម្រាប់តាមដានការប្រើប្រាស់ទឹកនៅក្នុងអាងទន្លេ និងការបង្វែរទឹកនៅក្នុងអាងទន្លេពីទន្លេមេផងដែរ។

ចំណុចទាំងនេះអាចចាត់ទុកថាជាផ្នែកមួយនៃកញ្ចប់ដែលបង្កើតបានជាមាត្រា ៥ ដែលភាគីទាំងនេះអាចទទួលយកបានហើយមាត្រានេះ ក៏មានចែងពីលក្ខខណ្ឌនានាសម្រាប់ការប្រើប្រាស់ទឹកមកពីទន្លេមេនៅក្នុងរដូវប្រាំង។ នៅពេលក្រោយមកប្រទេសទាំងនេះទទួលយកកញ្ចប់នេះដែលបង្កើតឡើងដោយបានផ្អែកលើភាពខុសគ្នានៃទីតាំង (ដៃទន្លេឬទន្លេមេ) ប្រភេទនៃការប្រើប្រាស់ (នៅក្នុង ឬរវាងអាង) ថេរៈវេលា (រដូវវស្សា ឬរដូវប្រាំង) និងប្រភេទនៃតម្រូវការឲ្យមាននីតិវិធី (ដែលរាប់ចាប់ពីការជូនដំណឹងរហូតដល់ការពិគ្រោះយោបល់ជាមុន អំពីកិច្ចព្រមព្រៀងជាក់លាក់)។ ក្នុងពេលដែលទាមទារឲ្យមានការព្រមព្រៀងសម្រាប់តែការបង្វែរទឹករវាងអាងទន្លេនៅរដូវប្រាំង អត្ថបទនេះក៏រួមបញ្ចូលផងដែរនូវភាពបត់បែនបាននៅក្នុងកិច្ចព្រមព្រៀងនេះ ដោយបង្កើតប្រការមួយដែលនៅក្នុងនោះគណៈកម្មាធិការរួមរបស់ MRC អាចធ្វើការសម្រេចជាឯកច្ឆ័ន្ទ អំពីភាពមិនចាំបាច់ឲ្យមានកិច្ចព្រមព្រៀងបែបនេះ។ បើទោះជាសេចក្តីពិស្តារនេះតំណាងឲ្យការងាកចេញយ៉ាងឆ្ងាយនៃភាគីទាំងអស់ពីជំហរដើមដំបូងក៏ដោយ នៅពេលគិតបញ្ចូលប្រការទាំងអស់ជាមួយគ្នា ប្រទេសទាំងនេះឆ្លើយតបទៅនឹងកង្វល់ធំៗរបស់ភាគីទាំងអស់។នេះជាប្រភេទនៃការដោះដូររវាងការចង់បាននានា ដែលអាចបង្កើតគុណតម្លៃសម្រាប់ភាគីនៅក្នុងការចរចា។

នៅក្នុងដំណាក់កាលខុសៗគ្នា អ្នកសម្របសម្រួលអាចធ្វើការ"បោះឆ្នោតសាកល្បង" ដើម្បីពិនិត្យមើលកម្រិតនៃការគាំទ្រ ឬការជំទាស់ទៅនឹងគំនិតឬកញ្ចក់សំណើជាក់លាក់នានា។ប៉ុន្តែ គេពុំគួរសុំឲ្យអ្នកណាម្នាក់ធ្វើការប្តេជ្ញាអ្វីមួយឡើយ រហូតដល់មានអត្ថបទពិស្តារអំពីកិច្ចព្រមព្រៀងមួយ ត្រូវបានចែកចាយ ហើយតំណាងនីមួយៗអាចធ្វើការពិនិត្យឡើងវិញ ដោយធៀបនឹងរដ្ឋធម្មនុញ្ញរបស់ខ្លួន (តាមលំនាំណាមួយដែលយល់ថាមានប្រយោជន៍សម្រាប់ក្រុមនោះ)។ នៅពេលដែលកិច្ចព្រមព្រៀងមួយទំនងជាមានការគាំទ្រជាទូទៅរួចហើយនោះ អ្នកសម្របសម្រួលនឹងសាកសួរថាតើ"អ្នកណាមិនអាចទទួលយកកញ្ចប់សំណើនេះ?" នៅត្រង់ចំណុចនេះ តាមធម្មតាអ្នកដែលជំទាស់នឹងត្រូវគេស្នើសុំឲ្យលើកសំណើ "កែលម្អ" ដែលនឹងធ្វើឲ្យពួកគេអាចទទួលយកកញ្ចប់នេះបាន ដោយមិនធ្វើឲ្យស្ថានភាពកាន់តែអាក្រក់ឡើយសម្រាប់អ្នកណាម្នាក់ដែលទទួលយកកញ្ចប់នោះរួចទៅហើយ។ គួរកត់សំគាល់ថា អ្នកសម្របសម្រួលមិនសួរថាតើអ្នកណាម្នាក់ "មានការពេញចិត្តចំពោះកិច្ចព្រមព្រៀងនេះ" ទេ។ នៅពេលសួរថាតើពួកគេអាច"ទទួលយក" កិច្ចព្រមព្រៀងនេះឬទេ អ្នកចូលរួមម្នាក់ៗត្រូវបានស្នើសុំឲ្យធ្វើការប្រៀបធៀបកញ្ចប់នេះជាមួយករណីដែលគ្មានការព្រមព្រៀងទាល់តែសោះ។[62] នៅពេលដែលបានបង្កើតសេចក្តីព្រាងកិច្ចព្រមព្រៀងរួចហើយ អ្នកចូលរួមម្នាក់ៗនៅក្នុងដំណើរការបង្កើតការឯកភាពមតិនេះ រំពឹងថាអ្នកដទៃទៀតនឹងពិនិត្យមើល

ថាតើភាគីពាក់ព័ន្ធដទៃទៀតទាំងអស់យល់ច្បាស់ដែរឬទេថា ពួកគេអាចទទួលយកនូវអ្វីដែលបានលើកស្នើ។ បន្ទាប់មក ក្រុមអ្នកចរចាគួរតែជួបប្រជុំគ្នាយ៉ាងហោចណាស់ម្តងចុងក្រោយដើម្បី "ផ្តល់សច្ចាប័ន" លើកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ដែលពួកគេបានរៀបចំឡើង ហើយជាញឹកញាប់ការចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ គឺជាតម្រូវការរបស់អ្នកចូលរួម (ប្រសិនបើមិនមែនជាស្ថាប័នរបស់ពួកគេនោះទេ)ដើម្បីធ្វើកិច្ចការក្នុងនាមឲ្យកិច្ចព្រមព្រៀងនេះ និងគាំទ្រជាសាធារណៈ។ នៅក្នុងករណីកិច្ចព្រមព្រៀងដែលជាប់កាតព្វកិច្ចអន្តរជាតិ គេមាននីតិវិធីដែលបានបង្កើតឡើងសម្រាប់ការចុះហត្ថលេខា និងការផ្តល់សច្ចាប័ន។

ជាញឹកញាប់ គេចាំបាច់ត្រូវដាក់ជូននូវអ្វីដែលបានរៀបចំរួចជាស្រេចនៅក្នុងវេទិកាពិសេស ដើម្បីធ្វើការពិនិត្យជាផ្លូវការទៅតាមនីតិវិធីរដ្ឋបាលនៅពេលអាជ្ញាធរមួយ ដូចជា ទីភ្នាក់ងារនិយ័តកម្ម ឬអង្គភាពរបស់រដ្ឋាភិបាលរក្សាសិទ្ធិជាពិសេស ការទទួលខុសត្រូវក្នុងការធ្វើសេចក្តីសម្រេចចុងក្រោយ។ នៅពេលនោះ គេត្រូវដាក់ជូនកិច្ចព្រមព្រៀងដែលបានឯកភាពគ្នាមិនផ្លូវការទៅអ្នកធ្វើសេចក្តីសម្រេចដែលពាក់ព័ន្ធក្នុងនាមជាសំណើមួយសម្រាប់ធ្វើការពិចារណារបស់ពួកគេតែមិនមែនជាសេចក្តីសម្រេចចុងក្រោយទេ (អ្នកអព្យាក្រឹត្យ អាចបង្ហាញជូនកិច្ចព្រមព្រៀងនោះក្នុងនាមក្រុមទាំងមូល)។ គេអាចសុំអ្នកចូលរួមឲ្យធ្វើការបញ្ជាក់នៅក្នុងសវនាការក្នុងពេលបន្ទាប់មក។ដំណើរការពេញលេញមួយនៃការបង្កើតការឯកភាពមតិ អាចបង្កើតជាសំណើនានាដែលអ្នកធ្វើសេចក្តីសម្រេចអាចធ្វើសកម្មភាព ដោយមានទំនុកចិត្តថាការសម្រេចរបស់ពួកគេ និងការអនុវត្តន៍នៅពេលក្រោយនឹងទទួលបានការគាំទ្រពីភាគីពាក់ព័ន្ធទាំងអស់។ ផ្ទុយទៅវិញ អ្នកធ្វើសេចក្តីសម្រេចច្រើនតែមានអារម្មណ៍ជាប់កាតព្វកិច្ច ដើម្បីផ្តល់ហេតុផលដែលអាចបញ្ចុះបញ្ចូលឲ្យបាន ប្រសិនបើពួកគេបានជ្រើសរើសដើម្បីចេញដំណើរពីសំណើរបស់អ្នកចូលរួម។

មុនពេលការអនុវត្តន៍ចប់សព្វគ្រប់ជាទូទៅអ្នកចូលរួមតែងតែកំណត់ឲ្យបានច្បាស់លាស់អំពីជំហាននានាដែលពួកគេគិតថានឹងពាក់ព័ន្ធនៅក្នុងការអនុវត្តន៍កិច្ចព្រមព្រៀងដែលបានចរចាក្រៅផ្លូវការ។ គោលដៅនៃដំណើរការបង្កើតការឯកភាពមតិគឺត្រូវបង្កើត"កិច្ចព្រមព្រៀងដែលស្ទើរតែអាចប្រតិបត្តិបានដោយខ្លួនឯង"។[63]ជាការប្រសើរ កិច្ចព្រមព្រៀងមួយដែលបានពីការចរចា នឹងដាក់បញ្ចូលការប្តេជ្ញាជាយថាហេតុខុសៗគ្នា ដែលគួសបញ្ជាក់យ៉ាងច្បាស់ថា អ្វីដែលក្រុមចង់បាន គឺស្ថិតនៅក្រោមកាលៈទេសៈមួយអនាគត។ នេះជាវិធីមួយក្នុងការដោះស្រាយភាពមិនប្រាកដប្រជាខាងវិទ្យាសាស្ត្រ ឬនយោបាយ។ កិច្ចព្រមព្រៀងដែលបាន មកពីការចរចាក៏ត្រូវតែដាក់បញ្ចូលទៅក្នុងប្រការស្តីពីការដោះស្រាយវិវាទផងដែរ។ ពោលគឺដើម្បីឲ្យកិច្ចព្រមព្រៀងនានាស្ទើរតែអាចពង្រឹងការអនុវត្តន៍បានដោយខ្លួនឯង គេគួរតែចែងឲ្យបានច្បាស់នៅក្នុងមាត្រានានាអំពីថាតើភាគីមួយអាចលើកឡើងនូវកង្វល់នានាដោយរបៀបណា ប្រសិនបើភាគីនោះគិតថាអ្នកដទៃមិនធ្វើអ្វីដែលខ្លួនបានសន្យា ឬដោយសារតែហេតុផលណាមួយ ភាគីនោះមានអារម្មណ៍ថាខ្លួនមិនអាចអនុវត្តកិច្ចការទាំងអស់ដែលខ្លួនបានសន្យាហើយនោះឡើយ។ មុននឹងបើកចំហឲ្យដឹងអំពីកិច្ចព្រមព្រៀងទាំងមូល អ្នកសម្របសម្រួលអាចទទួលបានការស្នើសុំលើការប្រមូលផ្តុំដើម្បីឲ្យអ្នកទាំងអស់ដែលចូលរួមតាំងពីដើមដំបូងបានមកជួបជុំគ្នាឡើងវិញ និងព្យាយាមបង្ហើយកាតព្វកិច្ចនានាដែលត្រូវកែសម្រួល។

*"គោលដៅនៃដំណើរការបង្កើតការយល់ដឹងគឺត្រូវបង្កើត "កិច្ចព្រមព្រៀងដែលស្ទើរតែអាចពង្រឹងការអនុវត្តន៍បានដោយខ្លួនឯង"*

### ៤.៣.៥ ការអនុវត្តន៍កិច្ចព្រមព្រៀង ការធ្វើឲ្យភាគីនានាអនុវត្តតាមការប្តេជ្ញារបស់ខ្លួន

នៅពេលដែលកិច្ចព្រមព្រៀងមួយដែលបានមកពីការចរចាត្រូវបានចុះហត្ថលេខារួចហើយ (និងមុនពេលបញ្ជូនទៅទីភ្នាក់ងារកោះប្រជុំជាផ្លូវការ ប្រសិនបើចាំបាច់ឲ្យមានចំណាត់ការជាចុងក្រោយ) អ្នកចូលរួមត្រូវតែមានការពិភាក្សាអំពីថាតើពួកគេរំពឹងទុកបែបណាអំពីការអនុវត្តន៍កិច្ចព្រមព្រៀងនេះ។ ដូចនៅក្នុងករណីដានូបេ និងនីហ្សេរីយ៉ា អ្នកចូលរួមអាចចង់បង្កើតយុទ្ធសាស្ត្រ តាមដានផ្ទៀងផ្ទាត់ដោយប្រុងប្រយ័ត្ន (សូមអានករណី ៤.៦) និងបង្កើតកាលវិភាគទៀងទាត់សម្រាប់ធ្វើរបាយការណ៍ និងការប្រជុំដើម្បីចែករំលែក និងវាយតម្លៃលទ្ធផល។ ទិន្នន័យដែលប្រមូលបាន ការចែករំលែក ការវិភាគ និងចងក្រងតាមរយៈដំណើរការមួយដែលមានតម្លាភាពទំនងជានឹងបានការទទួលយក និងចាត់ទុកថាមាននិត្យានុកូលភាព។ កិច្ចប្រជុំជាទៀងទាត់ ផ្តល់ឱកាសសម្រាប់អ្នកចូលរួមទាំងអស់ ដើម្បីជួបប្រជុំឡើងវិញ និងពិចារណាលើកិច្ចព្រមព្រៀងរបស់ពួកគេ ក៏ដូចជា លើមាត្រាមិនទាន់ដាច់ស្រេចនានា ដែលមានការពាក់ព័ន្ធ ដោយសារតែមានទិន្នន័យថ្មីៗ ឬ ការប្រែប្រួលនៅក្នុងអាងនេះ។ ការចែករំលែក និងពិភាក្សាអំពីលទ្ធផលនៃការតាមដាន ក៏អាចបង្កើនទំនុកចិត្តក្នុងចំណោមអ្នកចូលរួមផងដែរ អំពីប្រការដែលអ្នកដទៃអាចឬមិនអាចគោរពបានតាមកាតព្វកិច្ចរបស់ពួកគេ។

នៅពេលអ្នកចូលរួមមិនអាចសម្រេចបានតាមកាតព្វកិច្ចរបស់ខ្លួនបើទោះជាមានកិច្ចប្រឹងប្រែងដោយស្មោះត្រង់ហើយក៏ដោយ គេត្រូវផ្តល់ការគាំទ្រខាងហិរញ្ញវត្ថុនិងបច្ចេកទេស។ យ៉ាងហោចណាស់ អ្នកចូលរួមគួរតែបង្កើតផែនការសម្រាប់ការប្រាស្រ័យឆ្លើយឆ្លង សហប្រតិបត្តិការ និងការសម្របសម្រួលជាប់ជាប្រចាំ។ នៅក្នុងករណីខ្លះ ការធ្វើបែបនេះអាចពាក់ព័ន្ធជាមួយ ការបង្កើតអង្គភាពអចិន្ត្រៃយ៍ ដើម្បីជួយភាគីនានានៅក្នុងកិច្ចព្រមព្រៀងនោះ។

*"នៅពេលដែលកិច្ចព្រមព្រៀងមួយដែលបានមកពីការចរចាត្រូវបានចុះហត្ថលេខារួចហើយអ្នកចូលរួមត្រូវតែមានការពិភាក្សាអំពីថាតើពួកគេរំពឹងទុកបែបណាអំពីការអនុវត្តន៍កិច្ចព្រមព្រៀងនេះ"*

*ករណី៤.៦៖ ការពិចារណាអំពីការអនុវត្តន៍ធម្មនុញ្ញទឹកអាងទន្លេកូម៉ាឌូហ្គូនៅនីហ្សេរីយ៉ា*[64]

នីហ្សេរីយ៉ាបានបង្កើតធម្មនុញ្ញទឹកតាមរយៈដំណើរការចូលរួមសម្រាប់អាងទន្លេកូម៉ាឌូហ្គូ យ៉ូបេ ដែលជាអនុអាងមួយនៃអាងបឹងឆាតអន្តរជាតិ។[65] ធម្មនុញ្ញទឹក ចែងជាពិសេសនូវតួនាទីរបស់អ្នកពាក់ព័ន្ធខុសៗគ្នា នៅក្នុងការអនុវត្តន៍កិច្ចព្រមព្រៀងព្រមទាំងយន្តការនានាទៅអនាគតសម្រាប់កិច្ចសហប្រតិបត្តិការក្នុងចំណោមពួកគេផងដែរ។ យន្តការទាំងនោះរួមទាំងកិច្ចប្រជុំជាប្រចាំ ការបរិយាយពិស្តារអំពីនិតិវិធីសម្រាប់កិច្ចសហប្រតិបត្តិការ និងកាតព្វកិច្ចតាមដាន។ ធម្មនុញ្ញទឹក មានចែងពីយន្តការស្ថាប័នសម្រាប់ការអនុវត្តន៍ដែលរួមមាន ប្រភេទនៃអង្គភាពគ្រប់គ្រងដែលត្រូវការជាចាំបាច់ អាណត្តិរបស់អង្គភាពនោះ និងបទបញ្ញានានា អំពីសមាជិកភាពរបស់ពួកគេ។ ធម្មនុញ្ញនេះក៏បង្ហាញផងដែរនូវសេចក្តីពិស្តារអំពីការចាត់ចែងសម្រាប់ការអនុវត្តន៍មូលនិធិ និងថាតើមូលនិធិទាំងនេះនឹងត្រូវចាត់ចែងគ្រប់គ្រងបែបណា។ នៅក្នុងករណីដែលមានវិវាទ ធម្មនុញ្ញនេះបានគូសបញ្ជាក់ថា ប្រទេសហត្ថលេខី (រដ្ឋចំនួនប្រាំមួយនៅប្រទេសនីហ្សេរីយ៉ា និងរដ្ឋាភិបាលសហព័ន្ធ) ជាដំបូងព្យាយាមដោះស្រាយភាពមិនចុះសម្រុងនានារបស់ពួកគេដោយសន្តិវិធី ក្នុងចំណោមពួកគេ។ ប្រសិនបើពួកគេមិនអាចដោះស្រាយបានទេ ពួកគេឯកភាពយកវិវាទ

របស់ពួកគេ ឬមួយទៅក្រុមប្រឹក្សាជាតិនៃរដ្ឋ ឬមួយទៅតុលាការកំពូលនៃប្រទេសនីហ្សេរីយ៉ា អាស្រ័យលើថាតើភាពមិនចុះសម្រុងនេះកើតឡើងរវាងរដ្ឋនានា ឬរវាងរដ្ឋមួយ និងរដ្ឋាភិបាលសហព័ន្ធ។ ដោយទទួលស្គាល់អំពីលក្ខណៈធម្មជាតិនៃអាងនេះ ធម្មនុញ្ញនេះសំដៅទៅរកវិវាទរវាងរដ្ឋាភិបាលសហព័ន្ធ និងប្រទេសដទៃទៀតនៅតាមដងទន្លេ ទៅរកយន្តការដោះស្រាយវិវាទនៅក្នុងគណៈកម្មការរួម នីហ្សេរីយ៉ា-នីហ្សេរ និងអនុសញ្ញាគណៈកម្មការអាងបឹងឆាត។

## *៤.៣.៦ ការសិក្សាដោយមានការចាត់ចែង ការគ្រប់គ្រងបែបបន្សាំ និងការកសាងសមត្ថភាព*

ក្នុងពេលដែលភាគច្រើននៃកិច្ចប្រឹងប្រែងដើម្បីចរចាកិច្ចព្រមព្រៀងជាក់លាក់ បានបញ្ចប់ជាមួយនឹងជំហានដែលមានចែងខាងលើនេះ គណៈកម្មាធិការផ្តល់យោបល់ដែលមានស្រាប់ ឬ វេទិកាចរចាខ្លះអាចធ្វើការកោះប្រជុំជាបន្ត តាមរយៈអង្គភាពអនុវត្តដែលបានចាត់តាំងឡើង ។ នេះជាករណីនៅក្នុងទន្លេមេគង្គដែលភាគីនានាមិនចង់ឲ្យមានកិច្ចព្រមព្រៀង ឬរូបមន្តណាមួយងាប់ស្លុកសម្រាប់បែងចែកធនធានទឹកឡើយ។ ជាជំនួស គណៈកម្មការទន្លេមេគង្គបានបង្កើតដំណើរការមួយដែលអាចឲ្យភាគីនានា ធ្វើការសម្រេចអំពីការបែងចែកទឹក ដោយផ្អែកលើការប្រែប្រួលលក្ខខណ្ឌ។ កិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ ចែងថា បទបញ្ជា (ឬ នីតិវិធី) សម្រាប់ការប្រើប្រាស់ទឹកអាចកែប្រែបានដោយផ្អែកលើលក្ខខណ្ឌជលសាស្ត្រដូចជា គ្រោះរាំងស្ងួត ទឹកជំនន់ ឬអតិរេកទឹកនៅក្នុងរដូវប្រាំង ៖

គំនិត និងការរំពឹងទុកនានា ផ្តល់នូវក្របខ័ណ្ឌនៃគោលការណ៍ គោលបំណង និងរចនាសម្ព័ន្ធស្ថាប័នទូទៅ និងអាចបត់បែនបាននៅពេលមានបញ្ហានានាត្រូវបានអាទិភាព ក្រុមប្រឹក្សានេះ [គណៈកម្មាធិការរួម (JC)] និងលេខាធិការដ្ឋាន អាចកែសម្រួល និងបន្សាំទៅនឹងតម្រូវការថ្មីៗ។ នេះជាមូលហេតុដែលកិច្ចព្រមព្រៀងនេះអំពាវនាវឲ្យមានបទបញ្ជា ឬ នីតិវិធីសម្រាប់ក្រុមប្រឹក្សានេះ និងគណៈកម្មាធិការរួម (JC) និងអនុញ្ញាតឲ្យក្រុមប្រឹក្សា និងគណៈកម្មាធិការនេះបង្កើតឡើងបទបញ្ជា នីតិវិធីទាំងនោះដូចនេះពួកគេពុំចាំបាច់វិលត្រឡប់ទៅសុំការអនុម័តពីរដ្ឋាភិបាល ឬ កែសម្រួលកិច្ចព្រមព្រៀងនេះឡើយ។

ប្រទេសនានានៅក្នុងអាងដានូបេ បង្កើតឲ្យមានភាពបត់បែនប្រហែលគ្នានេះ សម្រាប់ក្រុមការងារ និងបទបញ្ជា ដែលបង្កើតទៅជាកិច្ចព្រមព្រៀងក្របខ័ណ្ឌរបស់ពួកគេ សម្រាប់ការគ្រប់គ្រងទឹកដោយនិរន្តរភាព និងដោយសមធម៌។



រូបថត៤.១៖ ការនេសាទនៅក្នុងតំបន់ដីសើមហាដេចាគូរ្វ។ ការស្តារតំបន់ដីសើមទទួលបានការគាំទ្រពីមូលនិធិក្លូម៉ាខូហ្កាយ៉ូបេដែលជាផ្នែកមួយនៃផែនការគ្រប់គ្រងអាងរងទឹកភ្លៀងដែលបានចរចាដោយអ្នកពាក់ព័ន្ធនានា (នីហ្សេរីយ៉ា)។

*"គណៈកម្មាធិការផ្តល់យោបល់ដែលមានស្រាប់ឬវេទិកាចរចាខ្លះអាចកោះប្រជុំជាបន្តបន្ទាប់"*

សេចក្តីប្រាថ្នាក្នុងការបង្កើតក្របខ័ណ្ឌស្ថាប័នបន្សាំមួយដែលអាចដោះស្រាយបញ្ហាអនាគតដែលនៅពុំទាន់មានភាពច្បាស់លាស់នៅឡើយ ត្រូវពឹងផ្អែកខ្លាំងលើការពិនិត្យតាមដាន ដែលផ្តល់ទិន្នន័យដល់កិច្ចប្រជុំកសាងផែនការ និងការធ្វើសេចក្តីសម្រេច ដែលក្នុងនោះគេអាចកែសម្រួលគោលនយោបាយនានាទៅអនាគត។ អ្នកចូលរួមនៅក្នុងការចរចាអេវើគ្លេត បានសម្រេចដើម្បីឈានទៅតាមវិធីជាជំហានៗ និងចាត់ទុកអន្តរាគមន៍គោលនយោបាយនីមួយៗថាជាបទពិសោធន៍ ដែលអាចផ្តល់ព័ត៌មានសម្រាប់ចំណាត់ការជាបន្តបន្ទាប់។ ដូច្នេះ ពួកគេសហការគ្នាបង្កើតកាលវិភាគមួយ និងចាត់អាទិភាពទៅលើគម្រោងនានា សម្រាប់ការអនុវត្តន៍កាន់តែច្រើនឡើង។ នៅក្នុងន័យនេះ ភាគីនានាបានទទួលស្គាល់អំពីភាពមិនប្រាកដប្រជាខាងវិទ្យាសាស្ត្រ អំពីឌីណាមិកនៃប្រព័ន្ធអេកូឡូស៊ី ដោយទទួលស្គាល់ថា ពួកគេមិនដឹងថាអ្វីនឹងកើតឡើងឡើយ នៅពេលដែលប្រព័ន្ធអេកូឡូស៊ីវិលត្រឡប់ទៅរកលក្ខខណ្ឌជលផលកាន់តែដូចធម្មជាតិ។ ដោយសារតែមាត្រដ្ឋានរូបវន្ត និងពេលវេលា និងភាពស្មុគស្មាញនៃតំបន់អេវើគ្លេត អ្នកវិទ្យាសាស្ត្រ និងអ្នកគ្រប់គ្រងធនធាននៅពុំទាន់អាចអនុវត្តបានពេញលេញនូវបទពិសោធន៍តាមមូលដ្ឋាននៅឡើយទេ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេបានអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងតាមបែបបន្សាំ ដែលតំណាងដោយការផ្តោតលើដំណើរការរៀនសូត្រ តាមរយៈការតាមដាន និងប្រើប្រាស់ម៉ូដែលនានាដើម្បីសាកល្បងសេណារីយ៉ូដែលនឹងប្រាប់ពីការធ្វើសេចក្តីសម្រេចជាធម្មតា។

នៅក្នុងករណីកើតឡើងបែបនេះ ប្រការសំខាន់គឺអ្នកពាក់ព័ន្ធទាំងអស់ត្រូវចំណាយពេលខ្លះជាមួយគ្នា ដើម្បីឆ្លុះបញ្ចាំងអំពីថាតើអ្នកចរចារបស់ពួកគេបានធ្វើការដោយរបៀបណា និងតើពួកគេគួរតែរៀនសូត្រអ្វីខ្លះពីបទពិសោធន៍របស់ពួកគេ ខណៈដែលកិច្ចប្រឹងប្រែងបង្កើតការឯកភាពមតិបានផ្តល់ផលទាបជាងការរំពឹងទុក ឬប្រឈមនឹងឧបសគ្គធ្ងន់ធ្ងរ (សូមអានប្រអប់ ៩.១)។ ការរៀនសូត្រពីសង្គមបែបនេះ ឬការកសាងសមត្ថភាព ជួនកាលត្រូវបំពេញបន្ថែមជាមួយការបណ្តុះបណ្តាលបន្ថែមទៀត លើបច្ចេកទេសនៃការធ្វើសេចក្តីសម្រេចជាក្រុម។ វាជាការគួរឲ្យសោកស្តាយដោយមិនបានធ្វើអ្វីៗទាំងអស់ដែលអាចធ្វើបានដើម្បីជួយក្រុមនីមួយៗកែលម្អកិច្ចប្រឹងប្រែងរបស់ខ្លួន ប្រសិនបើពួកគេនឹងចូលរួមទៅក្នុងការដោះស្រាយបញ្ហាដែលមានស្រាប់។ សូម្បីតែការចរចាដែលធ្វើឡើងដោយគណៈកម្មាធិការផ្តល់យោបល់ដែលនឹងបន្តធ្វើទំនាក់ទំនងជាមួយគ្នាក៏ដោយជាញឹកញាប់បំផុត បើទោះជាការចរចាមានលក្ខណៈពិសេសៗខ្លះក៏ដោយក៏នឹងត្រូវបានគេមើលឃើញថាជាព្រឹត្តិការណ៍ឯករាជ្យនៃកិច្ចចរចាហើយកាលានុវត្តភាពសម្រាប់ការអភិវឌ្ឍរចនាសម្ព័ន្ធ ក៏នឹងត្រូវបាត់បង់ផងដែរ។[66]

*ប្រអប់៩.១ ត្រូវដឹងអំពីគ្រោះថ្នាក់នៃដំណើរការគ្មានរចនាសម្ព័ន្ធ*

គេអាចមើលឃើញយ៉ាងច្បាស់នូវចំណុចខ្សោយដែលអាចកើតឡើងទាក់ទងនឹងការបង្កើតការឯកភាពមតិ ជាពិសេសក្នុងពេលដែលទីភ្នាក់ងារជាច្រើនមានការប្តេជ្ញាដើម្បី "សហការ" នៅក្នុងទម្រង់នៃការបង្កើតការឯកភាពមតិ ប៉ុន្តែបន្ទាប់មករំលោភលើគោលការណ៍សំខាន់ៗបំផុតនៃការដោះស្រាយបញ្ហាតាមបែបសហការ។

ទីមួយ ជួនកាលអ្នកកោះប្រជុំ "ជ្រើសរើសដោយផ្ទាល់ដៃ" នូវតំណាងអ្នកពាក់ព័ន្ធនានាដែលពួកគេចង់ឲ្យមានមុខនៅក្នុងតុចរចា ជាជាងពឹងផ្អែកលើស្ថានភាពមួយ ឬ ការវាយតម្លៃវិវាទដែលរៀបចំឡើងដោយជនអព្យាក្រឹត្យផ្ទុយទៅវិញ អ្នកកោះប្រជុំខ្លះបានជ្រើសរើសតំណាងដែលពួកគេចង់បាន។

ទីពីរ ពួកគេមិនសុទ្ធតែពឹងផ្អែកលើអ្នកអាជីពអព្យាក្រឹត្យភាពឡើយ ដើម្បីគ្រប់គ្រងដំណើរការនៃការ

បង្កើតឯកភាពមតិឬប្រសិនបើពួកគេពិតជាពឹងផ្អែកវិញនោះ អ្នកកោះប្រជុំជ្រើសរើសដោយឯករាជ្យនូវអ្នកសម្របសម្រួលមួយរូប ដោយមិនអនុញ្ញាតឲ្យអ្នកចូលរួមជ្រើសរើសអ្នកសម្របសម្រួលដែលពួកគេចង់បាននោះឡើយ(ឬផ្តល់ឲ្យភាគីនូវអំណាចត្រួតត្រាលើជនអព្យាក្រឹត្យជាបន្តបន្ទាប់នោះឡើយ)។

ទីបីភ្នាក់ងារខ្លះផ្តោតលើការពិភាក្សាជាងលើការត្រៀមរៀបចំឲ្យមានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរដែលភាគីទាំងអស់អាចឯកភាពគាំទ្រ និងចុះហត្ថលេខា។ ក្នុងករណីនេះគេមានការសន្ទនា ប៉ុន្តែពុំមានការបង្កើតនូវការឯកភាពមតិពិតប្រាកដឡើយពីសំណាក់អ្នកពាក់ព័ន្ធនានាដែលចូលរួម និងគ្មានការប្តេជ្ញាដើម្បីអនុវត្តតាមអ្វីដែលបានចរចាឡើយ។ ដំណើរការមួយដែលរំលោភលើគោលការណ៍គ្រឹះនៃទម្លាប់ល្អមានការខ្វះខាតយ៉ាងធ្ងន់ធ្ងរ។ វាអាចមានលក្ខណៈជា "ការចូលរួម" ជាងការតថ្លៃតឹងតែងតាមប្រពៃណី និងអាចរាប់បញ្ចូលការពិចារណាកាន់តែទូលំទូលាយ និងមានតម្លាភាពជាងការចរចាឈ្នះចាញ់ជាច្រើន ដែលបានធ្វើឡើងនៅក្នុងបន្ទប់បិទជិត ពីសំណាក់អ្នកពាក់ព័ន្ធមួយចំនួន ប៉ុន្តែមិនបានឆ្លើយតបនឹងស្តង់ដារអប្បបរមានៃការបង្កើតការឯកភាពមតិឡើយ។ នៅក្នុងករណីទាំងនេះ ការបង្កើតឲ្យមានការឯកភាពមតិត្រូវបានប្រើប្រាស់ធ្វើជាតម្រង ដែលផ្តល់ជាអភិក្រមនៃការតថ្លៃតឹងតែងតាមបែបបុរាណដែលមានលំនាំបែបសហការជាងមុន។ គេឃើញមានយុទ្ធសាស្រ្តជាច្រើនសម្រាប់ចរចាអំពីទឹក ដែលមានគម្លាតចាប់ពីការតថ្លៃតឹងតែងក្នុងចំណោមក្រុមតូចមួយ រហូតដល់ការសន្ទនាតាមបែបផែននៃការចូលរួម និងតម្លាភាពជាងមុន ដែលបញ្ចប់ដោយការបោះឆ្នោត ដែលក្នុងនោះ ភាគីភាគច្រើនសម្រេចអំពីអ្វីដែលនឹងកើតឡើង ឬការបង្ខំឲ្យមានការសម្រេចពីសំណាក់ទីភ្នាក់ងារទទួលខុសត្រូវ រហូតដល់ដំណើរការបង្កើតការឯកភាពមតិ ដែលមានលក្ខណៈពេញលេញ និងមានគោលដៅសម្រេចកិច្ចព្រមព្រៀងដែលយកជាការបាន តាមរយៈការស្វែងរកការពិតរួមគ្នា ដែលសម្របសម្រួលដោយការដោះស្រាយបញ្ហា និងបច្ចេកទេសបង្កើតការឯកភាពមតិ ។

គេនៅតែមានសំណួរសំខាន់ៗនៅឡើយ តើគេអាចឈានតាមទិសដៅនៃការកសាងការឯកភាពមតិដោយគ្មានការប្តូរចេញពីអភិក្រមតថ្លៃយ៉ាងតឹងតែងដែរឬទេ? ឬតើមានការចូលរួមដោយអ្នកពាក់ព័ន្ធមួយចំនួនតូច បានប្រសើរជាងគ្មានការចូលរួមទាល់តែសោះដែរឬទេ? នេះជាជម្រើសមួយដែលមានតែអ្នកពាក់ព័ន្ធដោយផ្ទាល់ប៉ុណ្ណោះ ដែលចូលរួមដោយផ្ទាល់នៅក្នុងការចរចាអំពីទឹកនីមួយៗត្រូវតែធ្វើឡើងនោះ។ ឧបសគ្គចំពោះការបង្កើតនូវការឯកភាពមតិ ជាពិសេសនៅក្នុងករណីដែលមិនដែលប្រតិបត្តិការ តាមវិធីនេះ អាចមានទំហំធំ។ ភាគីមានអំណាចនឹងមើលឃើញការប៉ុនប៉ងអនុវត្តកិច្ចការនានាតាមវិធីថ្មីមួយ និងវិធីខុសប្លែក ពីមុនដែលជាការគំរាមកំហែងចំពោះសមត្ថកិច្ចរបស់ពួកគេ។ ពួកគេអាចយល់ខុសអំពីតួនាទី របស់អ្នកសម្របសម្រួលអព្យាក្រឹត ដែលបានស្នើសុំ។ គេមើលឃើញថាតម្លាភាព និងគណនេយ្យភាព ដែលកើតចេញពីការស្វែងរកការពិតរួមគ្នាអាចជាការគំរាមកំហែងមួយ។ ហើយនៅទីបំផុត នៅក្នុងតំបន់ជាច្រើននៃពិភពលោក កង្វល់នយោបាយសម្រាប់រយៈពេលខ្លីបានជម្រុញឲ្យមានការពិចារណាសម្រាប់រយៈពេលវែង។

ការអះអាង មិនមានភាពខុសគ្នាពីការជជែកវែកញែកអំពីប្រជាធិបតេយ្យនិយមនៃប្រតិបត្តិការរបស់រដ្ឋាភិបាលនៅតាមកន្លែងនានា ដែលជាទូទៅតែងតែកើតឡើងដោយឯកឯង តើជាការប្រសើរដែរឬទេការដែលមានប្រជាធិបតេយ្យ "តិចតួច" ជាងគ្មានទាល់តែសោះនោះ? មនុស្សជាច្រើនជឿថាការចូលរួមរបស់អ្នកពាក់ព័ន្ធខ្លះៗ លើការចរចាអំពីទឹក មានលក្ខណៈប្រសើរជាងគ្មានការចូលរួមទាល់តែសោះ។ ប៉ុន្តែគេមិនគួរអនុញ្ញាតឲ្យអ្នកដែលកាន់កាប់អំណាច ធ្វើការអះអាងថា ពួកគេចូលរួមនៅក្នុងការបង្កើតការឯកភាពមតិឡើយ ប្រសិនបើពួកគេមិនបានចូលរួមទេនោះ។

## *៤.៤ យោបល់ណែនាំដល់អ្នកចរចាកិច្ចព្រមព្រៀងអំពីទឹក*

គេមានជំហានជាបន្តបន្ទាប់ដែលអាចអនុវត្តបានសម្រាប់អ្នកចរចាអំពីទឹកណាដែលចង់ងាកចេញពីការចរចាតឹងតែងបែបប្រពៃណី ឆ្ពោះទៅអភិក្រមនៃការបង្កើតការឯកភាពមតិ។ អ្នកចរចាម្នាក់ៗគោរពតាមការវិភាគខាងលើ ៖

*១) ផ្ដោតការយកចិត្តទុកដាក់លើដំណើរការ*

- បើទោះជាមានការកាត់ចោលនីតិវិធីខ្លះៗ ក៏ដោយប្រការនេះច្រើនតែនាំទៅរកការពន្យាពេល ឬបង្កើនបញ្ហាខាងហិរញ្ញវត្ថុ ដែលបង្កដោយការប្រឈមនានាខាងនយោបាយ និងច្បាប់ ឬការអនុវត្តន៍ដែលបរាជ័យ។ ដោយផ្ដោតការយកចិត្តទុកដាក់លើដំណើរការនៃការពិគ្រោះយោបល់ ការធានាថាសិទ្ធិរបស់ភាគីនានានៅក្នុងតុចរចាតាំងពីដើមដំបូង (និងបានផ្ដល់នូវភាពអង់អាចដើម្បីធ្វើជាតំណាងឲ្យមណ្ឌលរបស់ពួកគេ) អ្នកចូលរួម និងអាជ្ញាធរដែលធ្វើសេចក្ដីសម្រេចអាចបង្កើតឲ្យមានកិច្ចព្រមព្រៀងដែលស្មើភាព និងកាន់តែមាននិរន្តរភាពជាងមុន ដែលបង្កើតឲ្យមានតុល្យភាពប្រកបដោយប្រសិទ្ធភាព រវាងវិទ្យាសាស្ត្រ និងនយោបាយ។
- រាល់ការសម្រេចណាមួយក្នុងការជ្រើសយកអភិក្រមបង្កើតការឯកភាពមតិ គួរតែធ្វើឡើងដោយផ្អែកលើការវាយតម្លៃអំពីស្ថានភាព ឬការវាយតម្លៃវិវាទដែរឬយ៉ាងណា។ ការវាយតម្លៃបានបង្ហាញពីចំណងទាក់ទងរវាងអ្នកពាក់ព័ន្ធនានា ផលប្រយោជន៍របស់ពួកគេដែលទាក់ទងនឹងបញ្ហាចំបងៗ និងអាចលើកស្នើឲ្យមានការបង្កើតដំណើរការបង្កើតការឯកភាពមតិ។
- ដំណើរការបង្កើតការឯកភាពមតិ គួរតែប្រឹងប្រែងផ្ដល់ឲ្យភាគីនានានូវផលប្រយោជន៍ខុសៗគ្នា និងទទួលស្គាល់អំពីឱកាសដើម្បីបង្កើតកិច្ចព្រមព្រៀងនានា ដែលមានលក្ខណៈប្រសើរជាងមុនសម្រាប់ភាគីទាំងអស់ជាជាងជម្រើសនៃ "អវត្តមានកិច្ចព្រមព្រៀង"។ គេអាចឈានដល់ការឯកភាពមតិ នៅពេលដែល "ផលចំណេញរួមគ្នា" ត្រូវបានសិក្សាស្វែងយល់ឲ្យបានពិស្ដារ និងមានកិច្ចប្រឹងប្រែងជាក់ស្ដែង ដើម្បីបំពេញតម្រូវការនានារបស់ភាគីទាំងអស់ បើទោះជាភាគីនានាមិនដែលបានទទួលសំណើឲ្យបោះបង់ចោលការប្រឹងប្រែងដើម្បីស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួនដោយខ្លួនឯងក៏ដោយ។
- ការឯកភាពមតិមិនទាមទារឲ្យមានការមូលមតិជាឯកឆន្ទឡើយ ពោលគឺ ភាគីទាំងអស់ត្រូវឯកភាពជាមួយគ្នា។ ទោះជាយ៉ាងណាក៏ដោយ វាពិតជាទាមទារឲ្យភាគីទាំងអស់ប្រឹងប្រែងឲ្យអស់លទ្ធភាពដើម្បីបំពេញបានមិនត្រឹមតែផលប្រយោជន៍របស់ខ្លួននោះទេ ប៉ុន្តែក៏បំពេញបាននូវផលប្រយោជន៍របស់អ្នកដទៃផងដែរ។

*២) ប្ដេជ្ញាប្រើប្រាស់សេវាកម្មអព្យាក្រឹត។ វាជាការងាយស្រួលក្នុងការធ្វើឲ្យភាគីនានាគោរពតាមកិច្ចព្រមព្រៀងរបស់ពួកគត ប្រសិនបើក្រុមទាំងមូលបាន ប្រើប្រាស់សេវារបស់អ្នកផ្សះផ្សាអ្នកសម្របសម្រួលអព្យាក្រឹត និងបានប្រកាន់យកបទបញ្ជាផ្ទៃក្នុងជាក់ស្ដែង។*

- ការបណ្ដុះបណ្ដាលជនអព្យាក្រឹត ឬអ្នកសម្រុះសម្រួលណាម្នាក់ គឺជាតម្រូវការចាំបាច់ដើម្បីគ្រប់គ្រងការដោះស្រាយបញ្ហារបស់ក្រុម។ អ្នកកោះប្រជុំឬភាគីដទៃទៀតដែលមានចំណាប់អារម្មណ៍លើសមិទ្ធផលនេះ មិនគួរមានភារៈទទួលបន្ទុកលើការសន្ទនានេះឡើយ។ មានជនអព្យាក្រឹតជាច្រើនដែលមានវិជ្ជាជីវៈកំពុងប្រតិបត្តិការនៅជុំវិញពិភពលោក។ ក្រុមអ្នកចរចាណាមួយដែលចង់បានអ្នកសម្របសម្រួល ឬ អ្នកសម្រុះសម្រួល គួរតែអាចស្វែងរកអ្នកណាម្នាក់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីឲ្យជួយពួកគេ។
- ការទទួលខុសត្រូវរបស់អ្នកជំនាញការអព្យាក្រឹត គឺការរម្លឹកដល់អ្នកពាក់ព័ន្ធនានានៅទូទាំងដំណើរការបង្កើតការឯកភាពមតិអំពីការប្ដេជ្ញាតាមនីតិវិធី ដែលពួកគេបានធ្វើឡើងដោយស្ម័គ្រចិត្ត។ ក្នុងនាមជាភាគីដែលមិនលំអៀង ជនអព្យាក្រឹតមាននិត្យានុកូលភាពដើម្បីធ្វើឲ្យអ្នកពាក់ព័ន្ធនានា

ស្ថិតក្នុងទិសដៅសមស្រប និងពិភាក្សាប្រកបដោយការស្ថាបនា។ ជាក់ស្តែង មូលហេតុនៃការស្នើសុំឲ្យអ្នកចូលរួមធ្វើការចុះហត្ថលេខាលើបទបញ្ជាផ្ទៃក្នុងដែលពួកគេបានជួយរៀបរៀងឡើង គឺជាការផ្តល់ឲ្យអ្នកអព្យាក្រឹតនូវអំណាច ដើម្បីធ្វើសកម្មភាពក្នុងនាមក្រុមនេះ ដើម្បីប្រឹងប្រែងបញ្ចុះបញ្ចូលអ្នកដែលមិនបានគោរពតាមនិយាមដែលក្រុមនេះបានបង្កើតឡើង។

៣) *ការបង្កើតនូវការឯកភាពមតិ នឹងអាចធ្វើទៅបានតែនៅពេលណាដែលអ្នកពាក់ព័ន្ធនានាកំណត់អត្តសញ្ញាណខ្លួនឯង និង "ធ្វើជាម្ចាស់" នៃគំរូដំណើរការសហការនោះតែប៉ុណ្ណោះ។ ត្រូវពង្រីកចំនួនភាគីដែលចូលរួមពាក់ព័ន្ធ និងស្វែងរកវិធីនានាដើម្បីបញ្ចូល "ភាគីមិនផ្លូវការផងដែរ"*

- អ្នកពាក់ព័ន្ធនានា ចាំបាច់ជួយបង្កើតដំណើរការនេះ ដែលក្នុងនោះពួកគេនឹងត្រូវចូលរួមដើម្បីពួកគេមានទំនុកចិត្តថា ចំណាប់អារម្មណ៍របស់គេត្រូវបានដាក់ចូលរួម។ យ៉ាងហោចណាស់ ក្នុងពេលដែលពួកគេជួបទល់មុខគ្នាជាលើកដំបូង ពួកគេគួរតែអនុម័តលើបទបញ្ជាផ្ទៃក្នុង និងឯកភាពលើរបៀបវារៈ និងលើកាលវិភាគផងដែរ។ ពួកគេអាចកែប្រែបទបញ្ជានេះ នៅទូទាំងដំណើរការនេះ។
- ការអនុវត្តន៍កិច្ចព្រមព្រៀងធនធានរួមនឹង ពិតជាប្រឈមការលំបាកជាទីបំផុតប្រសិនបើអ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់មិនគាំទ្រដល់លទ្ធផលនៃការចរចា។ ការគោរពតាមដោយស្ម័គ្រចិត្តអាចកាត់បន្ថយការលំបាកនានានៃការត្រួតពិនិត្យលើការអនុវត្តន៍ ហើយ "ការអនុវត្តន៍តាមពុំមានការចាប់បង្ខំ" គឺត្រូវការចំណាយទាបជាងច្រើនណាស់។ វិធីតែមួយដើម្បីឲ្យមានការគោរពតាមដោយស្ម័គ្រចិត្តគឺតាមរយៈការចូលរួមដោយផ្ទាល់ពីបុគ្គលនានាដែលគ្មានការទទួលខុសត្រូវជាផ្លូវការផ្សេងទៀត។ នេះអាចមានន័យថា តំណាងជាផ្លូវការមកពីក្រុមមួយត្រូវតែអង្គុយជាមួយបុគ្គលនានាដែលពុំមាន "ឋានៈ"ដូចខ្លួន។ ទោះជាយ៉ាងណាក៏ដោយការអនុវត្តតាមវិធីនេះនឹងផ្តល់ប្រយោជន៍ដល់ភាគីទាំងអស់។

៤) *ការចែករំលែកព័ត៌មានអំពីផលប្រយោជន៍ និងពិនិត្យមើលកញ្ចប់ជម្រើសនានា ក្នុងការស្វែងរកវិធីសម្រាប់បង្កើតផលដើម្បីទាំងអស់គ្នា។*

ការចរចាលើបញ្ហាជាច្រើនដែលពាក់ព័ន្ធជាមួយភាគីជាច្រើន និងពឹងផ្អែកលើវិទ្យាសាស្ត្រមានភាពស្មុគស្មាញៈ

- គេគួរតែផ្តោតកិច្ចប្រឹងប្រែងលើការចែករំលែកព័ត៌មានអំពីអាទិភាព និងអ្វីដែលអ្នកចូលរួមម្នាក់ៗគិតថាជាសមិទ្ធផលដែលអាចមិនទទួលយកបាន។
- ដើម្បីអាចចាត់ជាអាទិភាពនូវផលប្រយោជន៍នានា អ្នកចូលរួមត្រូវតែត្រៀមខ្លួនឲ្យបានល្អ។ ពួកគេគួរតែដឹងអំពី "ជម្រើសជំនួសប្រសើរបំផុតរបស់ខ្លួនធៀបនឹងកិច្ចព្រមព្រៀងដែលបានពីការចរចា" (BATNA) និងប្រើប្រាស់ជម្រើសជំនួសនោះ ដើម្បីវាយតម្លៃរាល់កិច្ចព្រមព្រៀងដែលបានស្នើឡើង ឬកញ្ចប់សំណើនានាដែលក្រុមនេះបានបង្កើតឡើង។
- ដោយពិនិត្យមើលកញ្ចប់នៃជម្រើសអំពីបញ្ហាទាំងអស់នៅក្នុងការចរចាមួយ អ្នកចូលរួមអាចបោះបង់អ្វីដែលពួកគេមិនសូវយកចិត្តទុកដាក់ ជាការដោះដូរជាមួយ "ការទទួលបាន" អ្វីដែលពួកគេចង់បានបញ្ហាអ្វីដែលគួរតែយកចិត្តទុកដាក់ជាទីបំផុត។ ប្រសិនបើអាចធ្វើបាន អ្នកចូលរួមគួរតែពិនិត្យមើលកញ្ចប់ជាច្រើននៅក្នុងពេលតែមួយជាមួយគ្នា ដើម្បីស្វែងយល់ពីមូលហេតុដែលអ្នកដើរតួនានាចង់បានកញ្ចប់ណាមួយជាងកញ្ចប់ណាមួយផ្សេងទៀត។

៥) *ត្រូវយល់ថាកិច្ចព្រមព្រៀងណាមួយនឹងមានប្រយោជន៍សម្រាប់តែរយៈពេលកំណត់ណាមួយ*

*តែប៉ុណ្ណោះ ហើយអ្នកនឹងអាចទទួលបានតែផ្នែកណាមួយដែលល្អត្រឹមតែប៉ុណ្ណោះ។ ការព្យាយាមអនុវត្តអភិក្រមគ្រប់គ្រងតាមបែបបន្សាំនៅក្នុងការដោះស្រាយវិវាទអំពីទឹក ឬបង្កើតគោលនយោបាយមួយសម្រាប់គ្រប់គ្រងទឹក គឺជាការប្រសើរជាងការព្យាយាមដើម្បីស្វែងរកដំណោះស្រាយទូលំទូលាយមួយសម្រាប់រយៈពេលវែង។*

- ត្រូវគាំទ្រដល់អំណះអំណាងតាមរយៈទិន្នន័យល្អបំផុតដែលមាន។ ទោះជាយ៉ាងណាក៏ដោយ គេនៅតែខ្វះជំនាញ និងចំណេះដឹង ដើម្បីបង្កើតម៉ូដែលប្រព័ន្ធអេកូឡូស៊ីស្មុគស្មាញបំផុតដែលអាចផ្តល់ភាពសុក្រិតកម្រិតខ្ពស់។ ដូច្នេះ ការសន្មត់ដែលជាមូលដ្ឋានសម្រាប់កិច្ចព្រមព្រៀងដែលបានចរចាភាគច្រើនអំពីទឹក មានច្រើនបំផុតត្រឹមតែជាតួលេខប្រហាក់ប្រហែលប៉ុណ្ណោះ។
- ដោយសារតែសមត្ថភាពសម្រាប់បង្កើតម៉ូដែលប្រព័ន្ធទាំងនេះនៅមានកម្រិតកំណត់ជាការល្អគួរតែទទួលយកកិច្ចព្រមព្រៀងក្រោមរូបភាពជាការប៉ាន់ប្រមាណ និងបន្ថែមយថាភាពទៅក្នុងកិច្ចព្រមព្រៀងនោះ ដោយចែងអំពីការតាមដានជាប់ជាប្រចាំ និងការចាត់ចែងពិស្តារសម្រាប់ការកោះប្រជុំឡើងវិញ ដើម្បីធ្វើបច្ចុប្បន្នភាព ឬកែតម្រូវ នៅពេលមានព័ត៌មានថ្មីៗជាបន្ថែមទៀត។
- ប្រសិនបើប្រើប្រាស់កិច្ចព្រមព្រៀងយថាភាព ភាគីនានាត្រូវតែមានការយល់ដឹងបានច្បាស់លាស់អំពីថាតើពួកគេនឹងចូលរួមធ្វើសកម្មភាពបែបណានៅក្នុងកាលៈទេសៈសំខាន់ៗ។

៦) *សុំឲ្យភាគីនានាចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ដែលពួកគេជាអ្នកជួយរៀបចំឡើង។*

- ការចុះហត្ថលេខាឬការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងដែលបានចរចារួចគឺជាសញ្ញាសំខាន់មួយដល់សាធារណជនថាពួកគេបានឈានដល់កិច្ចព្រមព្រៀងជាផ្លូវការហើយ។

៧) *មិនត្រូវភ្លេចផ្សារភ្ជាប់កិច្ចព្រមព្រៀងដែលបានពីការចរចាមិនផ្លូវការ ជាមួយសកម្មភាពផ្លូវការណាមួយដែលចាំបាច់ពីសំណាក់អ្នកដែលស្ថិតក្នុងតំណែងដែលមានអំណាចឡើយ ដើម្បីធានាឲ្យមានការអនុវត្តន៍។*

វាមិនសមស្របឡើយក្នុងការជំនួសជាបណ្តោះអាសន្ននូវគោលការណ៍ប្រជាធិបតេយ្យតាមរយៈតំណាង។ ទោះជាយ៉ាងណាក៏ដោយ កិច្ចប្រឹងប្រែងបង្កើតការឯកភាពមតិអាចបង្កើតសំណើដែលមន្ត្រីជាប់ឆ្នោត ឬមន្ត្រីជ្រើសតាំងអាចចូលចិត្តដោយសារតែភាគីពាក់ព័ន្ធទាំងអស់បានគាំទ្រសំណើទាំងនោះដោយចំហ។ អ្នកពាក់ព័ន្ធនានាមិនទំនងជាចូលរួមនៅក្នុងកិច្ចប្រឹងប្រែងបែបនោះឡើយទៅអនាគត (ឬបោះឆ្នោតជ្រើសរើសយកមន្ត្រីនោះឡើងវិញឡើយ ដោយសារតែសកម្មភាពដែលធ្វើឡើងតាមទម្រង់ខ្ចីខ្ចាបែបនេះឡើយ) ប្រសិនបើកិច្ចព្រមព្រៀងដែលបានពីការចរចាត្រូវបានគេផាត់ចោលនៅទីបញ្ចប់ ដោយមានការព្រួយបារម្ភត្រឹមតិចតួចចំពោះកិច្ចប្រឹងប្រែងដែលបានធ្វើឡើងសម្រាប់បង្កើតកិច្ចព្រមព្រៀងនោះ ។ ទំនុកចិត្តលើរដ្ឋាភិបាលនឹងថយចុះប្រសិនបើមនុស្សនៅក្នុងតំណែងដែលមានអំណាចបែបនេះមិនបានផ្តល់នូវហេតុផលដែលអាចទទួលយកបាន ដើម្បីពន្យល់ពីមូលហេតុដែលពួកគេសម្រេចច្រានចោលសំណើឯកភាពមតិដែលធ្លាប់បានលើកយកមកពិចារណា។

៨) ប្តេជ្ញាធ្វើការកសាងសមត្ថភាព (និងការអភិវឌ្ឍន៍ស្ថាប័ន) ជាបន្តបន្ទាប់

ជាញឹកញាប់ ការចរចានៅជុំជាបន្តបន្ទាប់ ប្រឈមការលំបាកកាន់តែច្រើនឡើង។ តាមធម្មតានេះដោយសារមានកិច្ចប្រឹងប្រែងតិចតួច ឬ គ្មានកិច្ចប្រឹងប្រែងដើម្បីរៀនសូត្រពីអ្វីដែលបានកើតឡើងនៅក្នុងជុំមុនៗ ឬពុំមានកិច្ចប្រឹងប្រែងចាំបាច់ដើម្បីធ្វើការអភិវឌ្ឍន៍ស្ថាប័នដែលចាំបាច់សម្រាប់ពង្រឹងទំនាក់ទំនងការងារទៅអនាគត។



# ជំពូក ៥

# កិច្ចព្រមព្រៀង

## *៥.១ សមិទ្ធផលពីការចូលរួមប្រកបដោយការស្តាបនា*

ការចូលរួមប្រកបដោយការស្ថាបនា អាចនាំទៅរកការសម្រេចកាន់តែមានយុត្តិធម៌ និងមានប្រសិទ្ធភាពជាងមុនអំពីវិភាជន៍ ការប្រើប្រាស់ និងការគ្រប់គ្រងទឹក។ សមិទ្ធផលជាក់ស្តែងដោយផ្ទាល់បំផុតពីការចរចាមួយគឺកិច្ចព្រមព្រៀងដែលស្រង់យកការសម្រេចនានាបានច្បាស់លាស់ និងដែលបានចែងអំពីជំហាននានា សម្រាប់ការអនុវត្តន៍។ មានកិច្ចព្រមព្រៀងខុសៗគ្នាជាច្រើនបែប ដែលអាចយកមកអនុវត្តនៅក្នុងកម្រិត និងលំដាប់ថ្នាក់ខុសៗគ្នា ចាប់ពីថ្នាក់មូលដ្ឋានដល់អន្តរជាតិ ចាប់ពីអណ្តូងដល់ទីជម្រាលខ្វាតតូច និងអាងទន្លេ និងរវាងអ្នកដើរតួខុសៗគ្នា។

*"ការចូលរួមប្រកបដោយការស្ថាបនាអាចនាំទៅរកការសម្រេចកាន់តែត្រឹមត្រូវ និងមានប្រសិទ្ធភាពជាងមុន អំពីការវិភាជន៍ ការប្រើប្រាស់ និងគ្រប់គ្រងទឹក"*

ការប្រែក្លាយកិច្ចព្រមព្រៀងមួយឲ្យទៅជាចំណាត់ការ គឺជាស្នូលនៃការកែប្រែយ៉ាងមានប្រសិទ្ធភាព និងទាមទារឲ្យមានការប្តេជ្ញាជាប់ជានិច្ច។ អ្នកពាក់ព័ន្ធនានាត្រូវតែបន្តធ្វើការជាមួយគ្នា ដើម្បីឆ្លុះបញ្ចាំងអំពីភាពត្រឹមត្រូវ និងប្រសិទ្ធភាពនៃការអនុវត្តន៍ ដោះស្រាយភាពមិនចុះសម្រុងគ្នាថ្មីៗ និងពង្រឹងកិច្ចសហប្រតិបត្តិការ។ ការចរចាអំពីវិភាជន៍ទឹកយ៉ាងស្មុគស្មាញ និងបញ្ហាគ្រប់គ្រងគឺជាដំណើរការដែលកំពុងកើតឡើង។

ការរៀបចំឲ្យចប់សព្វគ្រប់ និងការអនុវត្តន៍កិច្ចព្រមព្រៀងគឺជាលទ្ធផលសំខាន់មួយនៃការចរចា ប៉ុន្តែមិនមែនត្រឹមតែជាលទ្ធផលតែប៉ុណ្ណោះទេ។ លទ្ធផលដែលមិនសូវជាក់ស្តែងដូចជា កំណែលម្អទំនាក់ទំនង កំណើនការយល់ដឹង និងដំណើរការល្អជាងមុនសម្រាប់ការជជែកពិភាក្សា និងការធ្វើសេចក្តីសម្រេចមានសារៈសំខាន់ណាស់ ក្នុងការពង្រឹងទឹកនៅក្នុងរយៈពេលវែង។ សមិទ្ធផលទាំងនេះអាចចាប់ផ្តើមកើតឡើងជាយូរមកហើយមុនឈានដល់កិច្ចព្រមព្រៀងនេះ និងមានអាយុកាលវែងនៅក្រោយការចុះហត្ថលេខា និងការប្រកាសឲ្យប្រើកិច្ចព្រមព្រៀងជាក់លាក់ណាមួយ។

ដោយសារ MSP មិននាំទៅរកកិច្ចព្រមព្រៀងផ្លូវការណាមួយ សមិទ្ធផលផ្សេងទាំងអស់នេះអាចនៅតែមានឥទ្ធិពលជាខ្លាំង ទាក់ទងនឹងវិធីវិភាជន៍ និងការគ្រប់គ្រងទឹក។ តាមរយៈការបើកចំហយ៉ាងទូលាយសម្រាប់ការចូលរួមរបស់ក្រុមអ្នកដើរតួនានា ការយល់ដឹងអំពីទស្សនវិស័យរបស់អ្នកពាក់ព័ន្ធផ្សេងទៀតនឹងត្រូវកែលម្អដូចជា ស្តីពី 4Rs ពោលគឺ ភាគលាភ (rewards) ហានិភ័យ (risks) សិទ្ធិ (rights) និងការទទួលខុសត្រូវ (responsibilities) ដែលទាក់ទងនឹងទឹក។ កត្តាជម្រុញដើម្បីអ្នកទាំងឡាយអាចចូលរួមនៅក្នុង MSPs គឺធ្វើយ៉ាងណាដើម្បីអ្នកទាំងនោះអាចបង្ហាញកង្វល់របស់ខ្លួន ពោលគឺត្រូវឲ្យអ្នកដទៃផ្តល់តម្លៃចំពោះបញ្ហារបស់ពួកគេ និងមានការគោរពចំពោះគំនិតរបស់ពួកគេ ដើម្បីជាមូលដ្ឋាន និងមានឥទ្ធិពលមកលើការចរចា និងសេចក្តីសម្រេចប្រកបដោយការស្ថាបនា។ ទំនាក់ទំនងដែលផ្តល់

ទំនុកចិត្តនិងការគោរពច្រើនជាងមុនអាចកើតឡើង ដែលផ្តល់ជាលក្ខខណ្ឌអំណោយផលដើម្បីលើកឡើងអំពីភាពមិនចុះសម្រុងគ្នា និងដោះស្រាយកាន់តែបានត្រឹមត្រូវ និងមានប្រសិទ្ធភាពជាងមុន។ ប្រការនេះអាចបើកឱកាសដើម្បីឲ្យមានការស្វែងយល់អំពី ជម្រើសនានាប្រកបដោយភាពច្នៃប្រឌិតជាងមុន និងជាការប្រសើរដើម្បីនាំមកនូវការធ្វើសេចក្តីសម្រេចអំពីទឹកកាន់តែមានសមធមិជាងមុន។

*" ទំនាក់ទំនងដែលផ្តល់ទំនុកចិត្ត និងការគោរពច្រើនជាងមុនអាចកើតឡើង"*

ការគ្រប់គ្រង MSPs ការបង្កើតការឯកភាពមតិ និងដំណើរការនៃការចរចាផ្សេងទៀត ដើម្បីឲ្យមានឥទ្ធិពលលើការកែប្រែពិតប្រាកដមានន័យថា ផ្តោតការយកចិត្តទុកដាក់លើវិធីរៀបចំឲ្យមានកិច្ចព្រមព្រៀងដល់ទីបញ្ចប់ និងជាពិសេស ខ្លឹមសារនៃកិច្ចព្រមព្រៀងនោះ មានសង្គតិភាពជាមួយក្របខ័ណ្ឌច្បាប់ និងគោលនយោបាយដែលមានស្រាប់ និងការអនុម័តកិច្ចព្រមព្រៀងនេះ។ ចំពោះ MSP គោលដៅដើម្បីមានឥទ្ធិពល និងផ្តល់ជាមូលដ្ឋានសម្រាប់ការចរចាអំពីទឹកជាមួយមជ្ឈដ្ឋានខាងក្រៅអ្នកចូលរួមត្រូវតែពិចារណាអំពីវិធីល្អបំផុត ដើម្បីស្រង់យកការសម្រេចនានាដែលកើតចេញពីការសន្ទនារបស់ពួកគេ បើទោះជាអនុសាសន៍ជាក់លាក់ ការវិភាគជម្រើស ឬបញ្ហានានាសម្រាប់ការជជែកពិភាក្សាក៏ដោយ និងមានឥទ្ធិពលមកលើអ្នកធ្វើសេចក្តីសម្រេចដែលពាក់ព័ន្ធ។ នៅទីបញ្ចប់ អ្នកដើរតួខាងផ្នែកទឹក គួរតែពិចារណាអ្វីដែលអាចធ្វើបាន ដើម្បីពង្រឹងចលនការដែលបង្កើតឡើងនៅក្នុងអំឡុងពេលចូលរួមប្រកបដោយការស្ថាបនា ដើម្បីមានឥទ្ធិពលមកលើការធ្វើសេចក្តីសម្រេចអំពីទឹក និងអភិបាលកិច្ចទឹកទូទៅ។

## *៥.២ ស្វែងយល់អំពីកិច្ចព្រមព្រៀងស្តីពីទឹក*

### *៥.២.១ តើកិច្ចព្រមព្រៀងអំពីទឹកគឺជាអ្វី?*

"កិច្ចព្រមព្រៀង" គឺជាសមិទ្ធផលជាក់ស្តែងដោយផ្ទាល់ពីការចរចា ដែលបង្ហាញពីការសម្រេចរួមនិងចេតនានានា។ កិច្ចព្រមព្រៀងអំពីទឹកមានច្រើនបែបៈ គោលនយោបាយ ច្បាប់ ធម្មនុញ្ញ ក្រមអនុវត្តកិច្ចសន្យា ឬ កិច្ចព្រមព្រៀងផ្សេងទៀត ដើម្បីគ្រប់គ្រង និងវិភាជន៍ទឹក។ កិច្ចព្រមព្រៀងអាចមានទម្រង់ផ្លូវការ ឬមិនផ្លូវការជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ឬដោយស្ម័គ្រចិត្តដោយផ្ទាល់មាត់ឬជាលាយលក្ខណ៍អក្សរ។

កិច្ចព្រមព្រៀងអំពីទឹកត្រូវបានចរចានៅក្នុងកម្រិត និងលំដាប់ថ្នាក់ជាច្រើនដូចជា អនុសញ្ញាអន្តរជាតិ សន្ធិសញ្ញាអាងទន្លេ ច្បាប់និងយុទ្ធសាស្ត្រជាតិ បទប្បញ្ញត្តិរបស់រដ្ឋ ឬរបស់ខេត្ត ផែនការទីជម្រាល ឬ អាងផ្ទៃរងទឹកភ្លៀង និងកិច្ចព្រមព្រៀងនៅថ្នាក់មូលដ្ឋានដើម្បីគ្រប់គ្រង និងវិភាជន៍ទឹក។

កិច្ចព្រមព្រៀងអំពីទឹករាប់បញ្ចូល ចេតនា និងកម្រិតនៃសមត្ថកិច្ចខុសៗគ្នា៖ កិច្ចព្រមព្រៀងខ្លះផ្តោតច្រើនលើគោលការណ៍ គោលការណ៍ណែនាំ ឬក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការ កិច្ចព្រមព្រៀងផ្សេងទៀតគូសបញ្ជាក់អំពីមធ្យោបាយដែលជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ ដើម្បីគ្រប់គ្រង និងប្រើប្រាស់ទឹក និងដោះស្រាយវិវាទនានា។

កិច្ចព្រមព្រៀងអំពីទឹក ពាក់ព័ន្ធជាមួយអ្នកដើរតួខុសគ្នាជាច្រើនរដ្ឋ និងមិនមែនរដ្ឋ ពោលសំដៅលើអ្នកណាមានឥទ្ធិពលលើការអភិវឌ្ឍន៍កិច្ចព្រមព្រៀង អ្នកណាជាភាគី ឬហត្ថលេខី និងអ្នកណាមានឥទ្ធិពលកិច្ចព្រមព្រៀង។

កិច្ចព្រមព្រៀងនានាត្រូវបានប្រើប្រាស់ដើម្បីបង្ហាញការសម្រេចរួមគ្នា និងចេតនានានា ទាក់ទងនឹងបញ្ហាជាច្រើនដែលពាក់ព័ន្ធនឹងការប្រើប្រាស់វិភាជន៍ និងគ្រប់គ្រងធនធានទឹក។ ការសម្រេចបែបនេះអាចមានឆ្លុះបញ្ចាំងនៅក្នុងគោលនយោបាយ ឬច្បាប់ទឹកថ្មីៗ នៅក្នុងការបង្កើតយន្តការមួយសម្រាប់គ្រប់គ្រងទឹក វិភាជន៍ទឹកក្នុងចំណោមអ្នកប្រើប្រាស់ខុសៗគ្នា ការប្រើប្រាស់ខុសៗគ្នា និយ័តកម្មលើធនធានទឹករួមគ្នា ឬដោះស្រាយវិវាទដែលទាក់ទងនឹងទឹក។ កិច្ចព្រមព្រៀងទាំងនេះអាចលើកឡើងអំពីបញ្ហាទឹកជាទូទៅ ឬអនុវត្តនៅក្នុងវិស័យជាក់លាក់ ឬការប្រើប្រាស់ទឹកដូចជា អគ្គិសនី ការបញ្ជូនទឹក ឬកសិកម្ម។

មិនមែនគ្រប់គោលនយោបាយ ច្បាប់ ឬបទបញ្ញាសុទ្ធតែជាផលិតផលពីការចូលរួមប្រកបដោយការស្តាបនានោះឡើយ។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីឲ្យមានភាពស្របច្បាប់ និងមានយុត្តិធម៌ និងប្រសិទ្ធភាព កិច្ចព្រមព្រៀងធនធានទឹកអំពីវិភាជន៍ដ៏ស្មុគស្មាញ និងការគ្រប់គ្រងគួរតែផ្អែកលើការយល់ដឹង និងស្ថិតក្រោមឥទ្ធិពលនៃដំណើរការនានាដែលមានចំណាប់អារម្មណ៍ខុសៗគ្នាត្រូវបានលើកឡើង និងវិភាគដោយពិតប្រាកដ។

*"កិច្ចព្រមព្រៀងមួយគឺជាផលិតផលជាក់ស្តែង និងផ្ទាល់ពីការចរចា"*

## *៥.២.២ ផលប្រយោជន៍នៃការបង្កើតឲ្យមានកិច្ចព្រមព្រៀងជាផ្លូវការ*

ហេតុផលជាច្រើនបានបង្ហាញពីកិច្ចប្រឹងប្រែងដើម្បីប្រមូលយកការសម្រេចនានាដែលបានមកការចរចាផ្លូវការណាមួយនិងដែលបានចុះហត្ថលេខារួចរាល់។

កិច្ចព្រមព្រៀងនានាបង្ហាញអំពីសុឆន្ទៈរបស់ភាគីនានា ដែលពាក់ព័ន្ធនៅក្នុងការចរចាមួយជាសាធារណៈ និងច្បាស់លាស់ ដើម្បីឈានដល់ការប្រើប្រាស់ទឹកកាន់តែស្មើភាព និងមានប្រសិទ្ធភាពជាងមុន និងដើម្បីថែរក្សាធនធានផ្សេងៗដែលទាក់ទងនឹងទឹក។ កិច្ចព្រមព្រៀងមួយអំពីទឹក ជាការធានាលើការប្តេជ្ញាពីភាគីនានា បើទោះជារដ្ឋាភិបាល សាជីវកម្ម អង្គការសង្គមស៊ីវិល ឬបុគ្គលក៏ដោយ។

កិច្ចព្រមព្រៀងនាំមកនូវភាពប្រាកដប្រជា និងតម្លាភាព អំពីភាគលាភ ហានិភ័យ សិទ្ធិ និងការទទួលខុសត្រូវ ដែលរំពឹងទុក។ កិច្ចព្រមព្រៀងផ្តល់នូវក្របខ័ណ្ឌច្បាស់លាស់មួយសម្រាប់ផ្ទៀងផ្ទាត់ការអនុវត្ត។ កិច្ចព្រមព្រៀងល្អ ចែងអំពីជំហានច្បាស់លាស់ ដើម្បីដោះស្រាយភាពមិនចុះសម្រុងគ្នា ភាពខ្វះចន្លោះនៃការអនុវត្តកិច្ចព្រមព្រៀងនោះ ឬ ការរំលោភលើកិច្ចព្រមព្រៀងនោះ។ កាលណាកិច្ចព្រមព្រៀងមួយមានបញ្ជាក់កាន់តែច្បាស់លាស់មាត្រានានាដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនោះកាន់តែមិនមានភាពចម្រូងចម្រាស់ ហើយភាពខ្លាំងរបស់កិច្ចព្រមព្រៀងខាងផ្លូវច្បាប់ក៏កាន់តែរឹងមាំ ទាក់ទងនឹងឥទ្ធិពលដែលជាប់កាតព្វកិច្ច និងការប្រតិបត្តិ។

គុណតម្លៃនៃការបង្កើតជាផ្លូវការនូវកិច្ចព្រមព្រៀងមួយមានគូសបញ្ជាក់ដោយករណីមកពីប្រទេសប៉ុយតាន។ កសិករមកពីភូមិចំនួនប្រាំពីរបានចូលរួមនៅក្នុងលំហាត់សំដែងតួ ដើម្បីជួយដោះស្រាយវិវាទយូរអង្វែងដែលទាក់ទងនឹងការចែករម្លែកទឹកសម្រាប់ការស្រោចស្រពស្រូវ។នៅចុងបំផុតនៃលំហាត់មួយកសិករទាំងនោះបានឯកភាពលើមធ្យោបាយដែលស្មើភាពជាងមុន សម្រាប់ការបែងចែកទឹក។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងរដូវដាំដំណាំបន្ទាប់មក កសិកររស់នៅខ្សែទឹកខាងលើមិនព្រមបើកទឹក ដូចដែលបានឯកភាពដោយផ្ទាល់មាត់ឡើយ។ សិក្ខាសាលាមួយបន្ថែមទៀតត្រូវបានចាត់ចែងឡើង ដែល

នៅក្នុងនោះកសិករទាំងនោះបានឯកភាពបង្កើតគណៈកម្មការមួយ ដើម្បីធ្វើនិយ័តកម្មលើការគ្រប់គ្រងធនធាននៅក្នុងទីជម្រាល។ ធម្មនុញ្ញ និងលក្ខន្តិកៈ សម្រាប់គណៈកម្មការគ្រប់គ្រងទីជម្រាលត្រូវបានបង្កើតឡើង នៅក្នុងបណ្តាខែជាបន្តបន្ទាប់ និងបានចុះហត្ថលេខាដោយតំណាងនានាមកពីភូមិទាំងអស់។ [៦៨]

*"កិច្ចព្រមព្រៀងបង្ហាញអំពីសុឆន្ទៈរបស់ភាគីនានាដែលពាក់ព័ន្ធនៅក្នុងការចរចាជាសាធារណៈនិងគួសបញ្ជាក់យ៉ាងច្បាស់"*

កិច្ចព្រមព្រៀងដែលកើតចេញពីដំណើរការចរចាពេញលេញ និងប្រកបដោយការពិចារណាអាចងាយស្រួលក្នុងការអនុវត្តន៍ជាង និងអាចជៀសវាងបាននូវការរាំងស្ទះ និងការចំណាយដែលពាក់ព័ន្ធនិងពេលវេលាដែលអាចកើតឡើងនៅពេលប្រជាជនមានអារម្មណ៍ថាពួកគេពុំមានឱកាសបង្ហាញពីកង្វល់របស់ពួកគេ។ បញ្ហានេះត្រូវបានសង្កេតឃើញនៅក្នុងករណីអេវើគ្លេត នៅក្នុងជំពូក៤ ដែលក្នុងនោះអ្នកពាក់ព័ន្ធយល់ថាចំណាប់អារម្មណ៍របស់ពួកគេពុំបានដោះស្រាយឡើយ និងបានដាក់បណ្តឹង ដើម្បីរារាំងសំណើច្បាប់មួយ។កិច្ចព្រមព្រៀងដែលបានឯកភាពគ្នានៅក្នុងដំណើរការបង្កើតការឯកភាពមតិនៅពេលក្រោយមក ត្រូវបានប្រើប្រាស់សម្រាប់បង្កើតផែនការទូលំទូលាយមួយដើម្បីស្តារប្រព័ន្ធអេកូឡូស៊ី។ ការជំទាស់បានកើតឡើងកាន់តែធ្ងន់ធ្ងរនៅក្នុង "សង្គ្រាមទឹក" នៅបូលីវីយ៉ា ដែលក្នុងនោះវិវាទបានបង្កជាអំពើហឹង្សា មុននឹងប្រែក្លាយទៅជាការចូលរួមប្រកបដោយការស្តាបនា។ ដំណើរការប្រកបដោយការស្តាបនានិងការពិចារណានេះនៅពេលក្រោយមកបាននាំឲ្យមានច្បាប់ថ្មីមួយស្តីពី "ទឹក សម្រាប់ការស្រោចស្រព" ដែលបានដាក់ជូនទៅសភាបូលីដោយមានការអនុម័តជាឯកច្ឆន្ទ។

## *៥.២.៣ ការតាំងចិត្តដើម្បីផ្តោតលើកិច្ចព្រមព្រៀង*

កិច្ចព្រមព្រៀងអំពីទឹក អាចកើតឡើងតាមទម្រង់ខុសៗគ្នាជាច្រើន អាចដោះស្រាយបញ្ហាខុសៗគ្នាជាច្រើនអំពីទឹក និងអំពីបញ្ហាពាក់ព័ន្ធដទៃទៀត និងអាចគ្រប់គ្រងឥរិយាបថរបស់អ្នកដើរតួជាច្រើន។ ប្រការសំខាន់គឺថា ចាប់តាំងពីដើមដំបូងនៃការចរចា អ្នកដើរតួលើផ្នែកទឹកគួរតែបានយល់ច្បាស់អំពីប្រភេទនៃកិច្ចព្រមព្រៀងដែលពួកគេចង់បាន។ ការកំណត់អំពីប្រភេទនៃកិច្ចព្រមព្រៀងដែលសមស្របបំផុត អាចធ្វើឡើងដោយលើកសំណួរមួយចំនួនអំពីបញ្ហានានា សមត្ថកិច្ច និងឥទ្ធិពល កម្រិត និងលំដាប់ថ្នាក់ និងអ្នកដើរតួ។ ការលើកសំណួរទាំងនេះនឹងតម្រង់ទិសអ្នកពាក់ព័ន្ធនានាអំពីប្រភេទនៃកិច្ចព្រមព្រៀងដែលត្រូវការ ដូចជា គោលនយោបាយ ច្បាប់ ធម្មនុញ្ញ ឬ ក្រមអនុវត្ត កិច្ចសន្យា ឬ វិភាជន៍ផ្សេងទៀត និងការចាត់ចែងគ្រប់គ្រង។

*"កិច្ចព្រមព្រៀងអំពីទឹកអាចមានទម្រង់ខុសៗគ្នាជាច្រើន"*

*បញ្ហានានា*

កិច្ចការ ឬ បញ្ហាដែល នឹងត្រូវដោះស្រាយ គឺជាចំណុចដែលត្រូវគិតគូរជាដំបូង នៅពេលបង្កើតកិច្ចព្រមព្រៀងមួយ (ឬការកសាងផែនការ MSPs ឬការចរចា)។ ហេតុអ្វីចង់បានកិច្ចព្រមព្រៀងបែបណាមួយ? តើវានឹងផ្តល់ផលអ្វីខ្លះ?

កិច្ចព្រមព្រៀងអាចគ្របដណ្តប់គ្រប់បញ្ហាដែលទាក់ទងនឹងទឹក។ វាអាចមានគោលដៅផ្តល់ជាការណែនាំខាងគោលនយោបាយជាយុទ្ធសាស្ត្រសម្រាប់ការប្រើប្រាស់ទឹកជាទូទៅដូចជា ច្បាប់ទឹកឆ្នាំ១៩៩៧ នៅប្រទេសប្រេស៊ីល ឬ សម្រាប់វិស័យណាមួយជាក់លាក់ដូចជា ថាមពល។

កិច្ចព្រមព្រៀងអាចបង្ហាញពីមូលដ្ឋានសម្រាប់កិច្ចសហប្រតិបត្តិការ រវាងរដ្ឋ អំពីនៅទឹកជាប់ព្រំដែន ដូចជា អនុសញ្ញាការពារទន្លេដានូបឆ្នាំ១៩៩៤[69] ឬការចាត់ចែងស្ថាប័នជាក់លាក់សម្រាប់ការគ្រប់គ្រងទឹក ដូចមាននៅក្នុងបទប្បញ្ញត្តិឆ្នាំ១៩៩៧ដែលបានបង្កើតគណៈកម្មការធនធានទឹកនៅកម្រិតអាងទន្លេតារីម ក្នុងប្រទេសចិន។[70] កិច្ចព្រមព្រៀងអាចផ្តល់ការណែនាំទូលាយអំពីទម្លាប់ល្អ នៅក្នុងវិស័យណាមួយជាក់លាក់ ដូចជា គោលការណ៍ណែនាំស្តីពីនិរន្តរភាព IHA ឆ្នាំ២០០៤[71] ដែលរហូតដល់ឆ្នាំ២០០៩ បានវិវត្តន៍ទៅជាពិធីសារវាយតម្លៃនិរន្តរភាពថាមពលវារីអគ្គិសនី ឬលើកឡើងអំពីឥរិយាបថនៃការគ្រប់គ្រងដី និងទឹក ដូចមានចែងនៅក្នុងក្រមអនុវត្តសម្រាប់អាងទន្លេវ៉ុលហ្កានៅអាហ្វ្រិកខាងលិច(សូមអានករណី ៥.៣)។ កិច្ចព្រមព្រៀងទាំងនេះអាចបង្ហាញពីយន្តការនានាសម្រាប់វិភាជន៍ និងគ្រប់គ្រងទឹក ដូចជាកិច្ចព្រមព្រៀងបែងចែកទឹកនៅក្នុងអាងទន្លេមូរេ-ដាលីង ឆ្នាំ១៩៨៧។[72] ពេលវេលាសម្រាប់កិច្ចព្រមព្រៀងអាចមានរយៈពេលវែងដូចនៅក្នុងផែនការគ្រប់គ្រងទឹកនៅអាងរងទន្លេ អ៊ូម៉ាទីឡា ឆ្នាំ២០៥០ នៅរដ្ឋអូរីហ្គេន ស.រ.អា[73] ឬអាចដោះស្រាយវិវាទជាក់លាក់ ដូចមាន នៅក្នុងករណីកិច្ចព្រមព្រៀងជាមួយសហគមន៍អំពីការបន្តប្រតិបត្តិការអាជីវកម្មរ៉ែនៅប៉ាពូញូហ្គីនេ (សូមអានករណី ២.៣)។

អ្នកពាក់ព័ន្ធទាំងអស់ចូលរួមនៅក្នុងការបង្កើតកិច្ចព្រមព្រៀងមួយត្រូវការឲ្យមានការយល់ដឹងរួមនិងជាក់លាក់អំពីចេតនានៃកិច្ចព្រមព្រៀងនោះ។

*"កិច្ចព្រមព្រៀងអាចគ្របដណ្តប់លើកិច្ចការនានាជាច្រើនដែលទាក់ទងនឹងទឹក"*

## *សមត្ថកិច្ច និងឥទ្ធិពល*

កិច្ចការទីពីរដែលត្រូវពិចារណាគឺកម្រិតនៃសមត្ថកិច្ច។ កិច្ចការនេះទាក់ទងទៅនឹងថាតើកិច្ចព្រមព្រៀង ត្រូវមានឥទ្ធិពលតាមរយៈគោលការណ៍ គោលការណ៍ណែនាំ ឬអនុសាសន៍ ឬត្រូវមាននាទីជាសមត្ថកិច្ច ដោយកំណត់ជាច្បាប់ ឬបទបញ្ញាជាក់លាក់។

កិច្ចព្រមព្រៀងជាច្រើនមានលក្ខណៈជាការតម្រង់ទិសដោយសារកិច្ចព្រមព្រៀងទាំងនោះចែងអំពីគោលនយោបាយទូលាយ ឬអនុសាសន៍សម្រាប់ចំណាត់ការ។ ភាគីនានាត្រូវតែមានគណនេយ្យភាព តាមរយៈការគាបសង្កត់នៅក្នុងក្រុមពិនិត្យ ឬពីសាធារណជន។ អនុសញ្ញាអន្តរជាតិជាច្រើនមានគោលដៅផ្តល់ឥទ្ធិពលមកលើឥរិយាបថនៅលើពិភពលោក ហើយរដ្ឋនានាមានការទទួលខុសត្រូវដើម្បីចេញច្បាប់និងកម្មវិធីនានា សម្រាប់អនុវត្តអនុសញ្ញាទាំងនោះ។ ដូចគ្នានេះដែរ ក្រមអនុវត្ត ឬធម្មនុញ្ញ ចែងអំពីគោលការណ៍សម្រាប់សមាជិក ឬហត្ថលេខីជាក់លាក់ដូចជា ហិរញ្ញិកអន្តរប្រទេស នៅក្នុងករណីគោលការណ៍អេក្វាទ័រ[74] ឬ ស្ថាប័ន និងបុគ្គលនានា ដែលរស់នៅក្នុងអាងកូម៉ាឌូហ្គូ យ៉ូបេ (KYB) នៅនីហ្សេរីយ៉ា សម្រាប់ធម្មនុញ្ញទឹក KYB។[75]

## *កម្រិត និងលំដាប់ថ្នាក់*

ប្រការសំខាន់គឺត្រូវគូសបញ្ជាក់អំពីកម្រិត និងលំដាប់ថ្នាក់សមស្របសម្រាប់កិច្ចព្រមព្រៀង។ កម្រិត

ច្រើនតែទាក់ទងនឹងវិសាលភាពភូមិសាស្ត្រ ពោលគឺ តើព្រំប្រទល់ភូមិសាស្ត្រ ឬដែនដីបែបណា ដែលត្រូវដាក់នៅក្នុងកិច្ចព្រមព្រៀង។ វាអាចជាព្រំដែនរដ្ឋបាល ជលសាស្ត្រ ឬអេកូឡូស៊ី។ ការពិចារណាអំពីកម្រិតទៅតាមពេលវេលាក៏មានប្រយោជន៍ផងដែរសម្រាប់ MSP ឬកិច្ចព្រមព្រៀងណាមួយ និងលំដាប់ថ្នាក់នៅក្នុងកិច្ចព្រមព្រៀងនោះ (ជំពូក ៣)។ កម្រិត និងលំដាប់ថ្នាក់មានសារៈសំខាន់ណាស់ ដោយសារវាគូសបញ្ជាក់អំពីព្រំប្រទល់សម្រាប់កិច្ចព្រមព្រៀង និងជាលទ្ធផល បង្ហាញពីអ្នកដើរតួសំខាន់ៗ។ ប៉ុន្តែគេត្រូវប្រុងប្រយ័ត្ន ដោយមិនត្រូវមើលរម្លងអ្នកដើរតួនានា កិច្ចការ ឬដែនដីឡើយ។ MSP ឬកិច្ចព្រមព្រៀងដែលទាក់ទងនឹងទឹក អាចមានលក្ខណៈអន្តរកម្រិត ឬអន្តរជាប់ថ្នាក់ដើម្បីឆ្លើយតបទៅនឹងភាពមិនចុះសម្រុងគ្នាដូចជា រវាងកម្រិតខាងរដ្ឋបាល និងជលសាស្ត្រ។

ក្នុងពេលដែលមានការទទួលស្គាល់ថា អាចមានអន្តរអំពើរវាងកម្រិត និងនៅលំដាប់ថ្នាក់ខុសៗគ្នា ដោយការកំណត់អត្តសញ្ញាណកម្រិតនៃដែនដីភាគច្រើននៅក្នុងកិច្ចព្រមព្រៀងមួយ ពោលគឺ កម្រិតមូលដ្ឋាន ជាតិ (និងថ្នាក់ក្រោមជាតិ) អន្តរជាតិ (និងតំបន់) ឬរវាងប្រទេសនានា គឺជាវិធីមួយដែលមានប្រយោជន៍ ដើម្បីបង្ហាញពីភាពខុសគ្នានៃប្រភេទកិច្ចព្រមព្រៀងនានា (សូមអានខាងក្រោម និងតារាង៥.១)។

*"ប្រការសំខាន់គឺត្រូវបង្ហាញពីកម្រិត និងលំដាប់ថ្នាក់សមស្របនៃកិច្ចព្រមព្រៀង"*

## *នៅថ្នាក់មូលដ្ឋាន*

កិច្ចព្រមព្រៀងនៅថ្នាក់មូលដ្ឋាន អភិបាលទៅលើឥរិយាបថនៅក្នុងទីតាំងជាក់លាក់មួយនៅក្នុងប្រទេសណាមួយ។ គេអាចយកកិច្ចព្រមព្រៀងនោះមកអនុវត្តនៅក្នុងដែនដីរដ្ឋបាលមួយ (ក្រុង ស្រុក ភូមិ។ល។) ដូចជា ផែនការកែលម្អគុណភាពទឹកនៅដូក្លាស់សាយអឺ ឆ្នាំ២០០៦នៅភាគខាងជើងឃ្វីនស្លែន នៃប្រទេសអូស្ត្រាលី ឬកិច្ចសន្យារវាងអាជ្ញាធរមូលដ្ឋាន និងក្រុមស្ត្រី សម្រាប់ការថែរក្សាប្រព័ន្ធទឹកនៅ គុចារ៉ាត ប្រទេសឥណ្ឌា។[76] កិច្ចព្រមព្រៀងក៏អាចរៀបចំឡើងសម្រាប់បឹង ឬ ទីជម្រាលណាមួយជាក់លាក់ផងដែរ ដូចដែលឃើញមាននៅក្នុងកិច្ចប្រឹងប្រែងរបស់សហគមន៍នៅហ្គាតេម៉ាឡា និងម៉ិចស៊ិកកូ ក្នុងការឈានទៅការគ្រប់គ្រងចម្រុះនូវ ទីជម្រាលតូចៗជិតភ្នំភ្លើងតាកាណា។[77]

MSPs និងការចរចាខ្លះ ផ្តោតលើដំណើរការអភិបាលកិច្ចនៅមូលដ្ឋាន និងផ្តល់ជាមធ្យោបាយយ៉ាងសំខាន់នៃការមានឥទ្ធិពលទៅលើការគ្រប់គ្រង និងការប្រើប្រាស់ទឹកឲ្យកាន់តែមាននិរន្តរភាព និងសមធម៌។ ករណី៥.៦ ខាងក្រោយនេះ នៅក្នុងជំពូកនេះ គូសបញ្ជាក់អំពីចំណាត់ការនានារបស់ក្រុមសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីមានឥទ្ធិពលទៅលើគោលនយោបាយដោយផ្ទាល់នៅក្នុងប្រទេសឥណ្ឌា។

## *នៅថ្នាក់ជាតិ*

កិច្ចព្រមព្រៀងនៅថ្នាក់ជាតិអាចយកទៅអនុវត្តនៅក្នុងរដ្ឋនៃប្រទេសណាមួយ ដោយធ្វើអភិបាលទៅលើឥរិយាបថរបស់ពលរដ្ឋ និងអ្នកដទៃទៀតដែលបានកំពុងប្រតិបត្តិការនៅក្នុងប្រទេសនោះ។ កិច្ចព្រមព្រៀងទាំងនោះរួមបញ្ចូលគោលនយោបាយ ច្បាប់ នៅលំដាប់ថ្នាក់ខុសៗគ្នានៃដែនយុត្តាធិការ ដែលអាចមាននៅក្នុងប្រទេសណាមួយ ពោលគឺ ថ្នាក់ជាតិ ខេត្ត។ល។ ក៏ដូចជា កិច្ចព្រមព្រៀង ដែលមានលក្ខណៈជាក់លាក់សម្រាប់អាងទន្លេ ទីជម្រាល បឹង ឬល្អាងទឹកណាមួយជាក់លាក់ផងដែរ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋមួយ ដូចជាផែនការ

គ្រប់គ្រងយុទ្ធសាស្ត្រសម្រាប់អាងត្រេទអាតស៊ាននៅអូស្ត្រាលី។ ក្នុងពេលដែលអ្នកចរចាខ្លះផ្តោតលើការបង្កើត ឬកែសម្រួលគោលនយោបាយ ឬ ច្បាប់ជាក់លាក់នៅក្នុងប្រទេសជាច្រើន កំណែទម្រង់ដែលទាក់ទងនឹងទឹក កើតឡើងក្រោមទម្រង់ដែលមានភាពទូលំទូលាយជាងនេះ។ ដូចដែលមានចែងនៅក្នុងឯកសារណែនាំរបស់ IUCN បទបញ្ជា កំណែទម្រង់គោលនយោបាយច្បាប់ និងស្ថាប័ននាំឲ្យមានការកសាងសមត្ថភាពអភិបាលកិច្ចទឹកនៅថ្នាក់ជាតិ។ ឯកសារបទបញ្ជាផ្តល់ជាការណែនាំពិស្តារអំពីការបង្កើត និងអនុវត្តដំណើរការកែទម្រង់អភិបាលកិច្ចទឹក។ ឧទាហរណ៍ នៅអាហ្វ្រិកខាងត្បូង ការសេរីយ៉ាងច្រើនជាលក្ខណៈប្រព័ន្ធ បានបង្កើតគោលនយោបាយ និងច្បាប់ថ្មីៗ និងស្ថាប័ន និងដំណើរការនានា ដើម្បីអនុវត្តគោលនយោបាយ និងច្បាប់ថ្មីៗទាំងនោះ (ករណី ៥.១)។

*ករណី៥.១៖ កំណែទម្រង់ទូលំទូលាយខាងផ្នែកទឹកនៅអាហ្វ្រិកខាងត្បូង*

ក្រោយបង្កើតប្រទេសអាហ្វ្រិកខាងត្បូងថ្មីមួយនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ ទឹកស្ថិតក្នុងចំណោមបញ្ហាជាច្រើន ដែលស្ថិតក្រោមការសេរី។ ការចរចាដើមដំបូងបានបង្កើតជាតារាងមួយដែលមាន "គោលការណ៍គ្រឹះ និងគោលបំណងនានា" ចំនួន២៨ សម្រាប់ច្បាប់ទឹកជាតិថ្មីមួយ។ ឆ្នាំ១៩៩៧ ខុទ្ទកាល័យ បានអនុម័តគោលនយោបាយជាតិស្តីពីទឹក ហើយក្រោយមកនៅក្នុងឆ្នាំ១៩៩៨ច្បាប់ជាតិស្តីពីទឹកត្រូវបានរៀបចំជាសេចក្តីព្រាង និងអនុម័ត។ ចាប់តាំងពីពេលនោះមក ក្របខ័ណ្ឌជាមូលដ្ឋាននេះត្រូវបានពង្រឹងជាបន្ថែមតាមរយៈយុទ្ធសាស្ត្រជាតិធនធានទឹក ដែលការចេញផ្សាយលើកដំបូងបានធ្វើឡើងនៅក្នុងខែកញ្ញា ឆ្នាំ២០០៤។ សេចក្តីពិស្តារបន្ថែមទៀតត្រូវបានបន្ថែមទៅក្នុងជំហាននីមួយៗ ពោលគឺ ចាប់ពីគោលនយោបាយ រហូតដល់ច្បាប់ និងការគ្រប់គ្រងលើការអនុវត្តន៍នៅលំដាប់ថ្នាក់និងកម្រិតខុសៗគ្នា។ ការរីកចម្រើនបន្ថែមទៀត បាននាំទៅដល់ការអនុម័តផែនការវិស័យទឹកនៅថ្នាក់ខេត្ត ដូចជា ខេត្តម្ពូម្ពូឡាន់ហ្គានៅក្នុងឆ្នាំ២០០៦។ ចំណុចសំខាន់នៅទីនេះគឺ នៅអាហ្វ្រិកខាងត្បូងគេត្រូវការឲ្យមានកញ្ចប់មួយនៃកិច្ចព្រមព្រៀង (ដូចជានៅក្នុងប្រទេសដទៃផងដែរ) ហើយនៅក្នុងដំណាក់កាលនីមួយៗ ការចរចាតាមទម្រង់ខុសៗគ្នា មានសារៈសំខាន់ណាស់។

សមិទ្ធផលដែលគួរឲ្យកត់សំគាល់នៅក្នុងកំណែទម្រង់នេះ គឺការគូសបញ្ជាក់អំពី ថាតើគោលការណ៍នានានៃការគ្រប់គ្រងទឹក និងធនធានទឹកតាមបែបវិមជ្ឈការ និងសហការ នឹងត្រូវដាក់ឲ្យអនុវត្តបែបណា។ ច្បាប់ជាតិស្តីពីទឹក ទទួលស្គាល់អំពីសារៈសំខាន់នៃការចូលរួមរបស់សង្គមស៊ីវិល វិស័យឯកជន និងឧស្សាហកម្ម នៅក្នុងការគ្រប់គ្រងធនធានទឹក។ វាគូសបញ្ជាក់អំពី ការបង្កើតស្ថាប័នគ្រប់គ្រងអាងទន្លេដែលមានការចូលរួមពីអ្នកពាក់ព័ន្ធនានាដូចជា ទីភ្នាក់ងារគ្រប់គ្រងអាងផ្ទៃរងទឹកភ្លៀង វេទិកាគ្រប់គ្រងអាងផ្ទៃរងទឹកភ្លៀង និងសមាគមអ្នកប្រើប្រាស់ទឹក។ ផ្ទៃរងទឹកភ្លៀងបាន និងកំពុងក្លាយជាឯកត្តាបឋមសម្រាប់ការចរចាលើការគ្រប់គ្រងធនធានទឹក ហើយវេទិកាគ្រប់គ្រងអាងផ្ទៃរងទឹកភ្លៀង បានក្លាយជាវេទិកាស្ថាប័ននៅទូទាំងអាងទន្លេដែលសកម្មភាពតំណាង និងការចូលរួមដែលកើតឡើងអាចមានឥទ្ធិពលមកលើកំណែទម្រង់ និងកម្មវិធីថ្មីៗខាងស្ថាប័ន។ វេទិកាទាំងនេះលើកឡើងអំពីចំណាប់អារម្មណ៍នៅមូលដ្ឋាន និងអនុញ្ញាតឲ្យសមាជិកសហគមន៍ក្រីក្រចូលរួម កាន់តែមានប្រសិទ្ធភាពជាងមុនក្នុងការគ្រប់គ្រងធនធានទឹកដូចដែលឃើញនៅក្នុងវេទិកាជ្រលងទន្លេកាត។[79]

## *នៅកម្រិតអន្តរជាតិ*

កិច្ចព្រមព្រៀងអន្តរជាតិ គឺជាកិច្ចព្រមព្រៀងរវាងរដ្ឋនានា ដែលចែងអំពីអភិបាលកិច្ចនៃឥរិយាបថរបស់អ្នកដើរតួនៅក្នុងរដ្ឋ។ កិច្ចព្រមព្រៀងទាំងនេះរាប់បញ្ចូល កិច្ចព្រមព្រៀងនៅកម្រិតពិភពលោក តំបន់ ពហុភាគី និងទ្វេភាគី ដូចជា សេចក្តីថ្លែងការណ៍អ.ស.បនៃគោលការណ៍ អនុសញ្ញា និងសន្ធិសញ្ញានានា។ មានឧទាហរណ៍នានាអំពីកិច្ចព្រមព្រៀងអន្តរជាតិដែលចែងអំពីអភិបាលកិច្ចនៃឥរិយាបថរបស់រដ្ឋនៅក្នុង

ដែនយុត្តាធិការរបស់ខ្លួនទាំងមូលដូចជា អនុសញ្ញាស្តីពីកិច្ចការពារ និងប្រើប្រាស់ផ្លូវទឹកឆ្លងខ័ណ្ឌដែនសីមា និងបឹងអន្តរជាតិ (១៩៩២) ក៏ដូចជា កិច្ចព្រមព្រៀងសម្រាប់អាងទន្លេឆ្លងខ័ណ្ឌដែនសីមា ល្អាងទឹក និងបឹងនានា ដូចដែលបានប្រកាស នៅក្នុងកិច្ចផ្តួចផ្តើមអាងទន្លេនីល នៅឆ្នាំ ១៩៩៩[79] និងកិច្ចផ្តួចផ្តើមមួយផ្សេងទៀតសម្រាប់ណែនាំដល់ការចែករំលែកសម្បទាសេវាកម្មទឹកសម្រាប់ប្រើប្រាស់រវាងរដ្ឋរវាងដែនទឹកនៅជូ និងតាឡាស ដែលបានចុះហត្ថលេខាដោយរដ្ឋាភិបាល កាហ្សាក់ស្ថាន និងកៀរហ្គីស្ថាន នៅឆ្នាំ ២០០០។

កិច្ចព្រមព្រៀងអំពីទឹកថ្នាក់តំបន់ ក៏កំពុងត្រូវបានចរចាកាន់តែច្រើនឡើងផងដែរ ដូចជា បទប្បញ្ញត្តិទឹករបស់សហភាពអឺរ៉ុប ឆ្នាំ ២០០០ កិច្ចព្រមព្រៀងសហប្រតិបត្តិការលើផ្នែកទឹករវាងទ្វីបអាមេរិក (២០០៦) និងពិធីសារដើម្បីណែនាំសហគមន៍អភិវឌ្ឍន៍នៅអាហ្វ្រិកខាងត្បូង (SADC) ដោយសមាជិកមានទន្លេរួមគ្នាជាច្រើន។

## *នៅលំដាប់អន្តរប្រទេស*

កិច្ចព្រមព្រៀងអន្តរប្រទេស ជាប់ពាក់ព័ន្ធនឹងរដ្ឋនៅក្នុងប្រទេសខុសៗគ្នា និងអភិបាលឥរិយាបថនៃអ្នកដើរតួនៅក្នុងអន្តរប្រទេសទាំងនោះ។ ទិដ្ឋភាពសំខាន់នៃកិច្ចព្រមព្រៀងទាំងនេះគឺការផ្តោតលើឥរិយាបថរបស់អ្នកដើរតួដែលមិនជាផ្នែកមួយនៃរដ្ឋ បើទោះពួកគេជាស្ថាប័ន ឬបុគ្គលក៏ដោយ ដែលជាអ្នកប្តេជ្ញាគោរពតាមខ្លឹមសារនេះ។ តួនាទីរបស់ប្រទេសនីមួយៗ ឬ រដ្ឋាភិបាលនៃរដ្ឋទាំងនេះ មិនសូវសំខាន់ឡើយនៅក្នុងករណីនេះ។

អ្នកដើរតួរវាងប្រទេសកើតមានតាមទម្រង់ និងស្ថានភាពខុសៗគ្នា ៖

- អង្គការមិនមែនរដ្ឋាភិបាល ដូចជា WWF និងអង្គការទន្លេអន្តរជាតិ
- អង្គភាពឧស្សាហកម្មដូចជា WBCSD សមាគមធនធានទឹកអន្តរជាតិ (IWRA) និង សមាគមវារីអគ្គិសនីអន្តរជាតិ (IHA)
- ហិរញ្ញិកនៃការអភិវឌ្ឍន៍ដែលរួមទាំងធនាគារនីមួយៗ ឬស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ
- អង្គការអន្តរជាតិ ដែលធ្វើការលើកិច្ចការទឹក ដូចជា ក្រុមប្រឹក្សាទឹកពិភពលោក (WWC) ក្រុមប្រឹក្សាទឹកអន្តរជាតិ (IWMI) គណៈកម្មការអន្តរជាតិស្តីពីការស្រោចស្រព (ICID) និង IUCN។

  កិច្ចព្រមព្រៀងឆ្លងប្រទេសជាច្រើន គឺជាក្រុមអនុវត្ត ដែលចែងអំពីគោលការណ៍ ជាទូទៅ ក្រុមទាំងនោះ ច្រើនតែមិនជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ឡើយ ហើយការតាមដានលើគោរព ឬ ការប្រតិបត្តិអាចកាន់តែលំបាក ដោយសារកិច្ចព្រមព្រៀងឆ្លងប្រទេសទាំងនោះ ធ្វើឡើងតាមរយៈការគាបសង្កត់ពីក្រុមសមាជិកពិនិត្យកែសម្រួល ឬ ពីសាធារណជន។ កិច្ចព្រមព្រៀងអន្តរប្រទេសដែលទាក់ទងនឹងទឹកក៏រាប់បញ្ចូលយុទ្ធសាស្ត្រ គោលនយោបាយ និងកម្មវិធី ដែលអ្នកដើរតួមិនមែនរដ្ឋបានបង្កើតឡើងផងដែរ ដែលណែនាំដល់សកម្មភាពនៅទូទាំងពិភពលោក។

## *អ្នកដើរតួ និងភាគី*

សំណួរគន្លឹះដែលផ្អែកលើទស្សនវិស័យនៃការបង្កើតកិច្ចព្រមព្រៀងមួយគឺតើអ្នកណាចុះហត្ថលេខា តែគណនេយ្យភាព និងអ្នកណាជាអ្នកដឹកនាំ។ បើទោះជាអ្នកដើរតួជាច្រើនអាចចូលរួមនៅក្នុង MSP ណាមួយក៏ដោយក៏ការចុះហត្ថលេខា គឺអាស្រ័យលើប្រភេទនៃកិច្ចព្រមព្រៀង។

ភាគច្រើននៃកិច្ចព្រមព្រៀងអន្តរជាតិ និងគោលនយោបាយជាតិ និងច្បាប់ជាតិ ត្រូវចុះហត្ថលេខាដោយតំណាងរបស់រដ្ឋ។ កិច្ចព្រមព្រៀងអន្តរប្រទេស ច្រើនតែចុះហត្ថលេខាដោយអ្នកដើរតួជាក់លាក់នៅរវាងប្រទេស។ ធម្មនុញ្ញ និងក្រមអនុវត្ត អាចចុះហត្ថលេខាដោយអ្នកដើរតួខុសៗគ្នា ក៏ដូចជា កិច្ចសន្យា និងវិភាជន៍ផ្សេងៗទៀត និងកិច្ចព្រមព្រៀងគ្រប់គ្រងផងដែរ។

ការបង្ហាញឲ្យបានច្បាស់លាស់អំពីថាតើអ្នកណាចុះហត្ថលេខាលើកិច្ចព្រមព្រៀង ផ្តល់ជាមូលដ្ឋានសម្រាប់អ្នកដើរតួក្នុងការសម្រេចអំពីអ្វីដែលត្រូវការជាចាំបាច់ ដើម្បីចូលរួមនៅក្នុងការចរចា និងរៀបបង្កើតដំណើរការនេះ។ ទោះជាយ៉ាងណាក៏ដោយ សូមចងចាំដែលថាដំណើរការទូលំទូលាយនៃការចូលរួមដោយស្ថាបនា អ្នកពាក់ព័ន្ធនៅក្នុង MSP នៅតែអាចចរចា និងចុះហត្ថលេខានៅលើអនុសាសន៍មួយដែលមានគោលដៅផ្តល់ជាមូលដ្ឋានសម្រាប់ការធ្វើសេចក្តីសម្រេចពីអាជ្ញាធរខាងក្រៅផងដែរ។

> *"សំណួរសំខាន់ៗដែលផ្អែកលើទស្សនទាននៃការបង្កើតកិច្ចព្រមព្រៀងគឺតើអ្នកណាត្រូវមានគណនេយ្យភាព និងអ្នកណានឹងជាអ្នកដឹកនាំ"*

## *៥.៣ ប្រភេទនៃកិច្ចព្រមព្រៀង*

កិច្ចព្រមព្រៀងអាចចែកចេញជាក្រុមធំៗដូចតទៅ គោលនយោបាយ ច្បាប់ ធម្មនុញ្ញ និងក្រមអនុវត្ត កិច្ចសន្យា និងការចាត់ចែងលើការវិភាជន៍ និងលើការគ្រប់គ្រង។ កិច្ចព្រមព្រៀងទាំងនេះគឺជាក្រុមធំៗដែលអាចមានភាពត្រួតគ្នាខ្លះៗ។ ភាសានៅក្នុងកិច្ចព្រមព្រៀង និងជាពិសេស នៅក្នុងច្បាប់ និងគោលនយោបាយ អាចមានលក្ខណៈច្របូលច្របល់ ជាពិសេសនៅពេលធ្វើឡើងជាច្រើនភាសា។ គេអាចឲ្យឈ្មោះខុសៗគ្នានៃកិច្ចព្រមព្រៀងប្រភេទដូចគ្នានេះអាស្រ័យលើអ្នកដើរតួដែលពាក់ព័ន្ធនិងបរិបទនៃច្បាប់និងនយោបាយ។ ចំណុចសំខាន់គឺត្រូវយល់ឲ្យបានច្បាស់អំពីថាតើកិច្ចព្រមព្រៀងនេះមានគោលបំណងអ្វី និងតើវានឹងមានឥទ្ធិពល ឬចែងអំពីឥរិយាបថបែបណា និងមិនត្រូវផ្តោតខ្លាំងពេកទៅលើការឲ្យឈ្មោះរបស់កិច្ចព្រមព្រៀងនោះឡើយ។ ប្រភេទនៃកិច្ចព្រមព្រៀងមានសង្ខេបនៅក្នុងតារាង៥.១ (សូមអានទំព័រ ៨៦ និង៨៧)

### *៥.៣.១ គោលនយោបាយ*

គោលនយោបាយចែងជាគោលការណ៍រួម គោលបំណង និងអាទិភាពជាយុទ្ធសាស្ត្រ ដែលផ្តល់ជាការតម្រង់ទិសដល់រដ្ឋាភិបាល ឬអង្គការណាមួយ នៅក្នុងការគ្រប់គ្រងកិច្ចការរបស់ខ្លួន។ គោលនយោបាយត្រូវបានបង្កើតឡើងនៅគ្រប់លំដាប់ថ្នាក់នៃរដ្ឋាភិបាល និងពីសំណាក់ស្ថាប័នផ្សេងទៀត។ គោលនយោបាយត្រូវបានបង្កើតឡើងនៅគ្រប់កម្រិត និងលំដាប់ថ្នាក់ ដែលរួមទាំងឯកសារនានាដែលផ្តល់ការណែនាំអំពីការអនុវត្តន៍នៅកម្រិតពិភពលោកផងដែរ។ បើទោះជាឯកសារគោលនយោបាយអាចជាការទទួលខុសត្រូវរបស់ស្ថាប័នតែមួយក៏ដោយ វាអាចស្ថិតក្រោមឥទ្ធិពលពីអ្នកដើរតួជាច្រើនផងដែរ។

គេឃើញមានពាក្យជាច្រើនដែលពាក់ព័ន្ធនឹងគោលនយោបាយ ដូចជា សេចក្តីប្រកាស យុទ្ធសាស្ត្រ ផែនការយុទ្ធសាស្ត្រ និងចក្ខុវិស័យ។ គោលនយោបាយទឹក (និងយុទ្ធសាស្ត្រ ផែនការ ចក្ខុវិស័យ) ផ្តល់ជាក្របខ័ណ្ឌណែនាំសម្រាប់ផែនការកាន់តែជាក់លាក់នៅកម្រិតមូលដ្ឋាន ដូចជាផែនការធនធានទឹក(Great

Artesian)នៅឃ្វីនស្លែន (២០០៦)។

ការចរចារវាងរដ្ឋាភិបាលអាល់ហ្សេរី លីប៊ី និងទុយនីស៊ី បាននាំទៅរកសេចក្តីប្រកាសរួមថ្នាក់ក្រសួង នៅឆ្នាំ២០០៥ ដើម្បីបង្កើតមធ្យោបាយជាផ្លូវការជាងមុនសម្រាប់ស្ថាប័ន សម្រាប់ការសម្របសម្រួល និង ការគ្រប់គ្រងប្រព័ន្ធល្អាងទឹកនៅភាគពាយ័ព្យនៃតំបន់សាហារ៉ា (ដែលគេស្គាល់ថាជា SASS ពាក្យបំព្រួញ ជាភាសាបារាំង) នេះគឺជាកិច្ចព្រមព្រៀងដំបូងមួយសម្រាប់ល្អាងទឹកឆ្លងខ័ណ្ឌដែនសីមា។[81] បើទោះជាវាអាចមានកម្រិតកំណត់លើសេចក្តីពិស្តារក៏ដោយ កិច្ចព្រមព្រៀងបែបនេះអាចជាចំណុចគោល ដ៏សំខាន់ នៅក្នុងការបង្កើតឲ្យមានការយោគយល់ និងទំនុកចិត្ត ហើយដូច្នេះវាជាការបង្កើតមូលដ្ឋានគ្រឹះ សម្រាប់ឲ្យមានកិច្ចព្រមព្រៀងកាន់តែជាក់លាក់ទៅថ្ងៃអនាគត។

### *៥.៣.២ ច្បាប់*

ច្បាប់បម្លែងគោលនយោបាយ ឲ្យទៅជាបទបញ្ញាប្រតិបត្តិការ។ នៅក្នុងករណីភាគច្រើន គោល នយោបាយត្រូវបានកសាងឡើងជាមុន បន្ទាប់មកគឺច្បាប់ ដែលតាមធម្មតាច្បាប់មានលក្ខណៈជាក់លាក់ និងផ្តោតលើចំណាត់ការ។ ទោះជាយ៉ាងណាក៏ដោយវាមិនមែនជាបទបញ្ញាដ៏តឹងរ៉ឹង និងដែលអាចធ្វើបាន ដោយឆាប់រហ័សពីព្រោះឯកសារប្រភេទគោលនយោបាយមួយនេះក៏អាចត្រូវបានតាក់តែងឡើងជាមួយ នីតិវិធី និងបទបញ្ញានានា ដើម្បីអនុវត្តច្បាប់ផងដែរ (សូមអានករណី ៥.១)។ គេមានវាក្យស័ព្ទជាច្រើន ដែលទាក់ទងនឹងច្បាប់ ហើយភាពខុសគ្នារវាងពាក្យទាំងនោះនៅមានត្រឹមតិចតួចប៉ុណ្ណោះ។ ជាទូទៅ អនុសញ្ញា សន្ធិសញ្ញា កិច្ចព្រមព្រៀង និង Accord គឺជាច្បាប់ ដែលចុះហត្ថលេខាដោយប្រទេសមួយចំនួន។ ពាក្យថា ច្បាប់ សេចក្តីស្នើច្បាប់ លក្ខន្តិកៈ ក្រឹត្យ បទប្បញ្ញត្តិ និងនីតិវិធីសំដៅលើច្បាប់ដែលច្រើនតែនិយម ប្រើប្រាស់នៅថ្នាក់ជាតិ (ឬថ្នាក់ក្រោមជាតិ) និងសម្រាប់បទបញ្ញាអនុវត្តបទដ្ឋានច្បាប់ទាំងនោះនៅក្នុង ប្រទេស។

### *៥.៣.៣ ធម្មនុញ្ញ និងក្រមអនុវត្ត*

ធម្មនុញ្ញ និងក្រមអនុវត្ត ត្រូវបានប្រើប្រាស់ជាទូទៅ ដើម្បីបង្កើតគោលការណ៍រួមមួយចំនួន ឬគោល ការណ៍ណែនាំ ដែលនឹងចែងអំពីឥរិយាបថរបស់អ្នកដើរតួមួយក្រុម។ វាមានភាពខុសគ្នាលើចំណុចពិស្តារ ដែលរាប់ចាប់ពី បង្ហាញពីកិច្ចសហប្រតិបត្តិការទូលំទូលាយ រហូតដល់ការចែងបញ្ជាក់អំពីឥរិយាបថ និង ចំណាត់ការដែលភាគីនានានឹងត្រូវគោរពតាម។ ឧទាហរណ៍ ធម្មនុញ្ញទឹក KYB នៅប្រទេសនីហ្សេរីយ៉ា រួម បញ្ចូលការទទួលខុសត្រូវជាក់លាក់ និងបទបញ្ញាសម្រាប់ការប្រើប្រាស់ដី និងទឹក និងការគ្រប់គ្រងអាង ជាក់លាក់ណាមួយនៅក្នុងប្រទេសតែមួយ (សូមអានករណី ៩.៦ ក្នុងជំពូក ៤)។

ធម្មនុញ្ញ និងក្រមអនុវត្ត អាចមានភាពជាក់លាក់ទៅតាមទីតាំង និងអនុវត្តសម្រាប់បុគ្គល និងស្ថាប័ន មួយចំនួននៅក្នុងទីកន្លែងណាមួយ ដូចនៅក្នុងករណីធម្មនុញ្ញទឹក KYB នៅប្រទេសនីហ្សេរីយ៉ា ក្រមអនុវត្ត អាងវ៉ុលតា (សូមអានករណី ៥.៣) ឬធម្មនុញ្ញអាង ប្រោហ្សវ័ ដើម្បីនិរន្តរភាព។[82]

ផ្ទុយទៅវិញ ធម្មនុញ្ញ និងក្រមអនុវត្តនានាអាចផ្តោតលើអ្នកដើរតួជាក់លាក់ទោះបីជាពួកគេប្រតិបត្តិ ការនៅទីណាក៏ដោយដូចជា ពិធីសារវាយតម្លៃនិរន្តរភាពថាមពលវារីអគ្គិសនី ឬគោលការណ៍អេក្វាទ័រ ដែលអនុវត្តជាមួយហិរញ្ញិកសម្រាប់ការអភិវឌ្ឍន៍។

## តារាង៥.១៖ ប្រភេទនៃកិច្ចព្រមព្រៀង

| ប្រភេទនៃកិច្ចព្រមព្រៀង | មូលដ្ឋាន | ថ្នាក់ជាតិ/ក្រោមជាតិ | អន្តរជាតិ | រវាងប្រទេស |
| --- | --- | --- | --- | --- |
| វិសាលភាព | កិច្ចព្រមព្រៀងដែលអភិបាលឥរិយាបថនៅក្នុងទីតាំងជាក់លាក់មួយនៅក្នុងរដ្ឋមួយ អាចអនុវត្តនៅក្នុងដែនដីរដ្ឋបាលណាមួយ(ក្រុង,ភូមិ។ល។) ឬបឹង,ទីជម្រាលជាក់លាក់។ល។អាចចេញដោយរដ្ឋ ឬ កិច្ចព្រមព្រៀងរវាងភាគីជាច្រើន (រដ្ឋ និងមិនមែនរដ្ឋ) | កិច្ចព្រមព្រៀងនៅក្នុងរដ្ឋមួយដែលអភិបាលឥរិយាបថនៃពលរដ្ឋនិងអ្នកពាក់ព័ន្ធដទៃទៀតដែលប្រតិបត្តិការនៅទីនេះ។ អាចអនុវត្តបាននៅក្នុងដែនដីរដ្ឋបាលណាមួយ(ប្រទេស,ខេត្ត។ល។) ឬអាងទន្លេ,បឹង, ល្អាងជាក់លាក់។ល។ អាចចេញដោយរដ្ឋ ឬ កិច្ចព្រមព្រៀងរវាងភាគីជាច្រើន (រដ្ឋនិងមិនមែនរដ្ឋ) | កិច្ចព្រមព្រៀងនៅកម្រិតពិភពលោក ប្រចាំតំបន់ ឬទ្វេភាគីរវាងរដ្ឋនៃប្រទេសមួយ ដែលអភិបាលឥរិយាបថនៃអ្នកដើរតួនៅក្នុងរដ្ឋនៅក្នុងដែនយុត្តាធិការទាំងមូលរបស់ពួកគេ។ កិច្ចព្រមព្រៀងសម្រាប់អាងឆ្លង ល្អាង បឹងខ័ណ្ឌសីមា។ អ្នកដើរតួមិនមែនរដ្ឋខ្លះក៏អាចជាហត្ថលេខីផងដែរ។ | កិច្ចព្រមព្រៀងរវាងរដ្ឋនៅក្នុងប្រទេសណាមួយ និងអភិបាលឥរិយាបថនៃអ្នកដើរតួរវាងប្រទេសនៅតាមទីកន្លែងដែលពួកគេប្រតិបត្តិការ |
| **គោលនយោបាយ**<br>ចែងអំពីគោលការណ៍ទូទៅ គោលបំណងនិងអាទិភាពជាយុទ្ធសាស្ត្រដែលផ្តល់ក្របខ័ណ្ឌណែនាំ។ វាក្យស័ព្ទ:គោលនយោបាយ យុទ្ធសាស្ត្រ ផែនការយុទ្ធសាស្ត្រ ចក្ខុវិស័យ សេចក្តីប្រកាស។<br>ពាក្យគន្លឹះ: រដ្ឋនិងមិនមែនរដ្ឋ | យុទ្ធសាស្ត្រ និងគោលនយោបាយរបស់អាជ្ញាធរគោលនយោបាយ និងផែនការយុទ្ធសាស្ត្រនៅថ្នាក់មូលដ្ឋាន (ក្រុម ភូមិ។ល។) ឬរបស់អាងទឹកនៅក្នុងមូលដ្ឋាន ដូចជា ៖<br>-ចក្ខុវិស័យនៃពាមនៃទន្លេស្កែលនៅអឺរ៉ុប<br>-ផែនការមិក្រូទីជម្រាលដែលបានបង្កើតឡើងដោយសហគមន៍នៅតំបន់ភ្នំភ្លើងតាកាណាក្នុងប្រទេសម៉ិកស៊ិក និងហ្គាតេម៉ាឡា | ជាតិនិងថ្នាក់ក្រោមជាតិសម្រាប់ ៖<br>- ទឹកជារួម (ដូចជាគោលនយោបាយជាតិស្តីពីទឹកនៅអាហ្វ្រិកខាងត្បូង១៩៩៧ ផែនការស្តីពីទឹកនៅខេត្តម្ហូ ម៉ាឡាំងហ្គាឆ្នាំ២០០៦)<br>-វិស័យមួយ (ដូចជា ផែនការអភិវឌ្ឍន៍ថាមពលប្រទេសវៀតណាម)<br>-អាងទឹកជាក់លាក់មួយនៅក្នុងប្រទេសមួយ (ដូចជាផែនការគ្រប់គ្រងយុទ្ធសាស្ត្រសម្រាប់អាងហ្គ្រេតអាតេស៊ានឆ្នាំ២០០០ នៅអូស្ត្រាលីរវាងរដ្ឋជាសមាជិក ដែល មានល្អាងទឹករួមគ្នា បញ្ហានានាដែលប៉ះពាល់មកលើទឹក(ដូចជាការប្រែប្រួលអាកាសធាតុ) | សេចក្តីថ្លែងការណ៍ពិភពលោកឬតំបន់ដែលផ្តល់គោលការណ៍សម្រាប់ការណែនាំដូចជា៖<br>-សេចក្តីថ្លែងការណ៍ឌូប្លីន ឆ្នាំ១៩៩២<br>-បទបញ្ជាទឹកហែលស៊ីងគី ឆ្នាំ១៩៦៦<br>-បទបញ្ញាបែរឡាំងស្តីពីទឹកឆ្នាំ២០០៤<br>-កិច្ចព្រមព្រៀងសហប្រតិបត្តិការអន្តរទ្វីបអាមេរិក ឆ្នាំ២០០៦<br>-ពិធីសារស្តីពីទឹករួមគ្នាសម្រាប់អាហ្វ្រិកខាងត្បូងដែលបានកែសម្រួល(SADC)២០០០ គោលនយោបាយឬផែនការយុទ្ធសាស្ត្រសម្រាប់អាងឆ្លងខ័ណ្ឌសីមាដូចជាយន្តការពិគ្រោះយោបល់ដែលបង្កើតឡើងសម្រាប់ប្រព័ន្ធល្អាងទឹកនៅពាយ័ព្យនៃតំបន់សាហារ៉ានៅទ្វីបអាហ្វ្រិក២០០២។ | នយោបាយសម្រាប់អ្នកដើរតួខាងផ្នែកទឹក ដូចជា ៖<br>- ក្រុមប្រឹក្សាទឹកពិភពលោក<br>-ក្រុមប្រឹក្សាធុរកិច្ចទឹកស្តីពីការអភិវឌ្ឍន៍ដោយចីរភាព<br>-WWF (មូលនិធិពិភពលោកសម្រាប់អភិរក្សធម្មជាតិ |
| **ច្បាប់**<br>បម្លែងគោលនយោបាយទៅជាបទបញ្ជាអនុវត្តជាក់លាក់វាក្យស័ព្ទ៖ អនុសញ្ញា សន្ធិសញ្ញានិង Accord(រវាងប្រទេសច្រើន) ច្បាប់ សេចក្តីស្នើច្បាប់ លក្ខន្តិកៈ ក្រឹត្យ បទប្បញ្ញត្តិ (ច្បាប់ជាតិនិងបទប្បញ្ញត្តិ)អ្នកដើរតួគន្លឹះ៖ រដ្ឋ | បទប្បញ្ញត្តិរបស់សាលាក្រុង ទីប្រជុំជន និងភូមិដូចជា៖<br>-លក្ខន្តិកៈគ្រប់គ្រងទីជម្រាលដែលចុះហត្ថលេខាដោយកសិករប៉ិយគង់ ឬ<br>-បទប្បញ្ញត្តិនៃលក្ខន្តិកៈសម្រាប់គ្រប់គ្រងធនធានទឹកនៅអនុអាងទន្លេវ៉ាយវុលហ្គាដោយអភិបាលនៅមូលដ្ឋាន ក្នុងតំបន់ជាប់ព្រំដែនប្រទេសហ្គាណា និងប៊ូគីណាហ្វាសូ | ច្បាប់និងបទប្បញ្ញត្តិជាតិ និងក្រោមជាតិសម្រាប់៖<br>- ទឹកជារួម (ដូចជា ច្បាប់ជាតិស្តីពីទឹកនៃអាហ្វ្រិកខាងត្បូង ១៩៩៨)<br>- វិស័យជាក់លាក់មួយ (ដូចជា ច្បាប់ស្តីពីការស្រោចស្រពឆ្នាំ២០០៤នៃប្រទេសបូលីវីយ៉ា)<br>អាងទឹកជាក់លាក់មួយក្នុងប្រទេសមួយ (ដូចជាបទប្បញ្ញត្តិប្រទេសចិនឆ្នាំ២០០៧ដើម្បីគ្រប់គ្រងអាងទន្លេតារីម ឬកិច្ចព្រម ព្រៀងអាងទន្លេម៉ារេដេលីននៃប្រទេសអូស្ត្រាលី៥៨៥ | អនុសញ្ញា និងសន្ធិសញ្ញាពិភពលោកនិងតំបន់៖<br>- អនុសញ្ញារ៉ាមសារ ១៩៧១<br>- អនុសញ្ញាស្តីពីកិច្ចការពារនិងប្រើប្រាស់ផ្លូវទឹកឆ្លងខ័ណ្ឌសីមា និងបឹងអន្តរជាតិ១៩៩២<br>- អនុសញ្ញាស្តីពីផ្លូវទឹកអន្តរជាតិ ១៩៩៧<br>- បទបញ្ជាសហភាពអឺរ៉ុបស្តីពីទឹក ២០០០<br>- កិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ ១៩៩៥ | |

| ប្រភេទនៃកិច្ចព្រមព្រៀង | មូលដ្ឋាន | ថ្នាក់ជាតិ ឬក្រោមជាតិ | អន្តរជាតិ | រវាងប្រទេស |
|---|---|---|---|---|
| **ធម្មនុញ្ញ និងក្រមអនុវត្ត**<br>កំណត់អំពីចេតនាដើម្បីសហប្រតិបត្តិការ និងគោរពតាមគោលការណ៍ឬគោលការណ៍ណែនាំ រួមវាក្យស័ព្ទ:ធម្មនុញ្ញទឹក ក្រមអនុវត្ត គោលការណ៍ណែនាំ គោលការណ៍អ្នកដើរតួគន្លឹះ:រដ្ឋ និងមិនមែនរដ្ឋជាច្រើន | | ឧទាហរណ៍៖<br>- ធម្មនុញ្ញទឹកនៅអាងកូម៉ាឌុហ្គុយ៉ូបេ (សម្រាប់ នីហ្សេរីយ៉ា)<br>- ធម្មនុញ្ញអាងហ្សេរ៉េដើម្បីនិរន្តរភាព ឆ្នាំ ១៩៩៧ | ឧទាហរណ៍៖<br>- ក្រមអនុវត្តស្តីពីទឹកក្នុងអាងទន្លេវ៉ុលហ្គា<br>- កិច្ចព្រមព្រៀងដើម្បីកំណត់ និងណែនាំដល់កិច្ចផ្តួចផ្តើមអាងទន្លេនីល | ឧទាហរណ៍៖<br>- គោលការណ៍អេក្វាទ័រសម្រាប់និយ័តកម្មដំណើរការជួលហិរញ្ញិក<br>- គោលការណ៍ណែនាំអំពីនិរន្តរភាពនៃសមាគមថាមពលវារីអគ្គិសនីអន្តរជាតិគោលការណ៍ណែនាំវិស័យព្រៃឈើប្រទេសចិនឆ្នាំ ២០០៧ សម្រាប់ក្រុមហ៊ុនចិនដែលប្រតិបត្តិការក្រៅ ប្រទេសចិន |
| **កិច្ចសន្យា**<br>កិច្ចព្រមព្រៀងដែលជាប់កាតព្វកិច្ចក្រោមច្បាប់ ស្តីពីកិច្ចសន្យាអ្នកដើរតួសំខាន់៖ រដ្ឋ និងមិនមែនរដ្ឋ | ភាពជាដៃគូសាធារណៈ: ឯកជន ដូចជាណាមធឿង២, គម្រោងថាមពលវារីអគ្គិសនីក្រោមក្របខ័ណ្ឌ សាងសង់ ទទួលយក-ដាក់ឲ្យប្រតិបត្តិការ ផ្ទេរនៅក្នុងប្រទេសឡាវកិច្ចសន្យារវាងក្រុមស្ត្រី និងអាជ្ញាធរក្រុងនៅរដ្ឋ គុចារ៉ាតប្រទេសឥណ្ឌា សម្រាប់ការថែរក្សាប្រព័ន្ធទឹក | កិច្ចសន្យារវាងរដ្ឋាភិបាល និងក្រុមហ៊ុនផ្គត់ផ្គង់អគ្គិសនី | កិច្ចព្រមព្រៀងទ្វេភាគីដើម្បីលក់ទឹក (ដូចជា រវាងម៉ាឡេស៊ី និងសិង្ហបុរី។ ឬឡេសូថូ និងអាហ្វ្រិកខាងត្បូង) កិច្ចព្រមព្រៀងបែងចែកទឹកខុសៗគ្នា រវាងស.រ.អា កាណាដា និងម៉ិកស៊ិកកូ | |
| កិច្ចព្រមព្រៀងវិភាជន៍ និងការគ្រប់គ្រងដទៃទៀត<br>កិច្ចព្រមព្រៀងបែងចែកទឹកផ្សេងទៀត កម្មវិធី និងផែនការដែលណែនាំដល់សកម្មភាពអ្នកដើរតួគន្លឹះ៖ រដ្ឋ និងមិនមែនរដ្ឋ | ឧទាហរណ៍៖<br>- ប្រព័ន្ធប្រឡាយចាក់ហ្វ្លាដែលមានចំណាស់មួយសតវត្សរ៍នៅតង់ហ្សានី<br>- កិច្ចព្រមព្រៀងស្តីពីផលប៉ះពាល់ និងផលប្រយោជន៍ (ដូចជារវាងសហគមន៍និងរដ្ឋាភិបាលនៅថ្នាក់ជាតិសម្រាប់អណ្តូងរ៉ែអ្នកគេឌី នៅប៉ាពួញូហ្គីនេ)<br>- កិច្ចព្រមព្រៀង"ដីសម្រាប់ការងារ"នៅហ្គាណា រវាងស្ត្រីគ្មានដីធ្លី និងម្ចាស់ដី កម្មវិធី ផែនការ និងវិភាជន៍ថវិការបស់អាជ្ញាធរមូលដ្ឋាន (ដូចជា ផែនការកែលម្អគុណភាពទឹកនៅរដ្ឋក្លាស់ស៊រ ឆ្នាំ២០០៦ នៅអូស្ត្រាលី | ឧទាហរណ៍៖<br>ការកំហិតនៅលើអាងទន្លេម៉ូរ៉េដាលីន ស្តីពីការទាញយកទឹកនៅលើផ្ទៃដី ដែលបានដាក់ឲ្យអនុវត្តនៅឆ្នាំ ១៩៩៥ | ឧទាហរណ៍៖<br>កិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងកាហ្សាក់ស្ថង់ និងគៀងហ្គីស្តង់ស្តីពីការគ្រប់គ្រងសម្បទានៅលើទន្លេឆ្លងខ័ណ្ឌសីមាជូនិងតាឡាស់ ឆ្នាំ២០០៦ | កម្មវិធី និងផែនការសម្រាប់អ្នកដើរតួឆ្លងខ័ណ្ឌសីមាមកពីឧស្សាហកម្មអង្គការមិនមែនរដ្ឋាភិបាល។ល។ |

នៅប្រទេសចិនវិទ្យាស្ថានបរិស្ថានពិភពលោកដែលមានមូលដ្ឋាននៅក្រុងប៉េកាំង(GEI)សាកលវិទ្យាល័យធុរកិច្ចនិងសេដ្ឋកិច្ចអន្តរជាតិនិងបណ្ឌិតសភាចិនសម្រាប់កសាងផែនការបរិស្ថានបានសហការជាមួយមន្ត្រីរដ្ឋាភិបាល ដើម្បីបង្កើតក្រមអនុវត្តក្នុងវិស័យព្រៃឈើ សម្រាប់សហគ្រាសចិនដែលប្រតិបត្តិការនៅក្រៅប្រទេសចិន។ ក្រមនេះត្រូវបានចុះហត្ថលេខានៅឆ្នាំ២០០៧ ដោយក្រសួងពាណិជ្ជកម្ម និងរដ្ឋបាលព្រៃឈើរបស់រដ្ឋ និងតម្រូវឲ្យក្រុមហ៊ុនចិន គោរពតាមច្បាប់នានារបស់ប្រទេសជាកន្លែងដែលខ្លួនកំពុងប្រតិបត្តិការ សូម្បីតែច្បាប់ទាំងនោះស្ថិតក្រោមការគោរពតិចតួចពីអ្នកដើរតួដទៃក្នុងវិស័យព្រៃឈើក៏ដោយ។ បច្ចុប្បន្ននេះ ក្រុមហ៊ុនចិនប្រឈមហានិភ័យនៃការរំលោភលើច្បាប់នៃប្រទេសចិន បន្ថែមលើច្បាប់របស់ប្រទេសជាម្ចាស់សកម្មភាពរបស់ខ្លួន។ ក្រមជាឧបករណ៍រារាំងដ៏មានឥទ្ធិពលមួយចំពោះទម្លាប់អនុវត្តបែបបំផ្លាញនៅក្នុងវិស័យធុរកិច្ច។ ការបណ្ដែតបណ្ដោយដោយសារសក្ដានុពលនៃគោលការណ៍ណែនាំសម្រាប់វិស័យព្រៃឈើ ក្រមមួយផ្សេងទៀតបានចរចានៅឆ្នាំ២០០៨ក្នុងគោលដៅកែលម្អឥរិយាបថរបស់ក្រុមហ៊ុនចិន ដែលកំពុងប្រតិបត្តិការនៅជុំវិញពិភពលោកក្នុងវិស័យផ្សេងទៀត ដែលរួមទាំងថាមពល និងទឹក។ ភាគីនៅក្នុងការចរចា រួមមានអង្គការមិនមែនរដ្ឋាភិបាលចិន គ្រឹះស្ថានសិក្សា មន្ត្រីរដ្ឋាភិបាល និងតំណាងពីធុរកិច្ចនានា។

"ធម្មនុញ្ញ និងក្រមអនុវត្តត្រូវបានប្រើប្រាស់ជាទូទៅដើម្បីបង្កើតគោលការណ៍ និងគោលការណ៍ណែនាំមួយ"

ធម្មនុញ្ញ និងក្រមអនុវត្ត អាចត្រូវតាក់តែងឡើង និងអនុម័ត ដោយអ្នកពាក់ព័ន្ធមួយក្រុម ដូចជាករណីនៃគោលការណ៍អេក្វាទ័រ និងគោលការណ៍ណែនាំដើមដំបូងអំពីនិរន្តរភាពនៃ IHA ឬ ជាផលិតផលនៃដំណើរការដែលមានអ្នកពាក់ព័ន្ធច្រើនចូលរួម។ ឧទាហរណ៍៖ នៅកាណាដា អនុសាសន៍មួយឈុតត្រូវបានបង្កើតឡើងដោយផ្អែកលើកិច្ចប្រជុំតុមូលថ្នាក់ជាតិ ស្ដីពីការទទួលខុសត្រូវរបស់សាជីវកម្មលើទិដ្ឋភាពសង្គម (CSR) និងឧស្សាហកម្មនិស្សារណកម្មកាណាដា នៅក្នុងប្រទេសកំពុងអភិវឌ្ឍ។ កិច្ចប្រជុំតុមូលនានា ត្រូវបានកោះប្រជុំដោយរដ្ឋាភិបាលកាណាដា និងក្រុមផ្ដល់យោបល់ពហុភាគី ដែលមានសមាសភាពជាតំណាងមកពីឧស្សាហកម្ម និងសង្គមស៊ីវិលនៅកាណាដា ដែលបានចរចា និងចុះហត្ថលេខាលើអនុសាសន៍មួយ ក្នុងគោលដៅកាត់បន្ថយយ៉ាងច្រើននូវឥទ្ធិពលអវិជ្ជមានមកលើសង្គម និងបរិស្ថាននៅក្នុងវិស័យអាជីវកម្មរ៉ែ, ប្រេង និងឧស្ម័នក្នុងប្រទេសកំពុងអភិវឌ្ឍ និងការបែងចែកផលប្រយោជន៍របស់ខ្លួនឲ្យមានសមធម៌ជាងមុន។ អនុសាសន៍នានា រួមបញ្ចូល សំណើគោលការណ៍ណែនាំ CSR ដែលរួមទាំងស្តង់ដារយន្តការរាយការណ៍ និងការអនុវត្តន៍តាម។

### *៥.៣.៤ កិច្ចសន្យា*

កិច្ចសន្យាគឺជាកិច្ចព្រមព្រៀងជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ ដែលចែងច្បាស់អំពីការបែងចែក និងការគ្រប់គ្រងទឹក។ កិច្ចសន្យាទាំងនេះកើតឡើងនៅក្នុងកម្រិតខុសៗ គ្នាជាច្រើនដែលទាក់ទងនឹងអ្នកដើរតួខុសៗគ្នា។ កិច្ចសន្យាត្រូវបានដាក់ឲ្យអនុវត្តតាមរយៈច្បាប់កិច្ចសន្យារបស់ជាតិ ឬច្បាប់អន្តរជាតិ។

*"កិច្ចសន្យាគឺជាកិច្ចព្រមព្រៀងដែលជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ដែលចែងអំពីការបែងចែក និងការគ្រប់គ្រងទឹក"។*

អាជ្ញាធរជាតិ និងក្រោមជាតិ តាមធម្មតា ចុះហត្ថលេខាលើកិច្ចសន្យាជាមួយប្រតិបត្តិករថាមពលវារីអគ្គិសនី ដើម្បីផ្គត់ផ្គង់អគ្គិសនី។ អាជ្ញាធរមូលដ្ឋានអាចប្រើប្រាស់កិច្ចសន្យា ដើម្បីថែរក្សាប្រព័ន្ធទឹកនៅតាមភូមិ ដូចករណីនៅក្នុងប្រទេសឥណ្ឌា ភាគខាងលិចដែលក្រុមស្ត្រីត្រូវគេជួលឲ្យថែរក្សាស្នប់ទឹក។ កិច្ចសន្យាទ្វេភាគីអាចចែងអំពីការលក់ទឹក ឬការធានាឲ្យមានការផ្គត់ផ្គង់នៅក្នុង ឬរវាងប្រទេស។ ឧទាហរណ៍អំពីករណីខាងក្រោយនេះ រួមមានកិច្ចសន្យារវាងម៉ាឡេស៊ី និងសឹង្ហបូរី ឡេសូថូ និងអាហ្វ្រិកខាងត្បូងកាណាដា និងសហរដ្ឋអាមេរិក។

ភាពជាដៃគូសាធារណៈឯកជន គឺជាឧទាហរណ៍មួយផ្សេងទៀត។ ណាមធឿង២ ដែលជាគម្រោងថាមពលវារីអគ្គិសនីធំជាងគេនៅប្រទេសឡាវ គឺជាឧទាហរណ៍មួយអំពីប្រព័ន្ធសាងសង់ទទួលយក-ដាក់ឲ្យប្រតិបត្តិការ ផ្ទេរ។ ក្រុមហ៊ុនឯកជនមួយដែលជាកម្មសិទ្ធិរបស់សមាគមនៃក្រុមហ៊ុនថាមពលអន្តរជាតិដែលជារបស់រដ្ឋ និងក្រុមហ៊ុនឯកជនថាមពល នឹងផ្ទេរសម្បទានគម្រោងនេះទៅឲ្យរដ្ឋាភិបាលនៅក្រោយការសាងសង់ និងប្រតិបត្តិការរបស់ខ្លួនរយៈពេល ២៥ឆ្នាំ។

### *៥.៣.៥ កិច្ចព្រមព្រៀងវិភាជន៍ និងគ្រប់គ្រងដទៃទៀត*

ជំពូកចុងក្រោយមួយទៀតរួមមានកិច្ចព្រមព្រៀងដទៃទៀតដែលអភិបាលអំពីវិភាជន៍ និងការគ្រប់គ្រងទឹក។ កិច្ចព្រមព្រៀងជំពូកនេះអាចទាក់ទងនឹងការបញ្ចូលគ្នាផ្សេងៗនៃអ្នកដើរតួនៅក្នុងរដ្ឋ និងមិននៅក្នុងរដ្ឋ។ ជាទូទៅ កិច្ចព្រមព្រៀងជំពូកនេះមានសុពលភាពតាមរយៈគោលនយោបាយ និងច្បាប់ និងជាឯកសារដែលចែងបទបញ្ញាប្រតិបត្តិការជាក់លាក់ កំណត់អំពីកម្មវិធី ឬដាក់ផែនការការងារ ឬ ត្រូវបានគេប្រើប្រាស់សម្រាប់ដោះស្រាយជម្លោះណាមួយ។

ឧទាហរណ៍ កិច្ចព្រមព្រៀងអាងទន្លេមូរ៉េដាលីន ឆ្នាំ១៩៨៧ គឺជាកិច្ចព្រមព្រៀងបែងចែកទឹករវាងរដ្ឋាភិបាលសហព័ន្ធនៃប្រទេសអូស្ត្រាលី និងរដ្ឋ ដែនដីដែលជាសមាជិក។ នេះជាកម្មវិធីគ្រប់គ្រងអាងផ្ទៃរងទឹកភ្លៀងចម្រុះដ៏ធំជាងគេនៅលើពិភពលោក ដែលគ្របដណ្តប់ផ្ទៃដីធំជាងមួយលានគម២។ កិច្ចព្រមព្រៀងនេះចែងអំពីគោលបំណង មុខងារ និងសមាសភាពនៃស្ថាប័នថ្មីៗ និងនីតិវិធីដែលត្រូវអនុវត្តតាមសម្រាប់កែលម្អការគ្រប់គ្រងធនធានធម្មជាតិ ការចែកចាយទឹក ការគ្រប់គ្រងទ្រព្យ និងការផ្ទេរហិរញ្ញវត្ថុ។ កិច្ចផ្តួចផ្តើមអាងទន្លេមូរេដាលីន ក៏ជាភាពជាដៃគូរវាងរដ្ឋ និងសហគមន៍នានាផងដែរ។ រចនាសម្ព័ន្ធចាត់ចែងកិច្ចផ្តួចផ្តើមនេះ បានកែប្រែនៅក្នុងអំឡុងរយៈពេល២០ឆ្នាំដំបូង។ សម្រាប់អំឡុងពេលនេះ រចនាសម្ព័ន្ធនេះមានគណៈកម្មការផ្តល់យោបល់មកពីសហគមន៍ ដែលបានផ្តល់ដល់ក្រុមប្រឹក្សាថ្នាក់ក្រសួងតាមទស្សនៈរបស់សហគមន៍អំពីបញ្ហាគ្រប់គ្រងធនធានធម្មជាតិសំខាន់ៗ ដែលរួមទាំងបញ្ហាជនជាតិដើមផងដែរ។ ថ្មីៗនេះ នៅឆ្នាំ២០០៨ គណៈកម្មការអាងទន្លេម៉ូរ៉េដាលីន ត្រូវបានបម្លែងទៅជាអាជ្ញាធរអាងទន្លេម៉ូរ៉េដាលីន ដោយមានការកែប្រែអំណាចផងដែរ នៅក្នុងការសាកល្បងខាងផ្នែកស្ថាប័ន ដើម្បីស្វែងរកនិរន្តរភាព។ បើទោះជាបញ្ហានៃអាងទន្លេមូរេដាលីនៅមានទំហំធំធេង ហើយការស្វែងរកនិរន្តរភាពកំពុងប្រព្រឹត្តទៅក៏ដោយ នៅក្រោយរយៈពេល ២០ឆ្នាំ កិចព្រមព្រៀងនេះនៅតែជាចំនុចយោងដ៏សំខាន់មួយសម្រាប់ការពិចារណា និងការធ្វើសេចក្តីសម្រេច។[83]

កិច្ចព្រមព្រៀងកំរិតមូលដ្ឋានជាច្រើនស្ថិតនៅក្នុងជំពូកនេះ។ ខ្លះជាកិច្ចព្រមព្រៀងដែលបានសរសេរជាលាយលក្ខណ៍អក្សរ ដូចជាកិច្ចព្រមព្រៀងរវាងកសិករនៅប៊ុយតាន ដើម្បីគ្រប់គ្រងធនធាននៅទីជម្រាល

រួមគ្នា ឬ អនុស្សារណៈនៃការយោគយល់ ដូចមានចែងនៅក្នុងជំពូក២ រវាងអណ្តូងរ៉ែអ៊ូកតេឌី បានធ្វើឲ្យប៉ះពាល់ដល់សហគមន៍ និងអ្នកពាក់ព័ន្ធដទៃទៀតនៅប៉ាពូញូហ្គីណេ។ អនុស្សារណៈនេះបាន ចែងពីកិច្ចព្រមព្រៀងដែលបានពីការពិនិត្យកែសម្រួលអស់រយៈពេល១៨ខែ ស្តីពីកិច្ចព្រមព្រៀងជាមួយ សហគមន៍លើការបន្តអាជីវកម្មរ៉ែ។ អនុស្សារណៈនេះបានធានាកិច្ចសន្យាចំពោះសហគមន៍ទៅលើការ ចាត់ចែងប្រតិបត្តិការជាបន្តនៃអណ្តូងរ៉ែ ដែលមានចម្រូងចម្រាស់ដោយភ្ជាប់ជាមួយលក្ខខណ្ឌអំពីការទូ ទាត់សំណងឲ្យបានគ្រប់គ្រាន់ដល់សហគមន៍ជនរងគ្រោះ និងចំពោះការបង្កើតមូលដ្ឋានគ្រឹះ ដើម្បីគាំទ្រ ដល់ចំណាត់ការថ្មីៗលើការអភិវឌ្ឍន៍ដោយចីរភាព (សូមអានករណី ២.៣)។

កិច្ចព្រមព្រៀងដទៃទៀតមិនសូវមានលក្ខណៈជាផ្លូវការប៉ុន្មានទេ និងអាចជាកិច្ចព្រមព្រៀងផ្ទាល់ មាត់។ កិច្ចព្រមព្រៀងនេះមិនសុទ្ធតែអាចនិយាយបានថាជាភាពមិនច្បាស់លាស់ ឬមិនសូវម៉ត់ចត់នៅ ក្នុងការអនុវត្តន៍ឡើយ ដូចមានឃើញនៅក្នុងករណី៥.២ នៃប្រព័ន្ធគ្រប់គ្រងទឹកតាមរយៈប្រឡាយដែលមាន អាយុចំណាស់១សតវត្សរ៍ ដែលបានបង្កើតឡើងដោយប្រជាពលរដ្ឋចាក់ហ្កានៃប្រទេសតង់ហ្សានី។

*ករណី៥.២៖ ភាពចម្រុះគ្នាដែលបានចរចានៅក្នុងមូលដ្ឋានអំពីការគ្រប់គ្រងទឹកតាមរយៈ ប្រព័ន្ធប្រឡាយនៅតង់ហ្សានី*

ប្រជាជនចាហ្កានៃប្រទេសតង់ហ្សានី ត្រូវគេស្គាល់ភាពល្បីល្បាញចំពោះការបង្កើត និងការរក្សា ប្រព័ន្ធគ្រប់គ្រងទឹកចាហ្កា ដែលកំពុងនៅតែបន្តដំណើរការនៅកន្លែងខ្លះៗអស់រយៈពេលច្រើនជាងមួយ សតវត្សរ៍មកហើយ ប្រព័ន្ធនេះនៅតែសំខាន់នៅលើតំបន់ខ្ពស់រាបគីលីម៉ាន់ចារ៉ូ។ប្រព័ន្ធប្រឡាយចំហបន្ត ផ្តល់ទឹកសម្រាប់ផឹក និងការស្រោចស្រព និងជាការគាំទ្រដ៏សំខាន់មួយ នៅពេលដែលបំពង់ថ្មីៗជួនកាល មិនអាចផ្តល់ទឹក ដោយសារតែពុំមានការថែទាំ ឬគ្រោះរាំងស្ងួត។

បទបញ្ញាស្តីពីការគ្រប់គ្រងទឹកដ៏ពិស្តារ និងនៅតាមទីតាំងជាក់លាក់ ត្រូវបានចរចានៅក្នុងប្រព័ន្ធ របស់ចាហ្កា ដើម្បីរក្សាគុណភាពទឹក និងដើម្បីកំហិតលើការចែកចាយ។ ឧទាហរណ៍ នៅក្នុងភូមិមួយ ដែលទឹកសំបូរការកំហិតតែមួយគត់លើការប្រើប្រាស់ទឹកពីប្រឡាយនេះ គឺថាទឹកនោះត្រូវបម្រុងទុក សម្រាប់តែផឹក រវាងម៉ោង៥ និង៦ ព្រឹកតែប៉ុណ្ណោះ តែនៅកន្លែងដទៃទៀត គេបែងចែកទឹកទៅអ្នកភូមិ ខុសៗគ្នានៅក្នុងថ្ងៃខុសៗគ្នានៃសប្តាហ៍នីមួយៗ។ នៅក្នុងភូមិមួយដែលស្ថិតនៅខ្សែទឹកខាងលើ មានការ កំហិតប្រចាំរដូវ ដើម្បីឲ្យកសិករនៅខ្សែទឹកខាងក្រោមអាចស្រោចស្រពស្រែរបស់ខ្លួនបានផងដែរ។

ការគ្រប់គ្រងប្រឡាយបែបនេះបានស្រោចស្រង់ប្រទេសតង់ហ្សានីក្នុងអំឡុងក្រោយពេលទទួលបាន ឯករាជ្យ ជាមួយនឹងទិដ្ឋភាពចំបងៗទាំងនេះ ជាច្រើននៅតែរក្សាទុកដោយគ្មានការកែប្រែឡើយ។ ភាគ ច្រើន ទឹកនៅតែត្រូវបានគ្រប់គ្រងនៅតាមមូលដ្ឋាន តាមរយៈមេដឹកនាំគ្រប់គ្រងប្រឡាយ និងក្រុមប្រឹក្សា ប្រឡាយ ដែលបានបោះឆ្នោតជ្រើសតាំងហើយការគ្រប់គ្រងនេះបានគ្របដណ្តប់ភូមិមួយចំនួនផងដែរ។ ចាប់តាំងពីឆ្នាំ១៩៨២មកអាជ្ញាធរមូលដ្ឋានបានទទួលសិទ្ធិអំណាចជាផ្លូវការ(ឬទទួលអំណាចឡើងវិញ) ដើម្បីដោះស្រាយបញ្ហារំលោភលើលក្ខន្តិកៈនៅមូលដ្ឋាន។ ប្រការនេះបានផ្តល់ឲ្យអ្នកគ្រប់គ្រងប្រឡាយ នូវសមត្ថកិច្ចកាន់តែច្រើនឡើងដើម្បីធានាឲ្យមានការអនុវត្តន៍តាម។

## *៥.៤ ការបង្កើតកិច្ចព្រមព្រៀង*

នៅពេលមានភាពច្បាស់លាស់លើជំពូកភាគច្រើននៃកិច្ចព្រមព្រៀងសម្រាប់ការចរចាហើយនោះ ការយក

ចិត្តទុកដាក់ត្រូវជាកទៅរកថាតើការបង្កើតកិច្ចព្រមព្រៀងយ៉ាងដូចម្តេច។ ប្រការនេះពាក់ព័ន្ធនឹងប្រធានបទចំនួនបីគឺ ៖

- ធានាឲ្យមានសង្គតិភាពជាមួយក្របខ័ណ្ឌច្បាប់ និងគោលនយោបាយដែលមានស្រាប់
- កំណត់អំពីខ្លឹមសារ
- ជំហាននានាចាំបាច់ដើម្បីរៀបចំបង្ហើយ និងអនុម័តកិច្ចព្រមព្រៀងនេះ។

## *៥.៤.១ ការធានាឲ្យមានសង្គតិភាពជាមួយច្បាប់ និងគោលនយោបាយដែលមានស្រាប់*

កិច្ចព្រមព្រៀងនៅគ្រប់លំដាប់ថ្នាក់ត្រូវតែរៀបចំឡើង នៅក្នុងបរិបទនៃក្របខ័ណ្ឌគោលនយោបាយ និងច្បាប់ដែលមានស្រាប់។ ប្រសិនបើគ្មានសង្គតិភាពជាមួយគោលនយោបាយ និងច្បាប់នានាទេនោះ កិច្ចព្រមព្រៀងមិនទំនងជាអាចប្រើការបានឡើយ និងជាប្រភពនៃវិវាទ ជាងជាការចូលរួមចំណែកទៅក្នុងទឹកបានប្រសើរជាងមុនឡើយ។ដើម្បីធ្វើឲ្យមានសង្គតិភាពប្រការសំខាន់គឺអ្នកចរចាត្រូវយល់អំពីការពាក់ព័ន្ធនៃក្របខ័ណ្ឌដែលមានស្រាប់សម្រាប់កិច្ចព្រមព្រៀងថ្មីមួយ។ ការពិនិត្យមើលគោលនយោបាយនិងច្បាប់ដែលពាក់ព័ន្ធ មានសារៈសំខាន់ណាស់នៅក្នុងជំហានដំបូងនៃដំណើរការនៃការបង្កើតកិច្ចព្រមព្រៀងថ្មីមួយអំពីទឹក។

កិច្ចការនេះត្រូវពិនិត្យមើលក្របខ័ណ្ឌច្បាប់ដែលមានឥទ្ធិពលមកលើកិច្ចព្រមព្រៀងមួយ។ដូចដែលឯកសារណែនាំរបស់IUCN ស្តីពីបទបញ្ញា បានចែងបញ្ជាក់ស្រាប់ក្របខ័ណ្ឌនេះគ្របដណ្តប់សន្ធិសញ្ញាអន្តរជាតិ និងច្បាប់ជាតិ ដែលច្រើនតែជាប់ជាកាតព្វកិច្ច និងកិច្ចព្រមព្រៀង "ច្បាប់ទន់" ដែលមានការលំបាកក្នុងការប្រតិបត្តិ ប៉ុន្តែវាតំណាងឲ្យការប្តេជ្ញាពីសំណាក់រដ្ឋាភិបាល និងអាចផ្តល់នូវការណែនាំដែលមានប្រយោជន៍អំពីទម្លាប់អនុវត្តល្អៗ។ ទម្លាប់ល្អនីមួយៗមានការពាក់ព័ន្ធទៅនឹងការចរចាទាំងនៅថ្នាក់អន្តរជាតិ និងនៅក្នុងរដ្ឋនានា ដោយសារវាជាកាតព្វកិច្ច ដែលកិច្ចព្រមព្រៀងមួយមិនត្រូវមានភាពទំនាស់នឹងគ្នាឡើយ ដើម្បីអាចយកទៅអនុវត្តបាន។

> *"កិច្ចព្រមព្រៀងនៅគ្រប់លំដាប់ថ្នាក់ត្រូវតែរៀបចំឡើងនៅក្នុងបរិបទនៃក្របខ័ណ្ឌគោលនយោបាយ និងច្បាប់ដែលមានស្រាប់"*

បច្ចុប្បន្នមានស្ថាប័នតាក់តែងកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលនៅលើពិភពលោក ដែលមានការពាក់ព័ន្ធទៅនឹងកាអនុវត្តន៍គោលនយោបាយ និងច្បាប់ទឹក ដែលចាំបាច់ត្រូវតែលើកយកមកពិចារណា។ ឧទាហរណ៍នានា រួមមាន ៖

- គោលការណ៍ឌុប្លីន ឆ្នាំ ១៩៩២
- អនុសញ្ញាស្តីពីច្បាប់ប្រើប្រាស់ផ្លូវទឹកអន្តរជាតិសម្រាប់កិច្ចការក្រៅពីនាវាចរ (អនុសញ្ញាផ្លូវទឹកអន្តរជាតិ) ឆ្នាំ១៩៩៧
- សេចក្តីថ្លែងការណ៍សហស្សវត្សរ៍ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ឆ្នាំ២០០០
- ផែនការអនុវត្តក្រុងចូហានេស្បឺក ឆ្នាំ ២០០២។

នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គេចាំបាច់ត្រូវពិនិត្យមើលច្បាប់ និងគោលនយោបាយនានា

នៅក្នុងគ្រប់វិស័យដែលពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀងណាមួយ។ សម្រាប់កិច្ចព្រមព្រៀងដែលទាក់ទងនឹងទឹក នេះមានន័យថាជាការពិនិត្យមើលច្បាប់ និងគោលនយោបាយនានាដែលមានការពាក់ព័ន្ធដោយផ្ទាល់ទៅនឹងទឹក ដូចជា ច្បាប់ជាតិស្តីពីទឹក ឬ យុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានទឹក។ ទោះជាយ៉ាងណាក៏ដោយ ប្រការសំខាន់គឺការពិនិត្យមើលនេះត្រូវតែគ្របដណ្តប់លើសមាសភាគនានានៃច្បាប់ និងគោលនយោបាយដែលទាក់ទងនឹងទឹក ដែលមានប្រើប្រាស់នៅក្នុងវិស័យផ្សេងទៀត និងបញ្ហាផ្សេងទៀតផងដែរ ដែលរួមទាំង កសិកម្ម ព្រៃឈើ ដីធ្លី ការប្រែប្រួលអាកាសធាតុ បរិស្ថាន ថាមពល និងវារីអគ្គិសនី។

ដូច្នេះ កិច្ចព្រមព្រៀងនានាមិនដំណើរការដាច់ដោយឡែកឡើយ។ គេត្រូវបង្កើតកិច្ចព្រមព្រៀងណាមួយ ដោយត្រូវដឹងអំពីកិច្ចព្រមព្រៀង និងការប្តេជ្ញានានាដែលមានស្រាប់ ដែលរួមទាំង កិច្ចព្រមព្រៀង និងការប្តេជ្ញានានាដែល បានធ្វើឡើងនៅក្នុងវិស័យផ្សេងៗទៀតផងដែរ។ ការសម្រេចបាននូវសង្គតិភាពក្នុងចំណោមកិច្ចព្រមព្រៀងនានាទាមទារឲ្យមានការវិភាគ មានការចរចា និងធ្វើវិសោធនកម្មជាប្រចាំ។ កិច្ចព្រមព្រៀងនានាមានឥទ្ធិពលមកលើកិច្ចព្រមព្រៀងបន្តបន្ទាប់នៅពេលក្រោយ ទាំងខ្លឹមសារ និងដំណើរការដែលប្រើប្រាស់។

### *៥.៤.២ ខ្លឹមសារនៃកិច្ចព្រមព្រៀង*

ទោះបីគ្មានគំរូ ឬ ខ្នាតជាក់លាក់ក៏ដោយ កិច្ចព្រមព្រៀងនានាគួរតែផ្សំដោយសំណុំលក្ខណៈស្នូលខ្លះៗបើទោះជាកិច្ចព្រមព្រៀងនេះស្ថិតក្នុងក្រុមណាក៏ដោយ។ កាលណាកិច្ចព្រមព្រៀងចែងបានច្បាស់លាស់ ការអនុវត្តន៍កិច្ចព្រមព្រៀងនោះក៏មានប្រសិទ្ធភាពផងដែរ និងទំនងបំផុតថាអាចនាំទៅរកការសម្រេចសមិទ្ធផលដែលចង់បាន។

បើទោះជាគ្មានគំរូឬខ្នាតជាក់លាក់ក៏ដោយក៏កិច្ចព្រមព្រៀងនានា គួរតែផ្សំដោយសំណុំលក្ខណៈស្នូលខ្លះៗ

កិច្ចព្រមព្រៀងល្អមួយគួរតែកំណត់ និងអធិប្បាយអំពី ៖

#### *វិសាលភាព*

តើបញ្ហាអ្វីដែលត្រូវលើកឡើង? តើកិច្ចព្រមព្រៀងនោះត្រូវអនុវត្តនៅទីណា និងតើឥរិយាបថរបស់អ្នកណាត្រូវអភិបាល? តើអ្វីខ្លះជាភាគលាភ ហានិភ័យ សិទ្ធិ និងការទទួលខុសត្រូវរបស់ភាគីទាំងអស់ និងរបស់អ្នកដែលស្ថិតក្រោមឥទ្ធិពលនៃកិច្ចព្រមព្រៀងនេះ?

វិសាលភាពអាចគ្របដណ្តប់ភូមិសាស្ត្រ អ្នកដើរតួ និងបញ្ហានានា។ ដូចដែលបង្ហាញតាមរយៈឧទាហរណ៍ជាច្រើននៅក្នុងសៀវភៅនេះ កិច្ចព្រមព្រៀងអំពីទឹកគ្របដណ្តប់លើបញ្ហា ទីកន្លែង និងមនុស្សជាច្រើន។ សេចក្តីជាក់លាក់ និងសេចក្តីពិស្តារអាចខុសគ្នា ដោយអាស្រ័យលើចេតនានៃកិច្ចព្រមព្រៀងនោះ។

#### *យន្តការអភិបាលកិច្ច*

តើកិច្ចព្រមព្រៀងនេះនឹងត្រូវអនុវត្តបែបណានៅក្នុងស្ថានភាពជាក់ស្តែង?

តើអ្នកណាមានការទទួលខុសត្រូវអ្វីខ្លះ? តើភាគីនានានឹងមានអន្តរអំពើនៅពេលណា និងបែបណា នៅក្នុងពេលអនុវត្ត?

តួនាទី និងការទទួលខុសត្រូវរបស់អ្នកដើរតួទាំងអស់ដែលទាក់ទងនឹងអភិបាលកិច្ចនៃកិច្ចព្រមព្រៀងនេះ គួរតែមានចែងផងដែរ។ គេអាចជ្រើសរើសយកស្ថាប័នដែលមានស្រាប់ណាមួយ ដើម្បីគ្រប់គ្រងការអនុវត្តកិច្ចព្រមព្រៀងនោះ ឬ ស្ថាប័នថ្មីមួយ អាចនឹងត្រូវបង្កើតឡើង។ ជាញឹកញាប់ កិច្ចព្រមព្រៀងនានាត្រូវបានប្រើប្រាស់ដើម្បីបង្កើតអង្គភាពគ្រប់គ្រងទឹកថ្មី ដូចជា អង្គការ ឬ គណៈកម្មការអាងទន្លេមួយ។ គេអាចមានអង្គភាពដាច់ដោយឡែកសម្រាប់ការសម្រេចលើគោលនយោបាយការអនុវត្តឬការផ្តល់យោបល់ (ដូចជា ជាមួយតំណាងរបស់សហគមន៍ ឬ អ្នកឯកទេសខាងកិច្ចការបច្ចេកទេស)។

*ហិរញ្ញប្បទាន*

តើអ្នកណាបង់ថ្លៃសម្រាប់អនុវត្តកិច្ចព្រមព្រៀងនោះ ដែលរួមទាំងតាមដាន និងរៀនសូត្រពីនោះផងដែរ? តើហិរញ្ញប្បទាន នេះនឹងត្រូវចាត់ចែងគ្រប់គ្រងបែបណា?

គ្រប់កិច្ចព្រមព្រៀងទាំងអស់ត្រូវការហិរញ្ញវត្ថុតាមទម្រង់ខ្លះៗ សូម្បីតែកិច្ចព្រមព្រៀងទាំងនោះមិនផ្តោតលើចំណាត់ការនានា ដែលទាមទារឲ្យមានការផ្តល់មូលនិធិសម្រាប់ភាគីនានា ដើម្បីបន្តជួបប្រជុំដើម្បីតាមដានការអនុវត្តកិច្ចព្រមព្រៀងរបស់ពួកគេ ឬ ជម្រុញកិច្ចព្រមព្រៀងនោះទៅមុខក៏ដោយ។ ការចាត់ចែងមូលនិធិមិនបានច្បាស់លាស់ អាចធ្វើឲ្យទំនាក់ទំនងការស្ថាបនាប្រែក្លាយជាល្វីងជូរចត់យ៉ាងឆាប់រហ័ស។កិច្ចព្រមព្រៀងនោះគួរតែចែងបញ្ជាក់ថាតើភាគីណានឹងផ្តល់ធនធានអ្វីខ្លះ(សាច់ប្រាក់ឬមិនមែនសាច់ប្រាក់) ឬតើត្រូវស្វែងរកហិរញ្ញវត្ថុពីខាងក្រៅដោយរបៀបណា។ កិច្ចព្រមព្រៀងគួរតែគូសបញ្ជាក់ផងដែរអំពីរបៀបចាត់ចែងគ្រប់គ្រងមូលនិធិនោះ។

*"កិច្ចព្រមព្រៀងគួរតែចែងបញ្ជាក់ថាតើភាគីណានឹងផ្តល់ធនធានអ្វីខ្លះ"*

*ការចែករំលែកទិន្នន័យ និងព័ត៌មាន?*

តើត្រូវចែករំលែកអ្វីខ្លះ និងដោយរបៀបណា?

ទោះបីនេះមិនមែនជាសមាសភាគស្នូលនៃគ្រប់កិច្ចព្រមព្រៀងក៏ដោយ ការចែករំលែកព័ត៌មានគឺជាចំណុចចាប់ផ្តើមរួមគ្នាមួយ សម្រាប់កិច្ចសហប្រតិបត្តិការ ដោយសារវាបង្កើតការយោគយល់គ្នា និងអាចសម្រួលឲ្យមានការកសាងផែនការ និងចំណាត់ការប្រសើរជាងមុន។ ដោយសារតែវាអាចមានភាពរសើប

ការគូសបញ្ជាក់អំពីព័ត៌មានអ្វីខ្លះដែលត្រូវការចែករំលែក និងចែករំលែកដោយរបៀបណា គឺជាប្រការដែលមានប្រយោជន៍។

*"ការចែករំលែកព័ត៌មានគឺជាចំណុចចាប់ផ្តើមរួមគ្នាមួយសម្រាប់កិច្ចសហប្រតិបត្តិការ"*

*ការអនុវត្តន៍តាម*

តើភាគីនានាត្រូវបង្ហាញពីការអនុវត្តន៍ឲ្យមានប្រសិទ្ធភាពដោយរបៀបណា? តើពួកគេនឹងត្រូវធ្វើបែបណាដើម្បីឲ្យមានគណនេយ្យភាព?

គេគួរតែមានគោលការណ៍ណែនាំច្បាស់លាស់អំពីថាតើការអនុវត្តន៍កិច្ចព្រមព្រៀងនឹងអាចតាមដានបានដោយរបៀបណា។ តើអ្នកណាត្រូវធ្វើសេចក្តីរាយការណ៍ និងនៅពេលណា? ការពិនិត្យរួមគ្នាអាចឲ្យភាគីទាំងអស់ធ្វើការឆ្លុះបញ្ចាំងអំពីវឌ្ឍនភាព និងធ្វើការតាមដាន ដែលជាឱកាសដើម្បីរៀនសូត្រជាប់ជាប្រចាំ និងការគ្រប់គ្រងបែបបន្សាំ។ កិច្ចព្រមព្រៀងគួរតែពិចារណា ផងដែរអំពីមាត្រានានាដើម្បីចែងអំពីលទ្ធភាពដើម្បីឲ្យមានការអនុវត្តន៍តាមដូចជាការគាំទ្រខាងស្ថាប័នតាមរយៈការកសាងសមត្ថភាពឬការផ្តល់មូលនិធិ។

*ការប្រតិបត្តិ និងការដោះស្រាយវិវាទ*

តើមានជំនួយបែបណាខ្លះដើម្បីអាចដោះស្រាយបញ្ហាមិនគោរពតាមឬការរំលោភលើកិច្ចព្រមព្រៀង? តើមានក្របខ័ណ្ឌច្បាប់អ្វីខ្លះដែលទាក់ទងនឹងកិច្ចព្រមព្រៀងនោះ? តើភាគីរងគ្រោះអាចសំដែង និងដោះស្រាយសារទុក្ខរបស់ខ្លួនបែបណា? តើការមិនចុះសម្រុងគ្នាទៅអនាគតឬជម្លោះនឹងត្រូវដោះស្រាយដោយរបៀបណា?

កិច្ចព្រមព្រៀងគួរតែគូសបញ្ជាក់អំពីចំណាត់ការនានាដែលត្រូវធ្វើឡើង នៅក្នុងករណីដែលគ្មានការអនុវត្តន៍តាម ឬការរំលោភលើកិច្ចព្រមព្រៀងនោះ។ ជាការប្រសើរ ភាគីទាំងអស់នឹងអាចដោះស្រាយការមិនចុះសម្រុងគ្នា តាមរយៈការបន្ថែមការចូលរួម និងការចរចា។ ការធ្វើបែបនេះនឹងពង្រឹងសារៈសំខាន់នៃការប្រជុំជាទៀងទាត់ ឬវេទិកានានា ដើម្បីប៉ាន់ប្រមាណអំពីវឌ្ឍនភាព និងចរចាអំពីសកម្មភាពដើម្បីដោះស្រាយបញ្ហានានា។

នៅពេលភាគីនានាមិនអាចដោះស្រាយភាពមិនចុះសម្រុងគ្នា ឬជម្លោះក្នុងចំណោមពួកគេ គេមានមធ្យោបាយជំនួសមួយចំនួន៖ ប្រើប្រាស់ប្រព័ន្ធច្បាប់ដែលត្រួតត្រាលើកិច្ចព្រមព្រៀងនោះ ប្រើប្រាស់សម្ពាធជាសាធារណៈ ឬក្រុមសហសេវិក តាមរយៈកិច្ចការទូត ឬយុទ្ធនាការ ឬស្វែងរកការសម្រុះសម្រួល ឬមជ្ឈត្តវិនិច្ឆ័យពីភាគីទីបី។ កិច្ចព្រមព្រៀងត្រូវមានរួមបញ្ចូល យន្តការទាំងឡាយ ដើម្បីពង្រឹងការប្រតិបត្តិ និងដំណោះស្រាយជម្លោះ (ប្រអប់៥.១) និងចែងអំពីអំពីករណីនានាដែល ក្នុងនោះយន្តការនីមួយៗនឹងត្រូវយកមកប្រើប្រាស់។

*ប្រអប់៥.១៖ ជម្រើសដោះស្រាយវិវាទ*

កិច្ចព្រមព្រៀងដែលជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ ដូចជា កិច្ចសន្យា សន្ធិសញ្ញា និងច្បាប់ ស្ថិតនៅជាចំណុះនៃច្បាប់ជាតិ និងអន្តរជាតិនានាដែលពាក់ព័ន្ធ និងតុលាការដែលពាក់ព័ន្ធនឹងមានការអនុវត្តន៍ច្បាប់រដ្ឋប្បវេណី និងច្បាប់ព្រហ្មទណ្ឌ។

កិច្ចព្រមព្រៀងមិនជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ នៅតែតំណាងឲ្យកិច្ចសន្យាជាប់ "កាតព្វកិច្ច" រវាងភាគីនានា ប៉ុន្តែងាកទៅរកជំនួយ នៅក្នុងករណី គ្មានការអនុវត្តន៍តាមរួមមានប្រភេទផ្សេងៗនៃសម្ពាធខុសគ្នាពីសាធារណៈ និងក្រុមសហសេវិក។ ឧទាហរណ៍ សហហត្ថលេខីអាចប្រើប្រាស់ការទូតដើម្បីឲ្យភាគីនានាគោរពតាមការសន្យារបស់ខ្លួន ឬស្វែងរកអន្តរាគមន៍ពីអ្នកសម្រុះសម្រួល ឬមជ្ឈត្តករ។ យុទ្ធនាការជាសាធារណៈឬទម្រង់ផ្សេងទៀតនៃការតស៊ូមតិ ច្រើនតែត្រូវបានអ្នកពាក់ព័ន្ធមកពីមជ្ឈដ្ឋានខាងក្រៅប្រើប្រាស់សម្រាប់កៀងសង្កត់អ្នកដើរតួនៅក្នុងរដ្ឋ ឬនៅក្នុងឧស្សាហកម្ម ដើម្បីឲ្យគោរពតាមគោលនយោបាយ ឬក្រមអនុវត្តរបស់ពួកគេ។ ការបោះឆ្នោតគឺជាមធ្យោបាយមួយផ្សេងទៀតសម្រាប់ពលរដ្ឋ ក្នុងការសំដែងនូវការមិនពេញចិត្តចំពោះគោលនយោបាយឬចំណាត់ការរបស់រដ្ឋាភិបាល។

ភាគីនានាក៏អាចស្វែងរកការគាំទ្រពីខាងក្រៅ ដើម្បីដោះស្រាយជម្លោះមួយតាមរយៈការសម្រុះសម្រួល ឬតាមរយៈការកាត់ក្តី ។ ជូនកាលយោងទៅយន្តការជំនួសសម្រាប់ដោះស្រាយវិវាទ (ដោយសារតែវាជា

ជម្រើសជំនួសការដាក់ពាក្យបណ្ដឹងតាមផ្លូវច្បាប់) អភិក្រមទាំងនេះប្រហែលគ្នា ប៉ុន្តែខុសគ្នាលើតួនាទីរបស់ភាគីទីបី។ ការសម្រុះសម្រួលទាក់ទងនឹងភាគីទីបីឯករាជ្យមួយ ដែលធ្វើការជាមួយភាគីនានា ដើម្បីជួយពួកគេក្នុងការផ្សះផ្សាការមិនចុះសម្រុងរបស់ពួកគេ។ អំឡុងពេលកាត់ក្ដីភាគីអព្យាក្រឹតទីបីស្ដាប់ភស្តុតាង និងធ្វើការសម្រេចដោយឯករាជ្យអំពីចំណាត់ការដែលត្រូវអនុវត្ត។

*កាលបរិច្ឆេទចូលជាធរមាន អំឡុងពេល និងនីតិវិធីធ្វើវិសោធនកម្ម*

តើនៅពេលណាកិច្ចព្រមព្រៀងចូលជាធរមាន? តើនៅពេលណាផុតសុពលភាព? តើវិសោធនកម្មកិច្ចព្រមព្រៀងនឹងធ្វើឡើងបែបណា?

កាលបរិច្ឆេទចូលជាធរមានជាថ្ងៃកំណត់ណាមួយក៏បាន ឬជាប់លក្ខខណ្ឌនៅពេលចូលហត្ថលេខា ឬការអនុម័តពីសំណាក់ភាគីក្នុងចំនួនណាមួយ។ កិច្ចព្រមព្រៀងអាចនឹងត្រូវបញ្ចប់នៅកាលបរិច្ឆេទជាក់លាក់ណាមួយ ឬ នៅពេលបញ្ចប់កិច្ចការជាក់លាក់។ កិច្ចព្រមព្រៀង គួរបញ្ជាក់ច្បាស់ពីដំណើរការ ដែលការប្រែប្រួលណាមួយអាចធ្វើឡើងទៅបាន ឧទាហរណ៍ ដោយមានការព្រមព្រៀងពីភាគីទាំងអស់។

*"កិច្ចព្រមព្រៀងនីមួយៗត្រូវតែរៀបចំឡើងដោយឡែកសម្រាប់បញ្ហា និងអ្នកដើរតួជាក់លាក់"*

គេពុំមានកិច្ចព្រមព្រៀងល្អឥតខ្ចោះដែលអាចយកជាគំរូនោះឡើយ។ កិច្ចព្រមព្រៀងនីមួយៗត្រូវតែធ្វើឡើងសម្រាប់បញ្ហា និងអ្នកដើរតួជាក់លាក់ណាមួយ។ ករណី៥.៣ ស្ដីពីក្រមអនុវត្តសម្រាប់អាងទន្លេវ៉ុលហ្កា និង៥.៤ ស្ដីពី លក្ខន្តិកៈគ្រប់គ្រងទីជម្រាល នៅប៊ុយតង់ គឺជាឧទាហរណ៍នៃកិច្ចព្រមព្រៀងទូលំទូលាយ។

*ករណី៥.៣៖ក្រមអនុវត្តសម្រាប់អាងទន្លេវ៉ុលហ្កា*

ក្រមអនុវត្តរវាងរដ្ឋាភិបាលប៊ូគីណាហ្វាសូ និងសាធារណរដ្ឋហ្កាណា ត្រូវបានរៀបចំរួចរាល់នៅក្នុងខែកក្កដា ឆ្នាំ២០០៦ សម្រាប់ការគ្រប់គ្រងដោយនិរន្តរភាព និងសមធម៌នៃធនធានទឹករួមនៃការអភិវឌ្ឍន៍អាងទន្លេវ៉ុលហ្កា។ ក្រមនេះបានទទួលការគាំទ្រដោយ IUCN ដែលជាផ្នែកមួយនៃសកម្មភាពរួមគ្នាជាបន្តបន្ទាប់ពីសំណាក់ប្រធាននាយកដ្ឋានធនធានទឹកនៅប៊ូគីណាហ្វាសូ និងពីគណៈកម្មការធនធានទឹកនៃប្រទេសហ្កាណា ក្នុងខណៈពេលអនុសញ្ញាស្ដីពីស្ថានភាពនៃទន្លេវ៉ុលហ្កា និងស្ដីពីការបង្កើតអាជ្ញាធរអាងទន្លេវ៉ុលហ្កា ដែលជាកិច្ចព្រមព្រៀងក្របខ័ណ្ឌនៃប្រទេសចំនួនប្រាំមួយ សម្រាប់គ្រប់គ្រងនិងអភិរក្សធនធាននៅក្នុងអាងទន្លេ ជាដំណាក់កាលដំបូងនៃការបង្កើត (អនុសញ្ញានេះត្រូវបានចុះហត្ថលេខានៅពេលក្រោយមកក្នុង ឆ្នាំ២០០៧)។

ក្រមអនុវត្តមាន៨ជំពូក និង៥៩មាត្រា ដែលចែងអំពីគោលការណ៍ គោលការណ៍ណែនាំសកម្មភាពរួម និងយន្តការអនុវត្ត ដូចតទៅ៖

លំនាំដើម

- ផ្នែក ១ ៖ បទបញ្ញត្តិទូទៅ
  - មាន ៥ មាត្រា ស្ដីពី និយមន័យ គោលដៅ គោលបំណងវិសាលភាពនៃការអនុវត្តន៍ និងនិត្យានុកូលភាព។
- ផ្នែកទី ២ ៖ គោលការណ៍គ្រប់គ្រង
  - មាន ២៥ មាត្រាដែលចែងអំពីគោលការណ៍នានាដែលទាក់ទងនឹងការអភិឌ្ឍន៍ដោយចីរភាព ការគ្រប់គ្រងធនធានទឹកចម្រុះ កិច្ចសហប្រតិបត្តិការ និងអភិបាលកិច្ច។

ផ្នែកទី ៣៖ គោលការណ៍ណែនាំ

មាន ៥ មាត្រា ដែលចែងពីគោលការណ៍ណែនាំស្តីពី ៖ លំហូរបរិស្ថាន យុទ្ធសាស្ត្រចម្រុះ សុខុដុមនីយកម្មច្បាប់ និងគោលនយោបាយ ទម្លាប់អនុវត្តល្អៗខាងបរិស្ថាន និងជំហាននានាដើម្បីបង្កើតអនុសញ្ញាពហុភាគីសម្រាប់ការគ្រប់គ្រងចម្រុះអាងទន្លេ។

ផ្នែកទី ៤៖ សកម្មភាពរួមគ្នា

មាន ១៥ មាត្រា ដែលចែងអំពីសកម្មភាពរួម ដែលរួមទាំង ៖ ការកសាង និងការអនុវត្តន៍គោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីនានា ការចែករំលែកទិន្នន័យ និងព័ត៌មាន ការស្រាវជ្រាវ ការតាមដាន និងការប៉ាន់ប្រមាណ បង្កើតការយល់ដឹង និងការកសាងសមត្ថភាព និងការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាព។

ផ្នែកទី ៥៖ ការចាត់ចែងខាងស្ថាប័ន

មាន ៤មាត្រា ដែលចែងអំពីការបង្កើតគណៈកម្មការពិគ្រោះយោបល់ពហុភាគី ដែលមានភារៈទទួលខុសត្រូវសម្របសម្រួល និងតាមដានការអនុវត្តន៍ក្រមអនុវត្ត។ សមាសភាព មុខងារ និងបទបញ្ញាប្រតិបត្តិពិស្តាររបស់គណៈកម្មការនេះ នឹងត្រូវបង្កើតឡើងនៅក្នុងឧបសម្ព័ន្ធដោយឡែក។

ផ្នែក ៦៖ ការដោះស្រាយជម្លោះ

មាន ១ មាត្រាដែលអំពាវនាវដល់ភាគីនានា ដើម្បីដោះស្រាយជម្លោះនានាដោយសន្តិវិធី ជាដំបូងក្រោមការជួយគាំទ្រពីគណៈកម្មការពិគ្រោះយោបល់ និងប្រសិនបើមិនបានទទួលជោគជ័យនឹងប្រើប្រាស់មធ្យោបាយការទូត។

ផ្នែកទី ៧៖ ការលើកកំពស់ក្រមអនុវត្ត

មាន ១ មាត្រាដែលតម្រូវឲ្យរដ្ឋនានាលើកទឹកចិត្តដល់រដ្ឋនានានៅតាមអាងទន្លេដើម្បីអនុម័តក្រមនេះ។

ផ្នែក ៨៖ អវសានប្បញ្ញត្តិ

មាត្រាបីចែងអំពីរបៀបដែលរដ្ឋផ្សេងទៀតនៅក្នុងអាងទន្លេអាចក្លាយជាសមាជិក តើកិច្ចព្រមព្រៀងនេះនឹងត្រូវធ្វើវិសោធនកម្មបែបណា និងកាលបរិច្ឆេទនៃការចូលជាធរមាន (ក្រោយចុះហត្ថលេខានៃរដ្ឋមន្ត្រីធនធានទឹកនីមួយៗ)។

## *ករណី៥.៨៖ លក្ខន្តិកៈគ្រប់គ្រងទីជម្រាលលីងមូទៃជូនៅប៉ុយតាន*

លក្ខន្តិកៈនៃការគ្រប់គ្រងទីជម្រាលលីងមូទៃជូ ត្រូវបានរៀបចំឡើងបន្ទាប់ពីមានវេទិកាពហុអ្នកពាក់ព័ន្ធរបស់អ្នកភូមិទាំង៧ដែលរស់នៅក្នុងទីជម្រាលដោយបានប្រើប្រាស់ល្បែងសំដែងតួ ដើម្បីស្វែងយល់អំពីមធ្យោបាយសមស្របបំផុត និងសមធម៌ ក្នុងចែករំលែកទឹកសម្រាប់ការស្រោចស្រព (សូមអានករណី ៣.៧ នៅក្នុងជំពូក៣)។ លក្ខន្តិកៈដែលបានចុះហត្ថលេខាដោយតំណាងនានានៃភូមិទាំងអស់បន្ទាប់ពីការរៀបចំបង្ហើយ និងការអនុម័តនៅក្នុងកិច្ចប្រជុំក្នុងភូមិមួយរួចមកត្រូវសន្យាឲ្យអ្នកទាំងអស់ដែលរស់នៅក្នុងគ្រប់ភូមិធ្វើការជាសមូហភាព ដើម្បីគ្រប់គ្រងធនធានក្នុងទីជម្រាលសម្រាប់ជាប្រយោជន៍របស់មនុស្សក្នុងជំនាន់នេះ និងជំនាន់ក្រោយ។ ពួកគេបានបង្កើតបន្ថែមនូវគណៈកម្មាធិការគ្រប់គ្រងទីជម្រាលលីងមូទៃជូ និងចែងអំពីសមាសភាព ការទទួលខុសត្រូវ និងនីតិវិធីប្រតិបត្តិការជាក់លាក់របស់គណៈកម្មាធិការនេះ (ដូចជាភាពញឹកញាប់នៃការប្រជុំ មូលដ្ឋានសម្រាប់ធ្វើការសម្រេច ការបោះឆ្នោតរបស់សមាជិកគណៈកម្មាធិការ ការដាក់ទណ្ឌកម្មលើការមិនអនុវត្តន៍តាម។ល។)។

*"មិនមែន MSPs ទាំងអស់សុទ្ធតែនាំទៅរកកិច្ចព្រមព្រៀងផ្លូវការជាលាយលក្ខណ៍អក្សរនោះទេ...វានៅតែមានសារៈសំខាន់ក្នុងការស្រង់យកលទ្ធផលនៃ MSPs ដើម្បីមានឥទ្ធិពលមកលើអ្នកធ្វើសេចក្តីសម្រេចផ្សេងទៀត"*

មិនមែនគ្រប់ MSPs សុទ្ធតែនាំទៅរកការបង្កើតកិច្ចព្រមព្រៀងផ្លូវការជាលាយលក្ខណ៍អក្សរ ដែលគ្របដណ្ដប់ធាតុទាំងអស់ដែលមានបង្ហាញខាងលើឡើយ។ ទោះជាយ៉ាងណាក៏ដោយវានៅតែមានសារៈសំខាន់ក្នុងការស្រង់យកលទ្ធផលនៃ MSPs ដើម្បីមានឥទ្ធិពលមកលើអ្នកធ្វើសេចក្ដីសម្រេចផ្សេងទៀត។ ខ្លឹមសារនៃ "កិច្ចព្រមព្រៀង" បែបនេះគួរតែរាប់បញ្ចូលបញ្ហានានាដែលបានពិភាក្សា ជម្រើសផ្សេងៗ ដែលបានបង្កើតឡើង និងអនុសាសន៍សម្រាប់ចំណាត់ការ។ ភាគីនានាគួរចុះហត្ថលេខាលើកិច្ចព្រមព្រៀង ដើម្បីបង្ហាញឲ្យបានច្បាស់លាស់អំពីការអនុម័តយល់ព្រមលើខ្លឹមសារនៃកិច្ចព្រមព្រៀងនោះ។



*រូបថត៥.១៖ អ្នកភូមិប៊ុយតង់ ដែលប្រើប្រាស់ល្បែងសំដែងតួ ដើម្បីចរចាអំពីវិភាជន៍ទឹកសម្រាប់ការស្រោចស្រពក្នុងចំណោម ភូមិចំនួនប្រាំពីរ នៅក្នុងទីជម្រាលលីងមូទែជូ (ប៊ុយតង់)។*

## ៥.៤.៣ របៀបបញ្ចប់កិច្ចព្រមព្រៀង

ការបញ្ចប់កិច្ចព្រមព្រៀងមួយរួមមានជំហាននានាដូចតទៅ ៖

- រៀបចំសេចក្ដីព្រាង
- ការផ្ទៀងផ្ទាត់
- ការអនុម័តយល់ព្រម
- ការចូលជាធរមាន

*"នៅពេលដែលការចរចាត្រូវបានសម្រេចហើយនោះបញ្ហា និងការសម្រេចនានាដែលចាំបាច់ត្រូវស្រង់យកទៅដាក់នៅក្នុងអត្ថបទជាលាយលក្ខណ៍អក្សរ"*

នៅពេលការចរចាបានបញ្ចប់ហើយនោះរាល់បញ្ហា និងការសម្រេចនានាត្រូវស្រង់យកទៅដាក់នៅក្នុងអត្ថបទជាលាយលក្ខណ៍អក្សរ។ តាមធម្មតា ការរៀបចំជាសេចក្ដីព្រាងត្រូវធ្វើឡើងដោយក្រុមស្នូលមួយដែលអ្នកចូលរួមទាំងអស់បានជ្រើសរើស។

គ្រប់អ្នកពាក់ព័ន្ធទាំងអស់ត្រូវតែពិនិត្យអត្ថបទ និងផ្ទៀងផ្ទាត់ថាកិច្ចព្រមព្រៀងស្រង់យកចេញមានភាពសុក្រឹត្យ និងគ្រប់គ្រាន់នូវវិសាលភាព និងជម្រៅនៃការសម្រេចដែលបានធ្វើឡើង។ ប្រការនេះអាចទាម

ទារឲ្យមានការវិលឯកសារកិច្ចព្រមព្រៀងនេះទៅវិញ និងធ្វើការពិគ្រោះយោបល់ជាមួយស្ថាប័នរបស់គេ។ កង្វល់នានាចាំបាច់ត្រូវតែបញ្ជាក់ឲ្យបានច្បាស់លាស់តាមរយៈការពិចារណាជាបន្ថែមទៀតក្នុងចំណោមក្រុមនេះ និងធ្វើវិសោធនកម្មទៅតាមនោះផងដែរ។ នេះមិនមែនជាពេលវេលា ដើម្បីណែនាំឲ្យស្គាល់ផ្នែកថ្មីៗ ប៉ុន្តែដើម្បីធានាថាអត្ថបទនេះមានភាពច្បាស់លាស់ និងអាចឲ្យភាគីទាំងអស់ទទួលយកបាន។ សម្រាប់មាត្រានានា ដែលពុំមានការឯកភាពមតិពេញលេញទេនោះ ភាគីនានាអាចបញ្ជាក់អំពីការបម្រុងទុករបស់ពួកគេ ដូចនៅក្នុងករណី ៥.៥។

*ករណី៥.៥ ការកត់សំគាល់អំពីករណីលើកលែងនៅក្នុងកិច្ចព្រមព្រៀង*

> ការវាយតម្លៃជាអន្តរជាតិនៃចំណេះដឹងកសិកម្ម វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអភិវឌ្ឍ (IAASTD) គឺជាការពិនិត្យពិច័យដោយពហុអ្នកពាក់ព័ន្ធ និងពហុជំនាញ លើតួនាទីរបស់ចំណេះដឹងអំពីកសិកម្ម វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ក្នុងការកាត់បន្ថយភាពអត់ឃ្លាន និងភាពក្រីក្រ សម្រាប់ការកែលម្អរបរចិញ្ចឹមជីវិតនៅជនបទ និងសម្រាប់ការសម្រួលឲ្យមានការអភិវឌ្ឍន៍ដោយចីរភាពខាងផ្នែកបរិស្ថាន សង្គម និងសេដ្ឋកិច្ច។ របកគំហើញ និងជម្រើសនានាដែលបានពីការវាយតម្លៃនៅកម្រិតពិភពលោក និងប្រចាំតំបន់ត្រូវបានលើកយកទៅពិភាក្សានៅក្នុងកិច្ចប្រជុំអន្តររដ្ឋាភិបាល នៅក្នុងខែមេសា ឆ្នាំ២០០៨។ សេចក្តីសង្ខេបនៅកម្រិតពិភពលោកសម្រាប់អ្នកធ្វើសេចក្តីសម្រេច ត្រូវបានរដ្ឋចំនួន៥៧ អនុម័តលើរបាយការណ៍នេះទាំងមូល លើកលែងតែប្រទេសចំនួនបី បានអនុម័តគាំទ្រលើសេចក្តីថ្លែងការណ៍ដោយបើកចំហ ប៉ុន្តែមិនឯកភាពគាំទ្រដល់របាយការណ៍ទាំងមូលឡើយ។ ការបម្រុងទុករបស់ពួកគេមកលើរបាយការណ៍នេះទាំងមូល រួមជាមួយការបម្រុងទុកសម្រាប់ប្រទេសទាំងអស់លើប្រយោជន៍ជាក់លាក់ មានរួមបញ្ចូល នៅក្នុងឧបសម្ព័ន្ធនៃរបាយការណ៍នេះ។

ភាគីចរចាចុះហត្ថលេខាលើអត្ថបទនេះ ដែលជាការបង្ហាញអំពីការអនុម័តគាំទ្រ និងឆន្ទៈរបស់ពួកគេក្នុងការគោរពតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ។ នេះជាជំហានចុងក្រោយនៅក្នុងការរៀបចំបញ្ចប់កិច្ចព្រមព្រៀង ដែលភាគីក្នុងការចរចា មានសមត្ថកិច្ច និងការទទួលខុសត្រូវសម្រាប់ការអនុវត្ត។

*"អ្នកពាក់ព័ន្ធទាំងអស់ត្រូវពិនិត្យអត្ថបទក្នុងកិច្ចព្រមព្រៀង"*

សម្រាប់កិច្ចព្រមព្រៀងដែលអាជ្ញាធរស្ថិតនៅក្រៅតុចរចា ដូចជា កិច្ចព្រមព្រៀងអន្តរជាតិ ឬច្បាប់ជាតិ ជំហាននៃការអនុម័តច្បាប់បន្ថែមទៀតទាមទារចាំបាច់ឲ្យមាន។

កិច្ចព្រមព្រៀងពិភពលោកជាច្រើនទាមទារឲ្យមានការផ្តល់សច្ចាប័នដើម្បីអាចចូលជាធរមាន។ ជាទូទៅនៅពេលដែលមានការចរចាលើសន្ធិសញ្ញាអន្តរជាតិ រដ្ឋនានាចុះហត្ថលេខាដែលជាការបង្ហាញអំពីការព្រមព្រៀងរបស់ពួកគេ និងចេតនារបស់ពួកគេ ដែលត្រូវជាប់នៅក្នុងសន្ធិសញ្ញានេះ។ រដ្ឋនានានៅមិនទាន់ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ឡើយ រហូតដល់សន្ធិសញ្ញានេះចូលជាធរមាន ហើយរដ្ឋទាំងនោះបានផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងនេះ។ តាមធម្មតាសន្ធិសញ្ញានានាចែងអំពីពេលវេលាដែលត្រូវចូលជាធរមានតាមរយៈកាលបរិច្ឆេទ និងឬចំនួនរដ្ឋនានា ដែលទាមទារឲ្យផ្តល់សច្ចាប័ន ឬទទួលយកកិច្ចព្រមព្រៀងនោះ។ ការផ្តល់សច្ចាប័ន (ឬការទទួលយក ការអនុម័ត ឬដំណើរការចូលជាសមាជិក) គឺជាមធ្យោបាយផ្លូវការរបស់រដ្ឋនៃការបង្ហាញអំពីការត្រៀមខ្លួនជាស្រេចដែលត្រូវជាប់កាតព្វកិច្ចនៅក្រោមសន្ធិសញ្ញានេះ។

តាមធម្មតាគោលនយោបាយ និងច្បាប់ជាតិ និងថ្នាក់ក្រោមជាតិ ក៏ត្រូវបានដាក់ឆ្លងចូលជាធរមានពីសំណាក់អាជ្ញាធរជាតិដែលពាក់ព័ន្ធ។ ប្រការនេះអាចទាក់ទងនឹងការពិនិត្យមើល និងអនុម័តឯកភាពនៅកម្រិតខុសៗគ្នាដូចជា នាយកដ្ឋាន គណៈកម្មការក្រសួង និងគណៈកម្មការសភា។

កិច្ចព្រមព្រៀងខ្លះត្រូវបានបង្កើតឡើង និងចុះហត្ថលេខាដោយអ្នកដើរតួនៅក្នុងរដ្ឋនានា និងអ្នកដើរតួមិននៅក្នុងរដ្ឋ ប៉ុន្តែទាមទារឲ្យមានការអនុម័តឯកភាពជាផ្លូវការរបស់រដ្ឋ ដើម្បីចូលជាធរមាន។ ឧទាហរណ៍ ធម្មនុញ្ញទឹក KYB នៅនីហ្សេរីយ៉ាត្រូវបានបង្កើតឡើងតាមរយៈការចរចាពហុអ្នកពាក់ព័ន្ធដែលទាក់ទងនឹងរដ្ឋាភិបាលនៃរដ្ឋចំនួនប្រាំមួយនៅតាមដងទន្លេនៃប្រទេសនីហ្សេរីយ៉ា អ្នកនេសាទ អ្នកលែងសត្វស៊ីស្មៅ អ្នកស្រោចស្រព អាជ្ញាធរប្រពៃណី និងអង្គការសហគមន៍ផ្សេងទៀត ក៏ដូចជាគ្រឹះស្ថានអប់រំ អង្គភាពជំនាញ និងសមាជិកផ្សេងទៀតនៃសង្គមស៊ីវិល។ សេចក្តីព្រាងធម្មនុញ្ញនេះត្រូវបានអានជាសាធារណៈ ជជែកវែកញែក ធ្វើវិសោធនកម្ម និងនៅទីបំផុតត្រូវបានផ្តល់សុពលភាពនៅក្នុងវេទិកាពហុភាគីកាលពីខែកុម្ភៈ ឆ្នាំ២០០៧។ ធម្មនុញ្ញទឹកនឹងចូលជាធរមាននៅពេលដែលបានទទួលការអនុម័តគាំទ្រឲ្យក្លាយជាឯកសារច្បាប់ពីសំណាក់មេដឹកនាំនៃរដ្ឋទាំងប្រាំមួយនៅតាមដងទន្លេក្នុងប្រទេសនីហ្សេរីយ៉ា។

កិច្ចព្រមព្រៀងផ្សេងទៀតអាចនឹងត្រូវបង្កើតឡើង និងចុះហត្ថលេខាពីសំណាក់ក្រុមតូចៗនៃអ្នកដើរតួ និងបើកចំហសម្រាប់ការអនុម័តគាំទ្រពីសំណាក់អ្នកដើរតួដទៃជាបន្ថែម។ ឧទាហរណ៍ ការអនុម័តគាំទ្រលើគោលការណ៍អេក្វាទ័រត្រូវធ្វើឡើងដោយស្ថាប័នហិរញ្ញវត្ថុនីមួយៗ ដែលមិនចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ប៉ុន្តែប្រកាសជាផ្លូវការថាពួកគេឯកភាពក្នុងការគោរព តាមកិច្ចព្រមព្រៀងទាំងនោះ។

## *៥.៥ ធ្វើចំណាត់ការតាមការព្រមព្រៀង - ការអនុវត្តន៍ និងឥទ្ធិពល*

ការចូលរួមប្រកបដោយការស្ថាបនានាំទៅរកសមិទ្ធផលជាច្រើន។ ដំណើរការខ្លះនាំទៅរកការព្រមព្រៀងផ្លូវការដែលបានចរចា។ ការអនុវត្តន៍កិច្ចព្រមព្រៀងទាំងនេះប្រកបដោយប្រសិទ្ធភាពគឺជាជំហានបន្ទាប់ នៅក្នុងការរួមចំណែកទៅក្នុងការធ្វើវិភាជន៍ ការប្រើប្រាស់ និងការគ្រប់គ្រងទឹកបានស្មើភាពគ្នា និងប្រកបដោយប្រសិទ្ធភាពជាងមុន។

MSPs ផ្សេងទៀត មានគោលដៅបង្កើតឥទ្ធិពលមកលើការសម្រេចនានាដែលធ្វើឡើងដោយអ្នកដើរតួដទៃទៀត។ អ្នកពាក់ព័ន្ធនានាអាចឯកភាពលើបណ្តាបញ្ហា ឬសកម្មភាពនានា ដែលពួកគេចង់ឃើញមានការដាក់ចូលជាធរមាននូវគោលនយោបាយជាតិ ឬ អ្នកដើរតួឆ្លងប្រទេសត្រូវគោរពតាម។ ខ្លឹមសារនៃអនុសាសន៍បែបនេះនៅតែជាកិច្ចព្រមព្រៀងដែលកំពុងចរចានៅឡើយ ដែលចាំបាច់ត្រូវចុះហត្ថលេខា ប៉ុន្តែការធ្វើសកម្មភាពទៅលើកិច្ចព្រមព្រៀងទាំងនេះទាមទារឲ្យមានការកសាងយុទ្ធសាស្រ្តនានា ដើម្បីបម្លែងអនុសាសន៍នានាឲ្យទៅជាឥទ្ធិពល។

ការចូលរួមតាមបែបស្ថាបនា ក៏អាចពង្រឹងទំនាក់ទំនងនានាផងដែរ បង្កើនការយល់ដឹង និងជម្រើសនានា និងបង្ហាញពីដំណើរការដ៏មានប្រសិទ្ធភាព។ ដៃគូខាងផ្នែកទឹកគួរពិចារណាអំពីរបៀបរក្សា និងពង្រឹងទំនាក់ទំនងទាំងនេះ និងលើកទឹកចិត្តឲ្យមានការអនុម័តពីពហុអ្នកពាក់ព័ន្ធនានាជាច្រើន និងដំណើរការពិចារណានានា នៅក្នុងការធ្វើសេចក្តីសម្រេច និងទៅក្នុងអភិបាលកិច្ចកាន់តែទូលាយជាងមុន។

*"អ្នកដើរតួខាងផ្នែកទឹកគួរពិចារណារបៀបលើកទឹកចិត្តឲ្យមានការអនុម័តដំណើរការដែលមានពហុអ្នកពាក់ព័ន្ធនានា និងមានការពិចារណាច្រើនជាងមុននៅក្នុងការធ្វើសេចក្តីសម្រេច"*

### ៥.៥.១ ការអនុវត្តន៍កិច្ចព្រមព្រៀង

សម្រាប់ការចរចាដែលនាំទៅរកកិច្ចព្រមព្រៀងជាផ្លូវការ ការយកចិត្តទុកដាក់បម្លែងទៅជាជំហាននានាដែលចាំបាច់ ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះឲ្យមានប្រសិទ្ធភាព។
ការពិចារណាសំខាន់ៗរួមមាន ៖

- ការប្រាស្រ័យឆ្លើយឆ្លងអំពីខ្លឹមសារនៃកិច្ចព្រមព្រៀងទៅកាន់មណ្ឌលគាំទ្រហត្ថលេខី (ជាពិសេសអំពី 4Rs អំពីភាគលាភ ហានិភ័យ សិទ្ធិ និងការទទួលខុសត្រូវ)
- ការធ្វើឲ្យមានការចាត់ចែងស្ថាប័នសម្រាប់ការអនុវត្តន៍ ពោលគឺ ធនធានបច្ចេកទេស និងហិរញ្ញវត្ថុជំណើរការកសាងផែនការ និងការតាមដាន រចនាសម្ព័ន្ធគ្រប់គ្រង
- កសាងសមត្ថភាពរបស់អ្នកអនុវត្តតាមការចាំបាច់ (បុគ្គល និងស្ថាប័ន)
- ចាត់វិធានការអនុលោមតាមការទទួលខុសត្រូវដែលបានឯកភាព
- បង្កើតយុទ្ធសាស្ត្រតាមដានដោយមានសូចនាករដែលមានការឯកភាពជាមួយគ្នាអំពីជោគជ័យ (ឥទ្ធិពល ប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ)។ អភិក្រមនៃការតាមដានរួមគ្នាត្រូវបានលើកស្នើឡើង ដើម្បីលើកទឹកចិត្តឲ្យមានការឆ្លុះបញ្ចាំង និងការរៀនសូត្រ
- ការអបអរជោគជ័យ និងការផ្តល់ភាគលាភដល់អ្នកដែលទទួលជោគជ័យធ្វើការកែប្រែតាមការចាំបាច់
- បង្កើតយន្តការនានា ដើម្បីលើកឡើង និងដោះស្រាយបញ្ហានានាដែលកើតឡើងតាមស្ថានភាពជាក់ស្តែង និងដោះស្រាយបញ្ហានានាមិនអនុវត្តតាម
- រក្សា និងពង្រីកតាមដែលអាចធ្វើទៅបាននូវមណ្ឌលគាំទ្រ ដោយបន្តប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធទាំងអស់ និងបន្តពង្រីកអ្នកចូលរួមឲ្យបានទូលំទូលាយ និងដោយមានការចូលរួមជាមួយអ្នកដើរតួជាក់លាក់។

ទិដ្ឋភាពគន្លឹះនៃការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព គឺយន្តការនានាដែលបានបង្កើតឡើង ដើម្បីនាំយកភាគីនានាមកជួបគ្នា ដើម្បីតាមដានអំពីវឌ្ឍនភាព រៀនសូត្រអំពីការអនុវត្ត និងកែតម្រូវតាមការចាំបាច់។ ប្រការសំខាន់ គឺត្រូវគូសបញ្ជាក់ថាតើអ្នកណាខ្លះមានភារៈកិច្ចទទួលខុសត្រូវលើការដឹកនាំការអនុវត្តន៍ តើនេះជាស្ថាប័នដែលមានស្រាប់ ឬអង្គភាពមួយដែលបង្កើតឡើងពីតំណាងនានានៃអ្នកពាក់ព័ន្ធដែលចូលរួម។

### ៥.៥.២ ការមានឥទ្ធិពលទៅលើការសម្រេចដែលមានបង្កការប៉ះពាល់មកលើទឹក

គេត្រូវការឲ្យមានអភិក្រមខុសគ្នាមួយ ដើម្បីមើលឃើញអនុសាសន៍នានាបម្លែងទៅជាឥទ្ធិពលសម្រាប់ MSPs ដែលមានគោលដៅបង្កឥទ្ធិពលមកលើការសម្រេចនានា ដែលធ្វើឡើងដោយអ្នកដើរតួដទៃទៀត ។ ការកសាងផែនការប្រាស្រ័យទាក់ទង និងជំមានឥទ្ធិពលមួយគឺទាក់ទងជាមួយការពិចារណាដូចតទៅ ៖

- អ្នកណានឹងត្រូវវងឥទ្ធិពល? កំណត់អត្តសញ្ញាណអ្នកធ្វើការសម្រេចដែលមានឆន្ទៈខ្ពស់បំផុត និងអ្នកណាដែលអាចជម្រុញអនុសាសន៍នានា ដើម្បីឆ្ពោះទៅរកការកែប្រែជំមានឥទ្ធិពល
- តើសារនេះនឹងត្រូវប្រាស្រ័យទាក់ទងបែបណា? អនុសាសន៍អាចត្រូវសង្ខេបនៅក្នុងឯកសារ

ខ្លីត្រូវបង្ហាញជូននៅក្នុងរបាយការណ៍ពិស្តារជាលាយលក្ខណ៍អក្សរ ឬក៏ត្រូវចែករំលែកតាមរយៈបទបង្ហាញដោយផ្ទាល់មាត់។ របាយការណ៍នេះ នឹងអាចចែងរំលែកជាផ្លូវការ ឬមិនផ្លូវការ។

- តើមានអ្វីខ្លះជាកាលានុវត្តភាពសម្រាប់បង្កើតឥទ្ធិពល? វាអាចជាព្រឹត្តិការណ៍នានា ដែលអាចយកទៅប្រើប្រាស់ដើម្បីធ្វើឲ្យមានការយកចិត្តទុកដាក់ចំពោះបញ្ហានេះ ឬបុគ្គលនានាដែលអាចទាក់ទងជាមួយអ្នកធ្វើសេចក្តីសម្រេចដោយផ្ទាល់
- តើអាចពង្រឹងមណ្ឌលអ្នកគាំទ្រទៅបែបណា? គេអាចប្រើប្រាស់មធ្យោបាយជាច្រើនដើម្បីបង្កើនការយល់ដឹងអំពីបញ្ហាទាំងនេះដូចជា ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ការប្រជុំគេហទំព័រ ព្រឹត្តិបត្រព័ត៌មាន។ល។
- តើអាចបង្កើនសម្ព័ន្ធភាពនានាបែបណា? ភាពជាដៃគូអាចបង្កើតឡើងបានជាមួយអ្នកដើរតួឬក្រុមនានាដែលមានគំនិតដូចគ្នា
- តើត្រូវឲ្យមានការគាំទ្រអ្វីខ្លះ? បង្កើតឲ្យមានការរៀបចំស្ថាប័នសម្រាប់អនុវត្តយុទ្ធសាស្ត្រតស៊ូមតិនិងឥទ្ធិពលដែលរួមទាំងធនធានបច្ចេកទេស និងហិរញ្ញវត្ថុ។ កសាងសមត្ថភាពរបស់អ្នកអនុវត្តតាមការចាំបាច់ (បុគ្គល និង ស្ថាប័ន) លើការប្រាស្រ័យទាក់ទង ការតស៊ូមតិ។ល។

ឧទាហរណ៍ធាតុសំខាន់ៗនៃយុទ្ធសាស្ត្រនេះដែលមានប្រើប្រាស់នៅក្នុងហ្គូមុខគ្រាស់នៅក្នុងករណី ៥.៦ នៅភាគខាងត្បូងនៃប្រទេសឥណ្ឌា គឺក្នុងគោលដៅអញ្ជើញអ្នកធ្វើសេចក្តីសម្រេចនៅថ្នាក់ស្រុក និងកំរិតរដ្ឋមកស្វែងយល់អត្ថប្រយោជន៍ជាក់ស្តែងនៃយុទ្ធសាស្ត្រគ្រប់គ្រងអាងផ្ទៃរងទឹកភ្លៀងសមស្របមុននឹងបង្កើត MSPs ដើម្បីពិភាក្សាអំពីជម្រើសជំនួសឲ្យការគ្រប់គ្រងអាងទន្លេនេះ។ យុទ្ធសាស្ត្រនេះក៏កសាងសមត្ថភាព និងទំនុកចិត្ត ដើម្បីចូលរួមនៅក្នុងការកសាងផែនការផ្នែកទឹក និងយកចិត្តទុកដាក់ជាពិសេសចំពោះក្រុមនានាដូចជា អ្នកក្រ និងស្ត្រី តាមធម្មតាត្រូវបានគេដាក់ឲ្យស្ថិតនៅក្រៅ នៅក្នុងដំណើរការធ្វើសេចក្តីសម្រេច ។ កសាងសមត្ថភាពរបស់ស្ត្រី ដើម្បីចាត់ចែងក៏ដូចជា ដើម្បីបង្កើនជំនាញបច្ចេកទេស ក៏ត្រូវបានយកចិត្តទុកដាក់ផងដែរនៅក្នុងករណីមួយផ្សេងទៀតមកពីប្រទេសឥណ្ឌា ដែលជាករណីនាំមុខមួយក្នុងការពង្រឹងសមត្ថភាពរបស់ស្ត្រីលើការចរចាអំពីតួនាទីដែលកាន់តែមានសមធមិជាងមុននៅក្នុងការគ្រប់គ្រងទឹក។

*ករណី៥.៦៖ ការបង្កើនឥទ្ធិពលមកលើគោលនយោបាយអាងទន្លេនៅអាងទន្លេប៊ីម៉ា ប្រទេសឥណ្ឌា*

អង្គការសហគមន៍និងអង្គការមិនមែនរដ្ឋាភិបាល(ដែលរួមទាំងហ្គោម្វគ្រាស់)នៅក្នុងអាងទន្លេប៊ីម៉ានៃប្រទេសឥណ្ឌាមានឥទ្ធិពលដោយជោគជ័យមកលើគោលនយោបាយអាងទន្លេ និងការបង្កើតកម្មវិធីដោយប្រើប្រាស់អភិក្រមមួយដែលដឹកមុខដោយអ្នកនៅតាមមូលដ្ឋាននៅក្នុងការចរចា។ អភិក្រមនេះតំណាងដោយការរួមផ្សំរវាងការបង្ហាញឲ្យឃើញពីការបង្កើតវេទិកាខុសៗគ្នា ដើម្បីចរចាអំពីយុទ្ធសាស្ត្រនៅមូលដ្ឋាន និងបន្ទាប់មកមានឥទ្ធិពលមកលើការកសាងផែនការ និងគោលនយោបាយនៅកម្រិតអាងទន្លេ។

ជំហានដំបូងនៅក្នុងដំណើរការនេះគឺបង្កើតវេទិកាសហគមន៍ដើម្បីដោះស្រាយតម្រូវការទឹកប្រកបដោយភាពប្រកួតប្រជែង និងស្វែងរកជម្រើសនានាសម្រាប់ការធ្វើវិភាជន៍ និងការគ្រប់គ្រងអនុអាងទន្លេមួយដែលខ្វះខាតទឹកយ៉ាងធ្ងន់ធ្ងរប្រកបដោយនិន្តរភាព និងមានសមធមិជាងមុន។ ការចរចានានាទាមទារឲ្យមានការដោះដូរ។ បើទោះជាបុគ្គលខ្លះអាចបានទទួលភាគផលក៏ដោយ ដូចជា កសិករនៅក្នុងភូមិទាំង ១៦ បានឯកភាពថាមិនប្រើប្រាស់អណ្តូងខួង សម្រាប់ការស្រោចស្រពឡើយ ដើម្បីថែរក្សាប្រភពទឹកក្រោមដី។

ជំហានទីពីរ គឺត្រូវអនុវត្តយុទ្ធសាស្ត្រដែលបានជ្រើសរើសហើយ ដើម្បីបង្ហាញអំពីភាពស្ថិតស្ថេរនៃយុទ្ធសាស្ត្រទាំងនេះ។ អន្តរាគមន៍នានាបានផ្តោតលើបច្ចេកវិទ្យាសមស្របនៅតាមមូលដ្ឋាន ហើយអាចបង្កើតអភិក្រមប្រពៃណីនានាដូចជា ការស្តារអាងស្តុកទឹកនៅរដូវវស្សាតាមប្រពៃណី និងការពារកន្លែងគោរពបូជា (ព្រៃដែលមានសារៈសំខាន់ខាងសាសនា)។ អត្ថប្រយោជន៍នានាត្រូវបានបង្ហាញឲ្យឃើញច្បាស់នៅក្នុងរដូវរាំងស្ងួតធ្ងន់ធ្ងរមួយក្នុងឆ្នាំ២០០៣-២០០៤ ដែលនៅពេលនោះ មានតែជ្រលងភ្នំមួយគត់នៃអាងទន្លេនេះនៅតែមានពណ៌បៃតង។

ជំហានទីបី គឺពង្រីកបទពិសោធន៍នៅមូលដ្ឋាន ដើម្បីជះឥទ្ធិពលមកលើការគ្រប់គ្រងទឹកនៅក្នុងវិសាលភាពអាងទន្លេទាំងស្រុង។ អង្គការសហគមន៍ ដូចជា ហ្គោមុខត្រាស់ បានដើរតួក្នុងការសម្របសម្រួលដើម្បីនាំយកភាគីនានាមកជួបគ្នា និងជួយរៀបចំអង្គការសហគមន៍ដើម្បីឲ្យពួកគេអាចចូលរួមប្រកបដោយប្រសិទ្ធភាព។ យុទ្ធសាស្ត្រដ៏មានឥទ្ធិពលរបស់ពួកគេបានរួមបញ្ចូលការបង្កើនការយល់ដឹងទូទៅក៏ដូចជាផ្តោតលើការតស៊ូមតិជាមួយអ្នកធ្វើសេចក្តីសម្រេចនៅថ្នាក់ស្រុក និងកំរិតរដ្ឋផងដែរ ដើម្បីបង្ហាញដល់ពួកគេអំពីលទ្ធផលវិជ្ជមាន។ ពួកគេបានបង្កើតវេទិកានានាសម្រាប់ក្រុមសហគមន៍ អាជ្ញាធរមូលដ្ឋាន "អ្នកជំនាញការ" ខាងផ្នែកទឹក សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដទៃទៀតផងដែរ ដើម្បីពិភាក្សាអំពីវិធីនានា ដើម្បីកែលម្អការគ្រប់គ្រងទីជម្រាល និងអាងទន្លេ ពោលគឺ អភិក្រមខុសគេមួយដែលផ្តើមចេញពីការកសាងផែនការអាងទន្លេពីលើមកក្រោមដែលជាទម្លាប់កន្លងមក ដែលអាចផ្តល់ឱកាសសម្រាប់អ្នកនិយមបច្ចេកទេស ប៉ុន្តែមិនមែនសម្រាប់សហគមន៍ឡើយ។ វេទិកាទាំងនេះត្រូវបានលើកស្នើឡើង ដើម្បីជួយដោះស្រាយវិវាទនានា ក៏ប៉ុន្តែដើម្បីពិភាក្សាបញ្ហាគោលនយោបាយនានាផងដែរមុនមានវិវាទកើតឡើង។ តាមរយៈយុទ្ធសាស្ត្រនេះ ក្រុមនេះបានធ្វើការតស៊ូមតិប្រកបដោយជោគជ័យសម្រាប់ការអនុម័តអន្តរាគមន៍គ្រប់គ្រងទីជម្រាលមួយចំនួននៅទូទាំងរដ្ឋ។[85]

## *៥.៥.៣ ការមានឥទ្ធិពលមកលើដំណើរការអភិបាលកិច្ច*

ការបង្កើត MSPs និងការបង្កើតឲ្យមានការឯកភាពមតិគួរតែមានគោលដៅជាក់លាក់ឬរបៀបវារៈជាក់លាក់ដែលពួកគេព្យាយាមបង្កើនឲ្យមានឥទ្ធិពលឡើង។ ការអនុវត្តន៍កិច្ចព្រមព្រៀងមួយឬការទទួលយកអនុសាសន៍ពី MSPs ដើម្បីមានឥទ្ធិពលមកលើបញ្ហាជាក់លាក់ណាមួយគឺជាសមិទ្ធផលសំខាន់បំផុតនៃការចូលរួមប្រកបដោយការស្ថាបនាដើម្បីកែប្រែការប្រើប្រាស់និងគ្រប់គ្រងទឹក។

ទោះជាយ៉ាងណាក៏ដោយគេក៏អាចមានឱកាសដើម្បីពង្រឹងជាបន្ថែមលើចលនការដែលបានបង្កើតឡើងនៅក្នុង MSPs ផងដែរ ដើម្បីមានឥទ្ធិពលមកលើទិដ្ឋភាពនានានៃអភិបាលកិច្ចទឹក និងអភិបាលកិច្ចជាទូទៅ (សូមអានករណី៥.៧)។ ប្រការនេះអាចរាប់បញ្ចូលការឆ្លុះបញ្ចាំងអំពីដំណើរការដែលបានប្រើប្រាស់នៅក្នុងអំឡុងពេល MSPs ឬការចរចា និងការពិនិត្យមើលវិធីនានាដែលក្នុងនោះវិធីនានានៃការចូលរួមប្រកបដោយការស្ថាបនាអាចយកទៅអនុវត្តនៅក្នុងមជ្ឈដ្ឋានដទៃផ្សេងទៀតដែលមានឥទ្ធិពលមកលើការសម្រេចដែលទាក់ទងនឹងទឹក (ឬជាទូទៅ)ផងដែរ។

អ្នកចូលរួមនៅក្នុង MSPs អាចលើកទឹកចិត្តឲ្យមានការប្រើប្រាស់ជាប្រចាំនូវការចូលរួមប្រកបដោយការស្ថាបនានៅក្នុងអង្គការរបស់ខ្លួន ឬរបស់ដៃគូខ្លួនផងដែរ។ ការធ្វើបែបនេះគួរតែពង្រឹងបន្ថែមលើការវាយតម្លៃអំពីភាពខ្លាំង និងភាពទន់ខ្សោយនៃវិធីនានាដែលបានប្រើប្រាស់ និងការកសាងសមត្ថភាពនៅក្នុងការចរចា ឬឧបករណ៍ជាក់លាក់ដែលប្រើប្រាស់នៅក្នុង MSPs (ដូចជាការវិភាគ 4Rs អំពីភាគលាភហានិភ័យ សិទ្ធិ និងការទទួលខុសត្រូវ) ផងដែរ។ អ្នកដើរតួក្នុងផ្នែកទឹកក៏អាចមានតួនាទីជាអ្នកជម្រុញលើកទឹកចិត្តឲ្យមានការទទួលយកទូលំទូលាយនូវការចូលរួមតាមបែបស្ថាបនានៅក្នុងបញ្ហាផ្សេងទៀតដែលទាក់ទងនឹងទឹកឬនៅលំដាប់ថ្នាក់ និងកម្រិតខុសៗគ្នាផងដែរ។

*ករណីទី៥.៧៖ MSPs នៅលំដាប់ថ្នាក់ខុសៗគ្នាក្នុងអាងទន្លេវ៉ុលតា*

អាងទន្លេវ៉ុលតាមានទំហំ៤០៧.០០០គម២និង ៨៥% ជាអាងរួមគ្នារវាងប្រទេសហ្គាណា និងប៊ូគីណាហ្វាសូ។នៅឆ្នាំ២០០៧ ប្រទេសចំនួនប្រាំមួយនៅក្នុងអាងទន្លេនេះ (បេនីញ ប៊ូគីណាហ្វាសូ អ៊ីវ័រីខូស ហ្គាណា ម៉ាលីនិងតូហ្គោ) បានចុះហត្ថលេខាលើអនុសញ្ញាមួយស្តីពីស្ថានភាពនៃទន្លេវ៉ុលតា និងការបង្កើតអាជ្ញាធរអាងទន្លេវ៉ុលតា ដែលជាកិច្ចព្រមព្រៀងក្របខ័ណ្ឌមួយសម្រាប់គ្រប់គ្រង និងអភិរក្សធនធាននៅក្នុងអាងទន្លេនេះ។

ក្នុងពេលដែលដំណើរការផ្តល់សច្ចាប័នកំពុងតែអនុវត្ត ហើយអាជ្ញាធរអាងទន្លេវ៉ុលតាកំពុងស្ថិតនៅក្នុងដំណាក់កាលបង្កើត ដែលដំណាក់កាលនេះគឺជាសកម្មភាពបន្តបន្ទាប់ត្រូវបានអនុវត្ត ដោយកិច្ចផ្តួចផ្តើមរួមគ្នាមួយរបស់ IUCN ប្រធាននាយកដ្ឋានធនធានទឹកនៃប្រទេសប៊ូគីណាហ្វាសូ និងគណៈកម្មាធិការធនធានទឹកនៃប្រទេសហ្គាណា។ អន្តរាគមន៍នេះមិនត្រឹមតែបន្ថែមតម្លៃមកលើក្របខ័ណ្ឌស្ថាប័ននៅថ្នាក់ខ្ពស់ជាងស្ថាប័នជាតិប៉ុណ្ណោះទេប៉ុន្តែថែមទាំងបង្កើតជាដំណើរការមួយផងដែរដែលក្នុងនោះអ្នកពាក់ព័ន្ធទាំងអស់មកពីសហគមន៍រហូតដល់ក្រសួងនៅថ្នាក់ជាតិបានចូលរួមផងដែរ។ កិច្ចផ្តួចផ្តើមអភិបាលកិច្ចនេះ ត្រូវគេស្គាល់ថាជា PAGEV(ពាក្យបំព្រួញពីភាសាបារាំង) និងតំណាងដោយការកៀងគរភាពជាដៃគូ ជាមួយអ្នកពាក់ព័ន្ធនានា ដែលរួមទាំង ក្រសួង រដ្ឋាភិបាលមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល។ MSPs ត្រូវបានបង្កើតឡើងនៅលំដាប់ថ្នាក់ខុសៗគ្នា ដែលរួមទាំង ៖ ការបង្កើតគណៈកម្មការភូមិ ដែលសហគមន៍បានធ្វើការជាមួយគ្នាលើបញ្ហាគ្រប់គ្រងចម្រុះនានាដូចជា ការពារច្រាំងទន្លេ ការបង្កើតវេទិកាជាតិ (ដែលបង្កើតឡើងដោយអ្នកភូមិ អាជ្ញាធរមូលដ្ឋាននៃរដ្ឋាភិបាល អង្គការសហគមន៍ និងអង្គការសង្គមស៊ីវិល) និងការបង្កើតវេទិកាឆ្លងដែន (ដែលបង្កើតឡើងដោយតំណាងនានាមកពីវេទិកាជាតិ ក៏ដូចជាក្រសួងនាយកដ្ឋាន និងទីភ្នាក់ងារនានាមកពីប្រទេសទាំងពីរផងដែរ)។

គម្រោងនេះក៏បានសម្រួលឲ្យមានការបង្កើត និងអនុម័តក្រមអនុវត្តសម្រាប់ការគ្រប់គ្រងធនធានទឹករួមគ្នាប្រកបដោយនិរន្តរភាព និងមានសមធម៌ផងដែរនៅក្នុងអាងទន្លេវ៉ុលតា ដែលមានគោលដៅជម្រុញការគ្រប់គ្រងរួមគ្នានៅទូទាំងអាងទន្លេនេះ។ សហគមន៍មូលដ្ឋានបានអះអាងអំពីការប្តេជ្ញារបស់ពួកគេចំពោះក្រុមនេះ ដោយបង្កើតជាបន្ថែមទៀតនិងចុះហត្ថលេខាលើលក្ខន្តិកៈ និងបទប្បញ្ញត្តិនានា ដើម្បីតម្រង់ទិសសកម្មភាពរបស់ពួកគេលើការគ្រប់គ្រងទឹកឆ្លងដែន។[85]

## *៥.៥.៤ ការប្រែប្រួលរយៈពេលវែង*

ការរៀបចំបញ្ចប់ និងអនុវត្តតាមកិច្ចព្រមព្រៀងមួយ គឺជាការបញ្ចប់នៃដំណើរការចូលរួមប្រកបដោយការស្តាបនា និងការចរចា។ ការរក្សាជំហរតាមគោលការណ៍នានា និងគុណតម្លៃនៃភាពពេញលេញ យុត្តិធម៌ និងការពិចារណា នឹងជួយធានាថា ផលិតផលនេះក៏ឆ្លុះបញ្ចាំងដំណើរការនេះផងដែរ។ ការយកចិត្តទុកដាក់ទៅក្នុងទំនាក់ទំនងនានានៅគ្រប់ដំណាក់កាល នឹងពង្រឹងកិច្ចព្រមព្រៀងដែលកំពុងចរចា និងអាចបង្កើតជាមូលដ្ឋានគ្រឹះសម្រាប់ការចរចាទៅអនាគត។ ក្នុងពេលដែលដំណើរការនេះអាចទាមទារពេលច្រើនជាងមុន ដោយសារអ្នកពាក់ព័ន្ធទាំងអស់បង្កើនសមត្ថភាពរបស់ខ្លួន ដើម្បីចូលរួមប្រកបដោយប្រសិទ្ធភាព និងធ្វើជាតំណាងមណ្ឌលរបស់ពួកគេ កិច្ចព្រមព្រៀងមួយដែលមានការគាំទ្រធំទូលាយនឹងនាំទៅរកការអនុវត្តដែលមានភាពរលូនជាងមុន។ គេពុំមានដំណើរការឬកិច្ចព្រមព្រៀងមួយដែលសុក្រិត្យនោះទេ សមិទ្ធផលប្រសើរបំផុតគឺជាអ្វីមួយដែលអ្នកពាក់ព័ន្ធទាំងអស់ចាប់អារម្មណ៍ថា បញ្ហារបស់ពួកគេត្រូវបានសំដែងឡើង ហើយផលប្រយោជន៍ និងជម្រើសរបស់ពួកគេត្រូវបានពិចារណាគ្រប់គ្រាន់។

តថភាពស្ថិតនៅត្រង់ថា ជាញឹកញាប់គេត្រូវការពេលវេលាច្រើនដើម្បីធ្វើឲ្យមានការប្រែប្រួលវិជ្ជមានជាច្រើននៅក្នុងអភិបាលកិច្ចទឹក និងផ្អែកលើមូលដ្ឋាននៃការគ្រប់គ្រង និងការប្រើប្រាស់ដែលមានយុត្តិធម៌ និងប្រសិទ្ធភាពជាងមុន។ អភិបាលកិច្ចទឹកនៃពហុអ្នកពាក់ព័ន្ធ គឺជាដំណើរការរយៈពេលវែងមួយដែលគ្របដណ្តប់ការចូលរួម និងការចរចាដែលក្នុងនោះបញ្ហាថ្មីៗលេចឡើង និងត្រូវលើកឡើងនិងដោះស្រាយ។ កិច្ចព្រមព្រៀងនីមួយៗដែលបានចរចាមានសារៈសំខាន់ណាស់ ប៉ុន្តែប្រការដែលសំខាន់ផងដែរនោះគឺពង្រឹងជាបន្ថែមលើចលនការ និងទំនាក់ទំនងដែលបង្កើតឡើងនៅក្នុងអំឡុងពេលនៃការចូលរួមរបស់ពហុអ្នកពាក់ព័ន្ធ ដើម្បីធ្វើឲ្យមានឥទ្ធិពលវិជ្ជមានមកលើដំណើរការធ្វើសេចក្តីសម្រេច និងស្ថាប័ននានានៅក្នុងរយៈពេលវែង។

# ករណី និងប្រអប់


ប្រអប់១.១៖ តើមានអ្វីខ្លះជាចំណុចពិសេសៗដែលទាក់ទងនឹងទឹក?..........១៨
ប្រអប់២.១៖ ភាពរឹងប៉ឹងនៃសង្គម ក្រមួន ស្អួលអំបោះនិងអណ្តាតភ្លើង - វិទ្យាសាស្ត្រនិងសិល្បៈ.........៣០
ប្រអប់២.២៖ វេទិកាចរចាជាសកលអំពីទឹក..........៣៣
ប្រអប់៣.១៖ MSPs និងលំនាំនៃការសន្ទនា១ ២ ៣..........៥០
ប្រអប់៣.២៖ ជំហាននានាដែលប្រើប្រាស់នៅក្នុងការបង្កើតសេណារីយ៉ូ..........៦៧
ប្រអប់៤.១៖ ត្រូវដឹងអំពីគ្រោះថ្នាក់នៃដំណើរការពិសេសខ្លះៗ..........៩៧
ប្រអប់៥.១៖ ជម្រើសដោះស្រាយវិវាទ..........១២១

ករណី២.១៖ ភាពតានតឹងនៅអាងសមុទ្រអារ៉ាល..........៣៨
ករណី២.២៖ ផ្តើមចេញពីជម្លោះឈានទៅរកការចូលរួមប្រកបដោយការស្តាបនា ក្នុងវិស័យថាមពលវារីអគ្គិសនីនៅណេប៉ាល់..........៤២
ករណី២.៣៖ អណ្តូងរ៉ែអ្វកតេឌីនៅប៉ាពូញូហ្គីនេ - ការកែប្រែបែបផែននៃការចរចា..........៤៣
ករណី៣.១៖ "ការស្វែងយល់ជាមួយគ្នាអំពីអនាគតនៃទឹក" នៅក្នុងតំបន់មេគង្គ..........៤៩
ករណី៣.២៖ ការវាយកំទេចជញ្ជាំងនៅខេបយកនៃប្រទេសអូស្ត្រាលី..........៥៣
ករណី៣.៣៖ ការធ្វើឲ្យមានតុល្យភាពអំណាចក្នុងក្រុមប្រឹក្សាអាងទន្លេហ្វ្រេហ្សរ័នៅកាណាដា............៥៤
ករណី៣.៤៖ ការកែលម្អចំណេះដឹង វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាកសិកម្ម..........៦០
ករណី៣.៥៖ "កិច្ចសន្យាសង្គម" នៃវេទិកាវាយតម្លៃនិរន្តរភាពថាមពលវារីអគ្គិសនី..........៦៥
ករណី៣.៦៖ ការសន្ទនាដែលនាំមុខដោយសង្គមស៊ីវិលដែលវាយតម្លៃប្រព័ន្ធផ្សារភ្ជាប់ទន្លេនៅក្នុងប្រទេសឥណ្ឌា..........៦៦
ករណី៣.៧៖ ការបង្កើតម៉ូដែលរួមផ្សំ..........៦៨
ករណី៣.៨៖ សេណារីយ៉ូនៅក្នុងការវាយតម្លៃប្រព័ន្ធអេកូឡូស៊ីសហាស្សវត្សរ៍..........៦៩
ករណី៣.៩៖ ការចរចាអំពីលំហូរបរិស្ថាននៅអាងទន្លេសេនេហ្កាល់..........៧០
ករណី៣.១០៖ គណៈកម្មការពិភពលោកស្តីពីទំនប់..........៧១
ករណី៤.១៖ ការកំណត់របៀបវារៈសម្រាប់ការចរចាស្តីពីកិច្ចព្រមព្រៀងគ្រប់គ្រងទឹកដោយនិរន្តរភាពនៅអាងដានូបេ..........៧៧
ករណី៤.២៖ ដំណើរការបង្កើតការឯកភាពមតិសម្រាប់ការស្តារតំបន់អេវើគ្លេតនៅហ្វ្លរីដាខាងត្បូង......៨៤
ករណី៤.៣៖ ការបង្កើតរួមគ្នានូវដំណើរការចរចារវាងក្រុមហ៊ុនប៊ីអេជភីប៊ីលីតុន និងសហគមន៍រងគ្រោះនៅអណ្តូងរ៉ែទីនតាយ៉ាប្រទេសប៉េរូ..........៨៨
ករណី៤.៤៖ ការធ្វើសេចក្តីសម្រេចជារចនាសម្ព័ន្ធនៅក្នុងការកសាងផែនការប្រើប្រាស់ទឹកនៅប្រ៊ីធីសកូឡុំប៊ីយ៉ានៃប្រទេសកាណាដា..........៩១
ករណី៤.៥៖ ការដោះដូររវាងជម្រើសជំនួសនានានៅក្នុងអាងទន្លេមេគង្គ..........៩២
ករណី៤.៦៖ ការពិចារណាអំពីការអនុវត្តន៍ធម្មនុញ្ញទឹកអាងទន្លេកូម៉ាឌូហ្គូនៅនីហ្សេរីយ៉ា..........៩៥
ករណី៥.១៖ កំណែទម្រង់ទូលំទូលាយខាងផ្នែកទឹកនៅអាហ្វ្រិកខាងត្បូង..........១០៩

ករណី៥.២៖ ភាពចម្រុះគ្នាដែលបានចរចានៅក្នុងមូលដ្ឋានអំពីការគ្រប់គ្រងទឹកតាមរយៈប្រព័ន្ធប្រឡាយនៅតង់ហ្សានី........១១៧
ករណី៥.៣៖ ក្រមអនុវត្តសម្រាប់អាងទន្លេវ៉ុលហ្កា........១២២
ករណី៥.៤៖ លក្ខន្តិកៈគ្រប់គ្រងទីជម្រាលលីងមូទៃជូនៅប៉ិុយតាន........១២៣
ករណី៥.៥៖ កត់សំគាល់អំពីករណីលើកលែងនៅក្នុងកិច្ចព្រមព្រៀង........១២៥
ករណី៥.៦៖ ការបង្កើនឥទ្ធិពលមកលើគោលនយោបាយអាងទន្លេនៅអាងទន្លេបីម៉ាប្រទេសឥណ្ឌា....១២៨
ករណី៥.៧៖ MSPs នៅលំដាប់ថ្នាក់ខុសៗគ្នាក្នុងអាងទន្លេវ៉ុលតា........១៣០

# តារាង និងរូប

តារាង២.១៖ វិសាលគមន៍នៃការចូលរួមជាសាធារណៈ........៣០
តារាង២.២៖ ការបង្ហាញពីភាពផ្ទុយគ្នានិងការសន្ទតិនៅក្នុងការចរចា........៣៦
តារាង៣.១៖ ការវិភាគអ្នកពាក់ព័ន្ធដោយប្រើប្រាស់ 4Rs នៅក្នុងគម្រោងសម្បតិកម្មទឹក ........៦៤
តារាង៤.១៖ ការជំនះឲ្យបានលើបញ្ហានៃការតថ្លៃតឹងរ៉ឹង........៨១
តារាង៥.១៖ ប្រភេទនៃកិច្ចព្រមព្រៀង ........១១៣

រូប១.១៖ 4Rs........២២
រូបទី៣.១៖ ក្របខ័ណ្ឌគោលគំនិតនៃ MSPs និងសំណុំលក្ខណៈដែលចង់បាន ........៤៨
រូបទី៣.២៖ កម្រិត និងលំដាប់ថ្នាក់........៥២
រូប៣.៣៖ អំណាច ........៥៦
រូប៣.៤៖ កាលវេលា និងលំដាប់លំដោយនៃMSPsសម្បតិកម្ម........៥៩
រូបទី៤.១៖ ជំហានទាំងប្រាំមួយនៅក្នុងដំណើរការបង្កើតការឯកភាពមតិ ........៨៣

*he following NEGOTIATE case studies are available in full on the IUCN water website: www.iucn.org/about/work/programmes/water/resources/toolkits/negotiate*

*Learning to listen – government openness to work with community members resolves decades of conflict over waste water treatment in Coffs Harbour, Australia*
Pam Allan, Macquarie University, Australia

*Negotiations for an Agreement on Sustainable Water Management in the Danube Basin*
Catherine Ashcraft, Massachusetts Institute of Technology, United States

*South Florida Everglades Restoration*
Catherine Ashcraft, Massachusetts Institute of Technology, United States

*Using Companion Modelling to level the playing field and influence more equitable water allocation in northern Thailand*
Cécile Barnaud, Paris X-Nanterre University, France, Panomsak Promburom, Chiang Mai University, Thailand, and Guy Trébuil and François Bousquet, CIRAD, France

*Using Structured Decision Making in Collaborative Planning Processes for Better Water Management - An Innovative Approach to Water Use Planning in British Columbia, Canada*
Lee Failing and Graham Long, Compass Resource Management, Canada

*A Multi-Stakeholder Platform to solve a conflict over a Water and Sanitation Project in Tiquipaya, Bolivia*
Vladimir Cossio, Centro AGUA, UMSS, Bolivia

*Experience of a process leading to integration of the actors in a watershed committee in the Cara Sucia-San Pedro Belén hydrographic region in the department of Ahuachapán, El Salvador*
Nicolás Atilio Méndez Granados, and Maritza Guido Martínez, IUCN BASIM Project, El Salvador

*Interlinking of Rivers in India: Dialogue and Negotiations by National Civil Society Committee.*
Biksham Gujja, WWF International, Switzerland

*Sharing Irrigation Water in Bhutan: Companion Modeling for Conflict Resolution and Promoting Collective Management*
Tayan Raj Gurung, Aita Kumar Bhujel and Gyenbo Dorji, Renewable Natural Resources Research Center, Bhutan, François Bousquet and Guy Trébuil, CIRAD, France

*From "No Dams!" to "No Bad Dams!" Nepal's Engagement with the World Commission on Dams' Report.*
Dipak Gyawali, Nepal Water Conservation Foundation, Nepal

*How the Weak Prevailed - Nepali Activists Engaging the World Bank over Arun-3*
Dipak Gyawali, Nepal Water Conservation Foundation, Nepal

*Community-Based Approaches to Conflict Management - Umatilla County Critical Groundwater Areas*
Todd Jarvis, Oregon State University, United States

*Building Shared Understanding – Use of Role Playing Games and Computer Simulations to negotiate improved water management in the Republic of Kiribati*
Natalie Jones, Australian National University, Australia

*Strengthening Regional Consultation and Coordination of the SASS Aquifer*
Kerstin Mechlem, Transitional Justice Institute, University of Ulster, Ireland

*Negotiation Processes in Institutionalizing Grassroots Level Water Governance: Case of Self Employed Women's Association, Gujarat, India*
Smita Mishra Panda, Human Development Foundation, India

*The Challenge of International Watercourse Negotiations in the Aral Sea Basin*
Richard Kyle Paisley, University of British Columbia, Canada

Negotiating our way through Livelihoods and Ecosystems: The Bhima River Basin Experience
Vijay Paranjpye and Parineeta Dandekar, Gomukh Environmental Trust for Sustainable Development, India

*Mekong River Basin, Agreement & Commission Case Study*
George E. Radosevich, RAD International, Thailand

*Tarim River Basin Case Study*
George E. Radosevich, RAD International, Thailand

*Integrated Water Resources Management in Four Pilot Microwatersheds in San Marcos, Guatemala*
Ottoniel Rivera Mazariegos and Nora Herrera Illescas, IUCN Tacana Project, Guatemala

*Ok Tedi and Fly River negotiation over compensation: Using the mutual gains approach in multi-party negotiations*
Barbara Sharp and Tim Offor, OfforSharp, Australia

*Multistakeholder Platforms and Negotiation: The case of Kat River Valley Catchment Management Forum*
Eliab Simpungwe, Limpopo Department of Agriculture, South Africa

*Visioning on the future of the rivers Scheldt and Waal*
Jeroen Warner,Wageningen University, The Netherlands

*Komadugu Yobe Basin: A Case Study of Participatory Water Charter Development for Sustainable and Equitable Management of Water Resources*

D. K. Yawson, H.G. Ilallah and I.J. Goldface-Irokalibe, IUCN-Komadugu Yobe Basin Project, Nigeria and Ahmadu Bello University, Nigeria

វាក្យស័ព្ទមួយចំនួនដែលអ្នកអានអាចយល់ថាមានប្រយោជន៍ក្នុងការស្វែងយល់ និងក្នុងការបង្កើតការចរចា។

accord – n ដំណើរត្រូវគ្នា
ដំណើរត្រូវគ្នា ការយល់ព្រមកិច្ចព្រមព្រៀង ឬសន្និសញ្ញាផ្លូវការមួយ។

act - n ច្បាប់
ច្បាប់មួយដែលអនុម័តជាផ្លូវការដោយសភា។

actors - n អ្នកដើរតួ
អ្នកដើរតួក្រុមមនុស្សនៅលំដាប់ថ្នាក់នានា "ដែលដើរតួ" ជាលក្ខណៈបុគ្គល ឬរួមគ្នាជាសមូហភាពចូលរួមនៅក្នុងកិច្ចការណាមួយ។

administration (water) – n. រដ្ឋបាល( ទឹក )
រដ្ឋបាល( ទឹក )អង្គការ និងប្រតិបត្តិការនៃប្រព័ន្ធមួយដើម្បីគ្រប់គ្រងការផ្គត់ផ្គង់ វិភាជន៍ តម្រូវការ និងថែរក្សាទឹក។

agreement - n. កិច្ចព្រមព្រៀង
ការចាត់ចែងដែលបានចរចា។ មិនសុទ្ធតែមានន័យថាភាគីទាំងអស់ពេញចិត្តទាំងស្រុង ឬ ស្របមតិជាឯកឆន្ទលើហេតុផលនៅពីក្រោយការសម្រេចណាមួយនោះឡើយ ប៉ុន្តែឆ្លុះបញ្ចាំងអំពីការឈានដល់ការចាត់ចែង ឬផលិតផលមួយ ដែលយកជាការបាន និងអ្នកទាំងអស់គ្នាអាចទទួលយកបាន។

agreement ( water ) កិច្ចព្រមព្រៀង
កិច្ចព្រមព្រៀង(អំពីទឹក)គោលនយោបាយ ច្បាប់ និងការចាត់ចែងគ្រប់គ្រងដទៃទៀត ដែលមានអំណាចលើឥរិយាបថដែលទាក់ទងនឹងទឹក ការព្រមព្រៀងនានា ( ដូចជា ការចរចា ) អាចធ្វើឡើងនៅលំដាប់ថ្នាក់ និងកម្រិតខុសៗគ្នា ដែលអាចជាប់កាតព្វកិច្ច ឬមិនជាប់ ( ពោលគឺ អាចជាការចាប់បង្ខំតាមច្បាប់ ) ផ្លូវការ ឬមិនផ្លូវការ ផ្ទាល់មាត់ ឬជាលាយល័ក្សអក្សរ។

allocation ( water ) - n. វិភាជន៍( ទឹក )
ដំណើរការសម្រេច ( និងមិនសម្រេច )ផ្លូវការ និងមិនផ្លូវការ ដែលកែប្រែការបែងចែកទឹក និងភាគលាភដែលទាក់ទងនឹងទឹក ហានិភ័យ និងការទទួលខុសត្រូវ។

amendment - n. ការកែប្រែ
វិសោធនកម្មការកែលម្អតិចតួច។ការព្រមព្រៀងនានាអាចនិងគួរតែធ្វើវិសោធនកម្មជាបន្តបន្ទាប់ក្នុងពេល

ដែលកាលៈទេសៈប្រែប្រួល និងដែលត្រូវការឲ្យមានការកែតម្រូវ។

arbitrator -n. អាជ្ញាកណ្តាលបុគ្គល
អាជ្ញាកណ្តាលបុគ្គល ឬអង្គភាពឯករាជ្យមួយដែលត្រូវបានតែងតាំងជាផ្លូវការ ដើម្បីដោះស្រាយ និងកាត់ក្តីវិវាទ។

assisted negotiation - n. ការចរចានៅក្រោមការជួយចាត់ចែង
ការចរចានៅក្រោមការជួយចាត់ចែងនៅពេលដែលចំនួនភាគី និងបញ្ហានានានៅក្នុងការចរចាមួយកើនឡើង ជាញឹកញាប់គេចាំបាច់ត្រូវអញ្ជើញអ្នកសម្របសម្រួល ឬអន្តរការីអព្យាក្រឹតដើម្បីជួយគ្រប់គ្រងដំណើរការចរចា ការដោះស្រាយបញ្ហា ការសម្រេចយកជម្រើស ការស្វែងរកការឯកភាពមតិ ឬ ការធ្វើឲ្យប្រសើរបំផុត។

authority - n. សមត្ថកិច្ចអំណាច
សមត្ថកិច្ចអំណាច ឬសិទ្ធិក្នុងការចេញបញ្ជា និងចាប់បង្ខំឲ្យគោរព ឬបុគ្គល ឬអង្គការមួយ ដែលមានអំណាចជាផ្លូវការ ឬចំណេះដឹង ឬ ជំនាញដែលមានការទទួលស្គាល់។

bargain - v. តថ្លៃ
តថ្លៃចរចាលក្ខខណ្ឌនៃការព្រមព្រៀងមួយ។ ឧទាហរណ៍ ប្រយោគ "ការតថ្លៃតឹងតែង" មានន័យថា បង្ខំជាខ្លាំងដើម្បីឲ្យមានការឯកភាពគ្នាដែលលំអៀងទៅអ្នកណាម្នាក់។ ជាញឹកញាប់ ការតថ្លៃតឹងតែងទាក់ទងនឹងរបៀបចរចាជាលក្ខណៈប្រកួតប្រជែង។

best alternative to a negotiated agreement ( BATNA )
ជម្រើសល្អបំផុតចំពោះ កិច្ចព្រមព្រៀងដែលបានចរចា
គោលគំនិតដែល Roger Fisher and William Ury បានបង្កើតឡើង។[85] ជាជាងផ្តោតលើ "លក្ខខណ្ឌអប្បបរមា" ដែលជាទម្លាប់តាមប្រពៃណី អ្នកទាំងពីរអះអាងថា អ្នកចរចាគួរតែដឹងអំពីអ្វីដែលអាចជាសមិទ្ធផលដែលមាននៅក្នុងករណីអវត្តមានការចរចាដោយជោគជ័យ។ តាមរយៈការស្រាវជ្រាវ និងគិតគូរដោយច្នៃប្រឌិតអំពីជម្រើសមិនចរចា គេអាចមានរង្វាស់ច្បាស់លាស់ សម្រាប់វាស់សមិទ្ធផលដែលបានមកពីកិច្ចព្រមព្រៀងមួយដែលកើតចេញពីការចរចា។ ការដឹងអំពី BATNA របស់ខ្លួន គឺជាការពង្រឹងជំហររបស់អ្នក ហើយប្រសិនបើអ្នកដឹងអំពី BATNA របស់ភាគីម្ខាងទៀត អ្នកនឹងមានឱកាសកាន់តែប្រសើរក្នុងការធ្វើសេចក្តីសម្រេចបានត្រឹមត្រូវនៅក្នុងពេលចរចា។ ប្រសិនបើទទួលយកភាពសមហេតុផលនេះ ភាគីនានានឹងសម្រេចបានលទ្ធផលប្រសើរជាងចាត់ទុក BATNA របស់ពួកគេថាជាលក្ខខណ្ឌចាំបាច់សម្រាប់កិច្ចព្រមព្រៀងមួយ។

bill -n. សេចក្តីស្នើច្បាប់
សេចក្តីស្នើច្បាប់សេចក្តីព្រាងនៃសំណើច្បាប់មួយដែលដាក់ជូនទៅសភាសម្រាប់ការពិភាក្សា។

breakthrough - n. ការទំលុះទំលាយ

ការទំលុះទំលាយភាពទាល់ច្រក ការរីកចម្រើនទៅមុខ

ការអភិវឌ្ឍន៍ ឬជោគជ័យភ្លាមៗយ៉ាងច្រើន ដូចជា ជំហានយ៉ាងវែងមួយទៅមុខ នៅក្នុងការចរចាដែលជម្រុញឲ្យភាគីនានា ខិតទៅជិតការព្រមព្រៀងមួយ។

charter - n. ធម្មនុញ្ញ

រដ្ឋធម្មនុញ្ញ ឬ សេចក្តីអធិប្បាយជាលាយលក្ខណ៍អក្សរមួយអំពីមុខងាររបស់អង្គការមួយ ឬសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរអំពីសិទ្ធិរបស់ក្រុមមនុស្សដែលបានកំណត់ណាមួយ។

coalition - n. សម្ព័ន្ធភាព

សម្ព័ន្ធភាពបណ្តោះអាសន្នមួយ។

code - n. ក្រម

ក្រមកម្រងច្បាប់ ឬ លក្ខន្តិកៈមួយជាលក្ខណៈប្រព័ន្ធ ដូចជា ក្រមព្រហ្មទណ្ឌ ឬ កម្រងនៃការសន្មតមួយដែលចែងអំពីឥរិយាបថ។

competition - n. ភាពប្រកួតប្រជែង

ភាពប្រកួតប្រជែងសកម្មភាពនៃការប្រជែងគ្នាទៅវិញទៅមក ប៉ុន្តែក្នុងករណី កិ. គឺពុះពារ ដើម្បីកំណើន ឬឈ្នះ អ្វីម៉្យាង ដោយធ្វើឲ្យភាគីម្ខាង ទៀតចាញ់ ឬបង្កើតឲ្យមានឧត្តមភាពលើអ្នកដទៃ។

compliance -n. ការអនុវត្តន៍តាម

ការអនុវត្តតាមសកម្មភាពឬភាពជាក់ស្តែងនៃការអនុវត្តន៍តាមប៉ុន្តែក្នុងករណីកិ. មានន័យថាធ្វើសកម្មភាពអនុលោមតាមបំណងឬបទបញ្ជាណាមួយដើម្បីឲ្យស្របតាមស្តង់ដារជាក់លាក់ដែលអាចត្រូវបានកំណត់ជាមុនក្នុងនាមជាទម្រង់ណាមួយនៃកិច្ចព្រមព្រៀង។

compromise - n. ការសម្រុះសម្រួល

ការផ្តល់ ការសម្រុះសម្រួល ការផ្សះផ្សា កិច្ចព្រមព្រៀងមួយដែលសម្រេចបានតាមរយៈការលះបង់របស់ភាគីនីមួយៗ ឬ ស្ថានភាពមួយរវាងមតិខុសគ្នា ដែលឈានដល់ការឯកភាពតាមរយៈការធ្វើសម្បទាន។

concession -n. សម្បទាន

សម្បទានវត្ថុមួយដែលលះបង់ បោះបង់ ឬ សម្រេចថាចាកចោល។

conflict -n. វិវាទ

វិវាទភាពមិនស្របគ្នារវាងយោបល់ គោលការណ៍។ល។ វិវាទ មិនសុទ្ធតែអាក្រក់ មិនប្រក្រតី ឬធ្វើ

ឲ្យខូចដំណើរការនោះឡើយ ប៉ុន្តែគឺជាធាតុមួយដែលបានពីអន្តរអំពើរបស់មនុស្ស។ នៅពេលគិតអំពីទិសដៅដែលសង្គមប្រកាន់យក ដំណើរការអភិបាលកិច្ចដែលយើងប្រើប្រាស់សម្រាប់ដោះស្រាយទំនាស់គឺជាអ្វីដែលត្រូវចាប់អារម្មណ៍។ ក្នុងករណីមានវិវាទ ភាគីនានាអាចមិនសូវមានទំនោរ ឬអាចចូលរួមពេញលេញ ឬប្រកបដោយការស្ថាបនា នៅក្នុងការចរចាឡើយ រហូតដល់មានការទទួលស្គាល់បានគ្រប់គ្រាន់ថាជាវិវាទ។

consensus building - n. ការបង្កើតនូវការឯកភាពមតិ

ដំណើរការស្វែងរកការយល់ស្របគ្នាជាឯកច្ឆន្ទនៅក្នុងការធ្វើសេចក្តីសម្រេចជាក្រុម តាមរយៈការសន្ទនាដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយប្រុងប្រយ័ត្ន និងការចរចាដោះស្រាយបញ្ហារួមគ្នា។ ដំណើរការបង្កើតការឯកភាពមតិមួយអាច ដោះស្រាយចេញជាកិច្ចព្រមព្រៀងបានការមួយ ដែលក្នុងនោះអ្នកចូលរួមឯកភាពលើលំនាំនៃចំណាត់ការ ប៉ុន្តែដើម្បីហេតុផលខុសៗគ្នា នៅក្រោយពេលដែលភាគីទាំងអស់មានឱកាសដើម្បីសំដែងទស្សនៈរបស់ខ្លួន និងក្រោយការចំណាយពេល ឬ កិច្ចប្រឹងប្រែងបន្ថែមទៀត នឹងមិនកែលម្អកិច្ចព្រមព្រៀងឡើយ ទោះផ្អែកទស្សនៈណាមួយដោយ បើគ្មានការលះបង់ពីអ្នកដទៃ។

contract - n. កិច្ចសន្យា

កិច្ចសន្យា កិច្ចព្រមព្រៀងមួយដោយផ្ទាល់មាត់ឬលាយលក្ខណ៍អក្សរ ដែលចាប់បង្ខំឲ្យអនុវត្តទៅតាមច្បាប់។

convention - n. អនុសញ្ញាកិច្ចព្រមព្រៀងរវាងប្រទេសនានា។

cooperation -n. កិច្ចសហប្រតិបត្តិការ

កិច្ចសហប្រតិបត្តិការចំណាត់ការនៃកិច្ចសហប្រតិបត្តិការ ពោលគឺ ធ្វើការជាមួយគ្នាឆ្ពោះទៅរកគោលដៅចុងក្រោយ គោលបំណង ឬ ឥទ្ធិពលដូចគ្នា ប្រតិបត្តិការរួមគ្នា។

deliberation - n. ការត្រិះរិះ

ការពិចារណា ការជជែកពិភាក្សាការត្រិះរិះ គឺជាការជជែកវែកញែក និងពិភាក្សា ក្នុងគោលដៅបង្កើតជាយោបល់សមហេតុផល និងយល់ដឹងបានល្អ ដែលក្នុងនោះអ្នកចូលរួមមានឆន្ទៈកែសម្រួលលើការចង់បាន ដោយផ្អែកលើការពិភាក្សា ព័ត៌មានថ្មីៗ និងការទាមទាររបស់អ្នកចូលរួមដទៃទៀត។ បើទោះជាការឯកភាពមតិត្រូវតែជាគោលដៅចុងក្រោយនៅក្នុងការត្រិះរិះ ហើយអ្នកចូលរួមត្រូវគេរំពឹងថាស្វែងរកផលប្រយោជន៍របស់ខ្លួនក៏ដោយ ចំណាប់អារម្មណ៍ជារួមលើធម្មានុភាពនៃសមិទ្ធផល (យល់ថាជាយុត្តិកម្មចំពោះគ្រប់អ្នកដែលរងឥទ្ធិពល) តាមធម្មតា តំណាងឲ្យការត្រិះរិះ(Chambers,2003, at 309) ។[86]

dialogue -n. ការសន្ទនា

ការសន្ទនាការពិភាក្សាផ្តោតលើការស្វែងយល់អំពីប្រធានបទ ឬ ដំណោះស្រាយចំពោះបញ្ហាណាមួយ។

discourse - n. តម្លៃខ្ពស់

សេចក្តីថ្លែងការណ៍មួយ គឺជាគោលគំនិត ជំពូក និងគំនិតរួមគ្នាមួយឈុត ដែលចែងអំពីភាពស្របគ្នានៃសេចក្តីថ្លែងការណ៍នោះ ទៅនឹងក្របខ័ណ្ឌមួយសម្រាប់ផ្តល់អត្ថន័យចំពោះស្ថានភាព ការវិនិច្ឆ័យ ការសន្មតិ សមត្ថភាព ចំណាប់អារម្មណ៍ និងចេតនា។ ពាក្យនេះផ្តល់ជាមូលដ្ឋាននៃអត្ថន័យសម្រាប់ការវិភាគ ជជែកវែកញែក កិច្ចព្រមព្រៀង និងការមិនចុះសម្រុងគ្នា (Dryzek,2006, at 1)។[87] សេចក្តីថ្លែងការណ៍អាចបង្កប់ជាមួយនូវអំណាច ដែលក្នុងនោះមានសារបង្ហាញអំពីនិយាម និងការយល់ឃើញរបស់អ្នកដើរតួនានា កៀបសង្កត់លើចំណាប់អារម្មណ៍ណាមួយ ទន្ទឹមនឹងពង្រឹងចំណាប់អារម្មណ៍ផ្សេងទៀត (Dryzek, 2006, at 3)។ ការយល់ដឹងអំពីសេចក្តីថ្លែងការណ៍នឹងអាចធ្វើឲ្យកំណើនការយល់ដឹងថែមទៀតអំពីឥរិយាបថនៃភាគីនានានៅក្នុងការចរចាណាមួយ។

dispute - n. ទំនាស់

ទំនាស់ការមិនចុះសម្រុងមួយ។ ទំនាស់មួយសំដៅលើបញ្ហាកាន់តែជាក់លាក់មួយ ឬ ការមិនចុះសម្រុងគ្នាជាងទំនាស់មួយ ហើយអាចកើតឡើងដោយសារឧប្បត្តិហេតុជាក់លាក់មួយ ដែលភាគីមួយ ឬច្រើនខាតបង់។ ភាគីនានាអាចស្ថិតក្នុងទំនាស់ ដោយសារតែឧប្បត្តិហេតុមួយដោយគ្មានទំនាស់ដែលជាដើមហេតុធំដុំណាមួយឡើយ (ភាពមិនចុះសម្រុងគ្នា។ល។)

engage - v. ចូលរួម

ចូលរួមទាក់ទាញ ឬ ពាក់ព័ន្ធ (ចំណាប់អារម្មណ៍ ឬ ការយកចិត្តទុកដាក់របស់អ្នកណាម្នាក់) ឬ (ចូលរួមនៅក្នុង ជាមួយ) ចូលរួម ឬមានការពាក់ព័ន្ធនៅក្នុង។

equity - n. សមធម៌គុណភាពនៃយុត្តិធម៌ និងគ្មានលំអៀង។

ethics (in water negotiation) -n. សីលធម៌

សីលធម៌(នៅក្នុងការចរចាអំពីទឹក)គោលការណ៍សីលធម៌ដែលត្រួតត្រាឬមានឥទ្ធិពលលើការប្រព្រឹត្ត។ បទពិសោធន៍របស់មនុស្សក្នុងការជជែកត៉វ៉ាអំពីថ្លៃនៅ ក្នុងទីផ្សារ លើកទឹកចិត្តឲ្យមនុស្សជាច្រើនគិតថា កង្វះភាពសច្ចៈនៅក្នុងការចរចាគឺជារឿងដែលអាចទទួលយកបាន។ វាជារឿងធម្មតាសម្រាប់អ្នកចរចាក្នុងការបំប៉ោងគុណតម្លៃនៃអ្វីមួយ ដូចជា ពួកគេមានការចាប់ចិត្តចំពោះសំណើផ្តល់ផ្សេង ឬ ផ្តល់ព័ត៌មានមិនត្រឹមត្រូវដែលមានសារៈសំខាន់នៅក្នុងការចរចា។ នៅក្នុងការចរចាលើបញ្ហាទឹក ការគំរាមកំហែងបញ្ឆោត និងល្បិចមិនស្មោះត្រង់ដទៃទៀតអាចនឹងមានប្រើប្រាស់។ ក្រៅពីហេតុផលសីលធម៌ ចំពោះការមិនប្រកាន់សច្ចៈភាព ឬការបំភ្លើស គេក៏មានហេតុផលជាក់ស្តែងផងដែរដែលត្រូវគោរពតាមក្រមសីលធម៌។ ប្រសិនបើមានការផ្តល់ព័ត៌មានបំភ្លៃ គេលំបាកក្នុងការសម្រេចសមិទ្ធផលដែលពិតជាផ្តល់ជាមូលដ្ឋានសម្រាប់ការពឹងផ្អែកលើអ្វីដែលមានគុណតម្លៃខ្ពស់សម្រាប់ភាគីម្ខាង និងគុណតម្លៃទាបសម្រាប់ភាគីម្ខាងទៀត។ ដូចគ្នានេះដែរ ការអាក់អន់ចិត្តរយៈពេលវែងអាចកើតចេញពីការចរចាមិនស្មោះត្រង់ ដោយសាររឿងមិនពិតនឹងបង្ហាញច្បាស់នៅពេលដែលការចរចាឈានទៅមុខ។

facilitate - v. សម្រួល
សម្របសម្រួលធ្វើឲ្យងាយស្រួល ឬ ងាយស្រួលជាងមុន។

governance -n. អភិបាលកិច្ច
អភិបាលកិច្ចចំណាត់ការ ឬ ទម្រង់នៃការគ្រប់គ្រង។ ប្រព័ន្ធនៃការត្រួតត្រា ការដឹកនាំ ឬ និយ័តកម្មលើឥទ្ធិពល មានន័យទូលាយជាងរដ្ឋាភិបាល។ អភិបាលកិច្ចសំដៅលើដំណើរការស្មុគស្មាញ និងស្ថាប័នដែលសង្គមប្រកួតប្រជែង ធ្វើ ឬ គ្រប់គ្រងការសម្រេច។

governance ( water ) -n. អភិបាលកិច្ច ( ទឹក )
ប្រព័ន្ធនយោបាយ សង្គម និងរដ្ឋបាល ដែលបានដាក់ឲ្យអនុវត្ត ដើម្បីអភិវឌ្ឍន៍ និងគ្រប់គ្រងធនធានទឹក និងផ្តល់សេវាទឹកនៅលំដាប់ថ្នាក់ខុសៗគ្នានៃសង្គម ( Rogers and Hall, 2003 ) ។[88]

hegemony - n. អនុត្តរភាព
អំណាចខ្ពស់បំផុត អំណាចលប់មានអំណាចត្រួតត្រាជាពិសេសពីសំណាក់រដ្ឋ ឬក្រុមណាមួយលើអ្នកដទៃទៀត។

high value-low cost - adj. តម្លៃខ្ពស់
តម្លៃខ្ពស់ ការខាតបង់ទាបអ្នកចរចាត្រូវស្វែងយល់ពីអ្វីដែលមានតម្លៃខ្ពស់ សម្រាប់ភាគីរបស់ខ្លួន និងប្រឹងប្រែងទាមទារយក និងអ្វីជាការខាតបង់ទាប និងអាចបោះបង់ចោលបាន។ ពួកគេក៏គួរតែព្យាយាមស្វែងយល់ដូចគ្នានេះអំពីភាគីម្ខាងទៀតផងដែរ ដើម្បីភាគីទាំងសង្ខាង អាចទទួលបានតម្លៃខ្ពស់តាមតែអាចធ្វើបាន ទន្ទឹមនឹងលះបង់នូវអ្វីដែលជាការខាតបង់តិចតួច។

institutions - n. ស្ថាប័ន
ស្ថាប័ន គឺជាការចាត់ចែង ដំណើរការឬប្រពៃណីជាប់ជាប្រចាំដែលអាចព្យាករណ៍បានសម្រាប់បម្រើដល់រចនាសម្ព័ន្ធនយោបាយ សង្គម វប្បធម៌ និងសេដ្ឋកិច្ចនិងទំនាក់ទំនងនៅក្នុងសង្គម។ វាអាចមានលក្ខណៈមិនផ្លូវការឬផ្លូវការ និងអនុញ្ញាតឲ្យមានកិច្ចប្រឹងប្រែងរួមគ្នាប្រកបដោយការចាត់ចែងច្បាស់លាស់នៅជុំវិញកង្វល់រួម។ បើទោះជាស្ថាប័នមានលក្ខណៈជាប់លាប់ក៏ដោយវាក៏វិវត្តន៍ផងដែរ។[89]

interests -n. ចំណាប់អារម្មណ៍
